ហ្សូបី ខាត់ភីន

# សៀវភៅណែនាំសំរាប់អ្នកសារព័ត៌មានខ្មែរ



ការផ្សាយរបស់

មូលនិធិ-ខុនរ៉ាដ-អាដិនណៅអ៊ែរ, ប្រទេសអាល្លឺម៉ង់

A publication of the
Konrad-Adenauer-Foundation, Germany

៧៥.
៦

www.budinst.gov.kh www.elibraryofcambodia

# ស្នាដៃនេះ

កើតឡើងពីកិច្ចសហការគ្នា រវាង

**ពុទ្ធសាសនបណ្ឌិត្យ** និង **បណ្ណាល័យអេឡិចត្រូនិចខ្មែរ**

ក្នុងគោលបំណងយ៉ាងមុតមាំដើម្បីថែរក្សា ការពារ កុំឲ្យបាត់បង់តទៅទៀត

ព្រមទាំងផ្សព្វផ្សាយស្នាដៃ-ឯកសារទាំងនេះ

សម្រាប់សាធារណជនប្រើប្រាស់ដោយមិនគិតកម្រៃ។

សូមថ្លែងអំណរគុណដល់

**អង្គការរីស្សូ កូសី-កៃ  វិទ្យាស្ថានបើកទូលាយ**

**ការុណាខ្មែរ និង មូលនិធិខ្មែរសម្រាប់ការសិក្សា**

ដែលបានគាំទ្រគម្រោងការស្នាដៃនេះ សម្រាប់ទុកក្នុងបណ្ណាល័យអេឡិចត្រូនិច។

Buddhist Institute of Ministry of Cult and Religion and eLibrary of Cambodia have made a cooperative effort to digitalize books and manuscripts in order to preserve our Cambodian literary heritage. This will promote and provide easy, instant access, free of charge to the public and future generations to come.

A sincere thank you to our generous supporters: Rissho Kosei-Kai, Open Institute, Karuna Cambodia and Cambodian Education Excellence Foundation, who made this endeavor possible.

www.budinst.gov.kh      www.elibraryofcambodia.org

www.budinst.gov.kh      www.elibraryofcambodia

www.budinst.gov.kh www.elibraryofcambodia

បណ្ណាល័យ
LIBRARY
BUDDHIST INSTITUTE

www.budinst.gov.kh www.elibraryofcambodia

www.budinst.gov.kh www.elibraryofcambodia

សៀវភៅណែនាំសំរាប់
អ្នកសារពត៌មានខ្មែរ

www.budinst.gov.kh www.elibraryofcambodia

www.budinst.gov.kh www.elibraryofcambodia

០៧៥.៦

# សៀវភៅណែនាំសំរាប់ អ្នកសារព័ត៌មានខ្មែរ

ដោយ ហ្យូរ៏ វ៉ាត់គីន

វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ
បណ្ណាល័យ
LIBRARY
BUDDHIST INSTITUTE
៣៦៥៩/៩៨

ការផ្សាយរបស់
មូលនិធិ-ខុនរ៉ាដ-អាដិនណោអ៊ែរ, អាល្លឺម៉ង់

ភ្នំពេញ
១៩៩៨

www.budinst.gov.kh www.elibraryofcambodia

www.budinst.gov.kh www.elibraryofcambodia

# A HANDBOOK FOR CAMBODIAN JOURNALISTS

by Huw Watkin

A publication of the

Konrad-Adenauer-Foundation, Germany

Phnom Penh

1998

www.budinst.gov.kh www.elibraryofcambodia

www.budinst.gov.kh www.elibraryofcambodia

## អារម្ភកថា និង គារវកិច្ច

នៅក្នុងអំឡុងពេល ដែលខ្ញុំកំពុងធ្វើការជាមួយនឹង *ទីភ្នាក់ងារអ្នកសារព័ត៌មានខ្មែរ* ទើបខ្ញុំបានដឹងថាការបកប្រែ "ព័ត៌មាន" ជាភាសាខ្មែរដោយត្រង់ៗឲ្យទៅជាភាសាអង់គ្លេសគឺ ជាការងារមួយដែលមានការពិបាកជាទីបំផុត ជាពិសេស គឺនៅពេលដែលវាមានការទាក់ទងជាមួយនឹងសន្ទិដ្ឋិកម្មនៃការប្រើប្រាស់នូវឃ្លាប្រយោគ និងវេយ្យាករណ៍នោះតែម្តង។

ហេតុដូច្នេះហើយបានជាគេតែងសង្កេតឃើញថា ការសរសេរព័ត៌មានមួយជាភាសាខ្មែរគឺមានផ្នែកខ្លះវាត្រូវការប្រើពាក្យមួយចំនួនដើម្បីបញ្ជាក់ន័យមួយជានិច្ច។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ ខ្ញុំតែងបានប្រាប់ដល់មិត្តរបស់ខ្ញុំនៅទីភ្នាក់ងារសារព័ត៌មានខ្មែរជារឿយៗដែរថា ការពិតការសរសេរព័ត៌មានដោយយោងតាមគោលការណ៍ដែលមានជាមូលដ្ឋាននោះគឺ គេពុំអាចផ្លាស់ប្តូរបានឡើយ។ ខ្ញុំសង្ឃឹមថាគោលការណ៍ទាំងអស់នោះនឹងមានបរិយាយយ៉ាងពិស្តារនៅក្នុងសៀវភៅនេះជាពុំខាន។

នៅក្នុងការចងក្រងជាសៀវភៅនេះ គឺខ្ញុំបានប្រឹងអស់ទាំងកម្លាំងកាយចិត្តដើម្បីប្រមូលយកនូវរាល់ការណែនាំ និងគំនិតបណ្ឌិតរបស់មិត្តភ័ក្តិដ៏ច្រើនលើសលប់ដែលញ៉ាំងឲ្យរូបខ្ញុំបានក្លាយទៅជាអ្នកព័ត៌មានមួយរូប និងជាអ្នកនិយមនូវវិជ្ជាជីវៈនេះ។ ខ្ញុំសូមឧទ្ទិសស្នាដៃនេះជូនចំពោះដល់គ្រប់ពាក្យពេចន៍ទាំងអស់របស់បុគ្គល ដែលខ្ញុំបានអានចំពោះដល់អ្នកដែលបានប្រៀនប្រដៅខ្ញុំនៅក្នុងឆ្នាំសិក្សាដំបូងរបស់ខ្ញុំខាងផ្នែកទូរទស្សន៍ និងវិទ្យុ។ ចំពោះសហការីទាំងអស់នៅសកលវិទ្យាល័យ៉ឃើតទិញ (Curtin University) ដែលស្ថិតនៅក្នុងភូមិភាគខាងលិច នៃប្រទេសអូស្ត្រាលី។ ចំពោះមិត្តភ័ក្តិនិងសហការីទាំងអស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា និងចំពោះដល់បុគ្គលទាំងអស់ដែលខ្ញុំធ្លាប់បានដកស្រង់យកគំនិត ទីងចំណេះដឹងដោយពុំបានជំរាបឲ្យដឹងជាមុន។ ខ្ញុំសូមធ្វើគារវកិច្ចចំពោះ អ្នកដែលបានធ្វើវិភាគទានទាំងអស់នេះដោយក្តីគោរពជាទីបំផុត។

www.budinst.gov.kh www.elibraryofcambodia

# មាតិកាបទ


| ផ្នែកទីមួយ-ពត៌មាន | ទំព័រទី |
|---|---|
| តើពត៌មានជាអ្វី? | ១ |
| "តម្លៃ" ពត៌មាន | ៧ |
| បទសម្ភាសន៍ | ១២ |
| បច្ចេកទេសក្នុងការសរសេរពត៌មាន | ១៦ |
| រចនាសម្ព័ន្ធរបស់អត្ថបទពត៌មាន | ២១ |
| "ក្បួន" ក្នុងការសរសេរដំណើង | ២៦ |
| "រូបមន្ត" នៃអត្ថបទពត៌មាន | ៣១ |
| លំហាត់ | ៣៦ |
| អត្ថបទគំរូ | ៤៥ |

| ផ្នែកទីពីរ-ការសរសេរបទពណ៌នា | |
|---|---|
| ទំនាក់ទំនងរវាងបទពណ៌នា និងអត្ថបទពត៌មាន | ៦១ |
| ប្រភេទនៃអត្ថបទពណ៌នា | ៦៤ |
| "ការរកមើល" អត្ថបទពណ៌នា | ៦៨ |
| ការចូលឲ្យបានជិតទៅនឹងព្រឹត្តិការណ៍រឿង | ៧០ |
| "ឃ្លាដំបូង"ឬសេចក្តីផ្តើម | ៧៥ |
| បច្ចេកទេសក្នុងការសរសេរអត្ថបទពណ៌នា | ៧៨ |
| "អង្គសេចក្តី" និងរចនាសម្ព័ន្ធ | ៨២ |
| អត្ថបទគំរូ | ៩២ |

| ផ្នែកទីបី-សារពត៌មាន និងវិជ្ជាជីវៈជំនាញ | |
|---|---|
| ភាពច្បាស់លាស់ | ១០៣ |


www.budinst.gov.kh www.elibraryofcambodia

ប៉ុន្តែនៅពេលចុងបញ្ចប់នៃថ្ងៃមួយ សៀវភៅនេះនៅមានជំពាក់ច្រើនណាស់ចំពោះបងប្អូនខ្មែរទាំងអស់ដែលមានសេចក្តីក្លាហាន ហើយប្រកាន់ជាប់នូវសច្ចៈធម៌ និងដែលកំពុងមានសកម្មភាពយ៉ាងមមាញឹកនៅក្នុងវិជ្ជាជីវៈនេះ។ ខ្ញុំសូមបួងសួងដល់អ្នកទាំងអស់នោះឲ្យជួបតែនឹងសំណាងល្អនៅក្នុងការខិតខំប្រឹងប្រែងដើម្បីរួមចំណែកក្នុងការស្វែងរកសន្តិភាព និងសុភមង្គលឡើងវិញជូនកម្ពុជា។

**ហ្វ៊ូទ៍ ម៉ាត់គីន**

**ភ្នំពេញ. ១៩៩៦**

www.budinst.gov.kh www.elibraryofcambodia

"អ្នកចម្រាញ់" ពត៌មាន ១០៤
ការសន្មត់ (ពាក្យសំដីរបស់ប្រភពពត៌មាន) ១០៥
ពត៌មានដែលពុំទាន់មានការត្រួតពិនិត្យ ១១០
តុល្យភាព និងយុត្តិធម៌ ១១១
កម្មវិស័យភាព ១១២
ប្រភពពត៌មាន ១១៤
ការប្រើប្រាស់ប្រភព ១១៧
តាមដានអំពីអ្វីដែលគេបាននិយាយ ១២០
អ្នកយកពត៌មាន និង "ជ្រៀតជ្រែកគេ" គឺដូចគ្នា ១២២

**ផ្នែកទីបួន-ក្រមសីលធម៌ និងការបរិហារកេរ្តិ៍**
ការបរិហារកេរ្តិ៍ជាអ្វី? ហេតុអ្វីបានជាវាសំខាន់? ១២៤
ការបន្ទុះបង្អាប់តាមការប្រើពាក្យសំដី-តាមចុងស្លាប
ប៉ាកកា ប្រភេទនៃបុព្វសិទ្ធិ, សេចក្តីរាយការណ៍
ដោយត្រឹមត្រូវ, ការបកស្រាយដោយត្រឹមត្រូវ
និងការនិយាយពិតត្រង់ ១២៦
ការពិត និងមតិយោបល់ ១៣៣
ការអនុវត្តន៍តាមជំនាញដើម្បីចៀសវាងការបរិហាកេរ្តិ៍ :
ភាពច្បាស់លាស់-ត្រឹមត្រូវ ១៣៥
ស្វែងយល់អំពីការពិត ១៣៥
ការសាកល្បងរកការពិត ១៣៧
ក្រមសីលធម៌ - ដកស្រង់ចេញពីប្រទេសមួយចំនួន ១៤០

**បរិសិដ្ឋ**-ច្បាប់សារពត៌មាននៃព្រះរាជាណាចក្រកម្ពុជា ១៤៧

www.budinst.gov.kh www.elibraryofcambodia

## ផ្នែកទីមួយ

## តើដំណឹងជាអ្វី?

និយមន័យរបស់ពាក្យថា *ដំណឹង* (news) គឺមានច្រើនណាស់។ មាននិយមន័យមួយចំនួន វាមានប្រយោជន៍ជាងមួយចំនួនផ្សេងទៀត ប៉ុន្តែជាគោលការណ៍ដំណឹងគឺ នៅតែជាដំណឹងដដែល វាគឺជាការបោះពុម្ពផ្សាយនូវពត៌មាន (information) ដែលជាទីចាប់អារម្មណ៍សំរាប់មនុស្ស ឬមានអនុភាពមកលើមនុស្សនៅក្នុងពេលបច្ចុប្បន្នក៏ដូចជាអនាគតដែរ។

គន្លឹះនៃចំណុចនេះគឺយ៉ាងដូច្នេះ បើគេមិនទាន់បានយកទៅបោះពុម្ពផ្សាយពត៌មាននោះនឹងមិនអាចក្លាយទៅជាដំណឹងបានឡើយ។ ការបោះពុម្ពផ្សាយពត៌មាន គឺមានភាពសាមញ្ញ ងាយស្រួល ដូចជាការនិយាយប្រាប់ដល់ញាតិមិត្តជិតខាងរបស់អ្នកអំពីរឿងរ៉ាវ ដែលកើតមានកាលពីម្សិលមិញនោះអញ្ចឹង។ ចំពោះការដែលស្មុគ្រស្មាញហើយ ពិបាកយល់នោះគឺមានដូចជាការដែលត្រូវយកទៅផ្សាយតាមទូរទស្សន៍ តាមប្រព័ន្ធផ្កាយរណបផ្សាយចេញពីភ្នំពេញទៅហុងកុង បន្ទាប់មកក៏បន្តតាមប្រព័ន្ធផ្កាយរណបមួយទៀតចេញពីហុងកុងទៅប៉ារីស, ឡុងដុង, ញូវយក និងស៊ីដនី។ល។

ការទទួលបាននូវជោគជ័យជាចំបងនៃ "ការបោះពុម្ពផ្សាយ" ពត៌មានជាពិសេសគឺ សារពត៌មាននេះតែម្តងគឺ វាអាស្រ័យទៅលើសមត្ថភាពរបស់អ្នកយកពត៌មានដែលអាចធ្វើការបកប្រែដំណឹងនោះទៅតាម "ភាសាដំណឹង, News Language" មួយឲ្យបានច្បាស់លាស់។ ភាសាដំណឹងគឺ ជាភាសាមួយដែលមានគេអានច្រើនជាងគេ ហើយដែលមានលក្ខណៈខុសប្លែកពីប្រភេទនៃការសរសេរសំរាប់ការងារទំនាក់ទំនងធម្មតា។ អត្ថបទពត៌មានគឺវាមានរចនាបថ និងរចនាសម្ព័ន្ធរបស់វាតែមួយគត់គឺ ត្រូវប្រិតប្រៀងដូចគ្នាទៅនឹងការសរសេររឿងប្រលោមលោក, កំណាព្យ ឬ រឿងល្ខោនដែរ។ ម៉្យាងទៀតមិនចំពោះថា ពត៌មាននោះសរសេរជាភាសាជប៉ុន. អង់គ្លេស, ថៃ ឬខ្មែរឡើយ។ បើនិយាយអំពីគោលការណ៍វិញគឺ វាដូចតែគ្នាទេ។

www.budinst.gov.kh www.elibraryofcambodia

អត្ថបទដែលមានរចនាសម្ព័ន្ធល្អ គឺការចម្រាញ់យកតែចំណុចណាដែលសំខាន់ជាងគេពីក្នុងព័ត៌មានដែលទទួលបាន រួចយកមកសរសេរសង្ខេបឲ្យខ្លីជាទីបំផុតហើយយកវាទៅប្រើនៅលើឃ្លាដំបូងបង្អស់ ឬនៅលើឃ្លាដំបូងណាមួយនៃអត្ថបទទាំងមូលដែលវាទទួលបាននូវការចាប់អារម្មណ៍ជាងគេ គឺឃ្លានោះហើយដែលគេនាំគ្នាហៅវាថា "សេចក្តីផ្តើម" ឬ "បុព្វបទ" (Lead or Intro)។ រីឯអត្ថបទព័ត៌មានវិញក៏យ៉ាងដូច្នោះដែរ គឺត្រូវមានរចនាសម្ព័ន្ធច្បាស់លាស់។ ឃ្លាប្រយោគនិមួយៗត្រូវស៊ីចង្វាក់គ្នា និងដែលអាចទាក់ទាញអារម្មណ៍អ្នកអានឲ្យខិតចូលមកកាន់តែជិតសាច់រឿង។ ការប៉ិនប្រសប់នៅក្នុងការសរសេរអត្ថបទព័ត៌មានមួយ គឺត្រូវពឹងលើសមត្ថភាព ដែលអាចផលិតនូវនិរន្តរភាពដូចខាងលើហើយនៅក្នុងពេលជាមួយគ្នានោះដែរ គឺត្រូវអនុញ្ញាតឲ្យមានចំណុចដែលអាចផ្តោះ ទៅរកការបញ្ចប់ (ឬច្រកចេញ) ឲ្យបានច្រើនជាទីបំផុតបើសិនជាអាចធ្វើបាន។ យើងត្រូវធ្វើយ៉ាងណាដើម្បីឲ្យអត្ថបទនោះខ្លី (shortened) និងសមស្របទៅតាមសេចក្តីត្រូវការ។ ការធ្វើតាមកត្តាខាងលើនេះ គឺដើម្បីក្នុងគោលបំណងពីរយ៉ាង។

ទីមួយ, មានមនុស្សច្រើនណាស់ដែលគេចូលចិត្តអានព័ត៌មានដោយត្រួសៗ។ ពួកគេគ្រាន់តែចោលភ្នែកទៅលើទំព័រកាសែតរួចហើយរកមើលតែចំណងជើងណាដែលគួរឲ្យចាប់ចិត្តជាងគេតែប៉ុណ្ណោះ (បើសិនជាចំណងជើងនោះល្អ!) គេក៏ចាប់ផ្តើមអានអត្ថបទនោះតែម្តង។ បន្ទាប់មកបើសិនជាសេចក្តីផ្តើម ឬបុព្វបទនោះធ្វើឲ្យគេកាន់តែចាប់ចិត្តថែមទៀត។ គឺបានសេចក្តីថាអត្ថបទមួយនោះអាចទាក់ទាញអ្នកអានបានហើយ។ ប៉ុន្តែបើទោះជាព័ត៌មាននោះសំខាន់ ហើយអត្ថបទនោះត្រូវបានសរសេរល្អប្រសើរយ៉ាងណាក៏ដោយក៏នៅមានមនុស្សតិចណាស់ ដែលនឹងអានអត្ថបទនោះដល់ចប់។ (សូមរង់ចាំអានរចនាសម្ព័ន្ធនៃអត្ថបទព័ត៌មានដែលនឹង លើកយកមកបរិយាយនៅក្នុងពេលបន្តិចទៀតខាងមុខនេះ)។

ទីពីរ, តើគួរជឿដែរឬទេ? អត្ថបទព័ត៌មាន គឺជារបស់ចុងក្រោយ

www.budinst.gov.kh www.elibraryofcambodia

បង្អួសដែលត្រូវគេបានយកមកដាក់នៅលើទំព័រកាសែត។ រីឯការផ្សព្វផ្សាយពាណិជ្ជកម្មវិញ គឺត្រូវបានគេយកមកដាក់នៅលើទំព័រកាសែតមុនអ្វីទាំងអស់។ អត្ថបទពត៌មានមួយដែលមានអាទិភាពធំជាងគេក៏ដោយសារតែការផ្សាយពាណិជ្ជកម្មមួយមុខប៉ុណ្ណោះ។ ព្រោះការផ្សាយពាណិជ្ជកម្ម គឺអាចរកចំណូលបានសំរាប់ថ្លៃប្រាក់ខែអ្នកសារពត៌មាន និងសំរាប់ថ្លៃផលិតកម្មទាំងមូល។ តម្លៃចាយវាយសរុបសំរាប់ការបោះពុម្ពកាសែតមួយ បើគិតជាមធ្យមភាគ គឺមានចំនួនតិចជាងប្រាំភាគរយនៃតម្លៃសំរាប់ចាយវាយលើផលិតកម្មទាំងមូល។ ហេតុដូច្នេះហើយបានជាអត្ថបទពត៌មានទាំងអស់ចាំបាច់ត្រូវតែឲ្យមានការពិនិត្យផ្ទៀងផ្ទាត់ និងត្រូវសង្ខេបវាខ្លីតម្រូវទៅតាមទំហំខ្នងនៃទំព័រកាសែត។ ដើម្បីជាការងាយស្រួលដល់អ្នកនិពន្ធអត្ថបទពត៌មានទាំងនោះគឺត្រូវបានសរសេរដោយពឹងទៅលើចំណុចជាច្រើនសំរាប់ប្រើជាច្រកចេញចូល។

ការចាប់ផ្តើមនៃឃ្លាដំបូងគឺ ត្រូវតែធ្វើយ៉ាងណាឲ្យវាដូចជាគ្រឿងបញ្ជូនសារដើម្បីឲ្យវាឆាប់បានទៅដល់អ្នកអាន។ ត្រូវឲ្យមានចំណុចសំរាប់ជាច្រកចេញចូលឲ្យបានច្រើន ដើម្បីជាការងាយស្រួលក្នុងការកាត់តអត្ថបទដោយពុំចាំបាច់ឲ្យមានការសរសេរសារឡើងវិញ។ ចំពោះឃ្លាចុងក្រោយរបស់អត្ថបទក៏តម្រូវឲ្យមានការប្រុងប្រយ័ត្ននៅក្នុងការសរសេរដូចគ្នាទៅនឹងឃ្លាដំបូងដែរ។ នេះបើទោះជាមានការពិតណាមួយពុំបានត្រូវបោះពុម្ពផ្សាយក៏ដោយ។

## តើមានដំណើរល្អមែនឬ?

តើអ្វីខ្លះដែលជួយធ្វើឲ្យពត៌មានមួយអាចល្អទៅបាន? សំនួរនេះគឺពិបាកនឹងរកចម្លើយណាស់។ យើងនឹងដោះស្រាយបញ្ហានេះឲ្យបានពិស្តារនៅលើផ្នែកមួយដែលមានចំណងជើងហៅថា "*តម្លៃរបស់ពត៌មាន*"។ ប៉ុន្តែវានៅមានកត្តាជាមូលដ្ឋានខ្លះ ដែលយើងត្រូវតែយកមកអនុវត្តនៅ

www.budinst.gov.kh www.elibraryofcambodia

លើគ្រប់អត្ថបទពត៌មាន និងគ្រប់ប្រធានបទទាំងអស់។

ការទទួលស្គាល់ជាទូទៅអំពីសេចក្តីត្រូវការសំរាប់ការយកពត៌មានឲ្យបានល្អមាន :

**ភាពមិនលំអៀង** (ACCURACY)
**ការសរសេរសង្ខេបឱ្យបានខ្លី** (BREVITY)
**ភាពច្បាស់លាស់** (CLARITY)

មុននឹងលើកយកបញ្ហានេះមកពិនិត្យឲ្យបានច្បាស់លាស់ចូរយើងត្រឡប់ទៅមើលសេចក្តីតម្រូវការសំរាប់ការបោះពុម្ពផ្សាយវិញម្តង។ ដូចយើងដឹងស្រាប់ហើយថា ពត៌មាន (Information) គឺត្រូវបានគេអាន ឬស្តាប់បន្ទាប់មកទើបវាក្លាយទៅជាដំណឹង (News)។ ហើយនៅមុនពេល ដែលគេយកវាទៅអាន ឬស្តាប់នោះ គឺគេត្រូវតែយកវាមកសរសេរ ឬនិពន្ធជាមុនសិន។ ដូច្នេះដើម្បីនឹងធានាឲ្យអត្ថបទនៃដំណឹងនោះមានលក្ខណៈខ្លី - សង្ខេប, ច្បាស់លាស់ និងមិនលំអៀង ជាចាំបាច់គឺវា ត្រូវតែមានរូបមន្ត, មានរចនាបថ, និង មានទំនៀមទំលាប់របស់វា។ ទាំងអស់នេះគឺ ជាគន្លឹះនៃ "ភាសាសំរាប់ពត៌មាន" (News Language)។ ដូច្នេះគឺ វាត្រូវតែមានលក្ខណៈខុសប្លែកពីប្រភេទនៃការសរសេរអត្ថបទផ្សេងៗទៀត។

កត្តាមួយចំនួនដែលមានលក្ខណៈជាភាសាសំរាប់ពត៌មានគឺ :

*ទំហំនៃការសរសេរឃ្លា (sentences) នីមួយៗ និងវគ្គ (paragraphs)។
*ការលើកយកបទសន្ទនាកថាដោយប្រយោល (indirect speech) មកសរសេរឡើងវិញឲ្យទៅជាពាក្យសំដីដកស្រង់ផ្ទាល់(direct quotes)។
*សំរេចចិត្តប្រើសកម្មស័ព្ទ (active voice) ឲ្យបានច្រើនជាងអសកម្មស័ព្ទ (passive voice)។
*តើរឿងនោះត្រូវនិយាយប្រាប់ដោយរបៀបណា។ ដំណឹងគឺ វាមានរចនា

www.budinst.gov.kh www.elibraryofcambodia

សម្ព័ន្ធជារបៀបនិទានកថាមួយវាមានលក្ខណៈខុសប្លែកពីរបៀបនិទានរឿងដទៃផ្សេងទៀត។ មានគេធ្លាប់និយាយថា ភាសាសំរាប់ពត៌មាននៅមានរូបផ្សំទៅដោយកត្តាជាច្រើន ទៀតដើម្បីនឹងសរសេរអត្ថបទមួយឲ្យបានច្បាស់លាស់ (clear writing) ហើយដែលតាមធម្មតា គឺសុទ្ធតែល្អទាំងអស់។

កត្តាទាំងអស់នោះមានមួយចំនួនតូចដែលអ្នកនិពន្ធ និងអ្នកអានខ្មែរភាគច្រើនពុំធ្លាប់បានជួបប្រទះ គឺមានដូចជាការប្រើសញ្ញាក្បៀស(,)ឲ្យបានត្រឹមត្រូវ (correct use of còmmas,) ឃ្លាប្រយោគបន្ទាប់បន្សំ (subordinate clauses,) កិរិយាសព្ទដែលមិនទាន់ធ្វើកិរិយាវិភាគ (infinitives,) ឯកនិងពហុវចនៈ (singular and plural,) និងសហសញ្ញា (hyphens) ។

ដូចគ្នាដែរគឺវានៅតម្រូវឲ្យចៀសវាងប្រើភាសាដទៃ (the avoidance of jargon,) ចៀសវាងប្រើពាក្យ គំនិត និងឃ្លាដែលគេប្រើហើយ (clichés) និងភាពដែលមានន័យពុំប្រាកដ (ambiguity) ។

ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ ចូរអ្នកកុំបណ្តោយឲ្យការងារបច្ចេកទេសទាំងនេះរួសទាញអ្នកឲ្យឃ្លាតឆ្ងាយពីវិជ្ជាជីវៈនេះឲ្យសោះ។ វិជ្ជាជីវៈសារ-ពត៌មាននេះគឺតែងតែសប្បូរទៅដោយការរំភើបរីករាយណាស់។ វាអាចនាំអ្នកពត៌មានពីកន្លែងមួយទៅកន្លែងមួយទៀត និងអាចជួយឲ្យមានការជួបជាមួយនឹងមនុស្សដ៏ច្រើនទៀតផង។

បច្ចេកបាយមួយដ៏មានប្រសិទ្ធិភាព ក្នុងការធានាឲ្យវិជ្ជាជីវៈសារពត៌មានអាចជួបនូវការសប្បាយរីករាយ និងទទួលបាននូវពរាងកិត្តិយសនោះ គឺការសិក្សាអំពី រូបមន្តជាមូលដ្ឋានឲ្យបានច្បាស់លាស់ជាមុនសិន។ ចូរចាំថាហេតុអ្វីបានជាយើងត្រូវប្រើរូបមន្តដែលជាមូលដ្ឋាននោះ។ នៅពេលដែលយើងបានយល់ច្បាស់ ហើយព្រមទាំងមានគំនិតដ៏ល្អៗថែមទៀត។

ដូច្នេះគឺយើងនឹងលែងមានការពិបាកទៀតហើយ។ តែទោះជាយ៉ាងណាក៏ដោយយើងមិនត្រូវសរសេររឿងនោះឲ្យប្រាសចាកពីការពិតទេ។ ការងាររបស់យើងគឺ ត្រូវបំរើដល់អ្នកអាន គឺត្រូវធ្វើយ៉ាងណាឲ្យអ្នកអានបាន

www.budinst.gov.kh www.elibraryofcambodia

យល់ច្បាស់ថា តើយើងចង់និយាយអំពីអ្វី។ បើមិនដូច្នោះទេ អ្វីដែលយើងបានខំធ្វើច្បាស់ជានឹងក្លាយទៅជាអាសារឥតការជាមិនខាន។ ដូច្នេះចូរខំធ្វើយ៉ាងណាត្រូវសរសេរឲ្យបានច្បាស់លាស់ (write clearly,) ឲ្យសាមញ្ញ (simply) និងកុំឲ្យមានការណាយន័យទៅដោយភាព ដែលមានន័យពុំប្រាកដ (without ambiguity) ។

ជាទូទៅពត៌មាន គឺត្រូវបានសរសេរក្នុងភាពដ៏បន្ទាន់មួយ ដើម្បីគោរពតាមពេលវេលាដ៏សែនចង្អៀត និងដែលបានកំណត់ទុកដូច្នេះ។ អ្នកសារ-ពត៌មាន នៅក្នុងអង្គភាពកាសែត ស្ថានីយវិទ្យុ ឬស្ថានីយទូរទស្សន៍ត្រូវអនុវត្តន៍តាមវិធីសាស្ត្រមួយចំនួន ដូចមានកំណត់ជូននៅខាងក្រោមនេះ ៖
ពាក្យមួយម៉ាត់អាចសរសេរបានច្រើនរបៀបណាស់ ប៉ុន្តែរបៀបសរសេរដែលត្រឹមត្រូវ និងអាចយកជាការបាននោះ គឺមានតែមួយគត់។

តើត្រូវសរសេរចំណងជើងដូចម្តេច ត្រូវនាំពាក្យមួយចំនួនមកប្រើ និងចម្លាក់ ចោលនូវពាក្យណាដែលពុំគួរប្រើ ដូចជាពាក្យអាសគ្រាមនោះ (obscene) ជាដើម។

ត្រូវរៀនធ្វើការងារឲ្យបានរហ័សរហួន ដើម្បីឲ្យទាន់ពេលបោះពុម្ពផ្សាយ។ ប៉ុន្តែការបោះពុម្ពផ្សាយ គឺតែងមានការប្រែប្រួលជានិច្ច។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ គឺយើងត្រូវចេះសំរបទៅតាមរបៀបនៃការបោះពុម្ពផ្សាយណាដែលគោរពពេញទៅដោយការនិយមជាងគេ។

www.budinst.gov.kh www.elibraryofcambodia

## តម្លៃពត៌មាន (*News "Value"*)

អ្នកសារពត៌មានទាំងអស់នៅក្នុងលោកអាចទទួលស្គាល់រឿងមួយថាជាដំណឹងនោះ គឺនៅពេលណា ដែលគេបានឃើញវាផ្ទាល់នឹងភ្នែក។ យើងមាន "ច្រមុះ" មួយសំរាប់ហិតក្លិន ដើម្បីរកពត៌មានណាដែលល្អៗ។ ប៉ុន្តែនៅមានអ្នកសារពត៌មានភាគច្រើន ដែលពុំមានលទ្ធភាពអាចប្រាប់គ្នាទៅវិញទៅមកបាននោះថា តើអ្វីទៅដែលជាដំណឹងនោះ។ យើងដឹងហើយថា គឺជាការពិបាកបំផុតដើម្បីរកអត្ថន័យសំរាប់ពាក្យថាដំណឹងនេះ ។

ការធ្វើកាសែត គឺជាការធ្វើពាណិជ្ជកម្ម - កាសែតអាចរស់បានគឺដោយសារ "*ការលក់*" ចំនួនអ្នកអាន (*Readers*) ទៅឲ្យអ្នកឃោសនាពាណិជ្ជកម្ម (*advertisers*)។ បើកាសែតណាមួយមានចំនួនអ្នកអានច្រើនជាងគេ កាសែតនោះនឹងទទួលបាននូវការជាវដ៏ច្រើនលើសលប់ ពីអ្នកឃោសនាពាណិជ្ជកម្មជាមិនខាន។ ការយល់ដឹងរបស់យើងអំពីអ្វីដែលហៅថាពត៌មាននោះ គឺជាកត្តាសំខាន់ជាងគេ - ប៉ុន្តែបើសិនជាយើងយកពត៌មាននោះទៅផ្សព្វផ្សាយពុំបានត្រឹមត្រូវវិញ អ្នកអានច្បាស់ជាលែងមានការចាប់អារម្មណ៍មកលើកាសែតរបស់យើងទៀតហើយ។ ដូច្នេះការចែកចាយកាសែតរបស់យើងក៏ត្រូវធ្លាក់ចុះដែរ។ នៅពេលនោះអ្នកឃោសនាពាណិជ្ជកម្មមួយចំនួន ដែលធ្លាប់ចុះផ្សាយពាណិជ្ជកម្មនៅលើទំព័រកាសែតរបស់យើង គេច្បាស់ជាបែរក្បាលទៅរកគូរបដិបក្ខរបស់យើងវិញជាមិនខាន។

អ្នកសារពត៌មានដែលពោរពេញទៅដោយចំណេះដឹងខ្ពស់ គេបានខិតខំប្រើអស់មធ្យោបាយដើម្បីគិតគូរក្នុងការរកចម្លើយសំរាប់សំនួរដែលសួរថា៖ តើពត៌មានជាអ្វី? (*What is news?*) បន្ទាប់មកពួកគេក៏បានរកឃើញនូវរូបមន្តមួយចំនួន ដែលអាចជួយដល់ពួកគេកំណត់បានថា "ពត៌មាន គឺសំខាន់ណាស់" ពីព្រោះពត៌មាន គឺជាវត្ថុចាំបាច់សំរាប់ជួយកំដរអារម្មណ៍របស់អ្នកអានគ្រប់ៗគ្នា។ នេះហើយដែលគេហៅថា តម្លៃនៃដំណឹង (*News Values*)

www.budinst.gov.kh www.elibraryofcambodia

និងដែលត្រូវបាន គេកំណត់យ៉ាងដូច្នេះថាជាពត៌មានដែលគួរឲ្យជឿទុកចិត្ត (*the News Worthiness*) បាន។

**ឥទ្ធិពល** (*Impact*) - តើនៅក្នុងព្រឹត្តិការណ៍មួយវានឹងមានឥទ្ធិពលធំប៉ុណ្ណា? ហើយតើមានមនុស្សប៉ុន្មាននាក់ដែលត្រូវទទួលឥទ្ធិពលពីព្រឹត្តិការណ៍នោះ? តើអ្វីទៅដែលហៅថាឥទ្ធិពលនោះ? បើមានចំនួនមនុស្សច្រើនត្រូវបានទទួលរងនូវឥទ្ធិពលពីព្រឹត្តិការណ៍មួយ។ ដូច្នេះទំហំឥទ្ធិពលនៃព្រឹត្តិការណ៍នោះក៏វាមានទំហំធំ ឬតូចទៅតាមហ្នឹងដែរ។

**អំពីកាលវេលា** (*Timeliness*) - បើសិនជាព្រឹត្តិការណ៍មួយបាន និងកំពុងតែកើតឡើង ឬទើបតែនឹងកើតឡើងកន្លងទៅថ្មីៗ។ ដូច្នេះតម្លៃនៃពត៌មាននោះក៏វាមានទំហំទៅតាមកាលវេលានោះដែរ។ អ្នកអានពុំសូវជាមានការចាប់អារម្មណ៍ទៅលើរឿងចាស់ប៉ុន្មានទេ។ ពីព្រោះកន្លងមករឿងនោះធ្លាប់ពុំមានឥទ្ធិពលអ្វីរួចមកហើយ។ អ្នកនិពន្ធរឿងប្រលោមលោកជាតិបារាំងម្នាក់គឺលោក *អង់ដ្រេ ហ្សីដ* បានឲ្យអត្ថន័យលើពាក្យ វិជ្ជាជីវៈសារពត៌មាន (*journalism*) ជាភាសាបារាំងថា (*jour*) បកប្រែជាភាសាអង់គ្លេសថា (*day*) មានន័យជា ភាសាខ្មែរថា "ថ្ងៃ"។ រីឯខ្លឹមសារវិញគឺដូច្នេះ "អ្វីៗទាំងអស់សំរាប់ថ្ងៃស្អែកគឺ មានគេចាប់អារម្មណ៍តិចជាងថ្ងៃនេះ។"

**អ្វីដែលចេញមុខជាគេ** (*Prominence*) - ព្រឹត្តិការណ៍ដែលមានការទាក់ទងទៅនឹងបុគ្គលម្នាក់ ឬស្ថាប័នណាមួយដែលកំពុងពេញនិយម។ ដូច្នេះព្រឹត្តិការណ៍នោះគឺ ច្បាស់ជាមានអ្នកអានយកចិត្តទុកដាក់ជាងគេជាមិនខាន។ ពត៌មានអំពីរឿងព្រះមហាក្សត្រ គឺតែងតែមានអ្នកអានចាប់អារម្មណ៍ច្រើនជាងរឿងរបស់ពូប៉ន ដែលជាអ្នករត់ប៉ូតូឌុប។ អ្នកអានភាគច្រើនតែងចូលចិត្តចង់ដឹងរឿងរបស់តារាភាពយន្តជាងចង់ដឹងរឿងរបស់អ្នកដាំស្ពៃម្នាក់នៅក្នុងភោជនីយដ្ឋានដ៏តូចមួយ។ ខាងក្រោមនេះក៏ជាករណីសំខាន់ណាស់ដែរ គឺនៅពេលដែលអ្នកចង់ជ្រើសរើស

www.budinst.gov.kh www.elibraryofcambodia

យកបុគ្គលណាម្នាក់មកសម្ភាសន៍ ដើម្បីនឹងសរសេរអត្ថបទដំណើងមួយ។

ឧ. បើអ្នកចង់សរសេរព័ត៌មានមួយស្តីពីបញ្ហាសេដ្ឋកិច្ចជាតិ ដូច្នេះគឺបាន តែរដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុប៉ុណ្ណោះ ដែលជាប្រភពមួយនៅជិត យើងជាងគេគឺ គាត់អាចដឹងអំពីបញ្ហាសេដ្ឋកិច្ចច្បាស់លាស់ជាងរដ្ឋមន្ត្រីក្រសួងព័ត៌មាន។

**រឿងដែលនៅជិតជាងគេ** (*Proximity*) - អ្នកអានគឺគេចូលចិត្តចង់ដឹង នូវរឿងអ្វីៗទាំងអស់ ដែលបានកើតឡើងនៅជិតៗខ្លួនគេ។ ចំពោះប្រជារាស្ត្រ កម្ពុជាបើបានព្ទួពត៌មានអំពីរឿងទឹកជំនន់លិចនៅអូស្ត្រាលីគេច្បាស់ជាមិន សូវយកចិត្តទុកដាក់ដូចជារឿងទឹកជំនន់លិចនៅក្នុងខេត្តបាត់ដំបងប៉ុន្មានឡើយ។ ហើយក៏ដូចគ្នាដែរចំពោះប្រជាពលរដ្ឋដែលរស់នៅក្នុងទីក្រុងភ្នំពេញគឺ គេ ច្បាស់ជាពុំសូវចាប់អារម្មណ៍ប៉ុន្មាន អំពីរឿងទឹកជំនន់លិចនៅក្នុងខេត្តណាមួយ នោះទេ។

**ទំនាស់** (*Conflict*) - អ្នកអានគឺចូលចិត្តចង់តាមដានពត៌មាន ដែលស្តីពីរឿងទំនាស់នេះខ្លាំងណាស់។ ពីព្រោះបើបានរឿងទំនាស់គ្នាហើយ គឺមានន័យថា ច្បាស់ជាមានការប៉ះទង្គិចគ្នាក្នុងសង្គម សេដ្ឋកិច្ច និង នយោបាយជាមិនខាន។ ការទាស់គ្នាគឺមានន័យថា សង្គមកំពុងតែប្រឈមមុខ ទៅរកភាព ដែលនាំឲ្យមានការបាក់បែកគ្នា ហើយដែលគេជឿថាវាកំពុង តែជះឥទ្ធិពលយ៉ាងខ្លាំងក្លាមកលើមនុស្សដែលមាននៅក្នុងសង្គមនោះថែម ទៀតផង។ ការទាស់គ្នានេះ គឺមិនចាំបាច់សំដៅចំពោះការប្រើកម្លាំងបាយដាក់ គ្នានោះទេ គឺវាអាចមានការទាស់គ្នាជាអាទិភាព (*Priority*) ឬជារឿងផលប្រយោជន៍របស់មនុស្សមួយក្រុម។

ឧ. រឿងរដ្ឋាភិបាលបានចំណាយថវិការជាតិសំរាប់យោធាមានចំនួន ច្រើនជាងសំរាប់ការសិក្សាអប់រំ។ រឿងនេះអាចធ្វើឲ្យមនុស្សមានទស្សនៈយល់ ឃើញផ្សេងៗពីគ្នា - មានគំនិតជាអាទិភាពមិនស្របគ្នា - ដូច្នេះជាលទ្ធផលគឺ វានាំមកនូវទំនាស់ក្នុងការបញ្ចេញយោបល់ (*conflict of opinion*)។ ការ អភិវឌ្ឍន៍នៅលើតំបន់ដែលសំបូរទៅដោយអ្នកក្រដើម្បីយកទីនោះមក

www.budinst.gov.kh www.elibraryofcambodia

ធ្វើជាសណ្ឋាគារអន្តរជាតិមួយក៏វាអាចបង្កើតជាទំនាស់មួយដែរ គឺទំនាស់រវាងក្រុមអ្នកដែលចង់សាងសង់សណ្ឋាគារជាមួយនិងក្រុមមនុស្សក្រីក្រដែលនឹងត្រូវបាត់បង់ខ្ទមកំសត់របស់ខ្លួន។

ទំនាស់គឺជាមូលដ្ឋាននៃរឿងនានា និងមាននៅក្នុងគ្រប់វប្បធម៌ទាំងអស់ ដែលទាំងមានអាយុរាប់ពាន់ឆ្នាំហើយ ។

**រឿងចម្លែក** (*Bizarre*) - គឺរឿងអ្វីមួយដែលកើតឡើងហើយតែមិនបានឆ្លើយតបទៅនឹងអ្វីដែលគេបានស្មានទុក។ បទពិសោធន៍អំពីជីវិតរស់នៅប្រចាំថ្ងៃក៏ជាករណី ដែលគួរឲ្យយកចិត្តទុកដាក់ណាស់ដែរ។ ការដែលចម្លែកនោះគឺ ធ្វើនកាលពត៌មានមានបង្កប់ទៅដោយការភ័យខ្លាចផង។

ឧ. កូនពពែមួយកើតមកមានក្បាលពីរ នេះហើយគឺជារឿងដ៏សែនចម្លែកនោះ។ សមាជិករបស់សាសនាមួយ ដែលទើបនឹងបង្កើតថ្មីបានប្រកាសថាពួកគេអាចហោះហើរបាន នេះក៏ជារឿងចម្លែកដែរ។ រឿងចម្លែកអាចទាក់ទាញ និងធ្វើឲ្យអ្នកអានមានការយកចិត្តទុកដាក់ជាទីបំផុត។ ពីព្រោះវាមិនមែនជារឿងធម្មតា។

**រឿងកើតឡើងថ្មីៗ** (*Currency*) - គឺព្រឹត្តិការណ៍ និងស្ថានការណ៍ដែលត្រូវបានគេលើកយកមកនិយាយក្នុងគ្រាបច្ចុប្បន្ននេះរៀងរាល់ថ្ងៃ។

ឧ. អំពីបញ្ហាអេដស៍ (*AIDS*) យើងអាចមើលឃើញថាគឺ ជាព្រឹត្តិការណ៍មួយ ដែលទើបនឹងកើតឡើងនៅក្នុងពេលថ្មីៗនេះ តើវាមានសារៈសំខាន់យ៉ាងណាខ្លះ? អេដស៍ជាជម្ងឺយ៉ាងដែលគួរឲ្យភ័យខ្លាចជាទីបំផុត។ អេដស៍មានសក្តានុពល (*potentially*) ធំធេងណាស់នៅក្នុងប្រទេសកម្ពុជាយើង។ អ្វីៗទាំងអស់ដែលមានការទាក់ទិនទៅនឹងការរីករាលដាលនៃជម្ងឺអេដស៍ បើទោះបីជាវាមានរូបរាងតូចយ៉ាងណាក៏ដោយ ក៏ពត៌មាននោះនៅមានតម្លៃដែរ។ ដូចជារឿងស្ថិតិនៃការឆ្លងរាលដាលដែលទើបទទួលបានពីការពិសោធន៍នាពេលថ្មីៗនេះ។

រឿងមានមនុស្សម្នាក់ស្លាប់ដោយសារអេដស៍មុនគេនៅកម្ពុជា។ រឿង

www.budinst.gov.kh www.elibraryofcambodia

សន្និសីទមួយដែលបានរៀបចំឡើងដើម្បីធ្វើការអប់រំ និងសិក្សាអំពីជម្ងឺអេដស៍ និងរឿងវេជ្ជបណ្ឌិតខ្មែរម្នាក់បានប្រកាសថា ខ្លួនគាត់អាចព្យាបាលជម្ងឺអេដស៍ឲ្យជាសះស្បើយបានជាដើម ។ល។ និង ។ល៉។

និយាយរួមតម្លៃនៃព័ត៌មានគឺ ពុំមានអ្វីដែលអាចយកមកបញ្ជាក់ឲ្យច្បាស់លាស់បានទេ។ ការពិតគឺយោងទៅតាមការពិចារណារបស់អ្នកអានតែប៉ុណ្ណោះ។

មានថ្ងៃខ្លះយើងសំបូរព័ត៌មានណាស់។ ដូច្នេះមានអត្ថបទព័ត៌មានខ្លះត្រូវបានគេជំរុះចោលពីរបៀបវារៈនៃព័ត៌មានប្រចាំថ្ងៃ។ ប៉ុន្តែមានថ្ងៃណាមួយនោះក៏យើងមិនសូវជាសំបូរព័ត៌មានប៉ុន្មានដែរ។ ដូច្នេះអត្ថបទព័ត៌មានទាំងអស់ដែលមានគឺ ប្រហែលជាត្រូវបានគេយកទៅបោះពុម្ពផ្សាយទាំងអស់។ ហើយបើសិនជាគេត្រូវការព័ត៌មានផ្នែកពាណិជ្ជកម្ម គឺគេប្រហែលជាត្រូវតែជ្រើសរើសយកអត្ថបទប្រភេទនេះមកចុះផ្សាយនៅលើទំព័រពាណិជ្ជកម្មជាមិនខាន។ ពីព្រោះគេយល់ថា សាធារណៈជនទូទៅពុំសូវជាមានការចាប់អារម្មណ៍មកលើអត្ថបទនេះប៉ុន្មានទេ។ ប៉ុន្តែគឺមានសារៈសំខាន់ខ្លាំងណាស់សំរាប់សហគមពាណិជ្ជកម្មទៅវិញ។

នៅបស្ចឹមប្រទេស ស្ត្រីត្រូវបានគេទទួលស្គាល់ថាកំពុងតែមានឥទ្ធិពលនៅលើទីផ្សារលក់គ្រឿងប្រើប្រាស់នានា (*consumer market*) រីឯការបោះពុម្ពផ្សាយ របស់ស្ត្រីក៏កំពុងតែបង្ហាញអំពីប្រជាប្រិយ៍ភាពរបស់ខ្លួនខ្លាំងណាស់ដែរ។ ការជ្រើសរើសរកអត្ថបទប្រភេទនេះសំរាប់ការបោះពុម្ពផ្សាយក៏ត្រូវតែមានការច្បាស់លាស់ផងដែរ។ អ្នកនិពន្ធត្រូវសួរខ្លួនឯងថាៈ តើរឿងនេះធ្វើឲ្យស្ត្រីមានការចាប់អារម្មណ៍បានប៉ុណ្ណា?

## របៀបធ្វើសម្ភាសន៍

បទសម្ភាសន៍ ជាឧបករណ៍ចាំបាច់សំរាប់ប្រើនៅក្នុងការសរសេរអត្ថបទព័ត៌មាន។ ព័ត៌មានភាគច្រើនដែលយើងបានយកមកសរសេរនៅក្នុងអត្ថបទដំណឹង គឺសុទ្ធតែទទួលបានមកពីការធ្វើសម្ភាសន៍ទាំងអស់។ អ្នកយកព័ត៌មានដែលពុំសូវសំបូរបទពិសោធន៍តែងតែមានការភិតភ័យជានិច្ចនៅពេលដែលត្រូវធ្វើសម្ភាសន៍ម្តងៗ ហើយពួកគេតែងតែមានជំនឿថា អ្នកយកព័ត៌មានជាន់ខ្ពស់ទាំងអស់គឺ សុទ្ធតែបានត្រៀមនូវសំណួរជាមុន។ ប៉ុន្តែការសម្ភាសន៍យកព័ត៌មានគឺ ពុំមានអ្វីខុសប្លែកពីការប្រើសំណួរសួរអ្នកជិតខាង ឬមិត្តភ័ក្តិដែលមានរឿងរ៉ាវផ្សេងៗ និងដែលចង់ប្រាប់យើងនោះទេ។ នៅមានកត្តាមួយទៀតដែលយើងយល់ថា វាក៏ជាកត្តាសំខាន់ដែរនោះ - គឺពេលណាយើងធ្វើសម្ភាសន៍ យើងត្រូវចេះប្រើសំណួរដើម្បីតម្រូវតាមចំណង់ចំណូលចិត្តរបស់អ្នកអាន។ ពីព្រោះអ្នកអានពុំមានឱកាសអាចសួរនូវសំណួរផ្សេងៗ និងសំនួរពិសេសៗដូចយើងដែលជាអ្នកសារព័ត៌មាននោះបានទេ។

ដូច្នេះទោះជាយ៉ាងណាក៏ដោយក្តី យើងត្រូវចេះពិចារណារកមើលសំណួរណា ដែលយើងយល់ថា អ្នកអាននឹងសួរនូវសំណួរនោះជាមិនខាន។ រួចហើយចូរសាកល្បងរកចម្លើយដើម្បីឆ្លើយទៅនឹងសំណួរទាំងនោះសំរាប់ដល់អ្នកអានផង។ ដើម្បីដោះស្រាយការងារដ៏សែនលំបាកនេះ យើងមានសំនួរជាមូលដ្ឋានមួយចំនួនដូចតទៅនេះគឺ *អ្នកណា, អ្វី, ហេតុអ្វី, ពេលណា, ទីណា, និងដោយសារអ្វី?* (who, what, why, when, where and how?) តើអ្នកណាដែលបាននិយាយអំពីរឿងនោះប្រាប់ដល់យើង? តើហេតុអ្វីបានជាមានរឿងហ្នឹងកើតឡើង? តើកើតឡើងពីពេលណា? និងដោយសារមកពីហេតុអ្វី? បើយើងមិនប្រើនូវសំណួរជាមូលដ្ឋានដូចខាងលើនេះទេ អ្នកអានរបស់យើងច្បាស់ជាមានអារម្មណ៍ថា ខ្លួនហាក់ដូចជាបានអាននូវសាច់រឿងនោះបានត្រឹមតែពាក់កណ្តាលប៉ុណ្ណោះ។ ជាការពិតណាស់ សំណួរនិមួយៗ

www.budinst.gov.kh www.elibraryofcambodia

គឺអាចមានការវិវឌ្ឍន៍ - ដូចជាសំណួរដែលសួរថា តើនរណានិយាយរឿងនោះប្រាប់ដល់អ្នក? សំណួរនេះអាចមានការវិវឌ្ឍន៍ទៅជាដូច្នេះទៀតថា តើហេតុអ្វី បានជាបុគ្គលនោះមានវត្តមាននៅទីនោះ? តើគាត់មានតួនាទីជាអ្វី? ឬ បទពិសោធន៍របស់គាត់ តើយ៉ាងណាដែរ? ។ល។

នៅមានសំណួរពិស្តារមួយចំនួនទៀត ដែលមានលក្ខណៈស្មុគស្មាញជាងសំណួរខាងលើនេះទៅទៀត។ ពីព្រោះវាមានបំណងពីរផ្សេងគ្នា។

ទីមួយ គឺការធ្វើតាមទិដ្ឋភាពនៃពត៌មានដែលប្រភពពត៌មាន របស់យើងបានប្រាប់ដល់យើង។ មិនចំពោះថាវាមានការទាក់ទិនទៅនឹងរឿងសោកសៅរបស់សមាជិកនៃគ្រួសារមួយ ឬរឿងនយោបាយធ្ងន់ធ្ងរណាមួយនោះឡើយ។

ទីពីរ គឺការបង្ហាញឲ្យឃើញអំពីអ្វីៗផ្សេងទៀតដែលថ្មី។ គឺអ្វីៗដែលអាចផ្តល់ដល់យើងនូវពត៌មានក្នុងពត៌មាន និងដែលកំពុងតែកើតមាននៅក្នុងសង្គមសព្វថ្ងៃ។ គឺមានដូចជាបញ្ហា និងដំណោះស្រាយសំរាប់សង្គមនោះជាដើម។ល។

យើងគួរនាំគ្នាសាកល្បងរៀនប្រើសំណួរ សំរាប់បំពេញបំណងទាំងពីរនេះដោយឲ្យអ្នកណាម្នាក់ធ្វើសម្ភាសន៍ជាមួយនឹងបុគ្គលណាម្នាក់ផ្សេងទៀត។ យើងត្រូវត្រៀមលក្ខណៈរកសំណួរថ្មីៗ និងដែលពិបាកទាំងអស់នោះទុកជាមុន។ អ្នកសម្ភាសន៍ (interviewer) ដែលពូកែគឺ ត្រូវធ្វើតាមចំណុចមួយចំនួនដូចមាននៅខាងក្រោមនេះ។

ស្តាប់ (Listen) - បើទោះជាស្តាប់បានឮច្បាស់យ៉ាងណាក៏ដោយការងារដែលសំខាន់នោះគឺ នៅក្នុងពេលធ្វើសម្ភាសន៍យើងត្រូវខំប្រឹងស្តាប់ដើម្បីឲ្យដឹងថា តើគេនិយាយអំពីអ្វីខ្លះ? អ្នកយកពត៌មានដែលពុំសូវសំបូរបទពិសោធន៍មានពេលខ្លះបានសរសេរសំណួរទុកជាមុនមែន ប៉ុន្តែនៅពេលដែលគេសួររួចគឺ គេពុំបានយកចិត្តទុកដាក់ស្តាប់នូវចម្លើយនោះវិញទេ។

បើយើងប្រឹងត្រងត្រាប់ស្តាប់នូវចម្លើយទាំងអស់នោះវិញ។ ជាលទ្ធផល

www.budinst.gov.kh www.elibraryofcambodia

គឺយើងអាចទទួលបាននូវចំណុចសំខាន់ៗ ដែលគួចាប់អារម្មណ៍ និងដែលយើងនឹកស្មានមិនដល់ថែមទៀតផង។ ការយកចិត្តទុកដាក់របស់យើងគឺ អាចជួយដល់អ្នកដែលយើងកំពុងតែសម្ភាសន៍ (interviewee) នោះអាចរកពាក្យឆ្លើយបានក្បោះក្បាយថែមទៀតផង។

*ស្រាវជ្រាវ* (Research) - ត្រូវស្គាល់អំពីប្រធានបទរបស់សម្ភាសន៍។ ពីព្រោះវាអាចជួយឲ្យយើងអាចពិចារណាបានថា តើបុគ្គលដែលយើងសម្ភាសន៍ជាមួយនោះ គាត់មានការយល់ដឹងអំពីប្រធានបទមួយនោះមែន ឬអត់? ឬមួយក៏គាត់មានបំណងចង់នាំយើងឲ្យទៅរកផ្លូវខុសដែរ?

*ប្រើសំណួរឲ្យចំគោលដៅ* (Target your questions) - ចូរកុំឲ្យមានរឿងវែងវាទ - ពីព្រោះវាគាប់ធ្វើឲ្យមានការតុញទ្រាន់ និងនាំឲ្យមានការពិបាកនៅក្នុងការងារនិពន្ធថែមទៀតផង។ បច្ចេកទេសមួយ ដែលយើងអាចប្រើសំណួររបស់យើងឲ្យចំគោលដៅនោះ គឺយើងត្រូវធ្វើយ៉ាងណាកុំឲ្យមានករណីបង្អង់លើសពីមួយ។

*ចៀសវាងការជជែកយកឈ្នះចាញ់* (Don't Argue) - អ្នកយកព័ត៌មានមិនត្រូវយករឿងមួយទៅធ្វើវិនិយោគសំរាប់បុគ្គលខ្លួនឯងទេ។ ចូរប្រើគ្រប់មធ្យោបាយទាំងអស់ដើម្បីធ្វើការដេញដោលនៅក្នុងសំណួរនិមួយៗដោយមានអមទៅដោយព័ត៌មានដែលបានស្រាវជ្រាវច្បាស់លាស់ ឬក៏ត្រូវតែសំរួលឡើងវិញនូវអ្វី ដែលគេបានថ្លែងរួចមកហើយពៃអ្នកជឿថា វាជារឿងផ្ទុយទៅវិញ។
ចូរអ្នកអនុញ្ញាតិឲ្យបុគ្គល ដែលអ្នកកំពុងសំភាសន៍សួរនោះ គាត់មានឱកាសអាចធ្វើការពន្យល់អំពី ករណីនោះដោយផ្ទាល់ - ដើម្បីឲ្យអ្នកអានអាចយល់ថា តើចម្លើយនោះគេបានឆ្លើយដោយស្មោះត្រង់មែន ឬអត់?
*ត្រូវចេះសន្សំសំចៃ* (Be Economical) - យើងត្រូវដឹងឲ្យបានច្បាស់នៅមុនពេល ដែលយើងចាប់ផ្តើមធ្វើសម្ភាសន៍។ ចូរសរសេរទុកជាមុននូវសំណួរណាដែលជាគន្លឹះ ប៉ុន្តែយើងក៏ត្រូវត្រៀមទុកនូវសំណួរណា ដែលជាទីចាប់

www.budinst.gov.kh www.elibraryofcambodia

អារម្មណ៍ផ្សេងៗទៀតដែរ បើទោះបីជាសំណួរនោះវាពុំសូវមានលក្ខណៈឆ្លើយឆ្លងទៅនឹងគំនិតដើមក៏ដោយ។

ប៉ុន្តែទៀតចូរចាំថា បុគ្គលដែលអ្នកកំពុងតែសម្ភាសន៍នោះ គាត់មានការរវល់ខ្លាំងណាស់។ ហើយមានករណីខ្លះគឺ យើងបានដឹងមុនរួចទៅហើយ។ ដូច្នេះការធ្វើសម្ភាសន៍នេះគឺ គ្រាន់តែដើម្បីចង់បញ្ជាក់ និងបង្ហាញអំពីបុគ្គលដែលមានការទាក់ទិននៅក្នុងរឿងមួយនោះតែប៉ុណ្ណោះ។

*"ការរំលឹក" អ្នកដែលយើងសម្ភាសន៍* ("Warning" the interviewee) ទាំងអស់នេះគឺ សុទ្ធតែជាគំនិតដែលមានផ្សេងៗពីគ្នា ប៉ុន្តែការដែលសំខាន់នោះគឺ កុំភ្លេចប្រាប់ដល់បុគ្គលដែលអ្នកនឹងត្រូវសម្ភាសន៍នោះ ឲ្យគាត់រក្សានូវភាពស្ងប់ស្ងៀមដូចធម្មតា។ យើងត្រូវដឹងថា មានបុគ្គលខ្លះគេចូលចិត្តចាប់ផ្តើមសួរចូលទៅក្នុងសាច់រឿងតែម្តង។ ហើយមានបុគ្គលខ្លះទៀតគេចូលចិត្តជជែកលេងពីនេះពីនោះរួចហើយបានឈានចូលទៅក្នុងសាច់រឿង។ ដូច្នេះយើងត្រូវចេះធ្វើការស្វែងយល់អំពីចំណង់ចំណូលចិត្តរបស់បុគ្គលទាំងពីរប្រភេទដូចខាងលើនេះ។

ប្រវត្តិ (Background) - បើសិនជាមានលទ្ធភាពអាចធ្វើបាន ចូរស្រាវជ្រាវរកប្រវត្តិនៃពត៌មាននោះឲ្យបានគ្រប់គ្រាន់ជាមុនសិន។ រួចហើយចាំចាប់ផ្តើមធ្វើសំភាសន៍។ យ៉ាងហោចណាស់ក៏យើងត្រូវដឹងអំពី ពេលវេលានិងទីកន្លែងដែរ។ ដើម្បីជាការងាយស្រួល - ការចាប់ផ្តើមឡើងនូវសំណួរប្រភេទនេះគឺ អាចជួយដល់បុគ្គលដែលយើងកំពុងសំភាសន៍សួរនោះទទួលបាននូវអារម្មណ៍ស្ងប់ស្ងៀមមួយរយៈទម្រាំដល់ពេល ដែលគាត់ត្រូវប្រឈមមុខនឹងសំណួរពិបាកៗ។

www.budinst.gov.kh www.elibraryofcambodia

## បច្ចេកទេសក្នុងការសរសេរពត៌មាន

**បុព្វបទ ឬ សេចក្ដីផ្ដើម** (The Intro or lead)

គឺជាឃ្លាប្រយោគដំបូងគេបង្អស់នៃអត្ថបទដំណឹងមួយ។ យើងត្រូវយកចិត្តទុកដាក់ក្នុងការសរសេរសេចក្ដីផ្ដើមមួយ ដោយកំណត់មិនឲ្យលើសពីចំនួន២៥ពាក្យ (សំរាប់ភាសាអង់គ្លេស)។ ហើយនៅក្នុងបុព្វបទនិមួយៗ យើងមិនត្រូវផ្ដល់ពត៌មានឲ្យលើសពីមួយដែរ ពីព្រោះវានាំឲ្យមានការស្មុគស្មាញនៅក្នុងការអាន។

សំរាប់ភាសាខ្មែរយើងវិញ អំពីរឿងអ្វីមួយដែលមានក្បួនសារដូចគ្នានឹងភាសាអង់គ្លេសដែរ។ ក៏ប៉ុន្តែអំពីរបៀបសរសេរវិញ ភាគច្រើនគឺមានលក្ខណៈវែងជាងភាសាអង់គ្លេស។ ដូច្នេះការសរសេរបុព្វបទ ឬសេចក្ដីផ្ដើមមួយជាភាសាខ្មែរគឺ ត្រូវកំណត់មិនឲ្យលើពីចំនួន៤០ពាក្យទេ។

ទោះជាក្នុងករណីណាក៏ដោយកត្តាដែលចាំបាច់នោះគឺ យើងត្រូវចេះលើកយកតែចំណុចនៃពត៌មាន ដែលសំខាន់ជាងគេបកជំរាបជូនដល់អ្នកអានដោយសង្ខេបឲ្យច្បាស់ និងឲ្យរស់សេក្ដី។ ជាទូទៅការជំរាបដំណឹងមួយដល់អ្នកអានគឺ មានរបៀបរបស់វាដូចតទៅនេះ។

តើមានរឿងអ្វីកើតឡើង? កើតឡើងពីកាលណា? និងនៅទីកន្លែងណា? ជាដើម ។ល។ ចួនកាលនៅក្នុងសេចក្ដីផ្ដើមនោះក៏ត្រូវលើកផងដែរអំពីបុគ្គលដែលមានរឿងទាក់ទិន ឬបុគ្គលដែលបាននិយាយរឿងនោះប្រាប់ដល់យើង ករណីដូចនេះមិនសូវមានជាញឹកញាប់ប៉ុន្មានទេ។ ដូច្នេះអ្វីៗដែលត្រូវលើកយកមកនិយាយគឺស្ថិតនៅលើការវិនិច្ឆ័យរបស់យើងនេះឯង។

**អនុច្ឆេទ ឬ កថាខ័ណ្ឌ** (Paragraphs or "pars")

កថាខ័ណ្ឌ ឬប្រយោគរបស់អត្ថបទដំណឹង គឺមានលក្ខណៈខ្លីជាងកថាខ័ណ្ឌ ឬប្រយោគរបស់អត្ថបទរឿងនិទានផ្សេងៗទៀត។

www.budinst.gov.kh www.elibraryofcambodia

ជារឿយៗក្នុងកថាខ័ណ្ឌមួយគឺ មានតែមួយឃ្លាគត់ (only one sentence)។ កថាខ័ណ្ឌក្នុងភាសាដំណឹងមួយភាគច្រើនគឺខ្លីនិងសាមញ្ញ។ ពីព្រោះអត្ថបទនិមួយៗគឺ ត្រូវកាត់វាដើម្បីតម្រូវទៅតាមទំហំនៃខ្ទង់នៅលើទំព័រ ដែលគេមាន។ កថាខ័ណ្ឌនិមួយៗមិនត្រូវមានបង្ហាញអំពីគំនិត ឬទស្សនៈឲ្យលើសពីមួយទេ និងត្រូវសរសេរឲ្យខ្លីដើម្បីស្រួលកាត់តដោយពុំចាំបាច់យកអត្ថបទនោះទៅសរសេរឡើងវិញ។

**ប្រយោគ** (Sentences)

ប្រយោគនិមួយៗត្រូវសរសេរឲ្យខ្លី សាមញ្ញ និងមានបង្ហាញអំពីភាពរស់រវើក។ ដើម្បីនឹងធ្វើដូច្នេះបានចូរសាកល្បងរកពាក្យមួយម៉ាត់មកប្រើជំនួសពាក្យច្រើនម៉ាត់។ យកសកម្មកិរិយា (active verbs) មកបំលែកឲ្យទៅជាអសកម្មកិរិយា (passive verbs) ។ ("សកម្ម" និង "អសកម្ម" កិរិយានឹងមានលើកបង្ហាញជូនជាបន្តបន្ទាប់)។

**ការដកស្រង់ពាក្យសំដីដោយផ្ទាល់** (Direct Speech)

គឺជាការដកស្រង់ពាក្យសំដីរបស់បុគ្គលម្នាក់ដែលបាននិយាយផ្ទាល់អំពីរឿងអ្វីមួយ។ ហើយគេច្រើននិយមដាក់វានៅក្នុងអព្ភន្តរសញ្ញា ( "quoting mark")។ ពាក្យសំដីដែលបានថ្លែងដោយផ្ទាល់ ហើយដែលយើងបានស្រង់យកមកប្រើនោះគឺ ត្រូវមានបញ្ជាក់ឲ្យច្បាស់ថា នេះគឺជាសំដីរបស់បុគ្គលម្នាក់នោះមែន។ ជាទូទៅរបៀបប្រើពាក្យសំដី ដែលបានដកស្រង់យកមកប្រើនៅក្នុងអព្ភន្តរសញ្ញានេះ គឺមានដូចគ្នាទាំងអស់ (same style for quoting) ជាពិសេស គឺការសាងសង់វេយ្យាករណ៍សំរាប់ពាក្យសំដីទាំងនោះនៅក្នុងអត្ថបទនិមួយៗ (grammatical construction of a quote) ។ ការសន្មត់ពាក្យសំដី (attribute) ដែលមាននៅក្នុងអព្ភន្តរសញ្ញានេះថាជារបស់បុគ្គលណាម្នាក់។ ជួនកាលគេដាក់វានៅពីខាងមុខ ឬនៅពីក្រោយនៃអព្ភន្តរសញ្ញា។

ការសន្មត់មួយដែលមាននៅពីខាងក្រោយអព្ភន្តរសញ្ញា (Attribution **after**) "*ខ្ញុំនឹងឈ្នះ*" *លោកបានសុខ បាននិយាយ។ "I am going to*

www.budinst.gov.kh www.elibraryofcambodia

*win," Ban sok said.*

ការសន្មត់ដែលមាននៅពីខាងមុខអព្ភន្តរសញ្ញា (Attribution **before**) *លោកបាន សុខ បាននិយាយៈ "ខ្ញុំនឹងឈ្នះ"*។ (ចូរពិនិត្យមើលនៅកន្លែងមានចុចពីរ)។ *Ban Sok said: "I am going to win."*

នៅក្នុងពេលសរសេរអត្ថបទពត៌មាន ចូរប្រុងប្រយ័ត្នក្នុងការប្រើពាក្យណាដែលខ្វះសីលធម៌ពាក្យសើចចំអក មើលងាយ ពេបជ្រាយ និងពាក្យថ្មំដែលជាដើម។ល។ ពីព្រោះពាក្យទាំងអស់នោះបើទោះបីជាចង់ ឬមិនចង់ គឺវាមានបង្កប់ទៅ ដោយភាពលំអៀងឬបរួចស្រេចទៅហើយ។

នៅក្នុងប្រទេសកម្ពុជាមានអ្នកផ្តល់ពត៌មានភាគច្រើនគឺ ប្រហែលជាត្រូវជំរាបដល់អ្នកកាសែត ខ្មែរ អង់គ្លេស ឬបារាំងតាមរយៈអ្នកបកប្រែភាសា។ ករណីរបៀបនេះគឺ អាចនាំឲ្យមានការភាន់ច្រឡំអំពីអ្វីដែលជាធាតុពិត។ ដូច្នេះដើម្បីចៀសវាងនូវការភាន់ច្រឡំចាំបាច់យើងត្រូវតែប្រាប់ដល់អ្នកអានរបស់យើងផងថា បុគ្គលនោះបាននិយាយតាមរយៈអ្នកបកប្រែភាសា។ ឧ. តាមរយៈអ្នកបកប្រែភាសា *លោកបាន សុខ បាននិយាយៈ "ខ្ញុំនឹងឈ្នះ"*។ *ឬ "ខ្ញុំនឹងឈ្នះ" លោកបាន សុខ បាននិយាយតាមរយៈ អ្នកបកប្រែភាសា*។

បើសិនជាពាក្យសំដីនៅក្នុងអព្ភន្តរសញ្ញានោះវែងពេក។ យើងអាចកាត់វាបានតាមការប្រើសញ្ញាពងក្រពើ Ellipsis ។

សញ្ញាពងក្រពើគឺ (...) ជាសញ្ញាសំរាប់ជំរាបដល់អ្នកអានឲ្យដឹងថាអ្វីដែលគេបានលើកមកនិយាយនៅក្នុងនេះគឺ គេពុំបានលើកមកបកសរសេរកែសំរួលឡើងវិញឡើយ។

និយាយរួម បើមានចំណុចណាមួយនៅក្នុងអព្ភន្តរសញ្ញានោះត្រូវបានលើកយកមកបកស្រាយបំភ្លឺបន្ថែមពី យើងត្រូវដាក់វានៅក្នុងសញ្ញាវង់ដៀប *[square brackets]* ដើម្បីឲ្យអ្នកអានបានដឹងផងដែរ។

ចំណាំ - ពេលណាយើងប្រើអព្ភន្តរសញ្ញា (quotation mark) គឺយើងយកពាក្យសំដីដែលយើងបានស្រង់(quotation) មកសរសេរដាក់ក្នុង

www.budinst.gov.kh www.elibraryofcambodia

ចន្លោះនៃសញ្ញានេះ។ បើទោះបីជាពាក្យសំដីទាំងអស់នោះមានកថាខ័ណ្ឌដល់ទៅពីរ ឬច្រើនជាងពីរក៏ដោយ។ សូមមើលឧទាហរណ៍។

### ការដកស្រង់ពាក្យសំដីដោយប្រយោល (Indirect Speech)

ការដកស្រង់យកពាក្យសំដីដោយប្រយោល គឺជាការលើកបង្ហាញអំពីអ្វីដែលគេបាននិយាយរួចមកនោះ យកមកប្រើដោយពុំចាំបាច់សរសេរតាមពាក្យដែលគេបាននិយាយទាំងស្រុងនោះទេ។ អ្នកអាចធ្វើដូច្នេះបាននៅពេលណាដែលអ្នកបានឮនរណាម្នាក់បាននិយាយអញ្ចឹងមែន តែគាត់និយាយវែងពេកហើយយើងចង់សង្ខេបឃ្លាប្រយោគរបស់គាត់ឲ្យខ្លីដើម្បីឲ្យអ្នកអានងាយយល់។ ជាទូទៅយើងនៅមានមធ្យោបាយមួយទៀតក្នុងការសរសេរដើម្បីរាយការណ៍ដូចខាងលើនេះ។ មធ្យោបាយនោះគឺ ជាក្បួនសំរាប់បំបែកពាក្យសំដី ដែលបានដកស្រង់ដោយផ្ទាល់ (direct speech) មកសរសេរជាប្រយោលវិញ (indirect speech) និងការប្រើកាលនៃកិរិយានាមបច្ចុប្បន្នឲ្យផ្លាស់ទៅរកអតីតកាលមួយជំហានទៀត។ ឧ. *"ខ្ញុំនឹងឈ្នះ" លោកបាន សុខ និយាយ។* វានឹងក្លាយទៅជា ដូច្នេះវិញ *លោកបាន សុខ និយាយថា គាត់នឹងត្រូវឈ្នះ។* *("I am going to win," Ban Sok said becomes; Ban Sok said he was going to win.)*។ ឧ. *"កូនសិស្សប្រុសរបស់ខ្ញុំម្នាក់នេះមានសមត្ថភាព និងមានការប្រឹងប្រែងបានល្អណាស់ វានឹងអាចយកជ័យជំនះលើគូរប្រកួតបាន, " នេះគឺជាសំដីគ្រូរបស់លោកបាន សុខ។* ឃ្លានេះនឹងក្លាយទៅជា *គ្រូរបស់លោកបាន សុខនិយាយថា កូនសិស្សរបស់ខ្ញុំម្នាក់នេះ មានសមត្ថភាព និងមានការប្រឹងប្រែងបានល្អណាស់ វានឹងអាចយកជ័យជំនះលើគូរប្រកួតរបស់វាបាន។*

ការដកស្រង់ពាក្យសំដីដោយប្រយោលពីសន្ទរកថាមួយ (គឺមានន័យថាយើងបានរាយការណ៍តែអំពីអ្វីដែលគេបាននិយាយរួចមកហើយ។) ឬការសង្ខេបអំពីអ្វីមួយ ដែលមានគេនិយាយគឺយើងត្រូវសរសេរវាក្នុងនាមជាបុគ្គលទីបីនៅក្នុងនាមសព្វ(a third person account) ។

បុគ្គលទីមួយ គឺជាបុគ្គលដែលកំពុងតែនិយាយ។

www.budinst.gov.kh www.elibraryofcambodia

(*FIRST person is the one speaking.*)

បុគ្គលទីពីរ គឺជាបុគ្គលដែលត្រូវបានគេនិយាយជាមួយ។

(*SECOND person is the one spoken to.*)

បុគ្គលទីបី គឺជាបុគ្គលដែលត្រូវបានគេនិយាយប្រាប់អំពីអ្វីមួយ។ ឧ. *លោកបាន សុខ បាននិយាយប្រាប់ដល់គ្រូរបស់គាត់។*

(*THIRD person is the one spoken of i.e. Ban Sok told his coach.*)

**សំឡេ** (voice)

ពាក្យថា ស័ព្ទនេះប្រែមកថា ជាសម្លេង។ ប៉ុន្តែបើនៅក្នុងវេយ្យាករណ៍វិញ គឺវាជាសណ្ឋានរបស់កិរិយាស័ព្ទមួយ ដែលកំពុងបង្ហាញអំពីទំនាក់ទំនងរបស់ប្រធានទៅនឹងអំពើ។

ការប្រើអសកម្មស័ព្ទ (the passive voice) គឺពុំមែនជាការខុសឆ្គងអ្វីឡើយ។ ប៉ុន្តែជាទូទៅយើងគួរចៀសវាងកុំប្រើវានៅក្នុងការសរសេរអត្ថបទសំរាប់ពត៌មានឲ្យសោះ។ ពាបធម្មពាការសរសេរអត្ថបទជារបៀបអសកម្មស័ព្ទ គឺ តែងមានប្រើពាក្យច្រើនជាងការសរសេរជារបៀបសកម្មស័ព្ទ។ រីឯខ្លឹមសាររបស់ករណីមួយនោះវិញ ក៏មានន័យក្នុងលក្ខណៈពុំសូវជាចំប៉ុន្មានដែរ។ កាលណាប្រធានរបស់កិរិយាស័ព្ទបានសម្តែងនូវអំពើអ្វីមួយ កិរិយាស័ព្ទនោះហើយគឺជាសកម្មស័ព្ទ (active voice)។ ឧ. *គាត់ច្រៀងចំរៀង*។ (គាត់, ជាប្រធាន, គាត់បានច្រៀងមែន។) កាលណាប្រធានរបស់កិរិយាស័ព្ទជាអ្នកទទួលរងនូវអំពើអ្វីមួយកិរិយា ស័ព្ទនោះហើយគឺជាអសកម្មស័ព្ទ (passive voice)។ ឧ. *ចំរៀងនោះគឺបានច្រៀងឡើងដោយរូបគាត់*។ (ចំរៀង, ជាប្រធាន, ជាអ្នកទទួលរងនូវអំពើច្រៀង ដោយរូបគាត់។)

សកម្មស័ព្ទ - *សត្វឆ្មាអង្គុយនៅលើកន្ទេល* គឺជាសកម្មស័ព្ទ។ (The cat sat on the mat is an active voice) ឆ្មា. ជាប្រធាន ជាអ្នកសម្តែងនូវអំពើរបស់កិរិយាអង្គុយ។

www.budinst.gov.kh www.elibraryofcambodia

អសកម្មស័ព្ទ - *កន្ទេលត្រូវបានសត្វឆ្មាអង្គុយលើ ឬកន្ទេលត្រូវបានអង្គុយលើដោយសត្វឆ្មា*។ (The mat was sat on by the cat) កន្ទេលជាប្រធាន ជាអ្នកទទួលរងនូវអំពើរបស់កិរិយាអង្គុយ។

ការប្រើអសកម្មស័ព្ទ គឺបានធ្វើឲ្យប្រធាន (subject) និងវត្ថុ (object) ប្រែក្លាយទៅជាសកម្មស័ព្ទសំរាប់ឃ្លាមួយ។ អសកម្មស័ព្ទ គឺកើតចេញពីអ្វីមួយដែលមានដូច គ្នានៅក្នុងសកម្មស័ព្ទ និងដែលមានប្រធានធ្លាប់ដើរតួជាវត្ថុ។ នៅក្នុងឃ្លាថា "*សត្វឆ្មាអង្គុយលើកន្ទេល*" គឺមានសត្វឆ្មាជាប្រធាន និងកន្ទេលជាវត្ថុ។ ប៉ុន្តែក្នុងឃ្លា "*កន្ទេលត្រូវបានអង្គុយលើដោយសត្វឆ្មា*" វិញ គឺមានកន្ទេលជាប្រធាន។ សត្វឆ្មា គឺជាវត្ថុ។ ចួនកាលយើងអាចប្រើប្រធាន \ វត្ថុនេះដាក់បញ្ច្រាស់គ្នាបាន។ ប៉ុន្តែវាក៏អាចមានការងាយស្រួលភាន់ច្រឡំបានដែរ ដូច្នេះបើអាចធ្វើទៅបានយើងគួរចៀសវាងកុំប្រើអសកម្មស័ព្ទនេះពេកប្តូរទៅវាប្រសើរជាង។

**អំពីរចនាសម្ព័ន្ធរបស់អត្ថបទពត៌មាន** (News Story Structure)

ភាសានៃដំណើរមួយ គឺមានវិធីសាស្ត្ររបស់វាខុសប្លែកពីការនិយាយរឿងដទៃទៀត។ ការនិទានរឿងខ្លីៗ គឺវាមានវិធីសាស្ត្ររបស់វា។ អ្នកនិយាយប្រហែលជាត្រូវចាប់ផ្តើមនិយាយតាមលំដាប់លំដោយនៃសាច់រឿងពីដើមរហូតដល់ចប់។ វិធីសាស្ត្រនេះគឺ គេហៅថាការនិយាយរឿងតាមកាលវេលា (chronological order)។

ចំពោះកំណាព្យវិញ ក៏ប្រហែលជាត្រូវនិយាយរៀបរាប់អំពីសាច់រឿងមួយទៅតាមវិធីសាស្ត្ររបស់វាដែរ។ គឺការនិយាយជារបៀបរៀបរាប់ដោយមានការប្រៀបធៀប(metaphor) ឬការនិយាយជារបៀបប្រៀបប្រដូច(simile) ។ល។ ឧ. *ខ្យល់គឺជាកាំបិតមួយ (the wind was a knife.)*។ *ស្នេហាខ្ញុំដូចជាផ្កាកុលាបដ៏ក្រហមមួយទងនោះអញ្ចឹង (my love is like a red, red rose)* ។ ផ្ទុយទៅវិញការសាងសង់អត្ថបទពត៌មានមួយ តាមធម្មតាគឺច្រើនតែធ្វើបញ្ច្រាស់ពីក្រោយទៅមុខ - សេចក្តីបញ្ចប់នៃព្រឹត្តិការណ៍សំខាន់ៗគឺ ត្រូវបានលើក

www.budinst.gov.kh www.elibraryofcambodia

យកមកនិយាយមុនគេ។

យើងត្រូវតែចាប់ផ្ដើមអំពីអ្វី ដែលមានគេនិយមចូលចិត្តជាងគេ និងដែលយើងយល់ថាគឺ ជាព័ត៌មានសំខាន់ ហើយនៅពេលបញ្ចប់ទៅវិញគឺ នៅត្រឹមអ្វីដែលពុំសូវមានគេចូលចិត្ត និងដែលពុំសូវសំខាន់។ រចនាសម្ព័ន្ធរបៀបនេះគឺមានទ្រង់ទ្រាយ ដូចជាត្រីកោណបញ្ច្រាស់ (inverted triangle) ឬរាងសាជីផ្កាប់ (inverted pyramid)។

ហេតុអ្វីបានជាយ៉ាងដូច្នេះ? ពីព្រោះអ្វីដែលសំខាន់ជាងគេនៅក្នុងព័ត៌មាននោះគឺ ត្រូវបានលើកយកមកសរសេរនៅខាងលើគេបង្អស់។ បន្ទាប់មកនៅចុងកន្ទុយនៃព័ត៌មាននោះគឺគេអាចកាត់ចោលបាន ដោយពុំខ្លាចបាត់បង់នូវអ្វីដែលសំខាន់នោះឡើយ។ បើសិនជាយើងអាចធ្វើដូច្នេះបានមែនយ៉ាងហោចណាស់ក៏យើងអាចសំរេចបាននូវបំណងមួយចំនួន ដែលយើងចង់បាននោះដែរ។

នៅមានរចនាសម្ព័ន្ធផ្សេងៗទៀត ដែលយើងអាចប្រើសំរាប់ក្នុងការសរសេរអត្ថបទព័ត៌មាននេះដែរ។ ជាពិសេសគឺ បទពណ៌នា (feature stories) នេះឯង។ ប៉ុន្តែរចនាសម្ព័ន្ធរាងជាសាជីផ្កាប់ (inverted pyramid) គឺជារចនា សម្ព័ន្ធតែមួយគត់ ដែលគេនិយមប្រើច្រើនជាងគេសំរាប់ការសរសេរដំណឹងថ្មីៗ (news stories)។

*សូមអានព័ត៌មានគំរូនៅខាងក្រោមនេះ*

រថយន្តមួយកំពុងធ្វើដំណើរនៅលើផ្លូវវិថីមុនីវង្សពីទិសខាងជើងហើយបានបុកជាមួយនឹងរថយន្តកាមីញ៉ុងមួយទៀត ដែលកំពុងធ្វើដំណើរមកពីទិសខាងត្បូងនៅវេលាម៉ោងប្រាំល្ងាច។ មានមនុស្សពីរនាក់ត្រូវរងរបួសជាទម្ងន់ហើយរថយន្តទាំងពីរគ្រឿងនោះក៏មានការខូចខាតយ៉ាងដំណំដែរ។ គ្រោះថ្នាក់នេះបានបណ្ដាលឲ្យចរាចរស្ទះអស់រយៈពេលដប់ប្រាំនាទី។ វិធីនោះបានស្រឡះឡើងវិញដោយសារមានប៉ូលីសមកជួយធ្វើអន្តរាគមន៍ទាន់ពេល។ រថយន្តកាមីញ៉ុងណែពតមួយបានដឹក អ្នករបួសទាំងពីរនាក់នោះទៅកាន់មន្ទីរពេទ្យ

www.budinst.gov.kh www.elibraryofcambodia

កាល់ម៉ែត។ ប៉ុន្តែអ្នកទាំងពីរបានត្រូវស្លាប់នៅមុនពេលទៅដល់មន្ទីរពេទ្យ។

ខាងលើនេះគឺ ជាការសរសេរអត្ថបទមួយទៅតាមសាច់រឿងដែលកើតឡើងចាប់តាំងពីដើមដំបូងរហូតដល់ចុងបញ្ចប់។ នេះគឺពុំមែនជាវិធីសាស្ត្រក្នុងការសរសេរ អត្ថបទសំរាប់ពត៌មានទេ។

ចូរអ្នកសួរខ្លួនឯងសាកមើល តើអ្វីដែលមានឥទ្ធិពលខ្លាំងជាងគេនៅក្នុងរឿងនេះ? តើមានមនុស្សពីរនាក់ស្លាប់មែនឬទេ។ ករណីត្រង់នេះហើយដែលកាសែតត្រូវលើកយកមកសរសេរដើម្បីជាពត៌មាន។

ហេនមនុស្សពីរនាក់ត្រូវស្លាប់ ដោយសាររថយន្តបុកគ្នានៅលើវិថីមុនីវង្សកាលពីល្ងាចថ្ងៃម្សិលមិញ។

លោកសរ ផន និង លោកខែម វ៉ាន់ប៉ុក គឺជាប្រជាពលរដ្ឋរស់នៅក្នុងទីក្រុងភ្នំពេញ។ អ្នកទាំងពីរបានត្រូវគេដឹកទៅកាន់មន្ទីរពេទ្យកាល់ម៉ែត។ ប៉ុន្តែត្រូវស្លាប់នៅពាក់កណ្តាលផ្លូវ។

បុរសទាំងពីរនាក់នេះ គឺជាអ្នកដំណើរ។ ពួកគេបានជិះនៅក្នុងរថយន្តមួយដែល ...។ល។

ចូរលើកយកករណីដែលសំខាន់ជាងគេមកនិយាយមុន។ រួចហើយត្រូវចងចាំថា សំនួរដែលសំខាន់ជាងគេនោះគឺ នរណា? (who?) រឿងអ្វី? (what?) ពេលណា? (when?) និងកន្លែងណា? (where?) ចម្លើយដែលទទួលបានពីសំនួរទាំងអស់នេះគឺ ត្រូវបានយកមកប្រើនៅក្នុងសេចក្តីផ្តើម ឬឃ្លាដំបូង។ ចំពោះសំនួរបន្ទាប់មកទៀត គឺមានហេតុអ្វី? (why?) និងដោយរបៀបណា? (how?)។

ដូច្នេះដើម្បីនឹងសរសេរអត្ថបទអំពីដំណឹងថ្មីមួយ យើងត្រូវធ្វើតាមកត្តាដ៏ចាំបាច់មួយចំនួន។ ប៉ុន្តែជាទូទៅគឺយើងត្រូវគោរពតាមក្បួនវេយ្យាករណ៍ដែលមានស្រាប់។ កត្តាចាំបាច់ជាមូលដ្ឋានសំរាប់ប្រើក្នុងការសរសេរអំពីដំណឹងមួយនោះ គឺការសរសេរដោយប្រើពាក្យសាមញ្ញ ច្បាស់លាស់ និងប្រើភាសាឲ្យបានត្រឹមត្រូវតាមក្បួនវេយ្យាករណ៍។

www.budinst.gov.kh www.elibraryofcambodia

*នៅខាងក្រោមនេះមានសេចក្តីណែនាំមួយចំនួន*

**គន្លឹះសញ្ញា ឬក្បៀស** (commas)

ជារឿយៗមនុស្សមួយចំនួនបានប្រើសញ្ញាក្បៀសនេះនៅពុំទាន់បានសមស្របនៅឡើយទេ។ ដើម្បីជាការពិសោធន៍ ចូរសរសេរអត្ថបទខ្លីមួយដោយមានប្រើសញ្ញានេះ ឲ្យបានច្រើនតាមតែអាចធ្វើទៅបាន។ បន្ទាប់មកចូរសរសេរមួយវគ្គឡើងវិញដោយសាកល្បងលុបបំបាត់សញ្ញាក្បៀសមួយចំនួនចេញ។ ការប្រើសញ្ញាក្បៀសគឺ ជាសញ្ញាសំរាប់ប្រាប់អំពីកន្លែងដកដង្ហើមសមហេតុសមផលមួយ។

សញ្ញាក្បៀសអាចប្រើបានសំរាប់ :

- ជំនួសពាក្យ "និង" (and) គឺដើម្បីសំរាប់ញែកពាក្យមួយចំនួនចេញពីគ្នា។ ឧ. អ្នកពត៌មានត្រូវសរសេរអត្ថបទមួយឲ្យច្បាស់, ដោយសង្ខេប និងត្រឹមត្រូវ។

- ដាក់នៅពីមុខ និងពីក្រោយពាក្យមួយចំនួនដូចជាពាក្យថា "យ៉ាងណាក៏ដោយ (however)", "ឧទាហរណ៍ (for example)", "ជាក់ស្តែង (in fact)"ជាដើម។ល។ ឧ. *គាត់បាននិយាយថា, ទោះជាយ៉ាងណាក៏ដោយ, គាត់មិនអាច នឹងអញ្ជើញមកបានទេនៅថ្ងៃស្អែកនេះ (He said, however, he could not come tomorrow.)*។

- ញែកពាក្យមួយចំនួនដែលប្រើសំរាប់បញ្ជាក់ន័យ ឬសំរាប់ពន្យល់បន្ថែម។ ឧ. *ការសរសេររបស់គាត់ គឺបានប្រសើរជាង, ត្រឹមត្រូវជាងការសរសេររបស់ សុផល (His writing is better, more accurate, than Sophal's.)*។

- ញែកអនុប្រយោគ ឬប្រយោគដែលពុំទាន់មានន័យច្បាស់លាស់។

ឧ. *នគរបាលម្នាក់, មានឯកសណ្ឋានទទឹកជោកទៅដោយញើស, បានធ្វើការងារ យ៉ាងរហ័សរហួនជាទីបំផុត។ (The policeman, who's uniform was soaked with sweat, worked quickly.)*។ ចំពោះគ្រង់

www.budinst.gov.kh www.elibraryofcambodia

ឃ្លាថា "*មានឯកសណ្ឋានទទឹកជោកទៅដោយញើស (who's uniform was soaked with sweat)*" គឺយើងអាចដកវាចេញបាន រីឯឥទ្ធិពលរបស់វាវិញគឺនៅដដែល ប៉ុន្តែសញ្ញាក្បៀសនោះក៏ត្រូវបាត់ដែរ។

**ឃ្លា** (The Sentence)

ឃ្លាគឺ ជាចង្កោមនៃពាក្យដែលសម្តែងអំពីយោបល់មួយ។ ក្នុងឃ្លាមួយគឺត្រូវមានកិរិយាសព្ទមួយ និងប្រធានមួយ។

ឃ្លាទាំងអស់មានបួនប្រភេទៈ

១. សេចក្តីថ្លែងការណ៍(The statement) ទាហាននោះបានធ្វើឲ្យជើងរបស់គាត់បាក់។

២. ឧទានសញ្ញា (Exclamation) - ទាហាននោះបានធ្វើឲ្យជើងរបស់គាត់បាក់ !

៣. សំណួរ (Question) - ហេតុដូចម្តេចបានជាជើងទាហាននោះត្រូវបាក់ ?

៤. បញ្ជា (Imperative or command) - ចាប់យកគាត់ទៅមន្ទីរពេទ្យភ្លាម។

**ពេល ឬ កាល** (Tenses)

ប្រការដែលសំខាន់គឺ មិនត្រូវប្រើ "កាល" លាយឡំគ្នានៅក្នុងនិទានបទតែមួយនោះឡើយ។ ដើម្បីជាការត្រឹមត្រូវក្នុងការសរសេរចំណងជើងសំរាប់រូបភាពមួយ ចូរសរសេរដូច្នេះថា ៖ *ប្រជាជននៅបាត់ដំបងកំពុងនាំគ្នារត់គេចពីការបាញ់ផ្លោងរបស់ខ្មែរក្រហម (Villagers in Battambang province flee Khmer Rouge shelling.)* បន្ទាប់មកទៀតគឺ គ្មាននរណាម្នាក់អាចសរសេរបន្តទៀតដូចយ៉ាងនេះបានឡើយ។ ...*រួចហើយក៏បានចូលទៅក្នុងចំការមីនមួយ។ (...and stepped into a mine field.)*។ បញ្ហាផ្សេងៗទៀតដែលតែងតែបានកើតឡើងជាញឹកញាប់ដែរនោះគឺការសរសេរចប្លងសេចក្តីថ្លែងដោយផ្ទាល់ (direct quote) យកមកប្រើនៅក្នុងអត្ថបទ

www.budinst.gov.kh www.elibraryofcambodia

សញ្ញា។ ឧ. *មានរាត្តិខ្មែរនាក់បាននិយាយដូច្នេះថា : "ខ្ញុំដែលមានបំណងចង់បញ្ចុះបញ្ចូលឲ្យខ្មែរក្រហមត្រឡប់មកចូលរួមនៅក្នុងឆាកនយោបាយទៀតទេ។ ពីព្រោះពួកវាបានដកខ្លួនចេញពីការរៀបចំឲ្យមានការបោះឆ្នោតតាំងពីឆ្នាំ ១៩៩៣មកម៉្លេះ។ ហើយពួកវាថែមទាំងធ្លាប់បានច្រានចោលនូវសំណើរដើម្បីសន្តិភាពឡើងវិញនៅកម្ពុជាជាច្រើនលើកច្រើនសារថែមទៀតផង។"*

កិរិយាស័ព្ទដែលជា បច្ចុប្បន្នកាលសុទ្ធ (Present Simple) និងជាបច្ចុប្បន្នពេញលក្ខណៈ (Present Completed) នឹងត្រូវក្លាយទៅជាអតីតកាលសុទ្ធ (Past Simple) និងអតីតកាលពេញលក្ខណៈ (Past Completed ) វិញនៅពេលណាដែលយើងយកវាទៅប្រើនៅក្នុងសេចក្តីរាយការណ៍នៃបទឧទ្ទេសនាមមួយ។ ដូច្នេះឧទាហរណ៍ខាងលើនឹងត្រូវក្លាយទៅជា: *គាត់បាននិយាយថា គាត់ពុំធ្លាប់ដែលមានបំណងចង់បញ្ចុះបញ្ចូល... ហើយពួកវាថែមទាំងធ្លាប់បាន...។*

មូលហេតុដែលយើងត្រូវធ្វើដូច្នេះគឺដោយសារមកពីនៅក្នុងសេចក្តីរាយការណ៍នៃបទឧទ្ទេសនាម ត្រូវតែលើកយកព្រឹត្តិការណ៍ដែលធ្លាប់មានរួចមកហើយនោះយកមកនិយាយ។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយការដកស្រង់យកពាក្យសំដីផ្ទាល់ (direct quoting) មកប្រើ គឺវាអនុញ្ញាតិឲ្យយើងអាចរក្សាទុកនូវកាលវេលារបស់កិរិយាស័ព្ទឲ្យនៅដដែលបាន។

ចំពោះដំណឹងសំរាប់កាសែត (Newspaper news) ភាគច្រើន គឺត្រូវបានសរសេរជាអតីតកាល (Past tense) ពីព្រោះមកពីការផ្សព្វផ្សាយច្រើនចេញនៅក្រោយព្រឹត្តិការណ៍។ ចំណែកឯដំណឹងជាបទពណ៌នាវិញ (Feature writing) ទោះជាយ៉ាងណាក៏ដោយ គឺប្រហែលជាត្រូវប្រើជា បច្ចុប្បន្នកាល (Present tense) ច្រើនជាងដែរ។

**ច្បាប់សំរាប់សរសេរដំណឹង - Rules for News writing**

១. គ្រប់ពាក្យទាំងអស់ត្រូវសរសេរប្រកបឲ្យបានត្រឹមត្រូវ - ពាក្យបរទេស ឬ គ្រាមភាសាគឺ ត្រូវសរសេរជាអក្សរទ្រេត ។

www.budinst.gov.kh www.elibraryofcambodia

២. គ្រប់នាម និងឈ្មោះទាំងអស់ត្រូវសរសេរប្រកបឲ្យបានច្បាស់លាស់។ ជាការប្រសើរគួរសំណួមពរដល់បុគ្គលនោះឲ្យគាត់សរសេរឈ្មោះឲ្យ។

៣. គ្រប់ឃ្លា និងប្រយោគទាំងអស់ត្រូវគោរពតាមវេយ្យាករណ៍ឲ្យបានត្រឹមត្រូវ។

៤. គ្រប់ករណីជាក់ស្តែងទាំងអស់ត្រូវបង្ហាញនូវភាពទៀងទាត់ (ឬបើសិនជាមានអ្វីមួយទាមទារភាពជាក់ស្តែង ចាំបាច់គឺយើងត្រូវតែលើកដោយសន្មត់ថាជាសំដីរបស់វាគ្មិនម្នាក់នោះ។)

៥. ចូរសរសេរឲ្យបានច្បាស់លាស់ ពិរោះស្តាប់ ត្រឹមត្រូវតាមភាសា។

៦. គ្រប់អត្ថបទទាំងអស់ត្រូវតែឆ្លើយទៅនឹងសំណួរថាៈ នរណា? រឿងអ្វី? ហេតុអ្វី? នៅទីណា? ពេលណា? ហេតុដូចម្តេច? (Who? What? Why? Where? When? and How? )

៧. ចូរសរសេរឃ្លានិមួយៗជា សកម្មស័ព្ទ (Active voice) ។

៨. សំរាប់សេចក្តីរាយការណ៍អំពីបទឧទ្ទេសនាមណាមួយដោយប្រយោល ចូរប្រើកិរិយាស័ព្ទនៅក្នុងឃ្លានោះជាអតីតកាល (Past tense ) ជំនួសកាលវេលានៃកិរិយាដែលវាគ្មិនបាននិយាយ។

**លក្ខណៈដែលជាបំណងច្បាស់នៃភាសាសំរាប់ជំពឹល**

១. ភាពទៀងទាត់ (Accurate) - ចូរទាញយកន័យពិតពីអ្វី ដែលវាបំរុងនឹងមាន។

២. ត្រឹមត្រូវឥតខ្ចោះ (Correct) - ទាំងវេយ្យាករណ៍ ទាំងព្រាបភាសា (Idiom) ចូរសរសេរប្រកបឲ្យបានត្រឹមត្រូវ។

៣. ជ្រះស្រឡះ (Clear) - ធ្វើយ៉ាងណាឲ្យងាយយល់។

៤. និយាយខ្លីៗ (Concise) - ប្រើពាក្យតិច មានន័យបិនផ្លាស់ប្តូរ ទៀងទាត់ សមរម្យ និង ច្បាស់លាស់។

៥. សង្ខេបឲ្យខ្លី (Brief) - មានករណីរឿងច្រើនណាស់ ដែលត្រូវលើកយកមកបង្ហាញនៅលើខ្ទង់នៃទំព័រ ឬពេលវេលាដែលមានកំណត់រួច។ ប៉ុន្តែ

www.budinst.gov.kh www.elibraryofcambodia

ក្នុងនោះក៏នៅមានករណីពុំសូវសំខាន់មួយចំនួនដែរ។ ដូច្នេះយើងត្រូវតែសង្ខេបវាឲ្យបានខ្លី។

៦. បញ្ជាក់ឲ្យច្បាស់ (Specific) - អំពីឈ្មោះរបស់ប្រភព, កម្មវត្ថុ, ទីកន្លែង, ពេលវេលា, ភាពជាក់ស្តែង, ឧទាហរណ៍, និងត្រូវមានផ្តល់នូវរូបភាពសំរាប់សតិនៃចក្ខុផង។

៧. និយាយដោយត្រង់ៗ ហើយសាមញ្ញ (Direct and Simple) ប្រធាន -កិរិយា-កម្ម។ ត្រូវសរសេរជាសកម្មស័ព្ទ (active voice) ដាក់តាមលំដាប់លំដោយ។ ចំពោះអសកម្មស័ព្ទ (passive voice) វិញក៏ប្រហែលជាមានប្រយោជន៍ម្តងម្កាលដែរ។ គេប្រើវាសំរាប់ការប្តូរទិស ដើម្បីបញ្ជាក់អំពីអ្វីមួយឲ្យបានច្បាស់លាស់។

**រចនាសម្ព័ន្ធ និងយុទ្ធសាស្ត្រសំរាប់អត្ថបទដំណឹង**

១. ករណីណាដែលសំខាន់ជាងគេ គឺត្រូវលើកបង្ហាញនៅក្នុងឃ្លាដំបូងគេបង្អស់។ បន្ទាប់មកក្នុងការសរសេរអត្ថបទរឿងទាំងមូលត្រូវតែឲ្យមានទំនាក់ទំនងគ្នាទៅវិញទៅមកជាមួយ នឹងឃ្លាមួយចំនួន ដែលមានពីដំបូង។

២. ប្រយោគជាបន្តបន្ទាប់ គួរធ្វើការពន្យល់អោយបានច្បាស់លាស់ថែមទៀតអំពីករណីនៃពត៌មាន ដែលបានលើកឡើងនៅក្នុងប្រយោគទីមួយ។ ករណីនៃពត៌មាននេះគឺ ត្រូវតែបង្ហាញអំពីករណីដែលសំខាន់ៗហើយដាក់វាតាមលំដាប់លំដោយ។

៣. អត្ថបទរឿងនិមួយៗ ត្រូវរៀបចំធ្វើយ៉ាងណាឲ្យមានចំណុចមួយចំនួន សំរាប់ប្រើជាច្រកចេញទៅរកសេចក្តីបញ្ចប់ដោយរក្សាខ្លឹមសាររបស់សាច់រឿងឲ្យនៅដដែល។

**ចូរចាំថា**

- របៀបសរសេរអំពីដំណើងមួយ ដែលសំបូរទៅដោយករណីរឿងពាក់ព័ន្ធ ហើយដែលត្រូវបានគេកំណត់ពាក្យ ឬពេលវេលាឲ្យសរសេរថែមទៀត។ ដូច្នេះអ្នកសរសេរត្រូវទុកឱកាសនេះឲ្យអ្នកនិពន្ធអាចកាត់សាច់រឿងនៃដំណើង

www.budinst.gov.kh www.elibraryofcambodia

នោះបានដោយពុំមានការប៉ះពាល់ដល់ខ្លឹមសារនៃដំណើរនោះទាំងមូល។

- អ្នកអានសារព័ត៌មាន ជាដំបូងគឺគេគ្រាន់តែ "ក្រឡេកមើលត្រួសៗ" ទៅលើខ្លឹមនៃទំព័រកាសែតតែប៉ុណ្ណោះ។ របៀបសរសេរអំពីដំណើរមួយដើម្បីពង្រួវចិត្តអ្នកអានគឺ ជាការពិបាកជាទីបំផុត។ ពីព្រោះយើងត្រូវចេះធ្វើយ៉ាងណាដើម្បីទាញ អារម្មណ៍របស់អ្នកអានឲ្យស្ថិតមកនៅក្នុងសាច់រឿង របស់យើងតាំងពីដើមដល់ចប់។ ប៉ុន្តែចូរកុំម្លោចប្រើប្រាស់ឃ្លាមួយចំនួន ដែលសំរាប់ប្រើជាចំណុចនៃច្រកចេញចូល។

- ដើម្បីងាយស្រួលដល់ការកែសំរួលឡើងវិញ ឲ្យបានសមស្របទៅតាមប្រវែងនៃខ្លឹមទំព័រដូចបានកំណត់គឺ យើងត្រូវសរសេរប្រយោគនិមួយៗឲ្យបានខ្លី។

- ដើម្បីងាយស្រួលដល់ការកែសំរួលឡើងវិញ និងឲ្យបានឆាប់រហ័សគឺយើងត្រូវសរសេរអត្ថបទនោះឲ្យមានលក្ខណៈ ដែលអាចកាត់វាបានពីក្រោយមកមុន។

**ឧទាហរណ៍ខ្លះដែលត្រូវអនុវត្តក្នុងការសរសេរអត្ថបទដំណើរមួយ**

១. ត្រូវកុំលើកយកមកសរសេរនូវពាក្យណាដែលពុំចាំបាច់។ ឧ. *បុរសមនុស្សមួយក្រុមមានគ្នាប្រាំយនាក់បាននាំគ្នាឈរមើលកាំភ្លើង*។ ត្រូវសរសេរដូច្នេះថា *មានមនុស្សប្រាំយនាក់បាននាំគ្នាឈរមើលកាំភ្លើង*។ គាត់បានបន្តដោយពោលពាក្យបន្ថែមថា *សាលាផ្សេងទាំងមូលត្រូវបានគេបំផ្លាញចោលខ្ទេចអស់*។ ត្រូវសរសេរដូច្នេះថា *គាត់បាននិយាយដែរថា សាលាផ្សេងទាំងមូលត្រូវបានគេបំផ្លាញខ្ទេចអស់។ គាត់មានការឈឺចាប់ដោយសារគាត់ត្រូវបានបាត់បង់ភ្នែកខាងស្តាំរបស់គាត់*។ ត្រូវសរសេរដូច្នេះថា *គាត់ត្រូវបាត់បង់ភ្នែកខាងស្តាំហើយ*។

២. ត្រូវឲ្យមានភាពប្រាកដនិយម។ ឧ. ពាចាស់ម្នាក់បានមានប្រសាសន៍ថា *ឧប្បត្តិហេតុនោះបានធ្វើឲ្យរូបគាត់ត្រូវបាត់បង់ពេលវេលាយ៉ាងសន្ធឹកសន្ធាប់*។ ត្រូវសរសេរដូច្នេះថា *លោក ព្រោវិន, អាយុ៧៥ឆ្នាំ, បាននិយាយថា*

www.budinst.gov.kh www.elibraryofcambodia

*ចោរប្លន់រថយន្តនោះបានធ្វើឲ្យរូប គាត់សម្រាន្តមិនលក់អស់រយៈពេលប្រាំមួយអាទិត្យ។*)

នាងបាននិយាយថា *នាងធ្វើការច្រើនយ៉ាងណាស់ ហើយនាងទទួលបានកម្រៃតិចជាទីបំផុត។* ត្រូវសរសេរដូច្នេះថា *នាងបាននិយាយថា នាងទទួលបានកម្រៃតែម្ភៃដុល្លារប៉ុណ្ណោះពីការងារចំនួន៥០ម៉ោងក្នុងមួយអាទិត្យ។*

គ្រោះថ្នាក់នេះបានបង្កឡើង ដោយមកពីអ្នកបើកបរបាត់បង់ម្ចាស់ការ។ ត្រូវសរសេរដូច្នេះថា *គ្រោះថ្នាក់នេះបានបង្កឡើងដោយសារមកពីមានភ្លៀងធ្លាក់ខ្លាំងពេក ហើយបានធ្វើឲ្យអ្នកបើកបរមើលមិនច្បាស់។*

៣. ចៀសវាងប្រើភាពទូលំទូលាយ-រូបជាមួយ-ភាពពិតប្រាកដ។ កាលណាយើងមានភាពពិតប្រាកដតែមួយគត់គឺ យើងអាចសំរេចបាននូវបំណងនោះហើយ។ ឧ. *បុរសនោះនៅមានរបួសជាច្រើនកន្លែងថែមទៀតគឺ មានរបួសទាំងដៃបាក់របស់គាត់ផង។* ត្រូវសរសេរដូច្នេះថា *បុរសនោះត្រូវបាក់ដៃ និងឆ្អឹងកញ្ចឹងក។*

*អំពីសកម្មភាពខាងផ្លូវច្បាប់វិញ បន្ទាប់មកក៏ត្រូវបានក្រុមហ៊ុននោះរកឃើញ ហើយការរកឃើញនោះទៀតសោត គឺគ្រាន់តែជាឃុទ្ធសាស្ត្រមួយសំរាប់ទប់ស្កាត់កូដកម្មនោះតែប៉ុណ្ណោះ។* ត្រូវសរសេរដូច្នេះថា *ក្រុមហ៊ុននោះបានរកឃើញនូវយុទ្ធសាស្ត្រមួយសំរាប់ទប់ស្កាត់កូដកម្មនោះហើយ។*

*នេះគឺពុំមែនជាលើកទីមួយទេ ដែលគាត់ត្រូវបានគេបញ្ឈប់ពីការងារនៅក្នុងឆ្នាំនេះ។ ក្នុងរយៈពេលប្រាំបីខែកន្លងមក គាត់ត្រូវបានគេបញ្ឈប់ពីការងាររបស់ចំនួនបីដងហើយ។* ត្រូវសរសេរដូច្នេះវិញថា *ក្នុងរយៈពេលប្រាំបីខែចុងក្រោយនេះ គាត់ត្រូវបានគេបញ្ឈប់ពីការងារចំនួនបីដងហើយ។*

៤. ប្រើរចនាសម្ព័ន្ធសាមញ្ញ និងសកម្មស័ព្ទ។ ឧ. *ការទិះតៀនដ៏ស្រួចស្រាវនៃរឿងបណ្តឹង ដែលបានលើកឡើងដោយលោកសុភាពបុរសត្រូវបានលោកតុលាការរំលឹកឡើងវិញនៅក្នុងពេលកំពុងកាត់សេចក្តី។* ត្រូវសរសេរដូច្នេះថា *ក្នុងពេលកំពុងកាត់សេចក្តី តុលាការបានធ្វើការតិះតៀនយ៉ាងស្រួច*

www.budinst.gov.kh www.elibraryofcambodia

*ស្រាវទៅលើរឿងបណ្តឹងរបស់លោកសុភាចារបុរស។*

*ភ្នាក់ងារប៉ូលីសបានត្រូវអ្នកជិតខាងផ្តល់ដំណឹងឲ្យតាមទូរស័ព្ទ។* ត្រូវសរសេរដូច្នេះថា *អ្នកជិតខាងបានផ្តល់ដំណឹងដល់ភ្នាក់ងារប៉ូលីស។*

*គាត់បានត្រូវគេថតសម្លេងតាមខ្សែអាត់ ដោយគាត់បាននិយាយថា គាត់ត្រូវបានគេគាំទ្រដោយសាររូបគាត់ធ្លាប់ប្រឆាំងនឹងញត្តិនោះ។* ត្រូវសរសេរដូច្នេះថា *គាត់ត្រូវបានគេគាំទ្រដោយបកពីគាត់ធ្លាប់ប្រឆាំងនឹងញត្តិនោះ។*

៥. ប្រើកិរិយាសព្ទជាជាងប្រើនាមសព្ទ និងអាយតនិបាត។ ឧ. *ពួកគេបាននាំគ្នាធ្វើការបោះឆ្នោតដើម្បីនឹងដកលេខាធិការនោះចេញ។* ត្រូវសរសេរដូច្នេះថា *ពួកគេបានបោះឆ្នោតដើម្បីបណ្តេញលេខានោះចេញ។*

*ក្បួនយាត្រានោះនឹងត្រូវប្រារព្ធឡើង ដើម្បីបង្ហាញអំពីការតុបតែងខ្លួនរបស់មនុស្ស៦នាក់ និងដែលបានរៀបចំឡើងដោយលោកអភិបាលក្រុង។* ត្រូវសរសេរដូច្នេះថា *លោកអភិបាលក្រុង និងធ្វើការបង្ហាញអំពីការតុបតែងខ្លួនរបស់មនុស្ស៦នាក់នៅក្នុងក្បួនយាត្រានោះ។*

៦. ចៀសវាងនូវការសរសេរវែងហើយឥតប្រយោជន៍។ ឧ. *អាងមហោស្រពនោះមានកៅអីសំរាប់មនុស្សអង្គុយចំនួន៦០០នាក់។* ត្រូវសរសេរដូចនេះថា *ក្នុងអាងមហោស្រពនោះមានកៅអីចំនួន៦០០។*

*ពួកគេពេញចិត្តនឹងសកម្មភាពនៃការលេងកំសាន្តនោះណាស់។* ត្រូវសរសេរដូច្នេះថា *ពួកគេពេញចិត្តនឹងល្បែងទាំងអស់នោះណាស់។*

*ពួកគេបានសុខចិត្តទទួលយកការងារពាក់កណ្តាលនោះធ្វើហើយ។* ត្រូវសរសេរដូច្នេះវិញថា *ពួកគេបានទទួលយកការងារពាក់កណ្តាលនោះធ្វើហើយ។*

**រូបមន្តទីមួយ - មូលដ្ឋានក្នុងការសរសេរដំណឹង : "អត្ថបទដំណឹង" គឺជារឿងដែលកំពុងតែកើតឡើង ដូចជារឿង (គ្រោះថ្នាក់, ព្រឹត្តិការណ៍ថ្មី, កីឡា និងការសំរេចបាននូវជោគជ័យផ្សេងៗជាដើម)**

ចូរចាំថា - សកម្មសព្ទគឺ មានតែមួយមុខប៉ុណ្ណោះ

១. បុព្វបទ (Intro) : អំពីអ្វីដែលកើតមានឡើង។ កើតឡើងនៅ

www.budinst.gov.kh www.elibraryofcambodia

ពេលណា? និងកន្លែងណា? ហើយហេតុអ្វីបានជាវាកើតឡើង? ឧ. *នៅខេត្តកំពង់ឆ្នាំងមានមនុស្ស៥នាក់ស្លាប់ដោយសារផ្ទះរបស់ពួកគេត្រូវភ្លើងឆេះកាលពីម្សិលមិញ*។ នៅក្នុងភាសាអង់គ្លេស មិនត្រូវសរសេរឲ្យ លើសពីចំនួន២៥ពាក្យទេ។ ប៉ុន្តែចំពោះភាសាខ្មែរវិញគឺ មិនត្រូវឲ្យលើសពីចំនួន៥០ពាក្យឡើយ។ ដូច្នេះគឺ ត្រូវធ្វើយ៉ាងណាឲ្យចំនួនពាក្យនោះមានតិចជាជាទីបំផុតតាមការដែលអាចធ្វើទៅបាន។

២. អំពីចំនួនមនុស្សម្នាក់ ឬ ច្រើននាក់ដែលជាអ្នកធ្វើឲ្យមានរឿងនោះកើតឡើង។ នរណាជាអ្នកធ្វើឲ្យមានរឿងនោះកើតឡើង? នរណាជាអ្នកនិយាយរឿងនោះ? ចូរប្រយ័ត្នក្នុងការសរសេរឈ្មោះរបស់គេគឺ កុំឲ្យខុសឲ្យសោះ។ តើពួកគេមានអាយុប៉ុន្មាន? មានមនុស្សស្គាល់ច្រើនឬទេ ? តើដើម្បីអ្វី?

៣. តើរឿងនោះកើតឡើងដោយរបៀបណា ? ការបកស្រាយ ឬការពណ៌នារបស់សាក្សីដោយផ្ទាល់ ឬដោយយោងតាមពាក្យសំដីដែលមាននៅក្នុងសន្ទរកថា។

៤. តើនៅមាននរណាទៀតដែលទាក់ទិនក្នុងរឿងនេះ? អ្នកជិតខាងដែលបានមកជួយពន្លត់ភ្លើងអគ្គីភ័យនោះ? សាច់ញាតិដែលនៅរស់ដោយសារពួកគាត់ពុំបាននៅក្នុងផ្ទះនោះ។

៥. និងរឿងជាក់ស្តែងសំខាន់ៗផ្សេងទៀត។

ចូររៀនធ្វើតាមរូបមន្តទាំង៥ចំណុចខាងលើនេះ តែមិនត្រូវជឿស៊ប់ពេកទេ។ នោះក៏ពុំមែនមានន័យថា នៅក្នុងគ្រប់អត្ថបទនៃដំណឹងទាំងអស់គឺត្រូវតែមានគ្រប់ចំណុចទាំង៥នោះដែរ។

**ចំណាំ** : ត្រូវសរសេរជាសកម្មស័ព្ទ (Active Voice) *មនុស្សម្នាក់បានស្លាប់ដោយសារពស់ចឹកកាលពីម្សិលមិញ*។ មិនមែន "*មនុស្សម្នាក់បានត្រូវសត្វពស់សម្លាប់កាលពីម្សិលមិញ*" ទេ។ បន្ទាប់មកទៀតចូរកុំភ្លេចលើកអំពីប្រវត្តិរបស់ពត៌មាននោះផង។

**រូបមន្តទីពីរ "រឿងដែលគេកំពុងតែនិយាយ"** (Saying Stories)

www.budinst.gov.kh www.elibraryofcambodia

**(សន្ទរកថា,បទសម្ភាសព័ត៌មាន, សេចក្តីថ្លែងការណ៍ជាសាធារណៈ, របាយការណ៍ប្រចាំឆ្នាំ ។ល។)**

១. ចូរអានសេចក្តីថ្លែងការណ៍ ឬស្តាប់សន្ទរកថានោះឲ្យបានហ្មត់ចត់ រួចសាកល្បងច្រិចយកតែចំណុចណាដែលសំខាន់ជាងគេ។ ជារឿយៗវាពុំសូវមាននៅលើប្លង់ដំបូងនោះឡើយ។ ចូរកុំសរសេរដូច្នេះថា "*កាលពីម្សិលមិញមានការប្រារព្ធពិធីមួយ...* ។"

"*កាលពីម្សិលមិញសម្តេចហ៊ុនសែនបានធ្វើសេចក្តីថ្លែងការមួយ...* ។"

"*កាលពីម្សិលមិញសម្តេចក្រុមព្រះរណឫទ្ធិបានយាងទៅសម្ពោធសាលារៀនមួយ...* ។"

ករណីទាំងអស់ដូចបានលើកនៅខាងលើនេះគឺ ត្រូវស្ថិតនៅក្នុងវគ្គបន្ទាប់ពី - ចម្លើយទៅនឹងសំនួរដែលសួរថា ហេតុអ្វីបានជាត្រូវមានការប្រារព្ធពិធីនោះ? កាលពីម្សិលមិញសម្តេចហ៊ុនសែនបាននិយាយអំពីអ្វីខ្លះ? នៅក្នុងពិធីសម្ពោធសាលារៀននោះ តើសម្តេចក្រុមព្រះបានមានបន្ទូលដូចម្តេចខ្លះ ?

២. បន្ទាប់ពីច្រិចយកបានចំណុចសំខាន់ៗនោះបានហើយ ចូរអ្នកលើកវាមកនិយាយ ឬសរសេរនៅក្នុងបុព្វបទ (សេចក្តីផ្តើម) ដោយធ្វើយ៉ាងណាឲ្យវាខ្លីជាទីបំផុតតាមតែអាចធ្វើទៅបាន ។

៣. ចូរកុំភ្លេចលើកអំពីឈ្មោះ និងតួនាទីរបស់វាគ្មិន ឬអ្នកឧទ្ទេសនាម។ ហើយត្រូវគោរពឲ្យបាននូវភាពទៀងទាត់ និងប្រាកដប្រជា ។ យើងក៏ប្រហែលជាអាចលើកយកចំណុចទីមួយ និងទីពីខាងលើមកដាក់បញ្ចូលនៅក្នុងបុព្វបទនេះបានដែរ។ ប៉ុន្តែចូរប្រយ័ត្នក្នុងការប្រើកិរិយាស័ព្ទ និងកាលវេលាឲ្យបានត្រឹមត្រូវ។

៤. បង្កើតផ្តើមរឿង ឬសាច់រឿងនៅក្នុងបុព្វបទ ដោយប្រើប្រាស់សំដីដែលបានថ្លែងនៅក្នុងសន្ទរកថាផ្ទាល់ ឬដោយប្រយោល។

៥. ក្នុងមធ្យោបាយដូចគ្នានេះដែរ ចូរកុំភ្លេចលើកបន្ថែមអំពីចំណុចដែលសំខាន់ៗផ្សេងទៀត។ ជាពិសេសចូរពិចារណារកមើលនូវប្រវត្តិរបស់វាដែល

www.budinst.gov.kh www.elibraryofcambodia

ជាសក្ដានុពលសំខាន់ជាងគេនៅក្នុងផ្ទៃរឿងទាំងមូល។ តើអ្នកអានចាំបាច់ត្រូវការអោយយើងជួយរំលឹកនូវទិដ្ឋភាពអំពីអ្វីដែលមានការទាក់ទងទៅនឹងសន្ទរកថា ឬអំពីអ្វីដែលវាគ្មិន ឬអ្នកឧទ្ទេសនាមនោះដែរឬទេ?

**រូបមន្តទីបី: រឿងរបស់បុគ្គល** "People Story"

រឿងរបស់បុគ្គលត្រូវបានគេទទួលស្គាល់ថា គឺជារឿងរបស់មនុស្សម្នាក់ដែលធ្វើឲ្យអ្នកផងមានការចាប់អារម្មណ៍។ ក្នុងករណីនេះគឺ អ្នកផង ឬអ្នកអានតែងមានការចាប់អារម្មណ៍ទៅលើបុគ្គលនោះជាងការចង់តាមដានព្រឹត្ដិការណ៍ថ្មីៗ។

១. ត្រូវចាំថា មានអ្នកអានជាច្រើនចង់ស្គាល់ អំពីអត្តសញ្ញាណរបស់បុគ្គល ដែលពួកគេកំពុងតែអាននោះខ្លាំងណាស់។ ដូច្នេះការងាររបស់អ្នកគឺត្រូវធ្វើ យ៉ាងណាដើម្បីជួយដល់អ្នកអានឲ្យសំរេចបាននូវបំណងនេះ។

២. ដើម្បីនឹងអាចធ្វើដូចខាងលើនេះបាន ជាដំបូងគឺ អ្នកត្រូវធ្វើការបង្ហាញអំពី អត្តសញ្ញាណរបស់ខ្លួនអ្នកជាមុនសិន។ យើងត្រូវធ្វើដូច្នេះគឺ ដើម្បីគ្រាន់តែចង់ស្វែងរកនូវ "ការយល់ចិត្តគ្នា" ដំបូងតែមួយ។ បន្ទាប់មកទើបយើងចាប់ធ្វើការបង្ហាញអំពី អ្វីដែលបានឆ្លុះបញ្ចាំងចេញពីក្នុងសំនួរ ដែលអ្នកបានសួរនិងពត៌មានដែលអ្នកបានចម្រាញ់ចេញពីចម្លើយ។

៣. ត្រូវចេះធ្វើការជ្រើសរើសយកនូវចំណុចណា ដែលសំខាន់ជាងគេបកប្រែនៅក្នុងបុព្វបទ ។ គឺជាចំណុចដែលអាចចងក្រងផ្ទៃរឿងទាំងមូលជាមួយគ្នា។ ហើយក៏មិនមែនជាចំណុច ដែលមានលើកតែអំពីហេតុការណ៍មួយ ឬអំពីអ្វីតែមួយគត់នោះឡើយ។

៤. ចូរអនុវត្តន៍តាមរូបមន្តទីមួយ និងទីពីរទុកជាមូលដ្ឋានដោយត្រូវមានរូបជាមួយនឹងសកម្មស័ព្ទ (Active Voice) ។ អ្នកយកពត៌មាននៅមានភារៈកិច្ចទទួលខុសត្រូវមួយទៀត គឺត្រូវបង្ហាញអំពីអ្វីដែលជាធាតុពិតរួមជាមួយនឹងអ្វីដែលមាន នៅជុំវិញរឿងមនុស្សចរិតនោះផង។

www.budinst.gov.kh www.elibraryofcambodia



www.budinst.gov.kh www.elibraryofcambodia

## លំហាត់

*សូមអានទូរពត៌មានជាបន្តបន្ទាប់នេះដោយប្រុងប្រយ័ត្ន។ រួចហើយចូរឆ្លើយ ទៅនឹងសំនួរជាមូលដ្ឋាននៃកត្តាទាំងប្រាំមួយគឺ ៖ អ្នកណា? រឿងអ្វី? ហេតុអ្វី? កន្លែងណា? ពេលណា? និងដោយរបៀបណា? (Who? What? Why? Where? When? and How?) ។ បន្ទាប់មកចូរសរសេរអត្ថបទនោះឡើងវិញដោយអនុវត្តន៍តាមមេរៀនដូចមានបរិយាយរួចមកស្រាប់។ បញ្ជាក់ អត្ថបទនិមួយៗត្រូវសរសេរឲ្យបានចំនួនប្រាំវគ្គ (five paragraphs) ។*

**លំហាត់ទីមួយ**

សូមអានអត្ថបទដែលមានជាបំដាប់បំដោយនេះ ដោយប្រុងប្រយ័ត្ន។ បន្ទាប់មកចូរសរសេរបង្ហាញ អំពីកត្តានៃសំនួរជាមូលដ្ឋានទាំងប្រាំមួយ ដែលមានដូចជា ៖ *Who, When, Where, What, Why and How* (អ្នកណា, ពេលណា, កន្លែង ណា, រឿងអ្វី, ហេតុអ្វី, និងដោយរបៀបណា)។ កត្តានៃសំនួរខ្លះប្រហែលជាត្រូវមានច្រើនចំណុច។ និងចួនកាលពាក្យថា *Why* និង *How* អាចប្រើជាសំនួរដែលសួរបានដូចគ្នា។ ចូរចាំថា សំនួរដែលជាមូលដ្ឋានទាំងអស់នេះ គឺគេប្រើវាសំរាប់ប្រមូលពត៌មាន។ ដូច្នេះបើយើងចង់ធ្វើសេចក្តីរាយការណ៍អំពីព្រឹត្តិការណ៍អ្វីមួយដើម្បីជាការងាយស្រួលគឺ យើងត្រូវប្រើកត្តានៃសំនួរជាមូលដ្ឋានទាំងប្រាំមួយនេះជាចាំបាច់។ ជាធម្មតាទេ បើករណីនៃរឿងនោះមានភាពស្មុគស្មាញខ្លាំងមែនទែន ដូច្នេះការរកចម្លើយសំរាប់សំនួរនោះគឺ វាច្បាស់ជាមានការពិបាកខ្លាំងជាមិនខាន។

ការបើកអង្គប្រជុំឡើងវិញរបស់សភាជាតិ នឹងត្រូវពន្យាពេលមួយសប្តាហ៍ទៀត។ ថ្ងៃកំណត់ដែលថានឹងត្រូវធ្វើគឺ ថ្ងៃទី៩ ខែសីហានេះ។ ប៉ុន្តែត្រូវបានលើកទៅធ្វើនៅ ថ្ងៃទី១៦ ខែសីហាវិញ។

លោកឧត្តមបណ្ឌិត ស៊ឹមណៀង, អនុប្រធានទីមួយនៃសភាជាតិ បានមានប្រសាន៍ថា ការពន្យាពេលលើកនេះគឺ ដោយមកពីតំណាងរាស្ត្រភាគ

www.budinst.gov.kh www.elibraryofcambodia

ច្រើនត្រូវចុះទៅសួរសុខទុក្ខរាស្ត្រដែលមាននៅតាមមណ្ឌលរៀងៗខ្លួន។ ឯកឧត្តមបានមានប្រសាសន៍បន្ថែមទៀតថា តំណាងរាស្ត្រភាគច្រើនបានសុំច្បាប់ដើម្បីអញ្ជើញទៅជួយប្រជារាស្ត្រនៅតាមមណ្ឌលមួយចំនួន ដែលកំពុងជួបប្រទះនូវការខ្វះខាតស្បៀង។ ប៉ុន្តែនៅមានតំណាងរាស្ត្រមួយចំនួនទៀតបានត្អូញត្អែរដូចនេះថា សភាជាតិបានធ្វើការពន្យារពេលសំរាប់អង្គប្រជុំរបៀបនេះជាញឹកញាប់ពេកហើយ។ ដូច្នេះហើយបានជាមានពង្រាងច្បាប់សំខាន់ៗមួយចំនួនមិនអាចមានដំណើរការទៅមុខរួច។

បទបញ្ញត្តិផ្ទៃក្នុងរបស់សភាជាតិមានចែងថា នៅក្នុងពេលមានអង្គប្រជុំម្តងៗ ចំនួនវត្តមាននៃសមាជិកសភាត្រូវមានចំនួនយ៉ាងតិចក៏៨៤នាក់ដែរដើម្បីនឹងអាចអនុម័តច្បាប់មួយបាន។

តើនរណាខ្លះ ដែលមានការទាក់ទិននៅក្នុងរឿងនេះ?

តើនរណាខ្លះ ដែលបានប្រាប់យើងអំពីរឿងនេះ?

តើមានរឿងអ្វីកើតឡើង? ផ្នែកសំខាន់ៗនៃសាច់រឿង ដែលជាមូលដ្ឋាននៃពត៌មាន។

តើមកពីហេតុអ្វីបានជាមានរឿងហ្នឹងកើតឡើង?

តើវាកើតឡើងពីពេលណា? តើវានឹងកើតឡើងនៅពេលណា?

តើវាកើតឡើងនៅទីណា?

តើសាធារណជននឹងទទួលឥទ្ធិពលពីរឿងនោះដោយរបៀបណា?

**លំហាត់ទីពីរ**

ហោរាប្រចាំព្រះបរមរាជវាំងបានទស្សន៍ទាយថា នាឆ្នាំខាងមុខនេះព្រះរាជាណាចក្រកម្ពុជា នឹងមានភ្លៀងធ្លាក់គ្រប់គ្រាន់ មានសន្តិភាព និងមានសុភមង្គល។

លោកហោរាបានទស្សន៍ទាយដូចនេះ នៅក្នុងព្រះរាជពិធីច្រត់ព្រះនង្គ័លដែលបានប្រារព្ធធ្វើនៅវាលព្រះមេរុ និងដែលស្ថិតនៅជិតព្រះបរម

www.budinst.gov.kh www.elibraryofcambodia

រាជវាំង។ មានម្ហូបអាហារជាច្រើនមុខ ដែលគេបានដាក់នៅលើជើងពានសំរាប់ជាដង្វាយក្នុងនោះគឺ មានស្មៅ និងសុរាជាដើម។ ប៉ុន្តែគោឧសុភរាជទាំងបីគូរនោះគឺបានបរិភោគ ពោត, សណ្តែក, និងស្រូវច្រើនជាងមុខម្ហូបផ្សេងៗទៀត។

លោកហោរាបានពន្យល់ដូច្នេះថា បើគោឧសុភរាជទាំងអស់បរិភោគស្មៅនោះគឺ មានន័យថា នាឆ្នាំក្រោយគោក្របីទាំងអស់នឹងត្រូវមានកើតជម្ងឺឆ្លងរាលដាលជាមិនខាន។ ហើយបើគោនោះផឹកសុរាវិញ គឺមានន័យថា ព្រះរាជាណាចក្រកម្ពុជាយើងនឹងមានជួបប្រទះនូវរឿងចលាចល និងមានទុក្ខវេទនា។ មានគោឧសុភរាជមួយនឹមបានដើរដួលនៅក្នុងពេលដែលព្រះរាជពិធីកំពុងតែប្រព្រឹត្តទៅ ហើយមានមនុស្សជាច្រើន ដែលគេមានការយល់ឃើញថានោះគឺជាប្រផ្នូលដ៏អាក្រក់ជាទីបំផុត។

ព្រះរាជពិធីដ៏មហោឡារិកនេះបានប្រារព្ធធ្វើឡើង នៅក្រោមព្រះរាជកិច្ចដឹកនាំនៃព្រះរាជបុត្រារបស់ព្រះករុណាគឺ ព្រះអង្គម្ចាស់នរោត្តមរណឫទ្ធិ។ ឆ្នាំនេះព្រះករុណាបានយាងចូលរួមដែរ ប៉ុន្តែព្រះអង្គគ្រាន់តែយាងមកគង់ទតតែប៉ុណ្ណោះ។

ព្រះករុណាបានមានព្រះរាជបន្ទូលថា ដោយសារមកពីព្រះអង្គមានព្រះរោគនៅពុំទាន់ជាសះស្បើយ និងម្យ៉ាងទៀតដោយសារមកពីគ្រូពេទ្យរបស់ព្រះអង្គបានទូលដល់ព្រះអង្គថា សូមឲ្យព្រះអង្គសំរាកព្រះកាយពល ឲ្យបានច្រើន...។

តើនរណាខ្លះដែលមាននៅក្នុងរឿងនេះ? តើនរណាប្រាប់យើងអំពីរឿងនេះ?
តើនរណាខ្លះដែលត្រូវទទួលឥទ្ធិពលពីរឿងនោះ?
តើមានរឿងអ្វីកើតឡើងហ្នឹង?
តើហេតុដូចម្តេចបានជាមានរឿងហ្នឹងកើតឡើង?
តើរឿងហ្នឹងមានកើតឡើងពីកាលណា?
តើរឿងហ្នឹងកើតឡើងនៅកន្លែងណា?
តើប្រជារាស្ត្រទទួលបានឥទ្ធិពលពីរឿងហ្នឹងដោយរបៀបណា?

www.budinst.gov.kh www.elibraryofcambodia

**សំរាត់ទី២**

កាលពីម្សិលមិញ មានកងតម្រួតយោធាមកពីខេត្តបាត់ដំបង និងបន្ទាយមានជ័យបានធ្វើការបាញ់គ្នាដោយប្រើអាវុធធុនស្វ័យប្រវត្តិ និងរ៉ុកកែត។ ការបាញ់គ្នានេះបានកើតឡើងកាលពីម្សិលមិញនាវេលាម៉ោង២រសៀល គឺនៅត្រង់ប៉ុស្តិ៍ត្រួតពិនិត្យមួយ ដែលស្ថិតនៅលើផ្លូវជាតិលេខ៥ មានចម្ងាយប្រមាណជា២៥គីឡូម៉ែត្រពីខាងត្បូងទីប្រជុំជនស៊ីសុផុន។

ហេតុការណ៍នេះបានកើតឡើង បន្ទាប់ពីមានរថយន្តពាក់ស៊ីមួយគ្រឿងដែលមានតម្រួតយោធាម្នាក់ធ្វើដំណើរពីបាត់ដំបង ហើយគាត់ត្រូវបានប៉ូលីសប្រចាំការនៅកន្លែងប៉ុស្តិ៍ត្រួតពិនិត្យនោះឃាត់ខ្លួន ដោយសារមកពីគាត់ប្រកែកពុំព្រមបង់ប្រាក់ដល់ពួកគេ។

សាក្សីមួយចំនួនបាននិយាយថា មានប៉ូលីសត្រួតពិនិត្យម្នាក់បានចាប់គាត់ទាញចេញពីក្នុងរថយន្តពាក់ស៊ី ហើយបានសម្លុតថា នឹងសម្លាប់គាត់ចោល។ គាត់ក៏បានប្រើវិទ្យុទាក់ទងទៅមិត្តភ័ក្តិរបស់គាត់ ដោយបានប្រាប់ដល់ពួកគេថា គាត់កំពុងតែមានគ្រោះអាសន្ន គឺមានគេចង់សម្លាប់គាត់។ ក្នុងមួយរយៈពេលខ្លីក្រោយមកមានមិត្តភ័ក្តិរបស់គាត់ប្រមាណជាសែសិបនាក់ប្រកបដោយអាវុធគ្រប់ដៃបានមកដល់កន្លែងកើតហេតុ។

សាក្សីទាំងនោះក៏បាននិយាយដែរថា ខាងប៉ូលីសត្រួតពិនិត្យក៏បានប្រើវិទ្យុទាក់ទងសុំជំនួយពីគ្នាគេដែរ។ ហើយមួយរំពេចនោះក៏មានប៉ូលីសចំនួនប្រមាណជាហុកសិបនាក់បានមកដល់។ បន្ទាប់មកការផ្ទុះអាវុធមួយក៏ចាប់ផ្តើមឡើង។ ការបាញ់គ្នានោះបានត្រូវបញ្ចប់ទៅវិញ បន្ទាប់ពីខាងពួកប៉ូលីសត្រួតពិនិត្យនាំគ្នារត់ទៅដល់វាលស្រែ។ គ្មានរបាយការណ៍និយាយអំពីអ្នករបួសទេ។

ការសំភាសន៍ជាមួយអ្នកបើកពាក់ស៊ីម្នាក់ នៅត្រង់កន្លែងត្រួតពិនិត្យនោះបានឲ្យដឹងថារឿងរបៀបនេះតែងតែមានកើតឡើងសឹងគ្រប់ពេលវេលា។ គាត់បាននិយាយបន្តទៀតថា គាត់ធ្លាប់បើកបរនៅលើផ្លូវនេះជាយូរណាស់

www.budinst.gov.kh www.elibraryofcambodia

មកហើយ។ ជារៀងរាល់លើក គាត់តែងត្រូវបានគេឃាត់រថយន្តរបស់គាត់ ដើម្បីត្រួតពិនិត្យយ៉ាងតិចណាស់ក៏មានចំនួនប្រាំផងដែរក្នុងមួយជើងៗ។ ហើយតាមប៉ុស្តិ៍ត្រួតពិនិត្យនិមួយៗ គាត់ត្រូវបង់ប្រាក់ឲ្យគេចំនួនយ៉ាងតិចពី ១០០០រៀល ទៅ៣០០០រៀលដែរ។

តើរឿងនេះមាននិយាយអំពីនរណាខ្លះ?
តើនរណាជាអ្នកនិយាយរឿងនេះប្រាប់ដល់យើង?
តើមានរឿងអ្វីកើតឡើងខ្លះ?
តើហេតុអ្វីបានជាមានរឿងនេះកើតឡើង?
តើរឿងនេះកើតឡើងពីកាលណា?
តើរឿងនេះកើតឡើងនៅទីណា?
តើប្រជារាស្ត្រទទួលឥទ្ធិពលពីរឿងនេះដោយរបៀបណា?

**លំហាត់ទីបួន**

ឧទ្ធម្ភាគចក្ររបស់កងអាកាសចរខេមរភូមិន្ទមួយចំនួន បានធ្វើការទម្លាក់គ្រាប់បែកលើជំរកដ៏រឹងមាំមួយរបស់ខ្មែរក្រហមនៅប៉ៃលិន។

នៅឯទីក្រុងភ្នំពេញមាននាយទាហានអាកាសចរមួយរូប បាននិយាយថា កាលពីថ្ងៃអាទិត្យ និងថ្ងៃច័ន្ទកន្លងទៅនេះមានគ្រាប់បែកទម្ងន់៥០០ គីឡូក្រាមចំនួនបួនគ្រាប់បានត្រូវឧទ្ធម្ភាគចក្រធុន អ៊ីមអាយ១៧ (Mi-17) ដឹកយកទៅទម្លាក់លើជំរករបស់ពួកខ្មែរក្រហម។ អ្នកនាំពាក្យរូបនេះមានឋានន្តរស័ក្តិជាអនុសេនីយឯកនៃកងអាកាសចរខេមរភូមិន្ទ។ លោកពុំបានប្រាប់ឈ្មោះ ដល់អ្នកសារពត៌មានយើងទេ តែលោកបាននិយាយដែរថា គ្រាប់បែក ទាំងអស់នោះបានបំផ្លាញអាគារធំៗរបស់ខ្មែរក្រហមអស់ចំនួនពីរខ្នង។

ប៉ៃលិនគឺជាមូលដ្ឋានសឹក និងជាតំបន់ពាណិជ្ជកម្មត្បូង ដ៏សំខាន់របស់ខ្មែរក្រហម ដែលពួកគេអាចរកប្រាក់បានយ៉ាងច្រើនជាទីបំផុតដើម្បីយក

www.budinst.gov.kh www.elibraryofcambodia

ទៅទិញកាំភ្លើង និងគ្រាប់រំសេវ។ សព្វថ្ងៃនេះពួកខ្មែរក្រហមបានកំពុងតែធ្វើការវាយប្រហារយ៉ាងខ្លាំងក្លាមកលើកងទ័ពរាជរដ្ឋាភិបាល ដែលឈរជើងនៅព្រៃង ដែលជាឃុំមួយស្ថិតនៅតាមផ្លូវជាតិលេខ១០។ អ្នកសង្កេតការណ៍អន្តរជាតិម្នាក់បាននិយាយថា មានប្រជាពលរដ្ឋមួយភាគធំត្រូវបានជន្លៀសចេញពីប៉ៃលិន។

អាកាសយានិកមួយរូបបាននិយាយប្រាប់យើងថា នៅក្នុងពេលដែលលោក កំពុងតែធ្វើការហោះហើរនោះ ឧទ្ធម្ភាគចក្ររបស់លោកបានទទួលរងនូវការបាញ់រះយ៉ាងខ្លាំងក្លាពីក្រុមមនុស្សមួយចំនួននៅប៉ៃលិន។ ប៉ុន្តែសំណាងល្អដែរដោយលោកបានធ្វើការហោះហើរយ៉ាងខ្ពស់ផុតពីការបាញ់រះនោះ។ លោកបាននិយាយបន្តទៀតថា លោកមានការពិបាកណាស់ក្នុងការពិនិត្យមើលឲ្យច្បាស់អំពីគ្រាប់បែកដែលបានទម្លាក់ចុះទៅនោះថា តើវាបានធ្លាក់ទៅចំកន្លែងណាខ្លះ។ ប៉ុន្តែលុះមកដល់ថ្ងៃច័ន្ទ ដោយមេឃស្រឡះល្អ លោកក៏អាចមើលឃើញមានអាគារធំៗចំនួនពីរបានត្រូវទទួលរងនូវការខ្ទេចខ្ទាំគ្មានសល់។ ហើយបើតាមការបង្ហាញនៅក្នុងផែនទីវិញក៏បានបញ្ជាក់ដែរថា អាគារទាំងពីរនោះគឺជាសណ្ឋាគារ។

តើមាននរណាខ្លះនៅក្នុងរឿងនេះ? តើនរណាដែលបានប្រាប់យើងអំពីរឿងនេះ? តើនរណាខ្លះដែលបានទទួលឥទ្ធិពលពីរឿងនេះ?

តើមានរឿងអ្វីកើតឡើង?

តើហេតុដូចម្តេចបានជាមានរឿងហ្នឹងកើតឡើង?

តើរឿងហ្នឹងកើតឡើងពីពេលណា?

តើរឿងហ្នឹងកើតឡើងនៅកន្លែងណា?

តើសាធារណៈជននឹងទទួលបានឥទ្ធិពលអំពីរឿងនោះដោយរបៀបណា?

**លំហាត់ទី៣**

កាលពីម្សិលមិញនៅក្នុងរាជធានីភ្នំពេញ មាននិពន្ធនាយកពីររូប

www.budinst.gov.kh www.elibraryofcambodia

បានត្រូវតុលាការកាត់សេចក្តីអោយជាប់ទោស។

លោកទាំងពីររូបនោះបានត្រូវទោសពីបទថា បានផ្សព្វផ្សាយនូវពត៌មានមិនពិត និងដែលធ្វើឲ្យមានការប៉ះពាល់ដល់កិត្តិយសរបស់សហនាយករដ្ឋមន្ត្រីទាំងពីរគឺ ស្តេចក្រុមព្រះនរោត្តម រណឫទ្ធិ និងសម្តេចហ៊ុន សែន។

លោកហែន វិភាគ និពន្ធនាយកនៃសារពត៌មានសេរីភាពថ្មី និងលោកធុន ប៊ុនលី ចាងហ្វាងសារពត៌មានឧត្តមគតិខ្មែរ។ លោកទាំងពីរត្រូវបានតុលាការសំរេចឲ្យបង់ពិន័យជាប្រាក់ចំនួនប្រាំលានរៀល។ ដូចគ្នាដែរលោកហែន វិភាគត្រូវបានតុលាការកាត់ទោសឲ្យជាប់ពន្ធនាគារចំនួនមួយឆ្នាំ។ ប៉ុន្តែបើតាមការបកស្រាយរបស់បុគ្គលិកម្នាក់នៃសមាគមសិទ្ធិមនុស្សបាននិយាយឲ្យដឹងថា ទោសដែលត្រូវជាប់ពន្ធនាគារនេះនឹងកើនឡើងទ្វេមួយជាពីរ បើសិនជាលោកទាំងពីរគ្មានប្រាក់សំរាប់បង់ពិន័យទេនោះ។ បុគ្គលិកដដែលនេះបាននិយាយដែរថា ចំពោះករណីលោកធុន ប៊ុនលី ឧបករណ៍ការិយាល័យទាំងអស់របស់លោកនឹងត្រូវគេរឹបអូស។ ហើយរូបគាត់ផ្ទាល់នឹងត្រូវជាប់ពន្ធនាគារចំនួនពីរឆ្នាំដូចលោកហែន វិភាគដែរ។ បើសិនជាលោកគ្មានប្រាក់សំរាប់បង់ពិន័យទេនោះ។

នៅក្នុងពេលដែលលោកហែន វិភាគត្រូវបានតុលាការកាត់ឲ្យជាប់ទោសស្រាប់តែមាននិស្សិតមួយក្រុមបានស្រែកតវ៉ាយ៉ាងអឺងកងនៅក្នុងបន្ទប់សវនាការ។

សមាគមអ្នកសារពត៌មានខ្មែរ (KJA) ក៏បានបង្ហាញនូវការពុំពេញចិត្តរបស់ខ្លួនអំពីការកាត់ទោសរបស់តុលាការនេះដែរ។ លោកពិន សំខុនជាប្រធានសមាគម (KJA) ថែមទាំងបានធ្វើការអំពាវនាវដល់ក្រសួងយុត្តិធម៌សភាជាតិ និងរាជរដ្ឋាភិបាល ដើម្បីសុំឲ្យតុលាការធ្វើការវិនិច្ឆ័យលើករណីនេះសារឡើងវិញ។

លោកពិន សំខុន បាននិយាយថា ការកាត់ទោសរបៀបនេះគឺ បានរំលោភបំពានលើរដ្ឋធម្មនុញ្ញ ដែលជាព្រលឹងរបស់ជាតិ និងដែលបាន

www.budinst.gov.kh www.elibraryofcambodia

ការធានាថា ប្រជាពលរដ្ឋកម្ពុជាគ្រប់រូបត្រូវតែសប្បាយរីករាយជាមួយនឹងសេរីភាពក្នុងការបញ្ចេញមតិ យោបល់ និងសេរីភាពសារពត៌មាន។

តើមាននរណាខ្លះនៅក្នុងរឿងនេះ? តើនរណាជាអ្នកប្រាប់យើងអំពីរឿងនេះ?

តើមានរឿងអ្វីកើតឡើង?

តើហេតុដូចម្តេចបានជាមានរឿងហ្នឹងកើតឡើង?

តើរឿងហ្នឹងកើតឡើងពីពេលណា?

តើរឿងហ្នឹងកើតឡើងនៅកន្លែងណា?

តើរឿងនេះនឹងជះឥទ្ធិពលយ៉ាងណាខ្លះដល់សាធារណៈជន?

**លំហាត់ទីផ្ទាំមួយ**

មានរថយន្តដឹកទំនិញពីរគ្រឿង និងរថយន្តពាក់ស៊ីពីរគ្រឿងត្រូវបានគេឃាត់ដំណើរនៅលើកំណាត់ផ្លូវជាតិលេខ៤។

មានក្រុមប្រដាប់អាវុធមួយក្រុមមានគ្នាប្រហែលជាម្ភៃនាក់ប្រកបដោយអាវុធស្វ័យប្រវត្ត និងរ៉ុកកែតបាននាំគ្នាពួនស្ទាក់ឃាត់រថយន្តដឹកទំនិញ និងពាក់ស៊ីនៅខាងត្បូងទីក្រុងភ្នំពេញចំងាយ១៣០គីឡូម៉ែត្រ។ នាវេលាម៉ោង៧:៣០នាទីព្រឹក។

បុគ្គលិកជំនួយមនុស្សធម៌មួយរូបបាននិយាយថា អង្ករចំនួន៤០តោនដែលមាននៅលើរថយន្តដឹកទំនិញត្រូវបានគេលួចអស់។ ហើយអ្នកដំណើរដែលជិះនៅក្នុងរថយន្តពាក់ស៊ីទាំងអស់ក៏ត្រូវបានគេប្លន់ដែរ។ ពួកគេបាននិយាយថា គ្មានរបាយការណ៍អំពីមនុស្សស្លាប់ និងរបួសនោះទេ។ តាមប្រភពពត៌មានយោធាបាននិយាយថា អង្ករចំនួន២៥តោនត្រូវបានដណ្តើមយកមកវិញបន្ទាប់ពីមានក្រុមទាហានរដ្ឋាភិបាលធ្វើការដេញតាម និងវាយប្រហារទៅលើក្រុមចោរអស់រយៈពេលចំនួន៩០នាទីនោះមក។

ផ្លូវជាតិលេខ៤ គឺជាផ្លូវមួយដែលកំពុងស្ថិតនៅក្រោមការជួសជុល។ មានទាហានរដ្ឋាភិបាលមួយចំនួនធំត្រូវបានដាក់បន្ថែម ដើម្បីការពារសុវត្ថិភាព

www.budinst.gov.kh www.elibraryofcambodia

ដល់កម្មករ ដែលត្រូវធ្វើការងារនៅលើបណ្ដោយផ្លូវនោះ។

ប្រភពពត៌មានរបស់យោធាមួយបាននិយាយថា ហេតុការណ៍ដែលកើតឡើងនេះ គឺប្រហែលជាអំពើរបស់ក្រុមទាហានដែលគ្មានសណ្ដាប់ធ្នាប់។ ប៉ុន្ដែបើតាមសំដីរបស់បុគ្គលិកអង្គការជំនួយមនុស្សធម៌នោះវិញ គាត់បាននិយាយថា ឧប្បត្ដិហេតុនេះកើតឡើងគឺ ពុំមែនជាអំពើរបស់ទាហាន ដែលស្រវឹងស្រាមិនដឹងខ្យល់នោះឡើយ។ គាត់ថែមទាំងបានបញ្ជាក់ផង ដែរថាការរៀបចំពួនស្ទាក់ដើម្បីប្លន់នេះ គឺជាការរៀបចំមួយដោយមានការប្រុងប្រយ័ត្នជាទីបំផុត។ និយាយរួមគឺវាហាក់ដូចជាអំពើរបស់ពួកខ្មែរក្រហមអញ្ចឹង។ ពីព្រោះពួកវាប្រើសុទ្ធតែគ្រាប់រ៉ុកកែត។ បុគ្គលិករូបនេះក៏បានធ្វើការពន្យល់យ៉ាងដូច្នេះដែរថា ទោះជាយ៉ាងណាក៏ដោយផ្លូវជាតិលេខ៥ពុំមែនជាគ្មានសុវត្ថិភាពទាំងស្រុងនោះទេ។ ពីព្រោះហេតុការណ៍ ដូចនេះតែងតែមានកើតឡើងស្ទើរគ្រប់ពេលវេលា។

តាមប្រភពពត៌មានយោធាដដែលបានឲ្យដឹងដែរថា កន្លងទៅថ្មីៗនេះ គេធ្លាប់បានឃើញពួកខ្មែរក្រហមធ្វើការឆ្លងកាត់តាមផ្លូវជាតិលេខ៥ ញឹកញាប់ណាស់ពីព្រោះតំបន់នេះជាវាលស្រូវស្ងៀង។ ដូច្នេះពួកវាត្រូវតែធ្វើការផ្លាស់ប្ដូរទីកន្លែង។

តើនរណាខ្លះដែលមានមុខនៅក្នុងរឿងនេះ? នរណាជាអ្នកប្រាប់យើងអំពីរឿងនេះ? តើមានរឿងអ្វីកើតឡើង?

តើហេតុអ្វីបានជាមានរឿងហ្នឹងកើតឡើង?

តើរឿងហ្នឹងកើតឡើងនៅពេលណា?

តើរឿងហ្នឹងកើតឡើងនៅទីណា?

តើរឿងហ្នឹងវាផ្ដល់ឥទ្ធិពលដល់សាធារណជនដោយរបៀបណា?

www.budinst.gov.kh www.elibraryofcambodia

*សូមអានរឿងទាំងអស់ ដែលមានជាបន្តបន្ទាប់។ រួចហើយចូរធ្វើការបង្ហាញអំពីចម្លើយទៅនឹងសំនួរជាមូលដ្ឋានទាំងប្រាំមួយ។ តើអ្នកអាចសរសេររឿងទាំងអស់នេះតាមវិធីផ្សេងទៀតបាន ឬទេ?*

**អាជ្ញាធរខេត្តបាត់ដំបងបានធ្វើការណែនាំអោយបង្ខាំងពួកទាហានដោយហ្មត់ចត់ ទាត់តឹន** ថ្ងៃទី ២-៦-៩៦

អាជ្ញាធរខេត្តបាត់ដំបង បានធ្វើការណែនាំដល់គ្រប់មេបញ្ជាការទាំងអស់ឲ្យបង្ខាំងកូនទាហានរបស់ខ្លួននៅក្នុងបន្ទាយ។ គេធ្វើដូច្នេះគឺ ដើម្បីទប់ស្កាត់មិនឲ្យមានការហូរចេញនូវគ្រឿងសព្វាវុធ និងគ្រាប់រំសេវទៅឲ្យពួកខ្មែរក្រហម។

ឯកឧត្តមបណាំ ទុំ អភិបាលរងទី២ ប្រចាំខេត្តបាត់ដំបងមានប្រសាសន៍ថា ឯកឧត្តមធ្លាប់បានលើករំពឹករណីនេះនៅក្នុងពេល ដែលឯកឧត្តមសហរដ្ឋមន្ត្រីនៃក្រសួងការពារជាតិបានអញ្ជើញមកធ្វើទស្សនៈកិច្ចនៅក្នុងភូមិភាគពាយព្យនេះ។

នៅក្នុងពេលដែលយើងមិនទាន់មានភស្តុតាងច្បាស់លាស់ថា មានទាហានបានលក់អាវុធទៅឲ្យខ្មែរក្រហមនោះ ឯកឧត្តមបណាំ ទុំ បាននិយាយដែរថា គឺមានតែការបង្ខាំងទាហានឲ្យនៅក្នុងបន្ទាយទេ ទើបយើងអាចគ្រប់គ្រងសកម្មភាពនេះបាន។ ឯកឧត្តមបាននិយាយបញ្ជាក់ថា នៅក្នុងប្រទេសយើងសព្វថ្ងៃ គឺមានពោរពេញទៅដោយគ្រឿងសព្វាវុធ។ ហើយពួកខ្មែរក្រហមបានដើររកទិញអាវុធនិងគ្រាប់រំសេវ ដែលមាននៅលើទឹកដីក្នុងព្រះរាជាណាចក្រកម្ពុជាដោយសេរីថែមទៀតផង។

ឯកឧត្តមថែមទាំងបានធ្វើការណែនាំទៅខាងភ្នំពេញ ដើម្បីឲ្យពិចារណាឡើងវិញ ក្នុងការពិន័យទោសឲ្យធ្ងន់ជាងនេះថែមទៀត ចំពោះជនណាដែលបានរកឃើញថា មានអាវុធខុសច្បាប់។ នេះគឺសរុបទាំងការដែលត្រូវដាក់ពន្ធនាគារផង។

www.budinst.gov.kh www.elibraryofcambodia

ឯកឧត្តមបានមានប្រសាសន៍ដូច្នេះដែរថា ក្នុងពេលបច្ចុប្បន្ននេះចំពោះជនដែលមានអាវុធខុសច្បាប់ ហើយដែលត្រូវបានរឹបអូស គឺនៅមិនទាន់ត្រូវបង្ហាញខ្លួនចំពោះមុខច្បាប់នៅឡើយទេ។ ឯកឧត្តមណាំ ទុំ ថែមទាំងបានធ្វើសំណូមពរដល់រដ្ឋាភិបាលឲ្យជួយផ្តល់ថវិការដល់អាជ្ញាធរខេត្តដើម្បីទិញអាវុធ និងគ្រាប់រំសេវទាំងអស់នោះមកវិញ។

នៅក្នុងពេលថ្មីៗនេះ អាជ្ញាធរខេត្តបាត់ដំបងបានប្រកាសថា នឹងផ្តល់រង្វាន់ដល់ជនណា ដែលស្ម័គ្រចិត្តប្រគល់អាវុធខុសច្បាប់ទាំងអស់ជូនដល់រដ្ឋាភិបាល។ "យើងនឹងជូនរង្វាន់ចំនួនពី ៥០០ - ១០០០បាតសំរាប់អាវុធមួយដើម។ ហើយបើសិនជាយើងគ្មានលុយទេ យើងនឹងជូនជាអង្ករមួយបាវជំនួសវិញ។" នេះគឺតាមសំដីរបស់ឯកឧត្តមណាំ ទុំ។ ប៉ុន្តែឯកឧត្តមក៏បានមានប្រសាសន៍ដែរថា ការខ្វះខាតថវិការគឺ មិនអាចនឹងសំរេចបាននូវគំនិតផ្តួចផ្តើមនេះទេ។

យោងតាមប្រសាសន៍របស់ឯកឧត្តមអភិបាលរងទី២បានឲ្យដឹងថា អស់រយៈពេលបីឆ្នាំហើយ ផែនការនេះទទួលបានលទ្ធផលពីការលោមព័ទ្ធរឹបអូសបានអាវុធនៅក្នុងខេត្តចំនួន៥០០ដើម។ ហើយនៅមានចំនួន ២០០០ដើមទៀតដែលបានចាប់ និងរឹបអូសបានក្នុងអឡុងពេលដូចគ្នា។

**កងយោធពលខេមរភូមិន្ទធ្វើការវាយប្រហារសាជាថ្មីនៅប៉ៃលិន**

**ដោយលោកហ្សូអ៊ី ចាន់តឹង** ថ្ងៃទី២-៧-៩៦

បន្ទាប់ពីមានភាពស្ងប់ស្ងាត់អស់រយៈពេលចំនួនបីថ្ងៃមក។ កងកម្លាំងរដ្ឋាភិបាលបានចាប់ផ្តើមធ្វើការវាយរុញច្រានជាថ្មី ទៅលើពួកខ្មែរក្រហមនៅតាមផ្លូវជាតិលេខ១០គឺ ឆ្ពោះទៅប៉ៃលិន។ បើតាមការនិយាយរបស់ទាហានពួកគេបានឲ្យដឹងថា ការប្រយុទ្ធលើកនេះគឺ ជាការប្រយុទ្ធមួយដ៏ធំជាងគេបង្អស់ ដែលមិនធ្លាប់មាននៅក្នុងអឡុងពេលបីឆ្នាំកន្លងមកនេះ។

មន្ត្រីយោធាម្នាក់ដែលសុំមិនឲ្យបញ្ចេញឈ្មោះបាននិយាយថា ចាប់តាំង

www.budinst.gov.kh www.elibraryofcambodia

ពីថ្ងៃទី២២មករាកន្លងមកកងកម្លាំងរបស់រដ្ឋាភិបាលកំពុងតែជម្រុញទៅមុខបានចម្ងាយ ៥គីឡូម៉ែត្រហើយ។ ឥឡូវនេះយើងកំពុងជួបប្រទះនូវការប្រយុទ្ធដ៏ស្វិតស្វាញមួយពីពួកខ្មែរក្រហមក្នុងកងពលលេខ៤០៥ ដែលកំពុងឈរជើងនៅលើភ្នំសំណែ្តកមានចម្ងាយប្រមាណ៥០គ.ម. នៅទិសពាយព្យនៃទីរួមខេត្តបាត់ដំបង។

មន្ត្រីយោធាដដែលនេះបាននិយាយដែរថា ខាងខ្មែរក្រហមមានរថក្រោះចំនួន៧គ្រឿង និងមានកម្លាំងប្រមាណជា២០០០នាក់។ មានរថក្រោះរបស់ពួកវាមួយគ្រឿងបានត្រូវបំផ្លាញដោយគ្រាប់កាំភ្លើងធំកាលពីថ្ងៃសៅរ៍កន្លងទៅ។

ពួកខ្មែរក្រហមកំពុងបង្កំចិត្តពង្រឹងទីតាំងនេះ តាមការប្រមូលកម្លាំងរបស់ពួកវាមកពីខេត្តពោធិសាត់ និងកោះកុង។ ពួកវាមានគ្រាប់កាំភ្លើងស្តុកទុកច្រើនណាស់។ នេះជាការអះអាងរបស់មន្ត្រីយោធាដដែលខាងលើ។ "គ្រាប់របស់ពួកវាគឺនៅថ្មីៗ ជាគ្រាប់ផលិតមកពីប្រទេសចិន" មន្ត្រីយោធារូបនោះនិយាយ "យើងអាចដឹងថាវានៅថ្មី ពីព្រោះយើងបានឃើញសំបកគ្រាប់របស់ពួកវានៅភ្លឺរលោងនៅឡើយ។"

មន្ត្រីយោធានោះបានបន្តទៀតថា បើតាមសេចក្តីរាយការណ៍ពីភ្នាក់ងារស៊ើបអង្កេតរបស់យើងបានឲ្យដឹងថា ពួកគេបានឃើញគ្រាប់ទាំងអស់នោះត្រូវបានគេដឹកជញ្ជូនចេញពីរថយន្តជាច្រើនគ្រឿង ដែលឆ្លងកាត់មកពីប្រទេសថៃ។

លោកបាននិយាយបន្ថែមថា "ទឹកសំរាប់ផឹកនៅជួរមុខកំពុងមានការខ្វះខាតខ្លាំងណាស់។ ពីព្រោះពួកវាបានយកថ្នាំបំពុលទៅដាក់នៅតាមប្រភពទឹកទាំងអស់បន្ទាប់ពីពួកវាបានដកថយ។"

មានមន្ត្រីយោធាជាន់ខ្ពស់ជាច្រើនរូប ដែលជាមេបញ្ជាការនៅក្នុងយុទ្ធនាការនេះ គឺនៅរក្សាភាពស្ងៀមស្ងាត់នៅឡើយ។ ពួកគេថែមទាំងចេញបញ្ជាហាមមិនឲ្យមានអ្នកកាសែតធ្វើដំណើរហួសពីចំណុចត្រួត ពិនិត្យមួយ

www.budinst.gov.kh www.elibraryofcambodia

នៅលើផ្លូវជាតិលេខ១០ ដែលស្ថិតនៅត្រង់គីឡូម៉ែត្រលេខ ៣៧នោះឡើយ។

តាមការសង្កេតរបស់ព្រះសង្ឃនៅភូមិស្ទឹង និងនៅវត្តកំផែងបានឲ្យដឹងថា ការវាយប្រហារគ្នានោះមានរយៈពេលពីរសប្តាហ៍ហើយ។ ខាងកម្លាំងរបស់រដ្ឋាភិបាលបាននាំសាកសពទាហានចំនួន២១នាក់មកបូជា។

ការចូលទៅកាន់មន្ទីរពេទ្យយោធានៅបាត់ដំបងមានការពិបាកខ្លាំងណាស់។ ដោយសារមកពីមានការហាមឃាត់។ ប៉ុន្តែមានលោកវេជ្ជបណ្ឌិតនៅក្នុងខេត្តម្នាក់បានឲ្យដឹងថា គ្រែនៅក្នុងមន្ទីរពេទ្យនេះទាំងអស់មានចំនួន ២០០ ហើយគ្មានគ្រែណាមួយទំនេរទេ។ មានទាហានរបួសមួយចំនួនដែលយើងពុំមានតួលេខបានត្រូវគេដឹកឡៀសទៅភ្នំពេញកាលពីចុងសប្តាហ៍នេះ។ លោកវេជ្ជបណ្ឌិតដដែលនោះបាននិយាយថា មានអ្នករបួសភាគច្រើនគឺដោយសារដើរជាន់មីន។ ប៉ុន្តែបើតាមការអះអាងរបស់សារពត៌មានប្រចាំថ្ងៃមួយគឺឱ្យខាមបូឌាដេលីបានផ្សាយថា មានទាហានជាច្រើនរូបដែលបានរងរបួសដោយគ្រាប់កាំភ្លើងត្រូវបានគេបញ្ជូនមកព្យាបាលនៅក្នុងមន្ទីរពេទ្យខេត្ត។

ទោះជាយ៉ាងណាក៏ដោយ មានលោកអនុសេនីយទោមួយរូបសុំពុំបញ្ចេញឈ្មោះបាននិយាយថា ៣០%ភាគរយនៃចំនួនទាហានទាំងអស់ ដែលមានមុខនៅក្នុងយុទ្ធនាការនេះកំពុងជួបប្រទះនឹងជម្ងឺគ្រុនចាញ់។ ពួកគេកំពុងតែមានការខ្វះខាតថ្នាំប្រឆាំង នឹងជម្ងឺគ្រុនចាញ់ ថ្នាំជំនួយជាតិអំបិលក្នុងខ្លួន ថ្នាំបំបាត់ការឈឺចាប់ និងគ្រឿងប្រដាប់សំរាប់រុំដំបៅ។

## ការឆ្លងរាលដាលមួសពីការស្មានទុកនៃមេរោគហ៊ីវ (HIV)

**ដោយលោកហ្សូទ៍ ម៉ាត់គីន ថ្ងៃទី២៩-៨-៩៦**

ការឆ្លងរាលដាលនៃមេរោគហ៊ីវនៅក្នុងចំណោមមនុស្ស ដែលកំពុងធ្វើពាណិជ្ជកម្មខាងផ្លូវភេទនៅកម្ពុជា គឺអាចមានអត្រាឡើងរហូតដល់ ៤០%។ នេះគឺយោងតាមការស្រាវជ្រាវលើកដំបូងបង្អស់របស់ក្រសួងសុខាភិបាល។

លោកវេជ្ជបណ្ឌិត ហាវ ប៊ុនឡេង នាយកគ្រប់គ្រងកម្មវិធីជាតិដើម្បី

www.budinst.gov.kh www.elibraryofcambodia

ទប់ស្កាត់ហ៊ីវ និងអេដស៍ បានមានប្រសាសន៍ថា តាមការពិសោធន៍ដែលទើប នឹងកន្លងទៅថ្មីៗនេះបានឲ្យដឹងថា នៅក្នុងខេត្តកោះកុងមានអត្រាចំនួន៣៩% និងនៅក្រុងព្រះសីហនុមាន៣៨%។ មេរោគហ៊ីវកំពុងតែរាលដាលខ្លាំងមែនទែននៅក្នុងភូមិភាគនារតីនៃប្រទេសកម្ពុជា។

"ខ្ញុំមានការតក់ស្លុតខ្លាំងណាស់ចំពោះអត្រានៃមេរោគហ៊ីវ ដែលកំពុងតែកើនឡើងជាលំដាប់នេះ។ វាជារឿងមួយដែលគួរឲ្យភ័យខ្លាចជាទីបំផុតចំពោះប្រជាជនកម្ពុជា"។ សំដីរបស់លោកវេជ្ជបណ្ឌិត។

នៅក្នុងខេត្តសៀមរាប ដែលជាតំបន់ប្រាសាទបូរាណដ៏ល្បីល្បាញមួយ និងជាតំបន់ ដែលកំពុងតែមានការរីកចំរើនខាងផ្នែកទេសចរណ៍ផងនោះ គឺគេបានឲ្យដឹងថា បើតាមការពិសោធន៍លើអ្នកដែលកំពុងធ្វើពាណិជ្ជកម្មខាងផ្លូវភេទ គេឃើញមានអ្នកផ្ទុកមេរោគហ៊ីវចំនួន៣៥%។ ទន្ទឹមនឹងនោះដែរនៅមានខេត្តមួយចំនួនទៀត ដែលមានដូចជាខេត្តរតនគិរីនៅក្នុងភូមិភាគខាងជើង និងខេត្តកណ្តាលនៅភូមិភាគខាងត្បូង។

បើតាមការពិសោធន៍ទៅលើ អ្នកប្រកបរបរពាណិជ្ជកម្មខាងផ្លូវភេទមួយចំនួន គឺបានឲ្យដឹងដែរថា នៅខេត្តរតនគិរីមានអត្រា២១,៥% និងខេត្តកណ្តាលមាន១៣,៥%។ នៅក្នុងខែក្រោយកម្មវិធីនេះនឹងបន្តការងាររបស់ខ្លួនទៀតក្នុងខេត្តបាត់ដំបង គឺជាខេត្តធំជាងគេទីពីរនៅកម្ពុជា។

"លោកវេជ្ជបណ្ឌិត ហាវ ប៊ុនឡេង បានបញ្ជាក់យ៉ាងដូច្នេះថា នៅក្នុងការពិសោធន៍ម្តងៗ ជាមធ្យមគឺគេទទួលបានអ្នកស្ម័គ្រចិត្តចំនួន១៥០នាក់។ "ប៉ុន្តែដើម្បីនឹងអាចទទួលបាននូវលទ្ធផលជាទីគាប់ចិត្តសំរាប់ខេត្តនិមួយៗគឺ យើងត្រូវការអ្នកស្ម័គ្រចិត្តចំនួន២៥០នាក់។ ទោះជាយ៉ាងណាក៏ដោយ យើងនៅតែបន្តការងារនេះ ពីព្រោះយើងយល់ថា អត្រាដែលយើងទទួលបាននេះគឺ មានចំនួនមិនខុសគ្នាប៉ុន្មានឡើយ។ "លោកវេជ្ជបណ្ឌិត ហាវ ប៊ុនឡេង បានមានប្រសាសន៍ទៀតថា ឯកឧត្តម ឈា ថាំង ប្រធានគណកម្មាធិការជាតិទប់ស្កាត់ជម្ងឺអេដស៍ និងដែលជារដ្ឋ មន្ត្រីក្រសួងសុខាភិបាលបានធ្វើ

www.budinst.gov.kh www.elibraryofcambodia

សេចក្ដីប្រកាសភាពអាសន្ននៅក្នុងអង្គប្រជុំមួយ ដើម្បីទុកជាការឆ្លើយតបទៅនឹងកំណើនអត្រានៃមេរោគហ៊ីវនេះ។ លោកវេជ្ជបណ្ឌិតប៊ុនឡេងបានមានប្រសាសន៍នៅក្នុងអង្គប្រជុំថា ករណីនេះសំខាន់ណាស់ ដូច្នេះហើយបានជាយើងត្រូវតែយាងសម្ដេចក្រុមព្រះ នរោត្តមរណឫទ្ធិ នាយករដ្ឋមន្ត្រីទីមួយដើម្បីទទួលនាទីជាប្រធាននៃគណកម្មាធិការនេះ។ "សម្ដេចនាយករដ្ឋមន្ត្រីទីមួយបានយល់ព្រមទទួលសំណូមពរនេះហើយ"។ នេះជាប្រសាសន៍របស់លោកវេជ្ជបណ្ឌិត។

លោកវេជ្ជបណ្ឌិតក៏បានអំពាវនាវផងដែរដល់គ្រប់សហគមអន្តរជាតិឲ្យជួយផ្ដល់ជំនួយដល់វិភាគទានសំរាប់ការសិក្សាអប់រំ និងការពិសោធន៍អំពីមេរោគហ៊ីវនេះ។ បើតាមការប៉ាន់ស្មានរបស់អង្គការសុខភាពពិភពលោកបានឲ្យដឹងដែរថា ក្នុងមួយឆ្នាំៗប្រជាជនកម្ពុជាត្រូវចំណាយប្រាក់ក្នុងម្នាក់មួយដុល្លារសំរាប់កម្មវិធីនេះ។ និយាយរួមគឺ យើងត្រូវការចំនួនដប់លានដុល្លារក្នុងមួយឆ្នាំ។ ប៉ុន្តែសព្វថ្ងៃនេះយើងមានប្រាក់តែកន្លះលានដុល្លារប៉ុណ្ណោះសំរាប់ការចាយវាយនៅក្នុងកម្មវិធីនេះ។

**ខ្មែរក្រហមប្រាំពីរនាក់ស្លាប់ក្នុងការប្រយុទ្ធមួយនៅខេត្តបាត់ដំបង**

**ដោយលោកហ្សូ ឧរ៉េត់តឹន** ថ្ងៃទី៣-១០-៩៦

កងយោធពលខេមរភូមិន្ទបានធ្វើការវាយប្រហារទៅលើកម្លាំងខ្មែរក្រហមមួយក្រុមនៅភូមិឬស្សីគូ ជាភូមិមួយដែលស្ថិតនៅចម្ងាយ២៥គ.ម. នៅខាងត្បូងខេត្តបាត់ដំបង។ នៅក្នុងការប្រយុទ្ធលើកនេះមានពួកខ្មែរក្រហមស្លាប់ ចំនួនប្រាំពីរនាក់ និងចាប់ខ្លួនបានចំនួនបីនាក់។

ការប្រយុទ្ធគ្នានេះចាប់ផ្ដើមឡើងនៅវេលាម៉ោង២:៣០នាទីព្រឹកថ្ងៃអង្គារ។ នៅពេលនោះមានពួកខ្មែរក្រហមចំនួនប្រហែល ៦០នាក់បាននាំគ្នាធ្វើការវាយប្រហារមក លើទីបញ្ជាការយោធារបស់រដ្ឋាភិបាលមួយកន្លែងនៅក្នុងភូមិខាងលើ។ ខាងខ្មែរក្រហមបានប្រើកាំភ្លើងត្បាល់ធុន៨២ម.ម. ប៉េ៤០

www.budinst.gov.kh www.elibraryofcambodia

LIBRARY

និងអាកា៤៧។ លោកវរសេនីយឯក សួន សួលីបាននិយាយថា ពួកខ្មែរក្រហមមានជំនឿថាពួកវានឹងយកភូមិនេះជាប៉ុស្តិ៍ដើម្បីឈរជើងនៅមុនពេលដែលផ្ទះសំបែងមួយចំនួនត្រូវបានពួកវាដុតចោល និង បានប្លន់យកស្រូវអង្ករនិងទ្រព្យសម្បត្តិរបស់អ្នកភូមិ។ លោកបាននិយាយបន្តទៀតថា នៅក្នុងការប្រយុទ្ធគ្នារសរយៈពេលប្រហែលជាបួនម៉ោងនោះ ខាងលោកមានកូនទាហានម្នាក់ត្រូវស្លាប់ និងពីរនាក់ត្រូវរបួស។

មួយថ្ងៃបន្ទាប់ពីការប្រយុទ្ធគ្នានោះមក លោកមេញ្ញការកងពលលេខ៥ជា កងពលស្រុកបានបញ្ជូនទ័ពបន្ថែមចំនួន៣០០នាក់ទៀតឲ្យទៅឈរជើងនៅភូមិឃ្នង់គូ ជាភូមិមួយដែលស្ថិតនៅចំងាយប្រមាណ២ គ.ម. ខាងកើតបាណន់។ បាណន់ជាស្រុកមួយដែលសំបូរទៅដោយដំណាំកសិកម្ម និងដែលស្ថិតនៅខាងត្បូងនៃទីប្រជុំជនបាត់ដំបង។ “នៅពេលដែលកងជំនួយយើងបានមកដល់ ពួកខ្មែរក្រហមបានចែកផ្លូវគ្នាយ៉ាងបន្ទាន់ជាទីបំផុត”។ លោកបាននិយាយបន្តដូច្នេះទៀតថា កងកាំភ្លើងធំរបស់កងយោធពលខេមរភូមិន្ទក៏បានបាញ់ផ្លោងទៅលើភូមិបឹងវាលមានចំងាយប្រហែលជា៧គ.ម. នៅខាងត្បូងភូមិឃ្នង់គូ។ ការបាញ់ផ្លោងនេះគឺ ដើម្បីការពារកុំឲ្យពួកខ្មែរក្រហមអាចបញ្ជូនកម្លាំងរបស់ខ្លួនមកកាន់ភូមិឃ្នង់គូបាន។ “កម្លាំងជំនួយរបស់យើងនឹងឈរជើងនៅទីនោះរហូតដល់ពេលណា ដែលយើងដេញពួកខ្មែរក្រហមអស់។” នេះជាសំដីរបស់លោកវរសេនីយឯក។

សព្វថ្ងៃនេះ អាជ្ញាធរនៅក្នុងខេត្តបាត់ដំបងបានខិតខំអស់កម្លាំងកាយចិត្តដើម្បីការពារផ្លូវជាតិលេខ៥ កុំឲ្យខ្មែរក្រហមបន្តធ្វើការវាយប្រហារបានទៀត។ បើតាមពត៌មានពីស្ថានីយទូរទស្សន៍បាត់ដំបងបានផ្សាយកាលពីយប់ម្សិលម៉ិញថា លោកអភិបាលខេត្ត អ៊ុង សាមី បានមានប្រសាសន៍ដូច្នេះថា កម្លាំងបន្ថែមចំនួន ២៦០០នាក់ ដែលជាកងនគរបាលជាតិ និងកងយោធពលខេមរភូមិន្ទ នឹងត្រូវបញ្ជូនឲ្យទៅនៅការពារផ្លូវជាតិលេខ៥ គឺចាប់ពីខេត្តពោធិ៍សាត់ដល់បន្ទាយមានជ័យ។ ឯកឧត្តម អ៊ុង សាមី បាន

www.budinst.gov.kh www.elibraryofcambodia

មានប្រសាសន៍ដូច្នេះទៀតថា ថ្វីដ្បិតតែយើងមានកម្លាំងបន្ថែមមែន ប៉ុន្តែផែនការនេះអាចទទួលជោគជ័យបានគឺ យើងត្រូវពឹងផ្អែកទៅលើការបង្កើនទូវកិច្ចសហការណ៍ផ្សារវាងកងកម្លាំងនគរបាលជាមួយនឹងកងយោធពលខេមរភូមិន្ទ និងកងស្វ័យត្រានប្រចាំមូលដ្ឋានឲ្យកាន់តែជិតស្និតថែមទៀត។ ឯកឧត្តម បានអំពាវនាវដល់កងស្វ័យត្រាន ជាពិសេសឲ្យបង្កើនសមត្ថភាពរបស់ខ្លួនដើម្បីក្តាប់ឲ្យបានត្រឹមត្រូវអំពីកម្លាំងរបស់ខ្មែរក្រហមដែលមាននៅក្នុងភូមិនានាដែលស្ថិតនៅតាមបណ្តោយផ្លូវជាតិលេខ៥។ លោកអភិបាលខេត្តបានធ្វើការផ្សព្វផ្សាយផងដែរថា នឹងមានជាអំណោយចំនួន២០លានរៀលសំរាប់ជួយឧបត្ថម្ភដល់គ្រួសារទាហានរដ្ឋាភិបាលណា ដែលត្រូវពលីជីវិត ឬរងរបួសដោយសារការប្រយុទ្ធគ្នាណាមួយជាមួយខ្មែរក្រហម។ ឯកឧត្តមថែមទាំងបានសន្យាថា នឹងមានផ្តល់ជូនជារង្វាន់ដល់បុគ្គលណា ដែលបានផ្តល់ពត៌មានអំពីស្ថានភាពសឹករបស់ពួកក្រុមក្រៅច្បាប់នេះ។

នៅក្នុងខែកញ្ញានេះ ពួកទ័ពព្រៃបានបំបែកគ្នាជាក្រុមតូចៗនាំគ្នាធ្វើការវាយឆ្មក់នៅពេលយប់ បំផ្លាញស្ពាន ផ្តាច់ផ្លូវរថយន្ត និងផ្លូវដែកតាមការប្រើមីនផ្ទុះប្រឌិត។ ការវាយឆ្មក់ទាំងនោះច្រើនមាននៅត្រង់ស្រុកមោងឫស្សីជាស្រុកមួយដែលគេទទួលបានពត៌មានបកថា យ៉ាងតិចណាស់ក៏មានខ្មែរក្រហមចំនួន៦០នាក់ដែរ ដែលកំពុងធ្វើសកម្មភាពសព្វថ្ងៃនេះ។

**ខ្មែរក្រហមនៅបន្តការជីកត្បូង**

**ដោយ លោកហ្សង់ ម៉ាត់គីន** ថ្ងៃទី៥-១០-៩៦

**បាត់ដំបង:** ខ្មែរក្រហមកំពុងបញ្ចេញឥទ្ធិពលនៅភូមិភាគពាយព្យនៃប្រទេស កម្ពុជា និងដែលកំពុងបង្កើនសកម្មភាពជីកត្បូងនៅក្នុងតំបន់ ដែលខ្លួនកាន់កាប់។ នេះគឺយោងតាមប្រសាសន៍របស់លោកអភិបាលខេត្តរង ទី២ ណាំ ទុំ។ តាមរយៈការបកប្រែលោកមានប្រសាសន៍ថា យើងដឹងច្បាស់ណាស់គឺប្រាកដជាមានការជីកត្បូងមែន ព្រោះតាមការកត់សំគាល់របស់យើង

www.budinst.gov.kh www.elibraryofcambodia

ដែលជាអាជ្ញាធរមូលដ្ឋាន យើងបានសង្កេតឃើញទឹកស្ទឹងសង្កែប្រែពណ៌ឡើងពណ៌ដូចទឹកភក់ខុសប្លែកពីធម្មតា។ "ចំណាប់អារម្មណ៍របស់យើងនេះគឺទទួលបានពីអ្នកសង្កេតការណ៍របស់កងឃោធពលខេមរភូមិន្ទ ដែលបានរាយការណ៍មកថា មានសកម្មភាពជីកត្បូងដ៏ធំមួយនៅប៉ៃលិន។" នេះគឺជាប្រសាសន៍របស់លោកណាំ ទុំ ។ "អ្នកសង្កេតការណ៍ទាំងនោះបាននិយាយថា ពួកគេបានឃើញមានគ្រឿងម៉ាស៊ីនសំរាប់ជីកត្បូងថ្មីៗជាច្រើនគ្រឿង និងបានឃើញមានរថយន្ត ដែលអាចផ្ទុកទម្ងន់១៥តោន កំពុងធ្វើសកម្មភាពដឹកជញ្ជូនចំនួនយ៉ាងតិច១០០ជើងក្នុងមួយថ្ងៃនៅតាមមាត់ស្ទឹង ដែលគេបានសន្មត់ថាជាកន្លែងយកដីទៅលាង។"

តំបន់ប៉ៃលិនគឺ ជាតំបន់មួយត្រូវបានពិភពលោកទទួលស្គាល់ថា គឺជាទីផលិតត្បូងដ៏មានតម្លៃជាងគេ ជាពិសេសគឺដូចជាត្បូងកាទីប និងកណ្តៀងជាដើម។ "ត្បូងកាទីបខ្លះមានទំហំតូចប៉ុនគ្រាប់ពោតសោះ តែវាមានតម្លៃរហូតដល់២០.០០០ដុល្លាសហរដ្ឋ។" តាមប្រសាសន៍របស់លោកណាំ ទុំ។ យោងតាមប្រសាសន៍របស់លោកអភិបាលរងខេត្តបាត់ដំបងបានឲ្យដឹងដែរថា សកម្មភាពជីកត្បូងនេះបានចាប់ផ្តើមឡើងនៅក្នុងឆ្នាំនេះទន្ទឹម គ្នានឹងពេលដែលអាជ្ញាធរថៃចាប់ផ្តើមធ្វើសកម្មភាពទប់ស្កាត់មិនឲ្យមានការធ្វើអាជីវកម្មឈើ។ ប៉ុន្តែលោកបានមានប្រសាសន៍បន្តទៀតថា មានតែក្រុមអាជ្ញាធរថៃមួយចំនួនតូចប៉ុណ្ណោះ ដែលកំពុងធ្វើការងារដើម្បីទប់ស្កាត់មិនឲ្យមានការរត់ពន្ធត្បូងមានតម្លៃនេះ។ "អ្នករត់ពន្ធត្បូងគេលេបត្បូងចូលទៅក្នុងពោះ។ គេយកវាចេញមកវិញ គឺនៅពេលបន្ទាប់ពីគេបានធ្វើដំណើរឆ្លងដែនចូលទៅប្រទេសថៃរួច។ មនុស្សលែងខ្លាចអំពីគ្រោះថ្នាក់អ្វីទាំងអស់នៅពេលដែលគេដឹងថា គេនឹងរកលុយបានច្រើន។" លោកណាំ ទុំបានមានប្រសាសន៍ដែរថា "រៀងរាល់ខែការរត់ពន្ធរបៀបនេះគឺ នៅមានបន្តជាប់រហូត។ ប្រជាជនកម្ពុជាត្រូវខាតបង់ប្រាក់អស់រាប់រយលានដុល្លារក្នុងមួយខែៗ។" លោកបានបន្តដូច្នេះទៀតថា "មានមធ្យោបាយតែមួយគត់ដែលអាចបញ្ឈប់ការរត់ពន្ធ

www.budinst.gov.kh www.elibraryofcambodia

របស់ខ្មែរក្រហមបានគឺ ត្រូវធ្វើយ៉ាងណាវាយយកប៉ៃលិនមកកាន់កាប់ជាមុនសិន។" បើតាមការស្មានរបស់មន្ត្រីជំនួយមនុស្សធម៌គេបានឲ្យដឹងថា នៅក្នុងរដូវប្រាំងខាងមុខនេះគេសង្ឃឹមថា នឹងមានការព្រមព្រៀងគ្នាមួយដើម្បីវាយលុកទៅលើទ័ពព្រៃនៅក្នុងភូមិភាគខាងលិចខេត្តបាត់ដំបង។

**កម្ពុជាចាប់ផ្តើមធ្វើសកម្មភាពប្រឆាំងនឹងអាជីវកម្មផ្លូវភេទ**

**ដោយលោក ហ្សូម៍ ម៉ាត់តឺន** ថ្ងៃទី ១១.៧.៩៦

**ភ្នំពេញៈ** ពង្រាងច្បាប់មួយដែលរៀបចំឡើងដោយក្រសួងយុត្តិធម៌នៃព្រះរាជាណាចក្រកម្ពុជាបានលើកអំពីការពិន័យដ៏ធ្ងន់ធ្ងរមួយដោយរួមទាំងមានការជាប់ពន្ធនាគារក្នុងរយៈពេលចំនួនម្ភៃឆ្នាំចំពោះបុគ្គលណា ដែលប្រកបមុខរបររកស៊ីលក់នារីអាទ និងកុមារឲ្យធ្វើជាទាសភាពកាមគុណ។ នៅក្នុងព្រះរាជាណាចក្រទាំងមូលគេបានដឹងថា មាននារីចំនួន២០.០០០នាក់កំពុងប្រកបមុខរបរជាអ្នកបំរើកាមគុណ។ ហើយនៅក្នុងនោះគឺ មានចំនួនប្រហែលជាពាក់កណ្តាលត្រូវបានគេយកទៅលក់ឲ្យធ្វើជាពេស្យាចារ។ នេះគឺយោងទៅតាមរបាយការណ៍របស់សមាគមអភិវឌ្ឍន៍ស្ត្រីនៅកម្ពុជា។

លោកស្រី កៀន សិរីផល ប្រធាន *(សអសក)* បានមានប្រសាសន៍ថា តាមការស្រាវជ្រាវរបស់សមាគមបានឲ្យដឹងថា ចំនួន៣៧% នៃស្ត្រីដែលមានមុខរបរជាអ្នកបំរើកាមគុណ ត្រូវបានគេចាប់ពង្រាត់យកទៅលក់នៅតាមបនពេស្យា។ លោកស្រីបានបន្តទៀតថា នៅក្នុងនោះមានចំនួន ១១% គឺត្រូវបានមិត្តប្រុស ឬគ្រួសារនាំយកទៅលក់។ "ការរស់នៅរបស់ស្ត្រីទាំងនោះគឺវេទនាណាស់។ ពួកគេរស់នៅដូចជាសត្វធាតុអញ្ជឹង" ប្រសាសន៍របស់លោកស្រី។ "ពួកគេត្រូវបានឃុំឃាំងនៅក្នុងបន្ទប់រហូតមិនឲ្យចេញមកខាងក្រៅទេ។" បើពួកគេចង់លួចរត់ ពួកគេនឹងត្រូវទទួលរងនូវទារុណកម្មដោយត្រូវវាយនឹងរំពាត់ខ្សែតី ឬខ្សែភ្លើង និងជួនកាលត្រូវបានគេដុតនឹងភ្លើងបារី។ ពួកគេភាគច្រើនត្រូវបដិសេធមិនឲ្យមានការពិនិត្យ

www.budinst.gov.kh www.elibraryofcambodia

សុខភាព និងការថែរក្សាមិនឲ្យមានកូន។ ពួកគេមួយចំនួនធំត្រូវសំរេចចិត្ត បណ្តោយតាមយថាកម្មជាជាងការត្រឡប់ទៅរស់នៅក្នុងសហគមន៍វិញ ទាំងក្តីអាម៉ាស់។ "ចំណែកប្រាក់ដែលពួកនាងរកបាន គឺត្រូវបានម្ចាស់បនរក្សាទុក។" លោកស្រី បានមានប្រសាសន៍ដូច្នេះ។ យោងតាមប្រសាសន៍ របស់លោកស្រីកៀន សិរីផល ហើយលោកស្រីបានបញ្ជាក់ថា នៅមានរឿងផ្សេងជាច្រើនទៀតដូចជាមាននារីមួយចំនួនត្រូវបានបញ្ជូនទៅប្រទេសថៃ តាមច្រកប៉ោយប៉ែត និងកោះកុង។

ពង្រាងច្បាប់នេះ នឹងត្រូវបញ្ជូនទៅមន្ទីរសភា ដើម្បីធ្វើការអនុម័ត នៅក្នុងខែតុលាឆ្នាំនេះ។ នៅក្នុងច្បាប់នោះក៏មានចែងផងដែរចំពោះអ្នក ដែលមានរឿងពាក់ព័ន្ធនៅក្នុងការជំរុញនារីរោទនេះគឺ នឹងត្រូវជាប់ពន្ធនាគារ ចំនួនដប់ប្រាំឆ្នាំ និងម្ភៃឆ្នាំចំពោះអ្នកដែលត្រូវបានរកឃើញថា មានរឿងពាក់ព័ន្ធ ជាមួយក្មេងដែលមានអាយុក្រោម១៨ឆ្នាំ។ អ្នកដែលត្រូវជាប់ទោសពីបទ ថាបានរួមភេទជាមួយកុមារ និងអ្នកពាក់ព័ន្ធ គឺត្រូវជាប់ពន្ធនាគារក្នុង រយៈពេលដប់ប្រាំឆ្នាំ។ ប៉ុន្តែលោកស្រី កៀនសិរី ផលនៅមិនទាន់មានជំនឿ ថា អ្វីៗដែលមានចែងនៅក្នុងច្បាប់នោះ នឹងប្រាកដជាមានប្រសិទ្ធិភាព នោះឡើយ។ "ជាការប្រសើរណាស់ដែលយើងមានច្បាប់" នេះគឺប្រសាសន៍ របស់លោកស្រី "ប៉ុន្តែប្រទេសកម្ពុជានៅពុំទាន់មានបធ្យោបាយដើម្បី ឲ្យមានការប្រតិបត្តិតាមច្បាប់នោះបាន១០០%នៅឡើយទេ។" ចំពោះអង្គ ការអន្តរជាតិមួយចំនួនគេមានអារម្មណ៍ថា ពង្រាងច្បាប់នេះនឹងធ្វើឲ្យមានការ បញ្ចប់មួយ ពីព្រោះអាជ្ញាធរត្រូវចាត់វិធានការបំបាត់របររកស៊ីផ្លូវភេទនេះ នៅតាមមូលដ្ឋានរៀងខ្លួន។ ការធ្វើដូច្នេះ គឺត្រូវបង្ខំឲ្យមានការរកស៊ីលួចលាក់ និងធ្វើឲ្យអ្នកទាំងនោះត្រូវស្ថិតនៅឆ្ងាយពីច្បាប់ និងការសិក្សាអប់រំ។

នៅលើជំពូកទីបីមានចែងថា នឹងត្រូវផ្តន្ទាទោសដល់បុគ្គលណា ដែលរស់នៅដោយពឹងផ្អែកលើកម្លាំងញើសឈាមអំពីការរំលោភអាសអាភាសពីស្មៀវ ឬដែល

www.budinst.gov.kh www.elibraryofcambodia

បានផ្តល់ទីជំរកសំរាប់ពេស្យាចារ។ បុគ្គលនោះនឹងត្រូវមានទោសដោយជាប់ពន្ធនាគារចំនួនដប់ឆ្នាំ នឹងត្រូវពិន័យជាប្រាក់ចំនួន$១៦០០ គឺជាចំនួនដ៏ច្រើនលើសលប់ បើប្រៀបធៀបទៅនឹងប្រាក់ខែរបស់មន្ត្រីរាជការសព្វថ្ងៃ គឺទទួលបានត្រឹមតែ$២០ប៉ុណ្ណោះ។ ម្ចាស់ក្លឹបណា ដែលបានប្រព្រឹត្តិនូវអំពើអបាយមុខនៅលើកន្លែងរបស់ខ្លួនដូចមានចែងនៅក្នុងច្បាប់នេះ នឹងត្រូវមានទោសជាប់ពន្ធនាគារចំនួនប្រាំឆ្នាំ និងត្រូវពិន័យជាប្រាក់ចំនួន $១០០០ ។

នៅពេលដែលមានអ្នកកំពុងទះដៃអបអរសាទរលើករណីមួយចំនួនដែលមាន នៅក្នុងច្បាប់នេះ លោកស្រី ហ្ស៊ូ ហ្គ្រែន (Sue Grant) ទីប្រឹក្សារបស់អង្គការសុខភាពពិភពលោកផ្នែកការអប់រំជម្ងឺអេដស៍បាននិយាយថាពង្រាងច្បាប់នេះនឹងធ្វើឲ្យនារីទាំងនោះត្រូវទទួលរងនូវការធ្វើអធិរកម្មពីលើថែមទៀត និងមានគ្រោះថ្នាក់ដល់សុខភាពធំធេងណាស់។ "បើម្ចាស់បនពេស្យា នឹងត្រូវទទួលនូវការបង់ផាកពិន័យ និងត្រូវមានទោសជាប់ពន្ធនាគារដោយសារគេបានរកឃើញថា គាត់គឺប្រាកដជាអ្នកប្រកបមុខរបររកស៊ីជួញដូរខាងផ្លូវភេទ។ ដូច្នេះអ្នកទាំងអស់នោះនឹងត្រូវដើរចេញពីផ្ទះបន។ បន្ទាប់មកក៏ចាប់ផ្តើមរកស៊ីដោយឯករាជ្យ។ ច្បាប់ (ដែលចែងថាមិនឲ្យមានពេស្យាចារ) នោះនឹងលែងមានប្រសិទ្ធិភាពពី គ្មានប្រសិទ្ធិភាពនៅលើគ្រប់កន្លែងទាំងអស់ក្នុងពិភពលោកយើងនេះ។

"អ្វីដែលគេចង់ធ្វើនៅពេលនេះ គឺជាការបង្អំឲ្យមានការធ្វើទៀងដោយលួចលាក់។ បង្កើនការសូកប៉ាន់ និងអំពើពុករលួយ។ ហើយមុខរបរនេះនឹង លែងទទួលបានជំនួយផ្នែកច្បាប់នៅក្នុងពេលមានរឿងកាត់ក្តីប្តឹងៗដូចជារឿងចាប់នារី ឬកុមារយកទៅលក់ជាដើម ។ល។" នេះគឺជាគំនិតរបស់លោកស្រី ស៊ូ ហ្គ្រែន។ "វាក៏ជារឿងមួយ ដែលធ្វើឲ្យអ្នករកស៊ីជួញដូរខាងផ្លូវភេទ នេះលែងមានមុខមាត់នៅក្នុងសហគមន៍ទៀត និងលែងដឹងអំពីការប្រើ ស្រោមអនាម័យ ដែលជាការចាំបាច់នោះទៀតផង។

ការស្រាវជ្រាវមួយ ដែលកំពុងតែប្រព្រឹត្តទៅដោយក្រសួងសុខាភិបាល

www.budinst.gov.kh www.elibraryofcambodia

បានឲ្យដឹងថា នៅក្នុងប្រទេសកម្ពុជាគេបានរកឃើញមានសញ្ញានៃមេរោគហ៊ីវនៅក្នុងចំណោមអ្នកប្រកបរបររកស៊ីខាងផ្លូវភេទ។ នៅតាមតំបន់ឈ្នួងសមុទ្រ គឺកោះកុង និងក្រុងព្រះសីហនុគេបានរកឃើញអ្នកដែលផ្ទុកមេរោគហ៊ីវ មានចំនួនរហូតដល់ជិត៥០%។ នៅក្នុងខេត្តសៀមរាបគឺជាតំបន់អង្គរវត្ត ដែលកំពុងតែមានប្រជាប្រិយនៅក្នុងឆាកអន្តរជាតិខាងផ្នែកទេសចរ ចំនួនអ្នកផ្ទុកមេរោគហ៊ីវមានរហូតដល់ទៅ៣៥%។ "ខ្ញុំមានការភ្ញាក់ផ្អើលខ្លាំងណាស់ - ហ៊ីវជាគ្រោះថ្នាក់ដ៏ធំមួយសំរាប់ប្រជាជនកម្ពុជា។" នេះគឺជាប្រសាសន៍របស់លោកវេជ្ជបណ្ឌិត ហាវ ប៊ុនឡេង នាយកកម្មវិធី ជាតិនៃក្រសួងសុខាភិបាលដើម្បីទប់ស្កាត់មេរោគហ៊ីវ និងអេដស៍។ "ប៉ុន្តែប្រជាជនកម្ពុជាសព្វថ្ងៃនេះ ពុំព្រមទទួលស្គាល់ថាមេរោគហ៊ីវ និងអេដស៍នេះថា វាជាការពិតឡើយ។"

**កម្ពុជាមានវិធានការទប់ទល់ជាមួយនឹងសារពត៌មានភាសាអង់គ្លេស**

**ដោយលោកហ្សិ ម៉ាត់គីន** ថ្ងៃទី២៥-៨-៩៦

**កម្ពុជា**--ទីស្តីការគណៈរដ្ឋមន្ត្រីបានចាត់វិធានការតាមផ្លូវច្បាប់ដើម្បីទប់ទល់ជាមួយ នឹងសារពត៌មានភាសាអង់គ្លេសមួយឈ្មោះភ្នំពេញប៉ុស្តិ៍ដោយចោទថាបានធ្វើការផ្សព្វផ្សាយដំណើងមិនពិត។ នេះគឺយោងតាមប្រភពពត៌មានមួយដែលទទួលបានមកពីក្រសួងពត៌មាន។

រដ្ឋាភិបាលបាន និងកំពុងចាប់ផ្តើមធ្វើយុទ្ធនាការតាមផ្លូវច្បាប់ដ៏ខ្លាំងក្លាមួយដើម្បីតទល់ជាមួយនឹងការផ្សាយពត៌មាននៅកម្ពុជា ប៉ុន្តែបើតាមសំដីរបស់អ្នកនាំពាក្យក្រសួងពត៌មានគឺលោកឡេង សុជាបានឲ្យដឹងថា នេះជាលើកទីមួយហើយ ដែលរដ្ឋាភិបាលមានវិធានការដើម្បីតទល់ជាមួយនឹងសារពត៌មានមួយ ដែលជាកម្មសិទ្ធិរបស់ជនបរទេស។ "លោក ហេយ៍ នឹងត្រូវឡើងសាវនាការនៅចំពោះមុខតុលាការនាខែកញ្ញាខាងមុខនេះ។ តុលាការនឹងធ្វើសេចក្តីសំរេចថា តើករណីនេះត្រូវធ្វើបន្ត ឬយ៉ាងណា?" ជាសំដីរបស់

www.budinst.gov.kh www.elibraryofcambodia

និពន្ធនាយករបស់សារព័ត៌មាននេះ ប្រហែលជានឹងត្រូវជាប់ពន្ធនាគារក្នុងរយៈពេលចំនួនបីឆ្នាំ បើសិនជាករណីនេះត្រូវកាត់ទោសទៅតាមច្បាប់របស់អង្គការសហប្រជាជាតិ ដែលបានរៀបចំឡើងសំរាប់ការបោះឆ្នោតនៅកម្ពុជានាឆ្នាំ១៩៩៣។

ម្ចាស់សារព័ត៌មានភ្នំពេញប៉ុស្តិ៍ និងជានិពន្ធនាយកផងដែរ លោកម៉ៃកិលហេយ៍ឥឡូវនេះគាត់កំពុងនៅបាងកក និងមិនអាចទាក់ទងដើម្បីសុំយោបល់ ពី គាត់បានឡើយ។ ទោះជាយ៉ាងណាក៏ដោយ លោកស្រីខាតថ៍លើន ហេយ៍ បាននិយាយថា កាសែតនេះនៅមិនទាន់បានទទួលលិខិតប្រាប់ជាដំណឹងណាមួយពីការប្តឹងផ្តល់នៅឡើយទេ។ លោកស្រីបាននិយាយថា កាសែតរបស់លោកស្រីនឹងមិនបញ្ចេញយោបល់អ្វីទាំងអស់លុះត្រាតែកាសែតលោកស្រីទទួលដីការពីតុលាការ។ មានអ្នកសង្កេតការណ៍លើប្រព័ន្ធព័ត៌មាន។ អ្នកសារព័ត៌មាន និងអង្គទូតមួយចំនួនដែលមានវត្តមាននៅទីនេះបានធ្វើការបកស្រាយថា វិធានការនេះគឺ ជាការឲ្យសញ្ញាដល់ម្ចាស់កាសែតភាសាអង់គ្លេសទាំងអស់ដើម្បីកាត់បន្ថយការរិះគន់ថាកម្ពុជាកំពុងតែធ្វើដំណើរងាកចេញពីលទ្ធិប្រជាធិបតេយ្យ។

លោកប្រធានសមាគមអ្នកសារព័ត៌មានខ្មែរគឺ លោកពិន សំខុន បាននិយាយថា រដ្ឋាភិបាលហាក់ដូចជាយកចិត្តទុកដាក់លើរឿងយកប្រព័ន្ធព័ត៌មាននេះទៅកាត់ទោសជាងអ្វីដែលជាសេចក្តីត្រូវការជាបន្ទាន់របស់សង្គម និងបញ្ហាសេដ្ឋកិច្ច។ "កម្ពុជានឹងមានលទ្ធភាពអាចក្លាយទៅជាប្រទេសឈានមុខគេលើផ្នែកលទ្ធិ ប្រជាធិបតេយ្យនៅអាស៊ីអគ្នេយ៍យើងនេះ។ ប៉ុន្តែវាមិនដូច្នោះទេ។" លោកបានបន្តដែរថា "គំនិតរបស់គេ (រដ្ឋាភិបាល) មកលើសេរីភាពក្នុងការនិយាយស្តីគឺ ការនិយាយអំពីអ្វីៗដែលល្អៗអំពីរដ្ឋាភិបាល - មិនយូរទៀតទេ លោកនឹងលែង ឃើញមានការរិះគន់នៅលើទំព័រកាសែតដូចសព្វថ្ងៃនេះទៀតហើយ។"

ចាប់តាំងពីខែមករាមកម្ល៉េះ មាននិពន្ធនាយកសារព័ត៌មានខ្មែរបីរូបនឹង

www.budinst.gov.kh www.elibraryofcambodia

ត្រូវមានទោសដោយត្រូវជាប់ពន្ធនាគារចំនួនពីរឆ្នាំយ៉ាងតិច។ និពន្ធនាយកសារព័ត៌មានឧត្តមគតិខ្មែរគឺ លោកធន់ ប៊ុនលី បានបង្ហាញមុខនៅតុលាការកាលពីថ្ងៃច័ន្ទ ពីបទចោទថា បានធ្វើការផ្សព្វផ្សាយនូវព័ត៌មានមិនពិត និងនៅមាននិពន្ធនាយកចំនួនប្រាំនាក់ទៀតលើកលែងលោក ហេយ៍ ចេញ និងត្រូវមានការវិនិច្ឆ័យទោសនៅក្នុងខែក្រោយ។ ការដែលរដ្ឋាភិបាលបានកំពុងធ្វើការក្បៀបសង្កត់មកលើអ្នកសារព័ត៌មានខ្មែរនេះបានធ្វើឲ្យលេចចេញជាបាតុភាពមួយនៅក្នុងរង្វង់អ្នកសារព័ត៌មាននានាថា អំណាចនៃការគ្រប់គ្រងរបស់គណៈបក្សពីរ គឺកំពុងតែក្លាយទៅជាគ្រឿងប្រដាប់សំរាប់ឃ្លាំមាត់ពួកអ្នកសារព័ត៌មាននៅមុនពេលមានការបោះឆ្នោតនាឆ្នាំ៩៨ខាងមុខនេះ។

ច្បាប់មួយចំនួនដែលមានជាអាទិ៍ និងដែលអាចជ្រើសរើសគឺមានចំនួនបី ក្រឹត្យក្រមរបស់យូអិនមួយ ក្រឹត្យក្រមដែលមានកាលពីនៅក្នុងជំនាន់រដ្ឋកម្ពុជាមួយ និងច្បាប់សារព័ត៌មានដែលទើបបានអនុម័តថ្មីៗនេះមួយ។ ច្បាប់ទាំងអស់នេះគឺ មានចែងតែអំពីការយល់ព្រមអនុម័តឲ្យមានទោសឧក្រិដ្ឋ និងជាប់ពន្ធនាគារ។ ចាប់តាំងពីមានយូអិនចូលមករៀបចំឲ្យមានការបោះឆ្នោតក្នុងឆ្នាំខែឧសភា១៩៩៣មក អ្នកសារព័ត៌មានខ្មែរអន្តោគ្រាមត្រូវទទួលរងនូវការក្បៀបសង្កត់យ៉ាងធ្ងន់ធ្ងរដោយសារមកពីខ្លួនពុំបានបង្ហាញអំពីភស្តុតាង និងជួនកាលថែមទាំងបានធ្វើឲ្យអាម៉ាស់ដល់បុគ្គលមួយចំនួនអំពីរឿងពុករលួយជាដើម។ល។

កាលពីឆ្នាំកន្លងទៅ មានទីស្នាក់ការរបស់សារព័ត៌មានមួយត្រូវទទួលរងនៅការផ្ទុះគ្រាប់បែក។ មានអ្នកសារព័ត៌មានពីរនាក់ត្រូវបានគេលួចសម្លាប់ និងម្នាក់ទៀតត្រូវ បានគេសម្លាប់នៅក្រោមការសង្ស័យថាមានការប៉ុនប៉ង។ ហើយត្រូវបានគេលើកមក និយាយថាជាករណីគ្រោះថ្នាក់ចរាចរ។ ប៉ុន្តែបើតាមការអង្កេតរបស់អង្គការសិទ្ធិមនុស្សបាននិយាយថា ម៉ូតូរបស់អ្នកដែលស្លាប់នោះគ្មានការខូចខាត ឬមានការប៉ះពាល់ត្រង់ណាឡើយ។ ម៉្យាងទៀត

www.budinst.gov.kh www.elibraryofcambodia

នៅក្នុងពេលថ្មីៗនេះ មាននិពន្ធនាយកសារពត៌មានខ្មែរមួយចំនួនបានធ្វើសេចក្តីរាយការណ៍ថា ពួកគេបានទទួលពាក្យបំភ័យថា នឹងមានការសម្លាប់ចោល ហើយកាលពីក្នុងខែកក្កដានេះមានអ្នកកាសែតម្នាក់ត្រូវពួកកូនសិស្សនៅសកលវិទ្យាល័យវាយធ្វើបាប ដោយបាននាំគ្នាចូលមកអុកឡុកក្នុងការិយាល័យ ដើម្បីទាមទារឲ្យមានការសុំអភ័យទោសអំពីករណីថា មានចុះអត្ថបទទិទៀតដល់សម្តេចនាយករដ្ឋមន្ត្រីទីពីរ ហ៊ុន សែន។

www.budinst.gov.kh www.elibraryofcambodia

ផ្នែកទីពីរ

## ការសរសេរបទពណ៌នា
## (Feature Writing)

### អត្ថបទពណ៌នា និងចំណាត់ចំណងរបស់វាទៅនឹងអត្ថបទពត៌មាន

អត្ថបទពត៌មាន (*News Stories*) គឺជាការផ្ដល់ជូនដល់អ្នកអានដើម្បីជ្រាបអំពីប្រធានបទនៃ*ដំណើរ*មួយ ឬអំពីការវិវឌ្ឍន៍នៃដំណើរដែលបាននិងកំពុងតែកើតឡើង និងដែលមានប្រធានបទគួរឲ្យចាប់អារម្មណ៍។ ចួនកាលអត្ថបទដំណើរនេះ អាចមានធ្វើការបកស្រាយអំពីរឿងសំខាន់រឿងមិនធម្មតា ហើយថែមមានការទាក់ទងទៅនឹងបញ្ហាជីវិតរស់នៅរបស់អ្នកអានថែមទៀតផង។

ចំពោះអត្ថបទពណ៌នាវិញ (*Feature Stories*) គឺអាចមានការបកស្រាយ ប្រហាក់ប្រហែលគ្នាទៅនឹងអត្ថបទពត៌មានដែរ។ លក្ខណៈដែលខុសគ្នានោះគឺត្រង់ថា អត្ថបទពណ៌នានេះ វាតម្រូវឲ្យយើងមានការងារធ្វើច្រើនជាងអត្ថបទដំណើរធម្មតា។ អត្ថបទពណ៌នាមួយអាចនិយាយប្រាប់យើងដោយពិស្ដារអំពីព្រឹត្តិការណ៍ថ្មីៗដែលទើបកើតមានឡើង និងអំពីអ្វីដែលមានការទាក់ទងទៅនឹងព្រឹត្តិការណ៍នោះ។ យើងត្រូវចំណាយពេលច្រើនណាស់សំរាប់សរសេរអត្ថបទពណ៌នាមួយ។ ពីព្រោះវាតម្រូវឲ្យមានការ វែកញែក បកស្រាយ ពន្យល់ និងធ្វើវិភាគ ដើម្បីស៊ីជំរៅថែមទៀតផង។ បើនិយាយអំពីរចនាសម្ព័ន្ធវិញ អត្ថបទពណ៌នាមានលក្ខណៈវែងជាង និងមានភាពជឿនលឿនជាងអត្ថបទពត៌មានធម្មតា។ បើអ្នកសរសេរអត្ថបទពណ៌នាត្រូវមានស្មារតីទទួលខុស ហ៊ានសំដែងការស្មោះត្រង់ (ការពិត) និងមិនលំអៀង។ ដូច្នេះអត្ថបទពណ៌នានោះច្បាស់ជានឹងទទួលបាននូវលក្ខណៈដែលប្រកបទៅដោយការប្រឌិតញាណណាមួយ (*a more creative*) ជាមិនខាន។ ជាការពិតណាស់ការរក

www.budinst.gov.kh www.elibraryofcambodia

អត្ថន័យសំរាប់ពត៌មានបទពណ៌នាគឺ ប្រហែលជាមានច្រើនយ៉ាងណាស់ ហើយក៏ប្រហែលជាវាល្អទាំងអស់ដូចគ្នាទៀតផង។ រីឯការសរសេរអត្ថបទពណ៌នាវិញក៏វាដូច្នោះដែរ។

អត្ថន័យសំរាប់អត្ថបទពណ៌នាគឺ បានបង្ហាញយ៉ាងច្បាស់លាស់នៅពេលដែលយើងបានធ្វើការកែសំរួលអត្ថបទនៃដំណឹងមួយឡើងវិញ។ បន្ទាប់មកយើងយកអត្ថបទនៃដំណឹងថ្មីៗនោះមកធ្វើការប្រៀបធៀបនឹងអត្ថបទពណ៌នា។

១_ អត្ថបទដំណឹងនិមួយៗ វាមានរចនាសម្ព័ន្ធមួយពិសេសជាទីបំផុត។ ទ្រង់ទ្រាយរបស់រចនាសម្ព័ន្ធនោះមានរាងដូចជារូបសាជីផ្កាប់ ឬ រូបត្រីកោណផ្ការ។ ហើយចំណុចណាមួយដែលសំខាន់ជាងគេគឺ ត្រូវបានគេយកវាមកដាក់នៅខាងលើគេបង្អស់ និងអ្វីៗដែលបន្ទាប់បន្សំត្រូវដាក់វាតាមលំដាប់លំដោយ។ ចំពោះអត្ថបទពណ៌នាវិញ ក៏អាចយករចនាសម្ព័ន្ធខាងលើនេះទាំងស្រុង ឬផ្នែកណាមួយមកប្រើបានដូចគ្នា។ ប៉ុន្តែជារឿយៗគេតែងសង្កេតឃើញវាមាន (*lead*) សេចក្តីផ្តើម ឬឃ្លាដំបូងខុសប្លែកពីអត្ថបទពត៌មានធម្មតា។ សេចក្តីផ្តើមរបស់អត្ថបទពណ៌នា ចួនកាលវាអាចមានលក្ខណៈជាបទអធិប្បាយមួយ (*a description*) ជាបទដកស្រង់មួយ (*a quote*) ឬជាបទនិទានរឿងខ្លីៗមួយ *an anecdote*) ដែលជាទីចាប់អារម្មណ៍ និងដែលពុំមែនជារឿងប្រឌិត។ អត្ថបទពណ៌នា ភាគច្រើនតែងមានលំនាំដូចជារឿងនិទានផ្នែកអក្សរសាស្ត្រ (*a literary*) ច្រើនជាងមានលំនាំជាពត៌មានដោយត្រង់ៗតែម្តង។ ទ្រង់ទ្រាយរបស់អត្ថបទពណ៌នាមួយគឺមានសេចក្តីផ្តើម តួសេចក្តី និង សេចក្តីបញ្ចប់។ ដូច្នេះការកែសំរួលឬការនិពន្ធឡើងវិញគឺ តែងជួបប្រទះ នូវការពិបាកជាងការដែលគ្រាន់តែកាត់ឬទម្លាក់វគ្គ ឬកថាខ័ណ្ឌ (*paragraphs*) ដែលមាននៅក្នុងសេចក្តីបញ្ចប់នោះចោលទៅទៀត។

២_ ទាំងអត្ថបទពត៌មាន និងអត្ថបទពណ៌នាគឺ ត្រូវតែមានរូបផ្សំ

www.budinst.gov.kh www.elibraryofcambodia

ទៅដោយសំនួរដែលមានកត្តាសំខាន់ៗមួយចំនួនដូចគ្នា។ កត្តាទាំងនោះគឺ មានអ្នកណា, អ្វី, ហេតុអ្វី, ពេលណា, ទីណា, និង របៀបណា (*Who, What, Why, When, Where and How*)។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយចំពោះអត្ថបទពណ៌នានេះគឺមានការការគូសបញ្ជាក់មួយប្លែកពីអត្ថបទពត៌មានធម្មតា។ បើយើងចង់សរសេរអត្ថបទមួយជារបៀបពណ៌នាគឺយើងត្រូវចំណាយពេលច្រើនណាស់សំរាប់ធ្វើការពិពណ៌នាឲ្យបានពិស្តារអំពីមនុស្ស ទីកន្លែង ទស្សនីយភាព និងអំពីភាពរីវឌ្ឍន៍នៃព្រឹត្តិការណ៍នោះ។ យើងអាចលើក អំពីការពិតនៃប្រវត្តិសាស្រ្ត។ យើងអាចស្វែងរកគំនិតទស្សនៈ យោបល់ដែលមានលក្ខណៈទូលំទូលាយ និងដែលអាចយកទៅធ្វើជាការបកស្រាយបាន។ យើងក៏អាចទុកពេលឲ្យបុគ្គលម្នាក់មានឱកាសគ្រប់គ្រាន់ ដើម្បីធ្វើការពន្យល់ពីស្ថានភាពរបស់គាត់ឲ្យបានអស់សេចក្តីដែរ។

៣_ ជារឿយៗ ដើម្បីសរសេរអត្ថបទពណ៌នាមួយគឺ យើងត្រូវចំណាយពេលយូរណាស់។ ចូនកាលគឺយើងត្រូវចំណាយពេលសំរាប់តាមដានស្រាវជ្រាវអំពីអ្វីមួយ ដែលគេបាននិយាយប្រាប់ដល់យើង។ ហើយបើចំពោះពត៌មានធម្មតាវិញគឺ យើងគ្រាន់តែសរសេរអំពីអ្វីមួយ ដែលគេបានលើកឡើងនៅក្នុងសន្និសីទពត៌មាននោះតែប៉ុណ្ណោះ។ តែបើចំពោះអត្ថបទពណ៌នាវិញគឺ ត្រូវមានតាំងពីអ្វីដែលគេបានថ្លែងនៅក្នុងសន្និសីទនោះផង និងត្រូវធ្វើការតាមដានថែមទៀត ដើម្បីរកមើលក្រែងមានប្រតិកម្មណាមួយដែលអាចយកមកធ្វើការប្រៀបធៀបទៅ នឹងសេចក្តីដែលបានថ្លែងពីដើមនោះមកផង ដោយមានទាំងភស្តុតាង និងរូបភាព ត្រឹមត្រូវច្បាស់លាស់។ យោងតាមមធ្យោបាយនេះ អត្ថបទពណ៌នាគឺ តែងមានការធ្វើអធិប្បាយនិងការពន្យល់អំពីព្រឹត្តិការណ៍ ឬសេចក្តីថ្លែងការណ៍នៅក្នុងបរិបទមួយយ៉ាងល្អិតល្អន់ជាទីបំផុត។

៤_ អត្ថបទពណ៌នា គឺត្រូវតែធ្វើឲ្យអ្នកអានមានការ-កំសាន្តសប្បាយ-ជាមួយ។ គឺត្រូវតែធ្វើការអធិប្បាយឲ្យបានពិស្តារអំពីបុគ្គល, ទីកន្លែង,

www.budinst.gov.kh www.elibraryofcambodia

ទស្សនៈ, និងគ្រប់ព្រឹត្តិការណ៍ទាំងអស់។ ត្រូវខិតខំសិក្សាស្រាវជ្រាវរកមើលប្រធានបទមួយដែលមានលក្ខណៈស៊ីជម្រៅជាងគេ និងដែលពោរពេញទៅដោយភាពរស់រវើក។ គឺត្រូវមាននិយាយអំពីរឿងពិតខ្លីៗ (*anecdotes*) ដែលគួរឲ្យចាប់អារម្មណ៍។ ត្រូវចេះដកស្រង់យកពាក្យសំដីរបស់ប្រភពមួយមកប្រើ និងធ្វើការអធិប្បាយអំពីបុគ្គល និងទីកន្លែងឲ្យបានត្រឹមត្រូវនិងច្បាស់លាស់។ នេះគឺជាមធ្យោបាយតែមួយគត់ ដែលអ្នកអានរបស់យើងអាចទទួលបាននូវពត៌មានដែលជាទីគាប់ចិត្ត។ ជារឿយៗការសរសេរអត្ថបទពណ៌នាគឺ តែងតែមានជួបនូវការលំបាកក្នុងការធ្វើទំនាក់ទំនងជាងការសរសេរពត៌មានធម្មតា។ អ្វីៗដែលយើងមើលទៅឃើញហាក់ដូចជាមិនសូវសំខាន់សោះសំរាប់អត្ថបទពត៌មានធម្មតា ក៏ប៉ុន្តែស្រាប់តែវាក្លាយទៅជាវិភាគទានដ៏អស្ចារ្យមួយសំរាប់អត្ថបទពណ៌នាទៅវិញ។

៥_ អត្ថបទពណ៌នាអាចជួយដល់យើងសំរាប់ធ្វើការពន្យល់អំពីប្រវត្តិដើមនៃព្រឹត្តិការណ៍មួយអំពីបរិយាកាសសង្គម និងព្រឹត្តិការណ៍នយោបាយនានាដែលមាន និងកំពុងតែកើតឡើង។ ដើម្បីឲ្យកាន់តែច្បាស់សូមពិនិត្យមើលនៅលើឧទាហរណ៍មួយចំនួន ដែលមាននៅក្នុងសៀវភៅនេះស្រាប់។

**ប្រភេទនៃអត្ថបទពណ៌នា**

១_ កម្រងរឿង ឬបុគ្គលិកលក្ខណៈរបស់ឥស្សរជន ដែលត្រូវមាននៅក្នុងអត្ថបទពណ៌នា (*Profiles or Personality Features*) - ទាំងអស់នេះគឺ ជាការពិពណ៌នាអំពីឥស្សរជនណាម្នាក់ ដែលជាទីចាប់អារម្មណ៍និងដែលយើងត្រូវធ្វើការបកស្រាយឲ្យបានក្បោះក្បាយ។ គឺជាការសរសេរមួយ ដែលប្រហែលជាត្រូវមានការផ្ដែកពិភាក្សាអំពីជីវិត និងទស្សនៈរបស់អ្នកនយោបាយ ពាណិជ្ជករ ឬអ្នកសុំទានណាម្នាក់។ ដើម្បីឲ្យមានប្រសិទ្ធិភាព អត្ថបទពណ៌នារឿងប្រភេទនេះគឺ មិនមែនគ្រាន់តែត្រូវធ្វើការរ៉ាយរ៉ាប់អំពី អ្វីដែលបុគ្គលម្នាក់នោះបានទទួលជោគជ័យប៉ុណ្ណោះ នោះទេគឺវានៅមានការងារច្រើនជាងនេះទៀតដែលយើងត្រូវធ្វើ។ យើងត្រូវតែ

www.budinst.gov.kh www.elibraryofcambodia

បង្ហាញឲ្យគេបានឃើញ អំពីបុគ្គលិកលក្ខណៈរបស់បុគ្គលនោះ។ ហើយនៅមានលទ្ធផលមួយទៀតដែលអ្នកសរសេរអាចសំរេចបាននោះគឺ ការដកស្រង់យកពាក្យសំដីរបស់បុគ្គលនោះមកប្រើ។ បន្ទាប់មកទើបចាប់ផ្តើមធ្វើការពិពណ៌នាឲ្យបានក្បោះក្បាយអំពីប្រធានបទនោះ។ ត្រូវចុះជាប់ជាមួយបុគ្គលដែលជាតួអង្គនៅក្នុងរឿងនោះ ដើម្បីសង្កេតមើលអំពីសកម្មភាពប្រចាំថ្ងៃរបស់គាត់ដែលមានដូចជា នៅតាមកន្លែងធ្វើការនៅផ្ទះឬក៏សុំជួបជាមួយមិត្តភ័ក្តិ សាច់ញាតិ និងសហការីរបស់គាត់ ។ល។ បើយើងចង់សរសេរអត្ថបទពណ៌នារឿងប្រភេទនេះបានល្អគឺ យើងត្រូវចេះធ្វើឲ្យអ្នកអានមានអារម្មណ៍ថា ខ្លួនគេកំពុង តែបានចូលរួមធ្វើជាសាក្សីម្នាក់នឹងគេដែរនៅក្នុងរឿងនៃជីវិតរបស់តួអង្គដែលមាននៅក្នុងរឿងនោះ។

២_ ពត៌មានជាបទពណ៌នា (*The News Feature*) - ពត៌មានប្រភេទនេះត្រូវមានការពន្យល់ឲ្យបានពិស្តារអំពីប្រវត្តិដើមនៃព្រឹត្តិការណ៍មួយនោះផង។ គ្មានអត្ថបទពត៌មានណាមួយដែលកើតឡើងដោយឯកឯងនោះឡើយ។ ឧទាហរណ៍ការបែកបាក់គ្នាដោយសង្គ្រាមគឺ វាមិនដែលមានកើតឡើងដោយឯកឯងនោះទេ។ ភាពតានតឹងរវាងប្រទេសមួយចំនួនកាន់តែស្មុគ្រស្មាញឡើងៗ។ ការចាប់ផ្តើមឡើងអំពីទំនាក់ទំនងខាងការទូតនោះត្រូវបរាជ័យ។ ពត៌មានបទពណ៌នានេះគឺ បានផ្តល់ដល់យើងនូវឱកាសដើម្បីរំលឹកដល់អ្នកអានឲ្យបានជ្រាបថា តើស្ថានការណ៍ ឬព្រឹត្តិការណ៍មួយនោះវាកើតមកពីណា។ ពត៌មានបទពណ៌នាអាច "ធ្វើឲ្យខ្ទរខ្ទារ (*break news*) បាន។

ប៉ុន្តែជារឿយសាច់រឿងនោះគឺ វាមានលក្ខណៈដូចជាបង្គោលស្នឹងឬជាផ្ទៃសន្ទុច (*pegged or hooked*) របស់ព្រឹត្តិការណ៍ដ៏ពិសេសណាមួយសន្និសីទដ៏ធំណាមួយរបស់អង្គប្រជុំពិភាក្សា អំពីច្បាប់នីតិកម្មអ្វីមួយរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ឬអំពីទស្សនកិច្ចរបស់ភ្ញៀវកិត្តិយសណាម្នាក់។ ក្នុងករណីរបៀបនេះ ពត៌មានបទពណ៌នាគឺ អាចផ្តល់ឱកាសដល់យើងក្នុងការផ្តល់

www.budinst.gov.kh www.elibraryofcambodia

ពត៌មាន ដែលទាក់ទងទៅព្រឹត្តិការណ៍នោះបានយ៉ាងល្អិតល្អន់។ ហើយអ្នកអានរបស់យើងក៏មានការងាយស្រួលក្នុងការធ្វើការពិចារណាអំពីព្រឹត្តិការណ៍នោះដែរ។

៣_ អត្ថបទពណ៌នាទាក់ទងប្រវត្តិសាស្ត្រ(*The Historical Feature*) ពត៌មាន ដែលមានទំនាក់ទំនងទៅនឹងការរំលឹកឡើងវិញនៃថ្ងៃខួបដែលមានជាប្រវត្តិសាស្ត្រ។ ឧទាហរណ៍ ថ្ងៃដែលទីក្រុងភ្នំពេញត្រូវធ្លាក់ក្នុងកណ្តាប់ដៃរបស់ខ្មែរក្រហម កិច្ចព្រមព្រៀងនៅទីក្រុងប៉ារីសឆ្នាំ១៩៩១ ឬការបោះឆ្នោតឆ្នាំ១៩៩៣ជាដើម ។ល។ ថ្ងៃខួបនៃព្រឹត្តិការណ៍ដែលជាឧទាហរណ៍ទាំងអស់នេះហើយដែលជាផ្លែសន្ទូច ឬជាបង្គោលស្ទឹង និងដែលបានផ្តល់ជូននូវសនិទានភាព (ភាពដែលប្រកបទៅដោយវិចារណញាណ) ដើម្បីស្រាវជ្រាវរកមើលរឿងរ៉ាវដែលមានទំនាក់ទំនងទៅនឹងព្រឹត្តិការណ៍នោះ និងដើម្បីជាកញ្ចក់សំរាប់ឆ្លុះបញ្ចាំងនូវអនុភាពរបស់ព្រឹត្តិការណ៍នោះផង។

បុណ្យខួបនៃថ្ងៃបោះឆ្នោតនៅកម្ពុជាតិ បានផ្តល់ដល់យើងនូវគោលគំនិតមួយដើម្បីធ្វើការពិនិត្យមើលអំពីការរីកចំរើននៅកម្ពុជា ចាប់តាំងពីថ្ងៃបោះឆ្នោតរហូតមកដល់សព្វថ្ងៃគឺទាំងខាងផ្នែកនយោបាយ និងផ្នែកសង្គម។ តើការរស់នៅរបស់ប្រជារាស្ត្រមានការល្អប្រសើរហើយឬនៅ? តើប្រជារាស្ត្រប្រភេទណាដែលទទួលបាននោះ? ចុះចំណែកអ្នកនៅតាមខេត្តវិញតើយ៉ាងណាដែរ?

៤_ អត្ថបទពណ៌នាអំពីរឿងផ្សងព្រេង (*The Adventure Feature*)- ពត៌មានប្រភេទនេះនឹងធ្វើការពិពណ៌នាយ៉ាងពិស្តារអំពីអ្វី ដែលមិនប្រក្រតី ឬដែលពោរពេញទៅដោយការរំជួលចិត្ត និងដែលមានផ្តល់ជូននូវពត៌មានអំពីបុគ្គលទី១ (*1st person feature*) - គឺជាពត៌មានមួយដែលនិយាយអំពីបទពិសោធន៍របស់បុគ្គលម្នាក់នោះជំរាបដល់អ្នកអាន។ បន្ទាប់ពីយន្តហោះនោះធ្លាក់តើបុគ្គលនោះអាចនៅគង់វង់ជីវិតបានដោយ

www.budinst.gov.kh www.elibraryofcambodia

របៀបណា? ការដើរផ្សងព្រេងកាត់ព្រៃភ្នំ ឬការប្រយុទ្ធនៅក្នុងសមរភូមិដ៏ធំណាមួយ។ ការពិពណ៌នា និងការប្រើពាក្យសំដីដកស្រង់នៅក្នុងករណីប្រភេទនេះគឺ សំខាន់ណាស់។

៥_ អត្ថបទទាក់ទងទៅនឹងរដូវ (*Seasonal Features*) - ពត៌មានប្រភេទនេះគឺ តែងតែមានការទាក់ទងទៅព្រឹត្តិការណ៍ ដែលកើតឡើងក្នុងឆ្នាំផ្សេងៗ។ វាអាចមានកើតឡើងជាព្រឹត្តិការណ៍ដូចជា ពិធីបុណ្យអុំទូក ការហូរត្រឡប់វិញនៃទឹកបឹងទន្លេសាប រដូវដកស្ទូង និងច្រូតកាត់ជាដើម។ល។ សំរាប់ពត៌មានប្រភេទនេះ ថ្វីដ្បិតតែត្រូវបានគេនិយាយអំពីភាពរស់រើកនៃព្រឹត្តការណ៍ ដែលមានកើតឡើងនោះមែន ក៏ប៉ុន្តែគេក៏មិនភ្លេចជំរាបជូនទូវអ្វីដែលជាបំណងល្អ ដូចជាសេចក្តីប្រកាសដើម្បីឲ្យអ្នកអានមានការប្រុងប្រយ័ត្នជាមុន។ល។ ឧទាហរណ៍, ដូចជានៅក្នុងរដូវក្តៅនាពេលខាងមុខនេះ ធាតុអាកាសប្រហែលជានឹងក្តៅខ្លាំងមែនទែន និងត្រូវមានរយៈពេលយូរជាងសព្វមួយដង។ ពត៌មានដែលមានការទាក់ទងទៅនឹងរដូវកាលនេះគឺ អាចធ្វើឲ្យយើងមានចិត្តចង់ស្រាវជ្រាវរកមើលថា តើហេតុដូចម្តេចបានជាវាអញ្ចឹង?

ករណីនេះប្រហែលជាអាចជួយដល់យើងឲ្យរកឃើញដែរអំពីការបាត់បង់អស់នូវព្រៃឈើ ឬដោយសារមកពីនៅក្នុងផែនដីមានកំដៅខុសពីធម្មតា។ យើងអាចដឹងបានតាមឯកសារស្រាវជ្រាវ ដែលមានបង្ហាញអំពីរដូវក្តៅខ្លាំង និងយូរជាងគេនេះ គឺតែងមានរៀងរាល់២៥ឆ្នាំម្តង។ ពិធីបុណ្យអុំទូក និងការចូលរួមសប្បាយរបស់ប្រជារាស្ត្រ ប្រហែលជាសញ្ញាមួយ ដែលគួសបញ្ជាក់អំពីកត្តាសំខាន់នៃសង្គម និងអំពីអ្វីផ្សេងទៀតដែលជាប់ទាក់ទងទៅនឹងពិធីនេះជាមិនខាន។

៦_ អំពីបទសម្ភាសន៍សំរាប់អត្ថបទពណ៌នា (*The Interview Feature*) បទពណ៌នាប្រភេទនេះគឺ តែងឃើញជារឿយៗនៅក្នុងទំព័រទស្សនាវដ្តី។ ចួនកាលវាមាននិយាយអំពីករណីរឿងសំខាន់ៗ ឬអំពីគំនិត

www.budinst.gov.kh www.elibraryofcambodia

យោបល់ ឬទស្សនៈវិជ្ជារបស់បុគ្គលណាម្នាក់ដែលសំខាន់ជាងគេ។ កាលណាយើងធ្វើដូច្នេះបានគឺ អ្នកអានអាចធ្វើការស្វែងយល់អំពីទស្សនៈយោបល់របស់បុគ្គលនោះ។ បន្ទាប់មកទើបគេចាប់ផ្តើមមានការពិចារណាថា តើគួរយល់ព្រមតាម ឬក៏ពុំគួរ។

៧_ អត្ថបទពណ៌នាគឺ ជាអត្ថបទមួយដែលត្រូវមានការរួមផ្សំទៅដោយកត្តាទាំងអស់ដូចមាននៅខាងលើនេះស្រាប់។

**ការរកមើលព័ត៌មានជាបទពណ៌នា – តើមានអ្វីខ្លះដែលអាចធ្វើអោយបទពណ៌នាមួយល្អបាន?**

ទស្សនៈយោបល់របស់អត្ថបទពណ៌នាគឺ មាននៅគ្រប់ទីកន្លែងទាំងអស់ហើយអ្នកដែលអាចសរសេរអត្ថបទនេះបានល្អ លុះត្រាតែអ្នកនោះសំបូរទៅដោយបទពិសោធន៍ខាងវិជ្ជាជីវៈសារព័ត៌មាននេះ។ អ្នកសរសេរអត្ថបទពណ៌នាគឺ គេចូលចិត្តអានច្រើនណាស់។ គេត្រូវអានឲ្យបានច្រើនពីព្រោះគេចង់ស្រង់នូវគំនិតដែលល្អៗសំរាប់យកមកប្រើនៅក្នុងអត្ថបទពណ៌នា។ គ្រប់អត្ថបទព័ត៌មានទាំងអស់គឺ មានបរិបទ (*context*) របស់វា និងមានការរួមផ្សំទៅដោយលក្ខណៈ (*characters*) មួយចំនួនដែលមានដូចជាបរិយាកាសនៅក្នុងសង្គមវប្បធម៌ សេដ្ឋកិច្ច ប្រវត្តិសាស្ត្រ និងនយោបាយជាដើម ។ល។

នៅមានលំនាំរឿង ដែលជាសាក្សីផ្ទាល់របស់បុគ្គល ដែលជាប់ទាក់ទិននៅក្នុងសេចក្តីស្រឡាញ់ ស្អប់ ស្មោះត្រង់ និងក្បត់ ។ល។ លក្ខណៈមួយចំនួនទៀត ដែលត្រូវរាប់បញ្ចូលដែរនោះគឺ អំពីរឿងកិច្ចពិភាក្សា និងការប្តូរយោបល់គ្នា ដែលគេបាននាំគ្នាធ្វើដោយសម្ងាត់ ដែលគេមិនយកវាទៅផ្សព្វផ្សាយជាសាធារណៈ ឬដែលត្រូវបានគេលើកយកទៅនិយាយក្នុងសន្និសីទសារព័ត៌មានមួយ។

អ្នកសរសេរអត្ថបទពណ៌នា ក៏ដូចជាអ្នកការសែតដ៏ពូកែមួយចំនួន

www.budinst.gov.kh www.elibraryofcambodia

ដែរ។ ពួកគេបានទៅជាប់នឹងការងារគ្រប់ពេលវេលា។ ពួកគេចូលចិត្តស្តាប់បទសន្ទនា ដែលមានលើកទៅក្នុងពិធីជប់លៀង និងដែលមាននៅតាមអោជនីយដ្ឋាន។ ពួកគេទាំងនោះចាំបាច់ត្រូវតាមដានទូវរាល់សកម្មភាពទាំងអស់ ដែលមាននៅក្នុងពិភពលោក និងត្រូវតែដឹងនូវអ្វីទាំងអស់ដែលវាមិនមែនជារឿងធម្មតា តែវាមានកើតឡើង នៅក្នុងរឿងធម្មតាទៅវិញ។ ពួកគេត្រូវតែចាប់យកឲ្យបាននូវ និន្នាការ (*the trends*) និងលំនាំអ្វីមួយ (*the patterns*) ដែលអាចកើតឡើងដោយពុំមានការប្រកាសឲ្យបានដឹងមុន។ ពួកគេត្រូវតែត្រៀមខ្លួនជាស្រេច ដើម្បីស្តាប់នូវរាល់ព័ត៌មាន ដែលមានបញ្ចេញនូវទស្សនៈយោបល់ (*unorthodox*) មិនធម្មតា។ ពួកគេតែងទទួលបាននូវព័ត៌មានជាបន្តបន្ទាប់។ ជាសេចក្តីបន្ថែម កត្តាដែលត្រូវដាក់បញ្ចូលទៅក្នុងបញ្ជីនៃតម្លៃរបស់ព័ត៌មាន ដូចយើងបានលើកមកជំរាបជូនក្នុងផ្នែកដំបូងរួចមកនោះគឺ មានដូចខាងក្រោមនេះ។ កត្តាទាំងអស់នេះគឺជាជំនួយស្មារតីក្នុងការសំរេចរើសយកអត្ថបទពណ៌នាណាមួយមកសរសេរដើម្បីបំពេញបំណងអ្នកអាន។

១_ ប្រវត្តិនៃរឿងត្រូវតែមានការបែងចែកឲ្យបានល្អ។ មានន័យថាត្រូវមានគំនិតដែលពោរពេញទៅដោយអ្វីដែលយើងហៅថា ជាផលប្រយោជន៍សំរាប់សាធារណៈជន។ អ្នកដែលយើងជួបសម្ភាសន៍ជាមួយត្រូវតែមាន លក្ខណៈពិសេសណាមួយ ដែលគួរជាទីចាប់អារម្មណ៍ដល់អ្នកអាន។ អំពីអ្វីដែលជាស្ថានភាពរបស់មនុស្ស។ ជារឿយៗគឺតែងនាំមកនូវរឿងដ៏ល្អៗដែលមានដូចជា *រឿងស្នេហា និងសេចក្តីស្អប់ រឿងជ័យជំនះនៅលើភាពដែលមិនគួរអនុគ្រោះ រឿងជីវិត និងសេចក្តីស្លាប់ រឿងសោកនាដកម្ម និងជ័យជំនះ រឿងបាន និងមិនបានជោគជ័យ រឿងជិះជាន់សង្កត់សង្កិន និងបដិវត្តន៍* ។ល។ រឿងទទួលបានជោគជ័យលើពួកបិសាច គឺជារឿងមួយ ដែលមិនចេះផ្លាស់ប្តូរ និងដែលមាននៅក្នុងគ្រប់វប្បធម៌ទាំងអស់ និងដែលមានអាយុរាប់រយពាន់ឆ្នាំមកហើយ។

www.budinst.gov.kh www.elibraryofcambodia

២_ អំពីស្ថានការណ៍គឺ មិនមែនធម្មតា និងគឺមានតែមួយគត់។ បើសិនស្ថានការណ៍នោះជាករណីធម្មតា (*common place*) ។ ដូច្នេះអ្នកយកពត៌មានត្រូវចេះឆ្លៃយ៉ាងណាដើម្បីរកវាឲ្យឃើញនូវសារៈសំខាន់នៃស្ថានភាពនោះ។ ជំនួយនៅក្នុងការស្រាវជ្រាវអំពីរឿងអ្វីមួយគឺ ត្រូវមានការផ្តិតចម្លងឯកសារចែកគ្នាឲ្យបានល្អត្រឹមត្រូវ។

៣_ អំពីគំនិតទស្សនៈយោបល់ គឺត្រូវតែឲ្យមានភាពស្វាហាប់ (*dynamic*)។ ត្រូវឲ្យមានគំនិតដែលមានលក្ខណៈជាចំនាស់ មានវិវាទកម្មផ្ទុយគ្នា និងធ្វើឲ្យមានការរំភើបចិត្ត។

៤_ គ្រប់អត្ថបទរឿងទាំងអស់គឺត្រូវតែមានប្រយោជន៍ដល់អ្នកអាន។ ឧទាហរណ៍ បើវាជារឿងរបស់បុគ្គលគឺ ត្រូវទុកឱកាសឲ្យអ្នកអានដើម្បីធ្វើការសិក្សា អំពីដំណើរជីវិតរបស់បុគ្គលនោះផង។

## ការចូលអោយបានជិតទៅនឹងរឿងហេតុមួយ
## (Approaching a story)

**ផែនការ (Planning)**

ការរៀបចំផែនការគឺ ជាកត្តាមួយដែលចាំបាច់ជាទីបំផុតសំរាប់អត្ថបទពណ៌នា។ អត្ថបទពណ៌នាគឺ ពុំមែនជាអត្ថបទដែលត្រូវបាននិពន្ធឡើងដោយចាប់សរសេរពីក្រោមឡើងមកលើនោះទេ។ តាមពិតគឺវាមានរចនាសម្ព័ន្ធរបស់វា នៅក្នុងនោះគឺ មានសរុបទាំងអ្វីដែលមាននៅក្នុងឃ្លាដំបូង, ឃ្លាកណ្តាល និងឃ្លាបញ្ចប់ផង។ រចនាសម្ព័ន្ធដែលពោរពេញទៅដោយការស្មុគស្មាញរបៀបនេះគឺ វាបាននាំមកនូវគំនិតច្រើនណាស់។

យើងត្រូវពិចារណាថា ចំណុចនៃពត៌មានមួយនេះ តើយើងត្រូវយកវាទៅដាក់បញ្ចូលនៅត្រង់ណា? ហើយចំពោះចំណុចផ្សេងៗទៀតវិញ តើត្រូវដាក់បញ្ចូលនៅត្រង់ណាដែរ? ឧទាហរណ៍:- នៅក្នុងពេលដែលយើងកំពុង

www.budinst.gov.kh www.elibraryofcambodia

ចង់ក្រងរឿងមួយ (*a profile piece*) គឺយើងប្រហែលជាមានបំណងចង់ដាក់បញ្ចូលនូវអ្វីទាំងអស់ ដែលមានស្តីពីជីវប្រវត្តិ (*the biographical*) នៅត្រង់កន្លែងមួយ។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយដើម្បីឲ្យកាន់តែប្រសើរ គឺយើងត្រូវដាក់វាឲ្យនៅលាយឡំគ្នាដោយមានដាក់បញ្ចូលការសង្កេតពិនិត្យដោយផ្ទាល់ជាមួយនឹងសេចក្តីបរិយាយពិស្តារ។ យើងក៏ប្រហែលជាមានបំណងចង់ធ្វើនូវអ្វីទាំងអស់ ដែលស្តីអំពីជីវប្រវត្តិនោះឲ្យទៅជានិទានកថាមួយថែមទៀតផង។ គឺយើងត្រូវប្រើវាសំរាប់ពន្យល់អំពីទម្រង់រឿងនោះឲ្យបានពិស្តារ។ ឧទាហរណ៍:- តើហេតុអ្វីបានជាប្រធានបទរបស់យើងនោះវាមានឥរិយាបថទៅជាយ៉ាងដូច្នេះ? ឬហេតុដូចម្តេចបានជាគាត់មានស្នាមនៅលើមុខដូច្នេះ? ។ល។

**សេចក្តីណែនាំខ្លះសំរាប់ត្រូវប្រើនៅក្នុងការរៀបចំផែនការ**

១_ ការជជែកពិភាក្សារកគំនិតថ្មីៗ (*Brainstorm*) គ្រប់បទពណ៌នាទាំងអស់គឺ វាបានកើតចេញមកពីគំនិតដ៏សាមញ្ញមួយ។ ដូច្នេះជាដំបូងគឺយើងត្រូវចំណាយពេលដើម្បីពិនិត្យរកមើលអំពីគំនិតនោះឲ្យបានហ្មត់ចត់ជាមុនសិន។ បន្ទាប់មកទើបបានចាប់លើកជាសំនួរសួរទៅលើគំនិត ដែលមានរួចមកនោះថា តើមាននរណាខ្លះដែលយើងត្រូវជួបនិយាយជាមួយ? តើយើងត្រូវទៅរកគាត់នៅកន្លែងណា? តើរឿងនោះបានលេចឮឡើងនៅទីណា? តើមានករណីអ្វីខ្លះដែលមានការទាក់ទិននៅក្នុងរឿងនេះ? តើផ្លូវណាមួយដែលមានការទាក់ទិននៅក្នុងរឿងនោះ? តើរឿងនោះមានប្រវត្តិយ៉ាងណាដែរ? ហើយតើយើងត្រូវទៅរកវានៅកន្លែងណា? តើនៅក្នុងរឿងនេះមានបទនិទានខ្លីណាមួយផ្អែកអក្សរសាស្ត្រ និងរឿងប្រជាប្រិយដែលសមរម្យ ហើយដែលអាចយកជាការបានដែរឬទេ?

ចូរយកក្រដាសមួយសន្លឹក រួចហើយចាប់សរសេរដោយសេរីអំពីអ្វីៗទាំងអស់ដែលអ្នកនឹកឃើញនោះ។ ចូរកុំខ្វល់អំពីអ្វីផ្សេងទៀតដែលអ្នកយល់ថា វាហាក់ដូចជាមិនសមហេតុសមផលនោះឲ្យសោះ។ ត្រូវយក

www.budinst.gov.kh www.elibraryofcambodia

តាមខ្លួននូវកូនសៀវភៅកំណត់ហេតុមួយ។ ជាពិសេសនៅលើគ្រែគេងរបស់អ្នកក៏ត្រូវឲ្យមានសៀវភៅនោះមួយដែរ។ ពីព្រោះនៅពេលណា ដែលអ្នកនឹកឃើញនូវគំនិតថ្មីអ្វីមួយគឺ អ្នកអាចចាប់យកវាមកសរសេរបានភ្លាម។ នៅចុងបញ្ចប់នៃវិធីនេះ ចូរយកកំណត់ហេតុទាំងអស់ ដែលអ្នកបានកត់ទុកនោះមកពិនិត្យឡើងវិញ។ រួចហើយចាប់ផ្តើមធ្វើការជ្រើសរើសយកតែគំនិតណាដែលអ្នកយល់ថា វាល្អជាងគេនោះមកប្រើ។

២_ ដាក់កត្តាដែលសំខាន់ៗឲ្យនៅជាប់ពីគ្នា - ករណីនេះគឺត្រូវចាប់ផ្តើមចេញពីកំណត់ហេតុទាំងឡាយ ដែលទទួលបានមកពីការជជែកពិភាក្សា។ បន្ទាប់មកត្រូវជ្រើសរើសយកតែគំនិតណា ដែលអ្នកចូលចិត្តជាងគេ និងដែលអាចផ្តល់ជារូបភាពសំរាប់ប្រធានបទមួយនោះ។ ត្រូវយកចំណុចនៃគំនិតទាំងអស់ ដែលអ្នកមានមកដាក់តំរៀបតាមលេខរៀងដោយមានរួមទាំងបញ្ជីឈ្មោះរបស់បុគ្គល, អំពីពេលវេលា, អំពីទីកន្លែង និងប្រភពរបស់ពត៌មាននោះផង។ នៅចុងបញ្ចប់អ្នកត្រូវចាប់អនុវត្តន៍ការងារនោះតាមលំដាប់លំដោយដូចមាននៅក្នុងសៀវភៅកំណត់ហេតុរបស់អ្នកស្រាប់។ ត្រូវអនុវត្តន៍ដូច្នេះរហូតដល់ពេលមួយអ្នកយល់ថា អ្នកទទួលបានពត៌មានអំពីរឿងនោះគ្រប់គ្រាន់។

៣_ រចនាសម្ព័ន្ធ (*Structure*) - ចូររៀបចំឡើងវិញនូវបញ្ជីកំណត់ហេតុទាំងអស់ដែលអ្នកមាន។ ត្រូវពិចារណាមើលម្តងទៀត តើចំណុចនៃពត៌មានណាមួយដែលត្រូវលើកមុនគេ? តើចំណុចណាមួយដែលត្រូវដាក់ក្រោយគេ? ហើយតើចំណុចណាមួយដែលត្រូវដាក់នៅចំកណ្តាល? ចំណុចសំខាន់ៗទាំងអស់នៃពត៌មានដែលអ្នកប្រមូលបាន តើអ្នកត្រូវយកវាមកតម្រៀបដាក់បញ្ចូលគ្នាតាមរបៀបណា?

ធ្វើការងារជាមួយនិពន្ធនាយកម្នាក់ (Working with an Editor) យើងទាំងអស់គ្នាបានដឹងហើយថា តើនិពន្ធនាយកម្នាក់ៗមានអាកប្បកិរិយាចម្លែកយ៉ាងណាខ្លះ? ជួនកាលពួកគេហាក់ដូចជាមានការយកចិត្តទុកដាក់

www.budinst.gov.kh www.elibraryofcambodia

ទៅលើការចង់បំបាត់ចោលនូវគំនិតល្អៗខ្លះសំរាប់ករណីរឿងមួយជាងអ្វីៗទាំងអស់។ ប៉ុន្តែអ្នកត្រូវចាំថា ទំនាក់ទំនងការងារ ដែលអ្នកត្រូវមានជាមួយនឹងនិពន្ធនាយកគឺ ជាកត្តាមួយសំខាន់ខ្លាំងណាស់។ ពួកគេប្រហែលជាមានមូលហេតុរបស់គេនៅពេលណា ដែលគេចង់ធ្វើការផែកពិនិត្យមើលឡើងវិញអំពីអ្វី ដែលអ្នកកំពុងតែរីករាយអបអរសាទរជាមួយនោះ។ ម៉្យាងទៀតត្រូវចាំថា "មានគំនិតពីរតែងតែប្រសើរជាងមានគំនិតតែមួយ"។

ការងារទីមួយ ដែលជាមធ្យោបាយសំរាប់ដោះស្រាយជាមួយនឹងនិពន្ធនាយករបស់អ្នកគឺ កាបញ្ចុះបញ្ចូលពួកគាត់ឲ្យយល់ថា គំនិតរបស់អ្នកគឺជាគំនិតដ៏ល្អមួយដែលត្រូវការប្រើវាសំរាប់ជាមូលដ្ឋាន។ អ្នកត្រូវត្រៀមលក្ខណៈប្រមូលយកនូវរាល់គំនិតថ្មីៗទាំងអស់ ដែលអ្នកទទួលបានបកពីការជជែកពិភាក្សា មកបង្ហាញដល់និពន្ធនាយករបស់អ្នក។ បើមានគំនិតកាន់តែច្រើន គឺកាន់តែល្អ។ បើអ្នកមានគំនិតច្រើន និពន្ធនាយករបស់អ្នកគឺកាន់តែមានការចាប់អារម្មណ៍មកលើរូបអ្នកដែរ។

ត្រូវស្មោះត្រង់ជានិច្ច *(Be honest)* - បើអ្នកមានគំនិតដ៏ល្អមួយ។ ប៉ុន្តែអ្នកមិនអាចយកវាទៅដាក់បញ្ចូលគ្នាបាន។ ដូច្នេះអ្នកត្រូវតែប់ជំរាបដល់និពន្ធនាយករបស់អ្នកឲ្យគាត់បានដឹងអំពីបញ្ហានោះភ្លាម។ ហើយបើនិពន្ធនាយកជឿថា គំនិតនោះវាមានគុណប្រយោជន៍មែនគឺ គាត់ប្រហែលជាអាចជួយផ្តល់នូវមធ្យោបាយដ៏សមស្របមួយដល់អ្នកជាមិនខាន។ ត្រូវរក្សាការផ្តល់ដំណឹងដល់និពន្ធនាយករបស់អ្នក អំពីការរីកចំរើនឲ្យបានគ្រប់ពេលវេលា។ តែចូរចាំថា និពន្ធនាយកគាត់មានភារកិច្ចទទួលខុសត្រូវនៅក្នុងការចាត់ចែងបុគ្គលិកទាំងអស់ ដើម្បីឲ្យសមស្របទៅតាមសេចក្តីត្រូវការរបស់កាសែតមួយ។ និពន្ធនាយករបស់អ្នកប្រហែលជាបានសំរេចចិត្តរួចហើយថា ករណីរឿងមួយនោះប្រហែលជានឹងពុំអាចចេញរួចបានទេ។ ដោយសារតែយ៉ាងដូច្នេះ វាក៏ប្រហែលជាត្រូវស្មុះនៅមួយកន្លែងដូចក្បាលដែកគោលមួយនៅលើជញ្ជាំងអញ្ចឹង។ ដូច្នេះបើអ្នកមានចំណុចណាមួយ

www.budinst.gov.kh www.elibraryofcambodia

ដែលអ្នកពុំយល់ស្របដូចគាត់ អ្នកត្រូវតែសួរគាត់ថា ហេតុអ្វី...? *(why...?)*។ ប៉ុន្តែចូរអ្នកកុំភ្លេចថា អ្នកត្រូវតែទទួលយកនូវអ្វីដែលគាត់បានសំរេចឲ្យរួចបន្តធ្វើការងារនោះទៅតាមលទ្ធភាពដែលអ្នកអាចធ្វើបាន។ ជាធម្មតា, និពន្ធនាយកស្ទើរតែទាំងអស់ គឺសុទ្ធសឹងតែជាអ្នកសារពត៌មានជើងចាស់។ គាត់ច្បាស់ជាធ្លាប់មានទំនាក់ទំនង និងមានបទពិសោធន៍ដ៏ច្រើនលើសលុបជាមិនខាន។ ចូរអ្នកកុំខ្លាចសាកសួរ ឬស្នើសុំយោបល់ល្អៗពីគាត់។ បើគាត់នឹកឃើញ អំពីចំនួនប្រាក់ខែរបស់គាត់ គឺគាត់ច្បាស់ជាជួយខ្នះខ្នែង ដើម្បីយករឿងដ៏ល្អនោះទៅបោះពុម្ពផ្សាយជាមិនខាន។

សំខាន់ជាងនេះទៅទៀត ចូរអ្នកចាំថា និពន្ធនាយក គាត់មានការរវល់ខ្លាំងណាស់។ ដូច្នេះអ្នកត្រូវត្រៀមអំពីករណី ដែលអ្នកចង់ធ្វើការជជែកតវ៉ានោះឲ្យបានរួចជាស្រេចនៅមុនពេលដែលអ្នកត្រូវចូលទៅជួបជាមួយគាត់។ បើយើងមានគំនិតទន់ជ្រាយ ដូច្នេះករណីណាមួយដែលយើងចង់លើកយកទៅជជែកតវ៉ានោះ ច្បាស់ជានឹងពុំអាចទទួលបាននូវជ័យជំនះនោះឡើយ។ ចូរធ្វើការងារជាមួយនឹងអ្នកនិពន្ធឲ្យបានហ្មត់ចត់នៅក្នុងការងារពិនិត្យអត្ថបទឡើងវិញ។ គ្រប់អ្នកសារពត៌មានទាំងអស់ គឺត្រូវការមានអ្នកជំនួយការម្នាក់ជាលេខានិពន្ធ។ នៅក្នុងពេលសរសេរអត្ថបទពត៌-មានមួយ ពេលនោះគឺយើងកំពុងតែជាប់រវល់មែនទែន យើងអាចមានការភ្លេចភ្លាំងខាងផ្នែកវេយ្យាករណ៍ ឬក៏អាចមានកំហុសនៅក្នុងរចនាបថណាមួយជាមិនខាន។ ហើយជាពិសេស គឺយើងនៅមានការខ្វះខាត ខាងផ្នែកចងក្រងអត្ថបទនោះថែមទៀត។ លេខានិពន្ធនេះហើយ គឺជាអ្នកពិនិត្យអត្ថបទរបស់យើងមុនគេ។ គាត់ត្រូវតែរកឲ្យឃើញនូវកំហុសដែលមាន និងសំនួរដែលគ្មានចម្លើយនោះមុនគេ។ លេខានិពន្ធគឺមិនមែនជាអ្នកដែលនៅចាំតែទិះតៀនយើងគ្រប់គ្នានោះទេ។ គាត់គឺជាអ្នកនៅចាំជួយចម្លងពាក្យសំដីយើងជូនទៅដល់អ្នកអានឲ្យបានច្បាស់ និងឲ្យប្រាកដប្រជា។ គឺធ្វើយ៉ាងណាឲ្យអ្នកអានឆាប់ចាប់បាន។

www.budinst.gov.kh www.elibraryofcambodia

## សេចក្តីផ្តើមសំរាប់បទពណ៌នា
## (The Feature Lead)

វគ្គដំបូងបង្អស់របស់រឿងនិមួយៗគេនាំគ្នាឲ្យឈ្មោះថា សេចក្តីផ្តើម។ គ្មានរូបមន្តពិតប្រាកដណាមួយ ដែលអាចយកមកប្រើសំរាប់សរសេរសេចក្តីផ្តើមមួយឲ្យបានល្អនោះទេ។ ប៉ុន្តែគ្រប់អត្ថបទពត៌មានទាំងអស់ ចាំបាច់ពិត្រូវតែមានសេចក្តីផ្តើម។

**សេចក្តីផ្តើមមានមុខងារពីរយ៉ាង:**

១. ត្រូវសរសេរដោយសង្ខេបជាទីបំផុតអំពីចំណុចសំខាន់ៗរបស់សាច់រឿង។ និង

២. ត្រូវធ្វើយ៉ាងណាឲ្យអ្នកអានចង់អានរឿងនោះខ្លាំងមែនទែន។

ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ ការសរសេរសេចក្តីផ្តើមសំរាប់បទពណ៌នាមួយ គឺវាមានលក្ខណៈខុសគ្នាបន្តិចពីការសរសេរសេចក្តីផ្តើមសំរាប់អត្ថបទពត៌មានថ្មីៗ។ ពីព្រោះសេចក្តីផ្តើមសំរាប់បទពណ៌នា គឺមិនតម្រូវឲ្យលើកយកចំណុចសំខាន់ៗរបស់សាច់រឿងមកសរសេរដោយសង្ខេបទាំងអស់នោះទេ។ អ្វីដែលយើងត្រូវអនុវត្តន៍ឲ្យបាននោះ គឺយើងត្រូវធ្វើយ៉ាងណាឲ្យអ្នកអានជក់ចិត្ត។

នៅក្នុងពេលដែលអ្នកកំពុងតែគិតរកមើលអំពីអ្វី ដែលអ្នកត្រូវលើកយកមកសរសេរនៅក្នុងសេចក្តីផ្តើមនោះ ចូរអ្នកសាកល្បងធ្វើការពិចារណាលើសំនួរមួយចំនួនដូចតទៅនេះ :

១. តើករណីនោះវាមានតែមួយគត់ វាសំខាន់ជាងគេ ឬវាមិនធម្មតាមែនឬ?

២. តើនរណាខ្លះដែលមានការទាក់ទិននៅក្នុងរឿងនោះ - តើនរណាជាអ្នកប្រព្រឹត្ត ឬជាអ្នកនិយាយអំពីរឿងនោះ?

៣. ការសរសេរសេចក្តីផ្តើមមួយដោយចំៗ(*a direct lead*) ឬដោយប្រយោល (*delayed lead*) តើណាមួយវាប្រសើរជាង? (យើងនឹងលើកយកសេចក្តីផ្តើមទាំងពីរនេះមកនិយាយនៅក្នុងពេលបន្តិច

www.budinst.gov.kh www.elibraryofcambodia

ទៀតនេះ)។

៤- តើយើងមានពាក្យណាដែលរស់រវើក ឬពាក្យដែលមានន័យពោរពេញទៅដោយវិនាដកម្មមកប្រើសំរាប់សេចក្តីផ្តើមនោះហើយ ឬនៅ?

៥- តើសេចក្តីផ្តើមនោះត្រូវលើកយកពាក្យសំដី ដែលបានដកស្រង់ (*quote*) មកប្រើ ឬក៏ត្រូវសរសេរជាបទបរិយាយ (*description*) ឬក៏ត្រូវប្រើ របៀបទាំងពីរនេះតែម្តង?

**ការសរសេរសេចក្តីផ្តើមដោយចំៗ** (*The Direct Lead*)

ការសរសេរសេចក្តីផ្តើមមួយដោយនិយាយចំៗគឺ អាចពន្យល់ប្រាប់ដល់យើងដោយត្រង់ៗអំពីករណីនៃសាច់រឿងមួយដែលបាន ឬដែលនឹងកើតមានឡើង។ ជាធម្មតានៅក្នុងនោះ គឺមានសរុបនូវពត៌មានមួយចំនួនដែលមានបញ្ចាក់អំពីសំនួរ (*who, what, where, and when.*) នរណា, អ្វី, ទីណា, និងពេលណា ថែមទៀតផង។ ចំពោះពត៌មានសំរាប់ (*how*) និង (*why*) នឹងត្រូវបង្ហាញ នៅក្នុងវគ្គក្រោយៗទៀត។

**ការធ្វើសេចក្តីផ្តើមដោយប្រយោល** (*The Indirect or Delayed Lead*)

សេចក្តីផ្តើមប្រភេទនេះគេចូលចិត្តប្រើវាសំរាប់បទពណ៌នាណាស់ (*the feature story*)។ ការសរសេរសេចក្តីផ្តើមដោយប្រយោល គឺជាការសរសេរដើម្បីពណ៌នា អំពីអ្វីមួយដែលកើតមានឡើង ឬចង់ធ្វើការបង្ហាញអំពីរូបភាពមួយក្នុង គោលបំណងដើម្បីជាប្រយោជន៍សំរាប់អ្នកអាន។ សេចក្តីផ្តើមប្រភេទនេះ គឺត្រូវការបទពិសោធន៍ច្រើនណាស់។

**មួយករណី និងពហុករណី** (*Single and Multiple Element Leads*)

នៅក្នុងសេចក្តីផ្តើមដែលមានលើកតែមួយករណី គឺជាសេចក្តីផ្តើមមួយ ដែលនៅក្នុងនោះវាមានគំនិតតែមួយគត់។ ឧទាហរណ៍ៈ- នៅពេលណាដែលយើងចាប់ផ្តើម សរសេរអំពីការដកស្រង់ពាក្យសំដីណាមួយ គឺយើងត្រូវសរសេរយ៉ាងដូច្នេះថា (*someone* **said** *something*) "មនុស្សម្នាក់បាននិយាយអំពីអ្វីមួយ" នេះគឺជាគំនិតតែមួយគត់ដែលត្រូវមាននៅក្នុង

www.budinst.gov.kh www.elibraryofcambodia

សេចក្តីផ្តើមនោះ។ ប៉ុន្តែមានពេលខ្លះ យើងចង់ធ្វើការបូកសរុបនូវគំនិត ចំនួនពីរ ឬច្រើនលើសពីនេះ ដែលជាពត៌មានចាំបាច់មកប្រើក្នុងសេចក្តីផ្តើមមួយ។ ហើយសេចក្តីផ្តើម ដែលមានលើកករណីលើសពីមួយដូច្នេះ គឺគេហៅថាពហុករណី។

**សេចក្តីសំរេចមួយនៅលើសេចក្តីផ្តើម** (*Deciding on the Lead*)

តើយើងត្រូវធ្វើសេចក្តីសំរេចចិត្តដោយរបៀបណា ដើម្បីរកអ្វីមួយមកសរសេរនៅក្នុងសេចក្តីផ្តើម? ជាដំបូងគឺយើងត្រូវតែសំរេចចិត្តថា តើយើងចង់ឲ្យសេចក្តីផ្តើមរបស់យើងនេះធ្វើអ្វីខ្លះ? តើយើងត្រូវប្រាប់ដល់អ្នកអាននូវអ្វីៗទាំងអស់ដែលមាននៅក្នុងសាច់រឿងនោះឬទេ? តើត្រូវធ្វើការបញ្ចុះបញ្ចូលអ្នកអានឲ្យយកចិត្តទុកដាក់តាមដានសាច់រឿងរបស់យើងថែមទៀតដែរឬទេ? ឬត្រូវហេនទាំងពីរ? ចូរពិនិត្យឡើងវិញនៅលើកំណត់ហេតុដែលអ្នកបានកត់ទុក។ ហើយត្រូវហ៊ានធ្វើការវះកាត់ជាបន្ទាន់ថា តើពត៌មានណាមួយដែលវាអាចនាំយើងឲ្យសំរេចបាននូវគោលបំណងនោះដោយជោគជ័យ។ នៅពេលដែលអ្នកកំពុងពិនិត្យឡើងវិញនៅលើកំណត់ហេតុទាំងអស់នោះ និងពេលដែលអ្នកកំពុងធ្វើសេចក្តីសំរេចចិត្តថា តើនឹងរើសយកសេចក្តីផ្តើមណាមួយនោះ។ ចូរអ្នកកុំភ្លេចអនុវត្តន៍តាមចំណុចសំខាន់ៗមួយចំនួននៅខាងក្រោមនេះ ៖

១- ត្រូវរក្សាវាឲ្យខ្លីជាទីបំផុត។ បើអ្នកចង់បង្ហាញអំពីពត៌មានច្រើនពេកនៅក្នុងសេចក្តីផ្តើមមួយនោះគឺ អ្នកធ្វើឲ្យអ្នកអានមានការភាន់ច្រឡំ។ ដូច្នេះពួកគាត់ ប្រហែលជានឹងឈប់អានសាច់រឿងនោះទៀតហើយ។

២- ត្រូវផ្តោតអារម្មណ៍ទៅលើអ្វី ដែលសំខាន់ជាងគេនៅក្នុងសាច់រឿងនោះ បើធ្វើដូច្នេះបានអ្នកអានប្រាកដជាអានតទៅទៀតដើម្បីរកឲ្យឃើញអំពីការពន្យល់មួយ។

៣- ចៀសវាងប្រើពាក្យណាដែលវែង ឬស្មុគ្រស្មាញ - ប្រើពាក្យណាដែលស្រួលៗ និងសាមញ្ញជាទីបំផុត។ ប៉ុន្តែនៅក្នុងពេលជាមួយ

www.budinst.gov.kh www.elibraryofcambodia

គ្នានោះ ចូរអ្នកសាកល្បងធ្វើសេចក្ដីផ្ដើមនោះមានពោរពេញទៅដោយភាពរស់រវើកផង។

៤_ ចូរកុំភ្លេចដាក់បញ្ចូលគ្រប់កត្តាចាំបាច់ទាំងអស់( *essential element of the story*) របស់សាច់រឿង។

## បច្ចេកទេសដ៏មានប្រសិទ្ធិភាពក្នុងការសរសេរបទពណ៌នា
## (The Techniques of Effective Feature Writing)

**ចូរបង្ហាញ តែកុំនិយាយប្រាប់** (*Show, Don't tell*)

បើទោះបីជាអ្នកមានគំនិតចង់និយាយប្រាប់អំពីរឿងអ្វីមួយក៏ដោយ ចូរគាប់បោះបង់ចោលនូវគំនិតនោះភ្លាម។ នេះគឺជាទស្សនៈរបស់លោក ថូលស្តូយ (*Tolstoy*) អ្នកនិពន្ធរឿងប្រលោមលោកជាតិរុស្ស៊ី។ លោកបានបញ្ជាក់យ៉ាងដូច្នេះថា "ខ្ញុំមិននិយាយប្រាប់, ខ្ញុំមិនពន្យល់, ប៉ុន្តែខ្ញុំចូលចិត្តបង្ហាញ។ ត្រូវទុកឱកាសនេះឲ្យតួអង្គនៅក្នុងសាច់រឿងនិយាយអំពីរឿងនោះជំនួសខ្ញុំវិញ។" (*I don't tell, I don't explain. I show; let my characters talk for me.*) បើអញ្ចឹងមែន តើបានសេចក្ដីថាយ៉ាងម៉េច? ចូរពិចារណាលើឧទាហរណ៍មួយនៅខាងក្រោមនេះ - ស្ដីអំពីរឿងមួយដែលនិយាយអំពីពិធីបុណ្យ បញ្ចុះសពរបស់កុមារម្នាក់ដែលគ្នាបានស្លាប់ទៅដោយសារការផ្ទុះមីន។

*មានអ្នកយកពត៌មានម្នាក់បានសរសេរយ៉ាងដូច្នេះថា:*

(*"The grief stricken parents wept during the service."*) បកប្រែថា "ទុក្ខដ៏សែនក្រៀមក្រំនេះបានធ្វើឲ្យមាតាបិតាយំស្ដាយស្រណោះយ៉ាងខ្លាំងនៅក្នុងពេលកំពុងធ្វើឈាបនកិច្ច។" ហើយមានអ្នកយកពត៌មានម្នាក់ផ្សេងទៀតបានសរសេរដូច្នេះដែរថា: (*"The parents wept quietly - the child's mother leaning on her husband for support."*)

www.budinst.gov.kh www.elibraryofcambodia

បកប្រែថា, “មាតាបិតាបានយំសោកសង្រេងយ៉ាងស្ញៀមស្ងាត់ - ម្ដាយរបស់សពកំពុងតែផ្អែកខ្លួនទៅលើប្ដីដើម្បីសុំការកក់ក្ដៅ។” ពិចារណាមើលតើមួយណាជាការបង្ហាញ និងមួយណាជាការនិយាយប្រាប់?

**ដកស្រង់ពាក្យសំដីដ៏ល្អមកដាក់លើគេបង្អស់** (*Good quotes Up High.*)

ពាក្យសំដីដែលបានដកស្រង់យកមកប្រើនៅក្នុងអត្ថបទសព្ទា គឺអាចជួយធ្វើឲ្យអ្នកអានមានអារម្មណ៍ថា ខ្លួនគេកំពុងតែស្ថិតនៅលើកន្លែងកើតហេតុនោះដែរ។ នេះគឺជាមធ្យោបាយតែមួយគត់ដែលមានប្រសិទ្ធិភាពជាងគេដើម្បីបណ្ដាច់ខ្លួនអ្នកឲ្យនៅក្រៅសាច់រឿង ហើយទុកឱកាសឲ្យអ្នកអានអាចមើលឃើញ និងពិចារណាដោយខ្លួនឯងអំពីបុគ្គល ដែលបាននិយាយរឿងនោះ។ ចួនកាលមានបុគ្គលខ្លះ គេនិយាយប្រាប់ដល់យើងដោយសង្ខេបជាទីបំផុតអំពីព្រឹត្តិការណ៍មួយ ឬអំពីស្ថានការណ៍មួយដោយប្រើពាក្យតែប៉ុន្មានម៉ាត់ប៉ុណ្ណោះ។ គឺពាក្យសំដីទាំងអស់នោះ ហើយដែលយើងអាចយកទៅប្រើនៅក្នុងអត្ថបទសព្ទាបាន។ ចួនកាលពាក្យតែប៉ុន្មានម៉ាត់នោះ គឺមានពោរពេញទៅដោយគតិបណ្ឌិត មានការបង្ហាញឲ្យឃើញភាពច្បាស់លាស់ ឬភាពដែលអាចបង្ហាញអំពីការរំជួលចិត្តដ៏សែនជ្រាលជ្រៅមួយជាមិនខាន។ ពាក្យសំដីដ៏ល្អៗ ដែលបានដកស្រង់យកមកប្រើនៅក្នុងអត្ថបទសព្ទានេះគឺនឹងធ្វើឲ្យអ្នកអានគាប់ចាប់ចិត្ត និងទាក់ទាញពួកគេឲ្យខិតចូលមកក្នុងសាច់រឿងនោះ ដើម្បីតាមដានព័ត៌មានតទៅទៀត។

**ចំណុចដែលអ្នកអានចាប់អារម្មណ៍ជាងគេ ត្រូវដាក់វានៅលើគេបង្អស់**
(***Human Interest Up High.***)

តើមនុស្សមានអ្វីខ្លះ? គឺអ្វីទាំងអស់នោះហើយ ដែលមនុស្សចង់ដឹងចង់ឮ អំពីមនុស្សដូចគ្នា និងអំពីបទពិសោធន៍របស់ពួកគេ។ យើងបាននាំគ្នាហៅនូវអ្វី ដែលមនុស្សចាប់អារម្មណ៍នោះថា ជារឿងធម្មតាសំរាប់ទំនាក់ទំនងនៃអន្តរបុគ្គលគ្រប់ប្រភេទ។ យើងចង់ឮមិត្តរបស់យើងនិយាយអំពីរឿងមួយ។ យើងចង់អានសៀវភៅមួយណាដែលអាចប្រាប់ដល់យើង

www.budinst.gov.kh www.elibraryofcambodia

អំពីជីវិតរបស់តួសំខាន់ៗ។ យើងទស្សនាភាពយន្ត ហើយយើងក៏មានការចាប់អារម្មណ៍ អំពីជីវិតរបស់តារាភាពយន្តទាំងនោះដែរ។

ចូរប្រើការចាប់អារម្មណ៍ទៅលើគ្នាទៅវិញទៅមកនេះ ដើម្បីទាក់ទាញអ្នកអានឲ្យខិតចូលមកក្នុងសាច់រឿងរបស់អ្នកឲ្យកាន់តែជិតមែនទែន។

**ការធ្វើអោយច្បាស់លាស់** (*Clarity*)

ចូរធ្វើការងារឲ្យបានហ្មត់ចត់ដើម្បីជួយដល់ការសរសេររបស់អ្នកឲ្យបានច្បាស់ - ចៀសវាងការប្រើពាក្យពិបាកៗ, កុំប្រើករណីពិតៗ និងរូបភាពច្រើនហួសកំណត់។ កុំផ្តល់ពត៌មានច្រើនពេកនៅក្នុងកថាខ័ណ្ឌតែមួយ។ ចូរសាកល្បងធ្វើយ៉ាងណាចៀសវាងសរសេរឃ្លាមួយវែងពេក។ ប្រើការប្រៀបធៀបដើម្បីពណ៌នាអំពីអ្វីមួយដែលអ្នកអានជាច្រើនពុំធ្លាប់ស្គាល់។

**អំពីអន្តរៈបទ ឬ ឃ្លាភ្ជាប់សេចក្តី** (*Transitions*)

ឃ្លាភ្ជាប់សេចក្តីទាំងអស់មានបួនប្រភេទៈ

១. សព្វនាម ឬនាមស័ព្ទ (*Pronouns*) ការប្រើសព្វនាមគឺ ដើម្បីសំរាប់និយាយសំដៅទៅលើអ្វីៗ ដែលមាននិយាយនៅ ក្នុងឃ្លា ឬប្រយោគមុនរួចមកហើយ។ ឧៈ បណ្ឌិតសុខ ជា ទើបនឹងចាប់ផ្តើមបង្រៀនប្រវត្តិសាស្ត្រខ្មែរនាឆ្នាំ១៩៥៤ ហើយគាត់បានទទួលសញ្ញាប័ត្រជាបណ្ឌិតនេះនៅក្នុងឆ្នាំនោះតែម្តង។ ប្រធានបទសំរាប់និក្ខេបបទរបស់គាត់ (*His dissertation subject*) គឺស្តីពីប្រវត្តិសាស្ត្ររបស់អាណានិគមបារាំងនៅលើទឹកដីឥណ្ឌូចិន។

២. ពាក្យដែលជាគន្លឹះ និងជាទស្សនៈ (*Key words and ideas*) ចូរប្រើពាក្យ ដែលជាគន្លឹះ និងជាទស្សនៈ នោះឡើងវិញនៅក្នុងឃ្លា ឬប្រយោគ ដែលនឹងត្រូវមាននៅខាងមុខ។ ឧៈ គាត់ត្រូវបានគេចោទប្រកាន់ថា ជាអ្នកសុំទោសពួកបារាំង។ ប៉ុន្តែពាក្យទាំងអស់នោះគឺបានធ្វើឲ្យគាត់ខ្ចើមជាទីបំផុត។ ហើយគាត់បានពន្យល់ថា “ការសុំទោស គឺគ្រាន់តែចង់បញ្ជាក់អំពីស្ថានភាពមួយនៅមុនពេលធ្វើការ

www.budinst.gov.kh www.elibraryofcambodia

ស្រាវជ្រាវ និងសំរេចយកអ្វីដែលជាប្រវត្តិសាស្ត្រពិតៗសំរាប់ទុកជាជំនួយដើម្បីគាំទ្រដល់ស្ថានភាពនោះ។"

៣. ពាក្យមួយចំនួនដែលប្រើសំរាប់អន្តរៈបទ (*Transitional expressions*) ការប្រើពាក្យសំរាប់ភ្ជាប់ឃ្លាមួយទៅឃ្លាមួយទៀត។ ពាក្យទាំងនោះមាន ទោះយ៉ាងណាក៏ដោយ (*however*) ប៉ុន្តែ (*but*) ដូចគ្នាដែរ(*likewise*) ដូចគ្នា (*also*) ជាទីបញ្ចប់ (*finally*) ជាដើម។ល។

៤. រចនាសម្ព័ន្ធដែលប្រព្រឹត្តឡើងស្របគ្នា (*Parallel structure*) គឺជាឃ្លា និងប្រយោគ ដែលបានតភ្ជាប់គ្នាតាមការសរសេរ ឬនិយាយដោយយកលំនាំតាមឃ្លាណាមួយ ដែលបានលើកម្តងរួចមកហើយ។ ឧ: គ្មាននរណាម្នាក់ហ៊ានចេញមុខសួរគាត់ទេ។ គ្មាននរណាម្នាក់មានសេចក្តីក្លាហានហ៊ានប្រកែកនឹងបញ្ហារបស់គាត់នោះឡើយ។ គ្មាននរណាម្នាក់ជឿថា ពួកគេហ៊ានវាយគាត់ឡើយនៅក្នុងពេលដែលកំពុងតែមានការប្រយុទ្ធគ្នានោះ។

**អ្វីដែលសំខាន់ៗត្រូវដាក់តាមលំដាប់លំដោយ** (*Logical Order*)

រាល់ករណីដែលសំខាន់ៗរបស់អត្ថបទមួយ គឺត្រូវយកវាមកតំរៀបជាលំដាប់លំដោយ។ ប្រយោគនិមួយៗគឺត្រូវតែឆ្លើយទៅនឹងសំនួរ ឬចម្ងល់របស់អ្នកអានបន្ទាប់ពីគេបានអានប្រយោគមុនរួច។ ចូរសាកល្បងធ្វើយ៉ាងណា ដើម្បីបង្ហាញអំពីករណីនៃពត៌មានមួយដល់អ្នកអានដែលកំពុងតែត្រូវការ។ សំនួរដែលអ្នកអាននឹងសួរយើងនោះគឺ ជាសំនួរដែលបានកើតឡើងបន្ទាប់ពីអ្នកអានបានបញ្ចប់ការអានអត្ថបទនោះរួច។ សរុបសេចក្តីទៅនៅខាងក្រោមនេះគឺមានការណែនាំមួយចំនួន :

១. ចូរកុំសរសេរ បើអ្នកពុំទាន់យល់ច្បាស់អំពីព្រឹត្តិការណ៍ ឬករណីនោះ។
២. ចូរកុំសរសេរ បើអ្នកមិនទាន់ដឹងថា តើខ្លួនអ្នកចង់និយាយអំពីអ្វីនោះ។
៣. ចូរធ្វើការបង្ហាញ, តែចូរកុំនិយាយប្រាប់ឲ្យសោះ។
៤. ចូរសាកល្បងយកពាក្យសំដីដ៏ល្អៗ ដែលបានដកស្រង់មកប្រើនៅលើ

www.budinst.gov.kh www.elibraryofcambodia

គេបង្អស់សំរាប់រឿងនិមួយៗ។

៥_ ចូរសាកល្បងយកបទពណ៌នា ឬរឿងនិទានខ្លីៗមកប្រើនៅលើគេបង្អស់សំរាប់រឿងនិមួយៗ។

៦_ ចូរចៀសវាងធ្វើការវិនិច្ឆ័យ និងធ្វើការវាយតម្លៃ។ ត្រូវទុកឱកាសនេះឲ្យតួអង្គដែលមាននៅក្នុងរឿងនោះ គេនិយាយអំពីរឿងរបស់គេដោយខ្លួនគេ។

៧_ ចូរចៀសវាងការលើកឡើងជាសំនួរណាមួយ ដែលយើងមិនអាចរកចម្លើយឃើញមកដាក់នៅក្នុងរឿងនោះ។

៨_ ចូរប្រើតែពាក្យណា ដែលសាមញ្ញជាទីបំផុត។

## អំពីអង្គសេចក្តីនៃបទពណ៌នា

## (The 'Body' of the Feature Story)

ពាក្យថា "អង្គសេចក្តី" (*body text*) គឺគេសំដៅទៅលើផ្នែកជាចំបងរបស់អត្ថបទនៃពត៌មានមួយ - លើកលែងសេចក្តីផ្តើមចេញ។ ផ្នែកនេះហើយ គឺជាផ្នែកដែលធ្វើចរាចរបកស្រាយពន្យល់ឲ្យបានកាន់តែច្បាស់អំពីអ្វីដែលមានលើកនៅក្នុងសេចក្តីផ្តើម។ គឺជាផ្នែកដែលមាននិយាយពន្យល់បន្ថែមអំពីពត៌មាន និងដើម្បីបង្កើតឲ្យបានជាអត្ថបទរឿងទាំងមូល។ តាមធម្មតាបទពណ៌នា តែងមានលក្ខណៈវែងជាងពត៌មានធម្មតា។ ដូច្នេះយើងត្រូវខំប្រឹងរកគ្រប់មធ្យោបាយ ដើម្បីប្រមូលរកគំនិតល្អឲ្យបានច្រើនជាទីបំផុតយកមកបញ្ចូលជាមួយនឹងការប៉ិនប្រសប់ដែលមានស្រាប់។

**អំពីរចនាសម្ព័ន្ធ** (*Structure*)

ដូចយើងធ្លាប់បានបរិយាយរួចមកហើយ រចនាសម្ព័ន្ធពត៌មានជាបទពណ៌នា មានលក្ខណៈដូចគ្នានឹងការនិយាយអំពីរឿងមួយអញ្ចឹង។ លក្ខណៈរបស់វាមិនដូចគ្នានឹងរចនាសម្ព័ន្ធអត្ថបទពត៌មានធម្មតា ដែលមានរៀងដូច "សាជីផ្កាប" នោះទេ (*"inverted pyramid" structure*)។

www.budinst.gov.kh www.elibraryofcambodia

អត្ថបទព័ត៌មានបទពណ៌នា (*the feature article*) គឺវាមានការងារដែលត្រូវធ្វើច្រើនជាងការពន្យល់អំពីព្រឹត្តិការណ៍នោះទៅទៀត។ អត្ថបទព័ត៌មានជាបទពណ៌នា គឺមានផ្តល់នូវព័ត៌មានចម្រុះ ដែលមានរួមទាំងពីប្រវត្តិនៃសាច់រឿង (*back-ground*) ការពិពណ៌នា (*description*) និងចួនកាលមានរួមទាំងពីទំហំនៃការដកស្រង់ពាក្យសំដី (*lenghty quotes*) ដ៏វែងអន្លាយ ដែលអ្នកសរសេរបានស្រង់យកមកប្រើនៅក្នុងអត្ថបទនោះថែមទៀតផង។ ដូច្នេះលទ្ធផលមួយ ដែលនឹងត្រូវទទួលបាន គឺរចនាសម្ព័ន្ធមួយដែលមានភាពស្មុគស្មាញជាងអត្ថបទព័ត៌មានធម្មតា។ ការធ្វើដូច្នេះគឺដើម្បីឲ្យអ្នកអានឆាប់យកចិត្តទុកដាក់ និងអាចទទួលបាននូវផលប្រយោជន៍នោះផង។ ខាងក្រោមនេះគឺ ជារចនាសម្ព័ន្ធមួយបែបទៀត ដែលយើងអាចយកមកប្រើជំនួសរចនាសម្ព័ន្ធរាងជា "សាជីផ្ការ"។

**យកចិត្តទុកដាក់អំពីរចនាសម្ព័ន្ធ** (*The Focus Structure*)

ចូរពិចារណាលើពាក្យសំដីដែលបានដកស្រង់ (*quote*) របស់អតីតមេដឹកនាំសហភាពសូវៀតម្នាក់ គឺលោកយ៉ូសែហ្វ ស្តាលីន (*Joseph Stalin*) បាននិយាយថា "មនុស្សស្លាប់ចំនួន១០លាននាក់ គឺគ្រាន់តែជាស្ថិតិមួយប៉ុណ្ណោះចំណែកមនុស្សស្លាប់ម្នាក់វិញគឺជារឿងសោកនាដកម្មមួយ" ("*10 million deaths are a statistic; one death is a tragedy.*") ថ្វីត្បិតតែរឿងរបស់លោកស្តាលីនមិនត្រូវបានលើកយកមកពិភាក្សានៅក្នុងអត្ថបទពណ៌នានោះក៏ដោយ ក៏ប៉ុន្តែពាក្យសំដីរបស់គាត់ខាងលើនេះ គឺបានជួយជាគំនិតឬជាទស្សនៈសំរាប់ជាមូលដ្ឋាននៃរចនាសម្ព័ន្ធមួយ ដែលធ្វើឲ្យមានគេយកចិត្តទុកដាក់ - នៅលើផ្នែកនិមួយៗរបស់សាច់រឿង។ ធ្វើដូចនេះ គឺបានសេចក្តីថា យើងបានលើកអំពីអត្ថន័យ និងខ្លឹមសារនៃរូបភាពដ៏សែនធំទូលំទូលាយមួយនោះមកបង្ហាញដល់អ្នកអានបានយ៉ាងក្បោះក្បាយជាទីបំផុត។ ដើម្បីនឹងធ្វើការបកស្រាយឲ្យបានល្អិតល្អន់ អំពីសេចក្តីថ្លែងការណ៍របស់លោកស្តាលីន - នៅក្នុងអត្ថបទមួយស្តីអំពីរឿងមនុស្សម្នាក់ស្លាប់ គឺយើង

www.budinst.gov.kh www.elibraryofcambodia

ត្រូវលើកអំពីសោកនាដកម្មរបស់បុគ្គលម្នាក់នោះតាមរយៈការបង្ហាញឲ្យគេបានឃើញអំពីធាតុពិតនៃហេតុការណ៍ និងអំពីអ្វីដែលបានកើតឡើងហើយតែវាជាលទ្ធផល ដែលយើងទទួលបានពីសេចក្ដីស្លាប់របស់បុគ្គលម្នាក់នោះ។ បើយើងធ្វើដូច្នេះបានមែន គឺយើងចាប់ផ្ដើមមានការយល់ឃើញកាន់តែច្បាស់ថែមទៀត អំពីចំនួនមនុស្សស្លាប់ទាំងដប់លាននាក់នោះជាមិនខាន។

**ការអនុវត្តទៅតាមរចនាសម្ព័ន្ធ**

ដើម្បីធ្វើឲ្យគេផ្ដោតអារម្មណ៍មកលើរចនាសម្ព័ន្ធមួយ យើងត្រូវអនុវត្តន៍តាមរូបមន្ត ដែលមានជាបន្តបន្ទាប់ដូចខាងក្រោមនេះ

១- ផ្ដោតអារម្មណ៍លើបុគ្គលម្នាក់ (*Focusing on the individual*)។

២- បង្ហាញអំពីអន្តរបទសំរាប់ករណីធំៗ (*Providing a transition to the larger issue*)។

៣- រាយការណ៍អំពីករណីនោះ (*Reporting on the issue*)។

៤- បង្ហាញអំពីអនុភាពនៃសេចក្ដីបញ្ចប់របស់អត្ថបទដោយវិលទៅរកប្រធានបទដែលអ្នកកំពុងតែផ្ដោតអារម្មណ៍ ឬ ដែលជាសេចក្ដីសង្ខេបរបស់សេចក្ដីថ្លែងការណ៍មួយ។

**ការផ្ដោតអារម្មណ៍ទៅលើបុគ្គលម្នាក់** (*Focusing on the Individual*)

ដើម្បីនឹងធ្វើការផ្ដោតអារម្មណ៍ទៅលើបុគ្គលមួយរូប គឺយើងត្រូវខ្ចីស្នាដៃរបស់កវីនិពន្ធដ៏ចំណានៗផ្នែកអក្សរសាស្ត្រ ដែលមានអាយុរាប់ពាន់ឆ្នាំមកហើយ។ ឧទាហរណ៍ - រូបភាពដ៏ធំអស្ចារ្យមួយនៃសង្គ្រាមពុំមាននិយាយអំពីអ្វី ដែលជាធាតុពិតនៃសង្គ្រាមមួយនោះទេ។ ប៉ុន្តែបើយើងនិយាយអំពីសង្គ្រាមនោះតាមរយៈការមើលឃើញរបស់បុគ្គលណាម្នាក់ ដែលគេធ្លាប់បានប្រឡូកនៅក្នុងសង្គ្រាម គឺយើងប្រហែលជាអាចបានសិក្សាបន្ថែមអំពីបទពិសោធន៍ពិតៗនៃសង្គ្រាម - អំពីការភ័យខ្លាច និងការញាប់ញ័រអំពីភក់ និងឈាមអំពីទុក្ខសោកចំពោះមិត្តភ័ក្តិ ដែលបាត់បង់ជីវិតអំពីសេចក្ដីក្លាហានរបស់មិត្តរួមអាវុធ និងអំពីសត្រូវរបស់យើង។ យើងក៏ប្រហែល

www.budinst.gov.kh www.elibraryofcambodia

ជាអាចយកដំបូន្មានដដែលនេះ ទៅប្រើសំរាប់សរសេរ អំពីរឿងមួយដែលអ្នកផងយល់ថា ជារឿងដែលគួរឲ្យធុញទ្រាន់ជាទីបំផុត។ ឧទាហរណ៍ អំពីការសរសេររឿងមួយស្តីពីការចំណាយពេលពេញមួយថ្ងៃនៅក្នុងមន្ទីរសភា។

បើយើងនិយាយរឿងនោះដោយពុំមានបង្ហាញ អំពីបទពិសោធន៍របស់បុគ្គលណាមួយដែលធ្លាប់បានចូលទៅអង្គុយស្តាប់នៅក្នុងអង្គប្រជុំរបស់សភានោះទេគឺបានសេចក្តីថា យើងប្រហែលជានឹងត្រូវបាត់បង់នូវចំណុចនៃការយល់ដឹងដែលជាកត្តាសំខាន់ៗនោះជាមិនខាន។ ហើយបើយើងមានការខ្វះខាតដូច្នេះយើងក៏ប្រហែលជាយល់ថា ច្រកនៃការចេញច្បាប់និតិកម្មមួយនោះច្បាស់ជាប្រព្រឹត្តទៅដោយស្រួលជាទីបំផុត។ ក៏ប៉ុន្តែបើសិនជាយើងនិយាយរឿងនេះ ទៅតាមការមើលឃើញរបស់អ្នកតាក់តែងច្បាប់ណាម្នាក់វិញ គឺយើងអាចរំលឹកឡើងវិញអំពីរូបភាពដែលមានដូចជា ការចង់ដឹងចង់ឮអំពីដំណោះស្រាយមួយនៅពីក្រោយឆាក ឬអំពីករណីនយោបាយផ្សេងៗ ដែលពុំមានបើកចំហរជាសាធារណៈ។ ទស្សនៈយល់ដឹងរបស់បុគ្គលម្នាក់ ជារឿយៗគឺតែងផ្តល់មកជាឧបករណ៍សំខាន់ៗ ដែលយើងអាចយកទៅប្រើធ្វើជាសេចក្តីផ្តើម និងដែលមានដូចជាការដកស្រង់ពាក្យសំដី ឬបទពិពណ៌នាណាមួយដែលអាចធ្វើឲ្យអ្នកអានឆាប់ជក់ចិត្ត និងចាប់អារម្មណ៍អំពីរឿងនោះ។

**អន្តរៈបទ ឬ ឃ្លាភ្ជាប់សេចក្តី** (*The transition*)

ដែលហៅថាអន្តរៈបទ គឺជាកថាខ័ណ្ឌមួយ ឬពីរ ដែលអាចជួយដល់អ្នកអានឲ្យមានការងាយស្រួលក្នុងការស្វែងយល់អំពីទស្សនៈ ដែលមាននិយាយនៅក្នុងសេចក្តីផ្តើម។ បន្ទាប់មកគឺយើងអាចទៅធ្វើជាស្ពានសំរាប់អ្នកអានដើម្បីឆ្លងចូលទៅក្នុងកថាខណ្ឌមួយទៀត ដែលមានការបកស្រាយបានក្បោះក្បាយផងដែរ។ ជួនកាលគេអាចហៅថាជា "គ្រាប់ពូជ" របស់កថាខ័ណ្ឌ។ ហើយតាមរយៈនេះ អ្នកអានអាចមានឱកាសដើម្បីសិក្សាអំពីគោលបំណងរបស់អត្ថបទនោះទៀតផង។ ដើម្បីនឹងធ្វើសទិសភាព

www.budinst.gov.kh www.elibraryofcambodia

(ការប្រៀបធៀបអំពីករណីមួយដែលមានលក្ខណៈស្រដៀងគ្នា) អំពីរឿងសង្គ្រាមរបស់យើង ដូចមានជូនជាឧទាហរណ៍ខាងលើ គឺយើងត្រូវមាន ៖ នៅក្នុងសេចក្តីផ្តើម - គឺត្រូវមាននិយាយរៀបរាប់អំពីបទពិសោធន៍របស់បុគ្គលម្នាក់នៅលើសមរភូមិ។
អន្តរបទ - មានផ្តល់ជាពត៌មានដូច្នេះថា ហេតុដូចម្តេចបានជាមនុស្សម្នាក់នោះមានជាប់ទាក់ទិននៅក្នុងរឿងនោះ។ គឺគាត់ម្នាក់នោះហើយនៅក្នុងចំណោមមនុស្សដ៏ច្រើន ដែលមានរឿងស្រដៀងៗគ្នា និងដែលចង់ប្រាប់ដល់យើងទៅតាមការយល់ដឹងរបស់គេម្នាក់ៗ។ ករណីដូច្នេះគឺ អាចបង្កើតបានជាសំនួរមួយចំនួនដែលមានដូចជា ៖ តើមានមនុស្សចំនួនប៉ុន្មាននាក់ដែលជាប់ទាក់ទិននៅក្នុងរឿងនោះ? តើសង្គ្រាមនោះចាប់ផ្តើមឡើងដោយរបៀបណា? ទំនាស់នៃសង្គ្រាមនោះត្រូវចំណាយរយៈពេលយូរប៉ុណ្ណាទើបបានដោះស្រាយរួច? ទាំងអស់នេះគឺ សុទ្ធតែជាសំនួរមានប្រយោជន៍សំរាប់ប្រើនៅក្នុងការប្រមូលពត៌មានបន្ថែមដើម្បីយកមកសរុបនៅក្នុងអន្តរបទ ឬឃ្លាភ្ជាប់សេចក្តីនេះ។

**ធ្វើសេចក្តីរាយការណ៍អំពីករណីមួយ** (*Reporting on the Issue*)

នេះគឺជាមូលហេតុពិត ដែលមាននៅពីក្រោយនៃការសរសេរអត្ថបទមួយ - នៅក្នុងការធ្វើសទិសភាពរបស់យើង។ ឧទាហរណ៍ - នៅក្នុងករណីនេះប្រហែលជាមានសំនួរមួយដែលគេអាចសួរបានគឺ តើហេតុអ្វីបានជាសង្គ្រាមនេះរកដំណោះស្រាយពុំបាន? ដូច្នេះនៅពេលដែលយើងធ្វើសេចក្តីរាយការណ៍អំពីករណីនេះ គឺយើងអាចសុំខ្ចីបច្ចេកទេសមួយចំនួនដែលយើងប្រើសំរាប់អត្ថបទពត៌មានធម្មតា និងដែលមានរាងជា "សាជីផ្កាប់" នោះ។ បន្ទាប់មកយើងចាប់ផ្តើមសរសេរបញ្ចូលពត៌មាន របស់យើងតាមលេខរៀងដោយយកករណីណាដែលសំខាន់ជាងគេមកដាក់នៅលើបង្អស់។ យើងត្រូវខំធ្វើយ៉ាងណាឲ្យពត៌មានរបស់យើងមានលក្ខណៈដូចជា ការសំដែងមួយដែលកំពុងមាននៅលើឆាក។ ដើម្បីធ្វើដូច្នេះបាន គឺយើងត្រូវលើកអំពីទស្សនៈរបស់បុគ្គលពាក់ព័ន្ធ ឬករណីណាមួយ ដែលគួរឲ្យជឿទុកចិត្តបាន

www.budinst.gov.kh www.elibraryofcambodia

មកដាក់បញ្ចូល។ ទាំងអស់នេះ គឺអាចជួយដល់យើងនៅក្នុងការដែលយើងចង់សរសេររឿងនិទានខ្លីៗ (*anecdotes*) ឬបទពិពណ៌នាណាមួយដែលពោរពេញទៅដោយពណ៌ធម្មជាតិ និងសកម្មភាពរស់រវើក។

**សេចក្តីបញ្ចប់** (*The Finish*)

ចំណុចយ៉ាងនៃការសរសេរអត្ថបទមួយឲ្យល្អ គឺនៅត្រង់សេចក្តីបញ្ចប់-គឺការបង្ហាញអំពីឥទ្ធិពលរបស់អត្ថបទនៅចុងបញ្ចប់-គឺជាការបន្សល់ទុកនូវស្នាមមួយដែលដក់ជាប់នៅក្នុងអារម្មណ៍របស់អ្នកអាន និងដែលអាចជួយដល់អ្នកអានសំរាប់យកទៅពិភាក្សាជាមួយអ្នកដទៃទៀត។ មានបច្ចេកទេសមួយសំរាប់ប្រើក្នុងការសរសេរសេចក្តីបញ្ចប់អោយបានជោគជ័យ គឺយើងត្រូវវិលត្រឡប់ទៅរកពាក្យសំដីរបស់បុគ្គលដែលយើងបានយកមកប្រើនៅក្នុងអត្ថបទពីដំបូងគេ។ បន្ទាប់មកត្រូវសរសេរបញ្ចប់ដោយដាក់បន្ថែមនូវបទពិសោធន៍ផ្សេងៗទៀតដែលបុគ្គលនោះមាន។ ដូចគ្នាដែរបើយើងចង់ធ្វើការបកស្រាយម្តងទៀតអំពីរឿងសង្គ្រាមដូចមានឧទាហរណ៍នៅខាងលើយើងអាចសរសេរបញ្ចប់អត្ថបទរឿងសង្គ្រាមនោះបានដោយធ្វើការពិពណ៌នាបន្ថែមអំពីបទពិសោធន៍ប្រចាំថ្ងៃរបស់ទាហានដែលបានប្រយុទ្ធដើម្បីការពារជីវិតរបស់ខ្លួននៅក្នុងពេលដែលពួកអ្នកនយោបាយ និងអ្នកការទូតទាំងអស់នោះគេកំពុងបន្តការរស់នៅរបស់គេ ក្នុងជីវភាព ដ៏សែនថ្លៃថ្នូរដ៏សែនសុខ និងដែលកំពុងតែពោរពេញទៅដោយជីវិតទាន់សម័យ។

**អំពីការផ្លាស់ប្តូរនៅលើរចនាសម្ព័ន្ធតាមការប្រមូលអារម្មណ៍** (*Variations to the Focus Structure*)

ការផ្តោតអារម្មណ៍នៅលើរចនាសម្ព័ន្ធមួយ គឺអាចជួយដល់យើងដើម្បីនិយាយ អំពីរឿងមួយបានតាមការប្រមូលអារម្មណ៍របស់យើងទៅលើបុគ្គលម្នាក់ និងអាចជួយធ្វើឲ្យពត៌មាននៅក្នុងសេចក្តីផ្តើមរបស់យើង ដែលធ្លាប់មានមកជាប្រពៃណីប្រែក្លាយទៅជាមានភាពទូលំទូលាយជាង។ ការប្រែប្រួលនោះមានពីរយ៉ាងគឺ ៖

www.budinst.gov.kh www.elibraryofcambodia

១. បង្ហាញពីទស្សនីយភាព ឬរូបភាពក្នុងសេចក្តីផ្តើម(*Scenic leads*)។
២. លើកយកខ្លឹមសារនៃរឿងនិទានខ្លីៗមកបង្ហាញក្នុងសេចក្តីផ្តើម(*Anecdotal leads*) ។

**ការបង្ហាញពីទស្សនីយភាព ឬរូបភាពនៅក្នុងសេចក្តីផ្តើម**

ការបង្ហាញពីទស្សនីយភាព ឬរូបភាពនៅក្នុងសេចក្តីផ្តើម គឺជាមធ្យោបាយដ៏មានប្រសិទ្ធិភាពជាទីបំផុតក្នុងការដែលយើងចង់ធ្វើឲ្យអ្នកអានឆាប់មានការចាប់អារម្មណ៍មកលើសាច់រឿង។ ការលើកបង្ហាញអំពីទស្សនីយភាព ឬរូបភាព នៅក្នុងសេចក្តីផ្តើម គឺជាការបង្កើតឲ្យមានជាទស្សនីយភាពមួយដែលចាំបាច់ ឬពុំចាំបាច់របស់តួអង្គណាម្នាក់នៅក្នុងសេចក្តីផ្តើមនោះទេ។ យើងត្រូវធ្វើការពិពណ៌នាអំពីទស្សនីយភាព ឬរូបភាពនោះ គឺដើម្បីគ្រាន់តែចង់លាតត្រដាងរឿងរបស់យើងឲ្យបានក្បោះក្បាយតែប៉ុណ្ណោះ។

**លើកយករឿងនិទានខ្លីៗមកបង្ហាញក្នុងសេចក្តីផ្តើម**

រឿងនិទានខ្លីៗ គឺជាផ្នែកនៃករណីមួយដែលមាននៅក្នុងរឿងមួយទៀត។ រឿងប្រភេទនេះអ្នកប្រហែលជាអាចជួបប្រទះនៅក្នុងពេលដែលអ្នកកំពុងអង្គុយនិយាយជាមួយមិត្តរបស់អ្នក។ រឿងនិទានខ្លីនេះជួនកាលវាអាចជាករណីដ៏ល្អមួយសំរាប់ប្រើក្នុងសេចក្តីផ្តើម ពីព្រោះវាអាចមានជារូបភាពស្រាប់ និងដែលអាចជួយជាគំនិតដល់អ្នកអានអំពីរឿងផ្ទាល់ខ្លួនរបស់បុគ្គលដែលជាតួអង្គ ឬអំពីទិដ្ឋភាពនៃប្រវត្តិសាស្ត្រ ដែលជាវិភាគទានសំរាប់ស្ថានការណ៍មួយ ដែលយើងនឹងលើកយកមកសរសេរនោះ។

**ការបន្ថយបទពណ៌នាដោយយោងតាមបទសន្ទនា**(*Extended Dialogue Stories*)

ជួនកាលអ្នកយកពត៌មានម្នាក់ ប្រហែលជាបានជួបជាមួយនឹងបុគ្គលម្នាក់ដែលសំបូរទៅដោយពាក្យសំដី និងដែលអាចយកជាការបាន ឬជួនកាលអ្នកយកពត៌មានរូបនោះក៏ប្រហែលជាបានជួបនូវសាច់រឿងមួយ ដែលពោរ

www.budinst.gov.kh www.elibraryofcambodia

ពេញទៅដោយសោកនាដកម្មថែមទៀតផង។ បើអ្នកបានជួបប្រទះនូវករណី ដូចខាងលើនេះយកល្អអ្នកគួរ "ដកខ្លួនចេញ" ឲ្យឆ្ងាយពីករណីនោះ។ រួចហើយទុកឲ្យអ្នកពាក់ព័ន្ធផ្ទាល់ គេនិយាយរឿងនោះដោយខ្លួនគេ។ ការបន្ទាយពត៌មានបទពណ៌នាដោយយោងតាមបទសន្ទនាមួយមានសេចក្ដីផ្ដើម ឃ្លាភ្ជាប់សេចក្ដី និងឃ្លាបញ្ចប់ដូចពត៌មាននានាដែរ។ ប៉ុន្តែរឿងដែលគេលើកយកមកនិយាយនៅក្នុងអត្ថបទរបៀបនេះ គឺច្រើនតែជាពាក្យសំដីសំខាន់ៗរបស់តួរអង្គដែលពាក់ព័ន្ធ។ នេះគឺជាការងារមួយ ដែលយើងគ្រប់រូបមានការពិបាកជាទីបំផុតសឹងតែមិនអាចធ្វើបាន បើយើងគ្មានខ្សែរអាត់ថតសម្លេង។ ចំណុចមួយចំនួនដែលត្រូវចងចាំៈ

១- ត្រូវចេះប្រើបច្ចេកទេសបន្ទាយបទសន្ទនា។ បទសន្ទនាត្រូវតែពិសេសជាងគេ។ ប៉ុន្តែត្រូវចាំថាបើបទសន្ទនានោះវាធាប់ធ្វើឲ្យគេធុញទ្រាន់ ដូច្នេះអត្ថបទរឿង ដែលយើងនឹងសរសេរនោះ ក៏វាធាប់ធ្វើឲ្យគេធុញទ្រាន់ដែរ។

២- នៅពេលដែលយើងយកបទសន្ទនាមួយមកប្រើ ហើយបើយើងគ្មានកាសែ្សត ថតសម្លេង នេះគឺជាការងារមួយដ៏សែនពិបាក ដែលយើងនឹក ស្មានមិនដល់។

៣- បើមានបទសន្ទនាតែមួយមុខក៏ពុំទាន់គ្រប់គ្រាន់ដែរ។ អ្នកត្រូវលើកបង្ហាញអំពីទស្សនីយភាព ឬរូបភាព និងត្រូវឲ្យមានឃ្លាភ្ជាប់សេចក្ដីជាមួយផង។ បន្ទាប់មកទើបបានចូលដល់សេចក្ដីបញ្ចប់តែម្ដង។

**ពត៌មានបទពណ៌នាយោងតាមពង្សាវតារ** *(The chronological Approach)*

ការសរសេរអត្ថបទពណ៌នាមួយដោយយកលំនាំតាមពង្សាវតារ គឺអាស្រ័យទៅតាមព្រឹត្តិការណ៍ដែលកំពុងកើតមាន និងមិនទាន់ចប់។ វាជារឿងចាស់ក៏ពិតមែនក៏ប៉ុន្តែអ្នកសរសេរអត្ថបទរបៀបនេះ គឺពុំចាំបាច់ត្រូវរៀបរាប់អំពីអ្វី ដែលមានតាំងពីដើមមកនោះទេ។ សេចក្ដីផ្ដើមរបស់អត្ថបទដោយយោងតាមពង្សាវតារនេះ គឺយើងអាចលើកយកតែអំពីអ្វី ដែលជា

www.budinst.gov.kh www.elibraryofcambodia

ទំនៀមទំលាប់ប្រពៃណី ដែលមានទំនាក់ទំនងទៅនឹងព្រឹត្តិការណ៍មួយ នោះមកសរសេរដោយចោះយកត្រង់កន្លែងណា ដែលមានខ្លឹមសារ និងដែលគួរឲ្យចាប់អារម្មណ៍ជាទីបំផុត។ គឺអាចមានដូចជា អំពីទស្សនីយ៍ភាព ឬអំពីរូបភាពនៃរឿងនិទានខ្លីៗជាដើម។ល។ បន្ទាប់ពីមានឃ្លាភ្ជាប់សេចក្ដីមួយរួចហើយ។ យើងត្រូវចាប់ផ្ដើមធ្វើការពិពណ៌នា អំពីសកម្មភាពនៃព្រឹត្តិការណ៍ដែលកើតមានឡើងនោះ។

**ប្រភពដើមនៃពត៌មានជាបុគ្គលទីមួយ** (*First Person Stories*)

នៅពេលដែលអ្នកយកពត៌មានសរសេរអំពីបទពិសោធន៍របស់គាត់ យើងឲ្យឈ្មោះលទ្ធផលនៃការសរសេរនោះថា ជារឿងរបស់បុគ្គលទីមួយ។ ដើម្បីធ្វើការវិនិច្ឆ័យទៅលើករណីរបស់បុគ្គលទីមួយ ដែលយើងបានលើកយកមកសរសេរនោះ គឺយើងត្រូវពិនិត្យទៅលើករណី ដែលពិសេសជាងគេ និងដែលនៅក្នុងវិធីសាស្ត្រណាមួយនោះ គឺមានតែមួយគត់។ ត្រូវចាំថា ពាក្យសំដីទាំងនោះ គឺតែងមានបង្កប់ទៅដោយករណីខ្លះ ដែលពិបាកមែនទែន និងដែលត្រូវមានការជជែកពិភាក្សាយ៉ាងច្រើនទៀតផង។ ដូច្នេះតើអ្នកយកពត៌មានត្រូវតែចូលរួមដែរឬទេ? ឬក៏ពួកគេត្រូវនៅឲ្យឆ្ងាយពីព្រឹត្តិ-ការណ៍នោះ? ឬក៏ត្រូវសរសេរពត៌មាននោះតាមរយៈអ្នកផ្សេងទៀតវិញ? និយាយរួមទោះជានៅក្នុងករណីណាក៏ដោយ អ្នកសារពត៌មានគឺ ត្រូវគោរពតាមតួនាទីរបស់ខ្លួន - ទោះជាព្រឹត្តិការណ៍នោះបានមកពីបុគ្គលទីមួយក៏ដោយអ្នកសារពត៌មានគឺមានកាតព្វកិច្ចតែមួយគត់ ដែលត្រូវបំពេញតាមការស្រេកឃ្លានរបស់អ្នកអាន - អ្នកសារពត៌មាន ត្រូវបង្ហាញដល់អ្នកអានទូវពត៌មានទាំងឡាយដែលពាក់ព័ន្ធ និងដែលអាចឲ្យអ្នកអានយកករណីនោះទៅពិចារណាដោយខ្លួនគេ។

www.budinst.gov.kh www.elibraryofcambodia



www.budinst.gov.kh www.elibraryofcambodia

## ឧទាហរណ៍មួយចំនួនអំពីអត្ថបទពណ៌នា

**មន្ទីរពេទ្យយោធាចាស់ជំបទ**

**ដោយលោក ហ្សូច៍ ម៉ាត់គីន** ថ្ងៃទី១៥-២-៩៦

មុនដំបូងបង្អស់អ្នកនឹងធុំក្លិនប៉ុណ្ណោះ។ ក្លិននោះគឺដូចជា ... អញ្ចឹង។ គ្មានអ្វីក្រៅពីនេះទៀតទេ គឺច្បាស់ណាស់។ នោះគឺជាក្លិនឈាមដែលទើបនឹងកកថ្មីៗ ក្លិនថ្នាំសម្លាប់មេរោគ និងក្លិនស្អុយនៃដំបៅក្លាយ - គឺជាក្លិនដែលធ្វើឲ្យជ្រួញច្រមុះ ព្រោះដោយសារបកពីទ្រាំមិនបាន។

នៅក្នុងបន្ទប់នេះងងឹតខ្លាំងណាស់ ខ្យល់អាកាសហាក់ដូចជាមានធាតុសើម និងសៃនស្អុះស្អាប់រួមទៅដោយក្លិនគ្រប់ជំពូក។ ក្នុងភាពដ៏សែនអាប់អួរនេះ នាជ្រុងម្ខាងនៃជញ្ជាំងយើងឃើញមានគ្រែបី។ នៅលើគ្រែមួយមានកំណាត់ភួយរហែករយ៉ាគ្របពីលើយុវជនម្នាក់ ដែលមានភ្នែកហើមពោរ។ នៅក្បែរនោះមានយុវនារីម្នាក់ដែរក្នុងវ័យប្រហែលពាក់កណ្តាលអាយុ។ នាងអង្គុយនៅលើគ្រែមួយក្នុងកាយវិការដ៏សែនល្អិតល្អៃ មានរាងកាយស្គមស្តើងដូចផ្លិត និងដែលប្រកបទៅដោយទឹកមុខសែនស្លូត និងដែលគួរឲ្យអាណិតជាទីបំផុត។ នៅលើគ្រែមួយទៀតមានយុវជនម្នាក់ទៀតកំពុងដេកបិទភ្នែកយ៉ាងជិត និងដែលមានដង្ហើមដកខ្លីៗ-បញ្ចេញខ្យល់មុតស្រួចតាមប្រឡោះជើងធ្មេញ។ ក្បាលរបស់គាត់នៅមិនស្ងៀម-ងាកឆ្វេង-ស្តាំ។ ជើងឆ្វេងរបស់គាត់ត្រឹមមួយកំណាត់ចុះក្រោមត្រូវដាច់បាត់ និងមានរុយពីរ-បីកំពុងរោមស្នាមដែលខ្មោចពណ៌ក្រហមនៅលើជើងស្តាំ ដែលហែនរបួសដោយសារគ្រាប់មីន។

លោកពេន ជាអ្នកថតរូបមកពីទីភ្នាក់ងារសារព័ត៌មានខ្មែរបានខ្សឹបតិចៗថា យុវជនម្នាក់នេះគឺជាបងប្អូនជាដូនមួយរបស់លោក។ ពេលឃើញដូច្នេះលោកពុំបានជំរាបសួរអ្នករបួសនោះទេ។ ប៉ុន្តែលោកបែរជាលើកម៉ាស៊ីនថត រួចថតអ្នករបួសដែលជាបងប្អូនជីដូនមួយនោះបានពីរបីប៉ុស្តិ៍។

www.budinst.gov.kh www.elibraryofcambodia

បន្ទាប់មកលោកក៏ចេញដំណើរមកតាមពួកយើងរហូតមកដល់ធ្លាខាងក្រៅនៃមន្ទីរពេទ្យ ដែលមានដីកំពុងហុយសំពោង។

បើសិនជាលោកពុំធ្លាប់មានស្លាកស្នាមដោយសារធ្លាប់មានរបួសម្តងទេនោះ គឺនៅត្រង់ដើមដៃ លោកពេនប្រហែលជាមិនអាចទប់អារម្មណ៍នៅព្រងើយកន្តើយយ៉ាងដូច្នេះបានឡើយ។ យើងបានចេញដំណើរទៅមុខទៀតក្លិនផ្កាបនៃឈាមនៅតែហើរមកប៉ះនឹងច្រមុះយើងដដែល។ តាមពិតយើងមិនត្រូវមកទីនេះសោះ សូម្បីតែបងប្អូនជីដូនមួយរបស់លោក ពេនក៏ដូច្នោះដែរ។

កាលពីក្នុងខែមករាកន្លងទៅក្រសួងការពារជាតិ បានចេញសេចក្តីប្រកាសមួយថា នៅក្នុងរដូវប្រាំងឆ្នាំនេះ នឹងពុំមានការវាយលុកដូចឆ្នាំមុនៗទៀតទេ។ ប៉ុន្តែនៅឯមន្ទីរពេទ្យឯណោះវិញ គឺមានពោរពេញទៅដោយអ្នករបួស។ មើលចុះគ្រែទាំងអស់មានចំនួនជាង២០០ ហើយគ្មានគ្រែណាមួយនៅទំនេរឡើយ។ ៦០%ភាគរយនៃគ្រែទាំងអស់ គឺសុទ្ធតែជាអ្នកដែលមានរបួសដោយសារមីន។ ក្រៅពីនោះគឺនៅមានអ្នករបួសដោយសារគ្រាប់កាំភ្លើង និងអំបែងគ្រាប់។ មិនតែប៉ុណ្ណោះនៅក្នុងចំណោមអ្នកជម្ងឺ១០នាក់ ដែលបានមកសំរាកនៅក្នុងមន្ទីរពេទ្យនេះ គឺមានអ្នកជម្ងឺបីនាក់មានជម្ងឺគ្រុនចាញ់។ មានតែអ្នករបួសទេ ដែលត្រូវបានឲ្យសំរាកនៅលើគ្រែ ក្រៅពីនោះគឺ ត្រូវសំរាកនៅកណ្តាលវាល។ ទាំងអស់នេះ គឺជាសំដីរបស់លោកអនុសេនីយឯក វេជ្ជបណ្ឌិតណឹក វណ្ណៈ។ នៅក្នុងឯកសណ្ឋានកាម្មូប្លា ពាក់មួកកាស្កេត និងស្បែកជើងប្រយុទ្ធ បើ ក្រឡេកមើលតែមួយភ្លែតគឺយើងច្បាស់ជាពុំអាចដឹងបានថា លោកវណ្ណៈ គឺជាគ្រូពេទ្យឡើយ។ លោកធ្លាប់ ទទួលការហ្វឹកហ្វឺនផ្នែកវិជ្ជាពេទ្យនេះនៅប្រទេសយៀកណាមអស់រយៈពេលចំនួនប្រាំមួយឆ្នាំ។ ហើយកន្លងមកលោកធ្លាប់មានការពិសោធន៍នៅលើសមរភូមិកម្ពុជាអស់រយៈ ពេលចំនួនប្រាំបីឆ្នាំថែមទៀត។ រូបលោកគឺប្រាកដជាមានបទពិសោធន៍ ក្នុងរឿងប៉ះទង្គិចខាងផ្លូវចិត្តនៅលើសមរភូមិ

www.budinst.gov.kh www.elibraryofcambodia

គឺជាអ្នកដែលមានពោរពេញទៅដោយជំនាញ និងបច្ចេកទេសច្រើនជាងនរណាទាំងអស់នៅលើលោកយើងនេះ។

យើងនៅមិនទាន់ដឹងច្បាស់ថា តើមកពីហេតុអ្វីបានជាលោកហ៊ាននិយាយជាមួយពួកយើងនេះឡើយ។ ប៉ុន្តែជាក់ស្តែងគឺ លោកបាននិយាយជាមួយពួកយើងមែន។ មានមនុស្សម្នាក់ក្នុងចំណោមគ្នាយើងបាននិយាយដូច្នេះថា លោកអនុសេនីយឯក គឺជាមនុស្សម្នាក់កប្រែរកនរណាបកប្រដូចបានណាស់។ ស្តាប់ចុះសម្លេងរបស់លោកគឺ បានសំដែងចេញមកដោយគ្មានលាក់លៀម និងក្នុងន័យស្មោះត្រង់ជានិច្ច។ "ឆ្នាំនេះការងាររបស់យើងបានល្អប្រសើរជាងឆ្នាំមុនៗ។ ឆ្នាំនេះយើងមានរថយន្តសង្គ្រោះចំនួនបី យើងអាចដឹកជញ្ជូនទាហានបានយ៉ាងឆាប់ទាន់ចិត្តជាទីបំផុត។" បន្ទាប់មកលោកបានបន្តទៀតថា "យើងមានទាហានពេទ្យច្រើនដែរ ដែលកំពុងប្រចាំការនៅឯខ្សែត្រៀម។ ពួកគេស្ទាត់ជំនាញណាស់ខាងវិជ្ជារុំរបួស។ នេះគឺជាការសំខាន់ ... ពួកគេអនុវត្តការងារ ដឹកជញ្ជូនអ្នករបួសមកកាន់បន្ទីរពេទ្យបានយ៉ាងឆាប់រហ័សទាន់ចិត្ត។

នៅជិតទីនោះមានបន្ទីរខេត្តមួយ លោកវេជ្ជបណ្ឌិត អ៊ីវស៍ ខុំប៉ែតក៏មានទស្សនៈតែមួយដូចគ្នា។ លោកយល់ថា នៅក្នុងរដូវប្រាំងឆ្នាំនេះកងយោធពលខេមរភូមិន្ទគឺ ធ្វើការងារបានល្អគ្រាន់បើជាងឆ្នាំមុនៗ ទាំងការដឹកជញ្ជូនអ្នករបួសពីសមរភូមិ និងទាំងការព្យាបាលអ្នករបួស។ ក្នុងនាមលោកជាវេជ្ជបណ្ឌិតមួយរូប និងជាអ្នកចាត់ចែងការងាររបស់អង្គការគ្រូពេទ្យគ្មានព្រំដែននៅបាត់ដំបង លោកបានពន្យល់ដូច្នេះថា បើមានការរុំរបួសបានឆាប់រហ័សទាន់ចិត្ត និងមានការដឹកជញ្ជូនមកកាន់បន្ទីរពេទ្យបានភ្លាមៗ អ្នកដែលអាចគេចផុតពីសេចក្តីស្លាប់ក៏អាចមានច្រើនដែរ។

"ចំពោះបញ្ហាមីន (អ្នករងរបួសដោយសារគ្រាប់មីន) និងបញ្ហាផ្សេងៗជាច្រើនទៀត ដែលកើតមានឡើងនៅលើសមរភូមិ គឺបានធ្វើឲ្យមនុស្សជាច្រើនត្រូវស្លាប់ដោយសារបកពីមានការបាត់បង់ឈាមច្រើនពេក។" នេះជា

www.budinst.gov.kh www.elibraryofcambodia

ប្រសាសន៍របស់លោកវេជ្ជបណ្ឌិតខួយយ៉ែត។ "អ្នកដែលរងរបួសដោយសារគ្រាប់មីន គឺមានឈាមហូរចេញលឿនណាស់។ អ្នករបួសត្រូវបាត់បង់ឈាមយ៉ាងតិចណាស់ក៏មួយលីត្រ ពីរលីត្រ ឬបីលីត្រដែរ។" លោកមានប្រសាសន៍ទៀតថា "យើងពុំមានស្ថិតិថា តើមានមនុស្សប៉ុន្មាននាក់ត្រូវស្លាប់នៅលើសមរភូមិក្នុងប្រទេសកម្ពុជានេះទេ។ ប៉ុន្តែបើនៅអាហ្វហ្គានីស្ថាន និងម៉ូហ្សាំប៊ិចវិញគេបាន់ឲ្យដឹងថា ក្នុងអ្នករបួសចំនួនប្រាំនាក់ គឺមានម្នាក់ត្រូវស្លាប់ដោយការសង្គ្រោះមិនទាន់។" បើសិនជាយើងមានមនុស្សនៅលើសមរភូមិចេះវិជ្ជាឃាត់ឈាម និងចេះរុំរបួសបានត្រឹមត្រូវគឺ យើងអាចកាត់បន្ថយនូវចំនួនខាងលើនេះបាន ... ហើយបើសិនជា អ្នករបួសត្រូវបានដឹកមកកាន់បន្ទីរពេទ្យដោយមានចំណាយរយៈពេលតិចជាងប្រាំមួយម៉ោង និងមានថ្នាំការពារដើម្បីកុំឲ្យមុខរបួសក្លាយផងនោះ អ្នករបួសច្បាស់ជាអាចមានសំណាងច្រើនមែនទែន។

អង្គការគ្រូពេទ្យគ្មានព្រំដែន បានរួបរួមសហការណ៍យ៉ាងជិតស្និទជាមួយបន្ទីរពេទ្យខេត្តតា ចាប់តាំងពីឆ្នាំ១៩៩១មកម្ល៉េះ។ លោកខួយយ៉ែតមានការពេញចិត្តនឹងកម្មវិធីរបស់លោកខ្លាំងណាស់។ លោកតែងបន់ស្រន់ដល់បុគ្គលិកពេទ្យទាំងអស់ក៏ដូចគ្នា នឹងក្រសួងសុខាភិបាលផងដែរឲ្យជួបប្រទះតែនឹងជោគជ័យ និងទទួលបានផលល្អៗក្នុងការងាររបស់ខ្លួនជានិច្ច។ លោកបានមានប្រសាសន៍ថា "ទោះជាយ៉ាងណាក៏ដោយចំពោះការងារនៅក្នុងក្រសួងការពារជាតិ គឺនៅពុំទាន់ទទួលលទ្ធផលល្អនៅឡើយទេ។ ប៉ុន្តែលោកស្ងួបសរំដែងនូវការកោតសរសើរដល់វេជ្ជបណ្ឌិតយោធាគ្រប់រូប ដែលបានខិតខំបំពេញការងារបានលទ្ធផលគួរជាទីពេញចិត្ត។"

អង្គការគ្រូពេទ្យគ្មានព្រំដែន គឺជាអង្គការតែមួយគត់ក្នុងចំណោមអង្គការមួយចំនួនតូចដែលមានមុខផ្តល់ជំនួយផ្នែកយោធាដល់កម្ពុជា។ កាលពីឆ្នាំទៅអង្គការនេះបានបើកវគ្គហ្វឹកហ្វឺនមួយសំរាប់វេជ្ជបណ្ឌិតយោធាកម្ពុជា។ ហើយនៅក្នុងឆ្នាំនេះគឺ គេកំពុងធ្វើការចរចារដើម្បីរកដំណោះស្រាយដល់

www.budinst.gov.kh www.elibraryofcambodia

អាផ្ទាធរស៊ីវិល និងយោធាផងដែរ។ "យើងបានខិតខំសហការណ៍ឲ្យបាន ជិតស្និតជាមួយនឹងសេវាកម្មផ្នែកវិជ្ជាពេទ្យរបស់កងយោធពលខេមរភូមិន្ទ កម្ពុជា។" នេះគឺជាប្រសាសន៍របស់លោក ខួយយ៉ែត។ "ខាងផ្នែកយោធា គឺបានយល់ព្រមទទួលខុសត្រូវក្នុងការព្យាបាលជាបន្ទាន់ រួចហើយត្រូវដឹក អ្នករបួសមកបាត់ដំបង។ ចំណែកខាងយើងយល់ព្រមទទួលខុសត្រូវខាង ផ្នែកព្យាបាលតែអ្នករបួសណាដែលធ្ងន់ធ្ងរ។ យើងមានឧបករណ៍ល្អ គ្រាន់បើ ជាងពេទ្យយោធាខេត្ត និងមានការផ្គត់ផ្គង់ឈាមទៀតផង។ នៅពេលណា ដែលអ្នករបួសបានធូរស្រាលហើយ យើងនឹងបញ្ជូនឲ្យទៅសំរាកនៅក្នុង មន្ទីរពេទ្យយោធាវិញ។"

បច្ចុប្បន្ននេះនៅក្នុងមន្ទីរពេទ្យខេត្ត គឺមានពោរពេញទៅដោយទាហាន និងមន្ត្រីរាជការផ្នែកកងទ័ព ដែលបានមកសំរាកនៅក្នុងមន្ទីរពេទ្យនេះមានរយៈ ពេលមិនដល់មួយខែផង។ "... ការពិបាកមានកាន់តែច្រើនឡើងៗ ដោយសារមកពីមន្ទីរពេទ្យយោធាមានការរវល់ខ្លាំងពេក។ យើងមានការព្រួយ បារម្ភខ្លាំងណាស់ ពីព្រោះនៅក្នុងរយៈពេលប៉ុន្មានសប្តាហ៍ចុងក្រោយនេះ មន្ទីរពេទ្យកំពុងប្រឈមមុខ នឹងបញ្ហាកង្វះខាតគ្រឿងបរិក្ខាពេទ្យ។" នេះគឺជា ប្រសាសន៍របស់លោក ខួយយ៉ែត។ លោកអនុសេនីយឯក វណ្ណៈ ក៏មាន ទស្សនៈយល់ស្របដូច្នេះដែរ។ នេះជាលើកទីមួយហើយ ដែលលោកមាន ទឹកមុខប្រកបទៅដោយក្តីព្រួយបារម្ភ។ "ខ្ញុំត្រូវការពេទ្យទាហានជំនាញៗ ថែមទៀត ត្រូវការរថយន្ត សង្គ្រោះ ថ្នាំសំរាប់ចាក់ សរសៃរ បង់រុំរបួស អង់ទីប៊ីយ៉ូទិក អង់ទីសិបទិក ឧបករណ៍សំរាប់វះកាត់ ...។" លោកនិយាយ បន្តថា "ហើយអ្វីដែលខ្ញុំត្រូវការខ្លាំងជាងគេ គឺការផ្គត់ផ្គង់ឈាម ... ជារៀង រាល់លើកខ្ញុំតែងរំលឹកដល់បុគ្គលិករបស់ខ្ញុំឲ្យនាំគ្នាជួយធ្វើអំណោយឈាម។ ប៉ុន្តែយើងនៅតែមានការខ្វះខាតដដែល។" មើលទៅមុខលោកអនុសេនីយឯក គឺហាក់ដូចជាកំពុងតែមានសេចក្តីខ្មាស់អៀនខ្លាំងណាស់ បន្ទាប់ពីខ្ញុំបាន ជំរាបសួរលោកអំពីរឿងជំនួយអន្តរជាតិ។ លោកបានញញឹមទាំងក្តីបន្ទំលៃ។

www.budinst.gov.kh www.elibraryofcambodia

"អង្គការក្រៅរដ្ឋាភិបាលភាគច្រើន គេគ្មានបំណងចង់ជួយដល់ទាហានទេ។" លោកអនុសេនីយឯកបានមានប្រសាសន៍ថែមទៀតថា "ពីព្រោះវានាំឲ្យមានការប៉ះពាល់ដល់មុខមាត់របស់ពួកគេ។" លោកបន្តដូច្នេះថា "កាលពីមុនខ្ញុំទទួលបានថ្នាំពេទ្យមួយចំនួនពីអង្គការ (ICRC) អាយស៊ីអរស៊ី។ ប៉ុន្តែខ្ញុំពុំអាចយកថ្នាំទាំងនោះទៅព្យាបាលដល់ទាហានបានឡើយ។ ថ្នាំទាំងអស់នោះគឺ សំរាប់ព្យាបាលតែជនស៊ីវិលណា ដែលរងរបួសដោយសារសង្គ្រាមតែប៉ុណ្ណោះ។" គឺសឹងតែលែងមានវិញ្ញាណទៅហើយ។ ស្នាមញញឹមរបស់លោកអនុសេនីយឯក គឺគ្រាន់តែជាស្នាមញញឹមក្លែងក្លាយមួយប៉ុណ្ណោះ។

"ពួកយោធាអូស្ត្រាលីគេបានជួយដល់យើងច្រើនបង្គួរដែរ គឺមានរថយន្តសង្គ្រោះមួយគ្រឿង និងម៉ាស៊ីនភ្លើងមួយគ្រឿង។ រីឯថ្នាំពេទ្យ និងគ្រឿងបរិក្ខាពេទ្យមួយចំនួនធំ គឺមានតែនៅភ្នំពេញ។ មានតែអ្នកនៅទីនេះទេ ដែលជាអ្នកត្រូវការ ... នៅទីនេះគឺ មានការប្រយុទ្ធគ្នាជារៀងរាល់ថ្ងៃ។" "ចុះចំពោះអស់លោកឧត្តមសេនីយវិញ តើយ៉ាងណាដែរ?" ខ្ញុំសួរទៅលោកអនុសេនីយឯក។ "តើអស់លោកទាំងនោះបានយកចិត្តទុកដាក់ចំពោះទាហានដែលរងរបួសដែរឬទេ?" "សូមទោស!ខ្ញុំពុំអាចជំរាបរឿងនេះជូនបានទេ ..." លោកអនុសេនីយឯក ឆ្លើយទាំងបង្កប់នូវស្នាមញញឹមម្យ៉ាង។ ខ្ញុំបានបង្ខំឲ្យគាត់និយាយដែរ ប៉ុន្តែលោកអនុសេនីយឯកនៅតែពុំព្រមឆ្លើយដដែល ដោយទុកឲ្យខ្ញុំធ្វើការឆ្លុះបញ្ចាំងអំពីករណីនេះដោយខ្លួនឯងជាមួយនឹងសហការីទាំងអស់ដែលមានមុខនៅទីនោះ។ "គ្មានហេតុការណ៍អ្វីកើតឡើងនៅទីនេះទេ - អ្វីៗទាំងអស់ដែលកើតមានឡើង គឺដោយសារមកពីយើងក្រ និងខ្វះបច្ចេកទេស។" លោកអនុសេនីយ ឯកមានប្រសាសន៍អំពីរឿងទាំងរំជួលចិត្ត។ ខ្ញុំក៏មានបំណងថានឹងរំលឹកដល់លោកពេនដែរ អំពីរឿងបងប្អូនជីដូនមួយរបស់លោក គឺចង់ជួយដល់រូបលោកកុំឲ្យមានអារម្មណ៍ពិបាកនៅក្នុងចិត្តខ្លាំងពេក។

www.budinst.gov.kh www.elibraryofcambodia

**កម្ពុជាកំពុងមានវិធានការដើម្បីរកយុត្តិធម៌នៅក្នុងរឿងប្រល័យពូជសាសន៍ ដោយលោកហ្សុំ ចំរើន** ថ្ងៃទី ២១-៨-៩៥

ភ្នំពេញ--សំរាប់ប៉ុលពត គឺជាស្ថាបនិកនៅក្នុងការដែលបង្កើតឲ្យមានមូលវិវដ្តនៅ ក្នុងសង្គមដោយបានប្រែក្លាយទឹកដីកម្ពុជាទាំងមូលឲ្យក្រឡាប់ចាក់ និងក្លាយទៅជាវាលពិឃាតមួយដ៏សែនឃោរឃៅជាទីបំផុត។ ពេលវេលាបានកន្លងហួសទៅមែន។

ប៉ុន្តែនៅក្នុងសប្តាហ៍ក្រោយនេះ (ថ្ងៃទី២១-២២ ខែសីហា) នឹងមានអង្គប្រជុំមួយនៅក្នុងទីក្រុងភ្នំពេញដើម្បីពិនិត្យនៅលើច្បាប់មួយចំនួនសំរាប់ប្រើជាវិធានការក្នុងការកាត់ទោសថ្នាក់ដឹកនាំខ្មែរក្រហមមួយចំនួន។ នេះគឺជាលើកទីមួយហើយដែលចាប់តាំងពីឆ្នាំ១៩៧៩មកគឺ នៅពេលដែលមានកងទ័ពយៀកណាមបានចូលមកបណ្តេញពួកខ្មែរក្រហមឲ្យចេញពីរបបមួយ ដែលវាបានកាន់កាប់អស់រយៈពេលជាងបីឆ្នាំ និងដែលបានប្រព្រឹត្តនូវអំពើឃោរឃៅរកទីបំផុតគ្មាន។ ប៉ុលពត និងថ្នាក់ដឹកនាំជាន់ខ្ពស់របស់ខ្មែរក្រហមមួយចំនួននឹងត្រូវនាំខ្លួនឡើងតុលាការ អន្តរជាតិដើម្បីកាត់ទោសពីបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សលោកដូចគ្នា។ គ្មាននរណាម្នាក់អាចដឹងច្បាស់ថា ហានមនុស្សចំនួនប៉ុន្មាននាក់ ដែលបានស្លាប់នៅក្នុងរបបប៉ុលពតនោះទេ។ ប៉ុន្តែក៏គ្មានអ្វីដែលគួរឲ្យឆ្ងល់ដែរថា គឺរបបនេះហើយដែលបានប្រព្រឹត្តនូវអំពើដ៏សែនឃោរឃៅមួយ និងដែលពុំធ្លាប់មានសោះនៅលើលោកយើងនេះ។

យោងតាមការប៉ាន់ស្មានរបស់បណ្ឌិតសភា ហារី ឡូខាដ៍ គឺបានឲ្យដឹងថា នៅក្នុងចំណោមប្រជាជនចំនួន៨នាក់ គឺមានម្នាក់ត្រូវស្លាប់ដោយសារទង្វើរបស់បនប៉ុលពត គឺជាទង្វើមួយដែលពួកវាបានដាក់កម្ពុជាឲ្យនៅឯកោ។ កម្ពុជាបានផ្តាច់នូវទំនាក់ទំនងពីខាងក្រៅ។ ចំនួនអ្នកដែលស្លាប់ទាំងអស់ត្រូវបានគេលើកយកមកបង្ហាញនៅក្នុងស្ថិតិដ៏គួរឲ្យរន្ធត់មួយ គឺនៅក្នុងចន្លោះឆ្នាំ១៩៧៥ ខែមេសាមកទល់នឹង ឆ្នាំ១៩៧៩ ខែមករាមានមនុស្សចំនួនប្រមាណ៦០០.០០០នាក់បានស្លាប់នៅតាមមន្ទីរឃុំឃាំងនានា និងនៅមាន

www.budinst.gov.kh www.elibraryofcambodia

មួយចំនួនធំទៀតត្រូវបានសម្លាប់នៅលើទីពីឃាត។ តាមការសិក្សាដដែលនេះក៏បានឲ្យដឹងផងដែរថា មនុស្សមួយចំនួនធំត្រូវស្លាប់ដោយសារការអត់ឃ្លាន ដោយជម្ងឺឆ្លង និងដោយមកពីបានធ្វើការហួសកម្លាំង។ ចំណែកប៉ុលពត និងពួកបរិវាគិតតែពីរឿងការពារអំណាចតែមួយមុខប៉ុណ្ណោះ។

មកដល់ថ្ងៃនេះមនុស្សដែលជាអ្នកទទួលខុសត្រូវនៅក្នុងការបង្ហូរឈាមគ្នាពេញផ្ទៃប្រទេសនេះ គឺវាជិតដល់ពេលស្លាប់ហើយ។ យើងនៅតែពុំទាន់បាននាំខ្លួនរបស់វាមកកាត់ទោសបានទៀត។ បើនិយាយថាតើពេលនេះវាកំពុងតែរស់នៅកន្លែងណានោះ គឺគ្មាននរណាម្នាក់បានដឹងច្បាស់ថាវាកំពុងរស់នៅកន្លែងណាទេ។ នេះគឺជាសំដីរបស់លោកឧត្តមសេនីយញ៉ឹក ប៊ុនឆៃ អគ្គមេបញ្ជាការរងនៃក្រសួងការពារជាតិ។ ប៉ុល ពត និងដៃជើងរបស់ពួកវាឮថាកំពុងរស់នៅលើទឹកដីមួយ ស្ថិតនៅជិតទល់ដែនថៃក្នុងភូមិភាគនិរតី។ ពួកខ្មែរក្រហម និងថ្នាក់ដឹកនាំជាន់ខ្ពស់របស់វាបានឡើងកាន់អំណាចនៅក្នុងឆ្នាំ១៩៧៥។ សព្វថ្ងៃកំពុងកាន់កាប់ទឹកដីមួយចំនួនដែលមាននៅតាមបណ្តោយទល់ដែនថៃ គឺជាទីដែលសំបូរទៅដោយព្រៃក្រាស់មួយ ចាប់តាំងពីភូមិភាគខាងត្បូងដល់ខាងលិច។ សព្វថ្ងៃនេះនៅតាមទីកន្លែងដែលមានពួកវាត្រួតត្រា គឺហាក់ដូចជាពុំមានភាពរឹងប៉ឹងដូចពីមុនទៀតទេ។ អ្នកសង្កេតការណ៍យោធាម្នាក់បាននិយាយថា ចាប់តាំងពីរដ្ឋាភិបាលបានចាប់ផ្តើមធ្វើការវាយលុកទៅលើពួកវាសារជាថ្មីមក គេសង្កេតឃើញមានពួកខ្មែរក្រហមជាច្រើននាក់ត្រូវរងរបួស និងស្លាប់ជាបន្តបន្ទាប់។ ពួកវាហាក់ដូចជាកំពុងមានបញ្ហាកង្វះខាតឧបករណ៍យោធា និងគ្រាប់រំសេវ ហើយថែមទាំងមានអ្នករត់ចោលជួរជាច្រើនទៀតផង។

បើសិនជាថៃគោរពតាមពាក្យសន្យារបស់ខ្លួនពួកខ្មែរក្រហម គឺច្បាស់ជាមិនអាចយកទឹកដីថៃសំរាប់ធ្វើពាណិជ្ជកម្មបានទៀតទេ។ ពីព្រោះថៃបាននិយាយថា ខ្លួននឹងបំបាត់ចោលនូវការជួញដូរត្បូង និងឈើជាមួយខ្មែរក្រហម។ ដល់ពេលនោះភស្តុតាងនានាដើម្បីនឹងសំរេចឲ្យបានក្នុងការកាត់

www.budinst.gov.kh www.elibraryofcambodia

ទោសឧក្រិដ្ឋជននេះក៏ប្រហែលជាអាចដោះស្រាយបាននៅក្នុងពេលដំណាល គ្នាដែរ។ យោងតាមការកត់សំគាល់ ដែលគេទទួលបានពីការស៊ើបអង្កេតមួយ និងដែលបានធ្វើឡើងនៅក្នុងក្រុងភ្នំពេញដោយក្រុមស៊ើបអង្កេតរបស់សហ រដ្ឋអាមេរិកសំរាប់កម្មវិធីសម្ងាប់រង្គាលនៅកម្ពុជា គឺជាកម្មវិធីមួយដែលកំពុង ចាប់ផ្តើមធ្វើការស្រាវជ្រាវរកភស្តុតាងនៅទូទាំងពិភពលោកដើម្បីយកមក កាត់ទោសអ្នកដឹកនាំជាន់ខ្ពស់មួយចំនួនរបស់ពួកខ្មែរក្រហម។ នៅមានការ ស៊ើបអង្កេតមួយផ្សេងទៀត ដែលកំពុងធ្វើនៅអឺរ៉ុប អូស្ត្រាលី និងសហរដ្ឋ គឺគេបានខិតខំធ្វើការប្រមូលរកគ្រប់ភស្តុតាង និងដែលបានធ្វើសំណូមពរ ដល់គ្រប់រដ្ឋាភិបាលទាំងអស់ក្នុងពិភពលោកឲ្យជួយធ្វើសហប្រតិបត្តិការណ៍ ជាមួយនឹងកម្មវិធីនេះថែមទៀតផង។ ចាប់តាំងពីបានរៀបចំឡើងមកកម្ម វិធីនេះបានទទួលនូវដំណឹងស្រពិចស្រពិលមួយថា ដំណើរការនៅក្នុងកម្មវិធី កំពុងស្ថិតនៅក្នុងភាពរងារ ឬទាល់ច្រកដោយហេតុថា អ្នកស្រាវជ្រាវមានការ បារម្ភអំពីសាក្សីមួយចំនួនប្រហែលជាត្រូវបានស្លាប់បាត់ទៅហើយ ពីព្រោះ ករណីនេះបានផ្តើមឡើងតាំងពីម្ភៃឆ្នាំមុនមកម្ល៉េះ។ ការចងចាំទាំងប៉ុន្មាន ក៏ប្រហែលជាត្រូវភ្លេចអស់ រីឯឯកសារមួយចំនួនវិញក៏ប្រហែលជាត្រូវ បំផ្លាញខ្ទេចអស់ដែរ។ ប៉ុន្តែពួកគេក៏ហាក់ដូចជាមានការសប្បាយរីករាយ ណាស់ដែរ និងជួនកាល គឺហាក់ដូចជាមានការភ្ញាក់ផ្អើលទៅនឹងទំហំនៃ សំណុំរឿង - ដែលនៅក្នុងពេលថ្មីៗនេះ គេកំពុងតែធ្វើការស្រាវជ្រាវ។

លោកនាយកកម្មវិធី ស៊ីហ្សីភី (CGP) គឺលោកបណ្ឌិត ក្រេក អិតឆេ សិន បានមានប្រសាសន៍ថា មានសំណុំរឿងច្រើនណាស់ដែលយើងទើបបាន ទទួល ហើយរឿងមួយទៀតគឺ យើងមានការគាំទ្រយ៉ាងពេញទំហឹងពីថ្នាក់ ដឹកនាំជាន់ខ្ពស់នៃរាជរដ្ឋាភិបាលសព្វថ្ងៃនេះទៀតផង។ “យើងបានទទួល ជោគជ័យក្នុងថ្ងៃនេះ គឺជាជោគជ័យមួយដ៏អស្ចារ្យរបស់កម្មវិធីនេះ ដែលទើប មានអាយុពីរឆ្នាំ។” តាមប្រសាសន៍របស់លោកក្រេក។ ការស្រាវជ្រាវឡើងវិញ នៅតាមកន្លែងដែលពួកខ្មែរក្រហមវាទាំងឡាយហៅថា “មន្ទីរកសាង” និងនៅតាម

www.budinst.gov.kh www.elibraryofcambodia

ផ្នូរចម្រុះមួយចំនួន។ ឧទាហរណ៍ដូចជានៅលើកន្លែងមួយមានចំងាយប្រហែល៣០គីឡូម៉ែត្រប៉ុណ្ណោះពីភ្នំពេញគេបានរកឃើញភស្តុតាងថា មានមនុស្សស្លាប់រហូតដល់ទៅជាង ២០.០០០នាក់។ យោងតាមការឆ្លុះបញ្ចាំងរបស់លោកឡូខាដ៍បានឲ្យដឹងថាមន្ទីរកសាងទាំងអស់ ដែលមាននៅក្នុងកម្ពុជា គឺមានចំនួនរហូតដល់ទៅជាង១៥០កន្លែង។ លោកក្រេតបាននិយាយថា ជោគជ័យដែលកម្មវិធីនេះទទួលបាននឹងក្លាយទៅជាប្រផ្នូលមួយដែលអាចយកពួកខ្មែរក្រហមទៅកាត់ទោសបាននៅក្នុងពេលឆាប់ៗខាងមុខនេះ។ មិនតែប៉ុណ្ណោះតាមការសង្កេតរបស់គាត់ក៏បាន់ឲ្យដឹងដែរថា ការគាំទ្រពីសហគមអន្តរជាតិមកលើកម្មវិធីនេះក៏មានការកើនឡើងជាលំដាប់ដែរ។ “នៅពេលដែលខ្ញុំទើបនឹងចាប់ផ្តើមធ្វើការនៅក្នុងកម្មវិធីនេះ គឺកាលពីប្រាំឆ្នាំមុន(ធ្វើដោយខ្លួនឯង)ខ្ញុំតែងមានការពិបាកខ្លាំងណាស់ក្នុងការរកសញ្ញាអ្វីមួយពីខាងសហគមអន្តរជាតិ ដើម្បីឲ្យជួយដោះស្រាយបញ្ហានេះ។ ប៉ុន្តែស្ថានភាពនោះឥឡូវបានប្រែក្លាយទៅជាមានដំណើរការល្អប្រសើរទៅវិញ។ “ខ្ញុំមានជំនឿថា ការប្តេជ្ញាចិត្តដែលថានឹងដើរតាមគំ ទាំងអស់នេះហើយជាភស្តុតាង។” ជាសំដីរបស់លោកក្រេត។

តើហេតុអ្វីបានជាពិភពលោកចំណាយពេលយូរម្ល៉េះ នៅក្នុងរឿងនេះ? ពាក្យបណ្តឹងអំពីរឿងក្តីពីបទប្រល័យពូជសាសន៍នេះ គឺមានតែធ្វើរួចទៅហើយនៅ រវ៉ាន់ដា និងនៅអតីតយូហ្គូស្លាវី។ តើកម្ពុជានៅចាំដល់ណាទៀតទើបបានចាប់ផ្តើមធ្វើការកាត់ទោសនេះ? លោកក្រេតបានជូនជាយោបល់អំពីចម្លើយកុហកមួយចំនួនដែលទទួលបានពីតាមទីកន្លែងដែលមានពោរពេញទៅដោយការស្មុគស្មាញនៅក្នុងសង្គមវប្បធម៌ និងអ្វីដែលមានជាប្រវត្តិសាស្ត្រ។ ប៉ុន្តែជនជាប់ចោទទាំងប៉ុន្មានដែលមានបន្ទាប់ពីមានសង្គ្រាមត្រជាក់មួយបានចប់ទៅនិងអ្វីដែលពិតជាមានកើតឡើងមែននោះ វានឹងអាចបង្កើតបានជាទ្រង់ទ្រាយមួយសំរាប់យកទៅបង្ហាញនៅតុលាការដើម្បីនឹងធ្វើសេចក្តីកោះហៅប្រជុំបាន។ លោកនៅមានជំនឿដែរថា ជាការពិតណាស់ក្នុងករណី

www.budinst.gov.kh www.elibraryofcambodia

ុយនេះគឺ យើងត្រូវចំណាយប្រាក់អស់ច្រើនណាស់ ... វាមានការពិបាកខ្លាំង
រាស់ក្នុងការរករដ្ឋាភិបាលណា ដែលហ៊ានចំណាយលុយរាប់សិបលាន
'ល្លារសំរាប់កម្មវិធីរបៀបនេះ។

ដើម្បីជាពន្លឺក្នុងការគិតគូរដូចនេះ នៅមានរឿងចាំបាច់ច្រើនណាស់ ដែលយើងត្រូវធ្វើមុននឹងយើងយកមនុស្សម្នាក់ទៅកាត់ទោស។ យើងត្រូវមានភស្តុតាងជាក់ស្តែង។ នៅក្នុងច្បាប់អន្តរជាតិបានទាមទារឲ្យគ្រប់ការកាត់ទោសទាំងអស់ត្រូវធ្វើឡើងទៅតាមផ្លូវច្បាប់។ ជាក់ស្តែងកាលពីឆ្នាំ១៩៧៩ ប៉ុលពតត្រូវបានរដ្ឋាភិបាលក្នុងសម័យរដ្ឋកម្ពុជាកាត់ទោសប្រហារជីវិត។ ច្បាប់ដែលគេបានយកមកអនុវត្តនោះ គឺពុំមានលក្ខណៈដូចគ្នាទៅនឹងច្បាប់អន្តរជាតិដូចដែលមាននៅក្នុងបស្ចឹមប្រទេសនានានោះទេ។ ទោះបីជាមានគំនរឆ្អឹង និងលលាដ៏ក្បាលនៅលើទីលានពិឃាតជាភស្តុតាងស្រាប់នោះយ៉ាងណាក៏ដោយក៏ប៉ុន្តែការកាត់ទោសរបៀបនេះ គឺនៅពុំទាន់ត្រឹមត្រូវនៅឡើយ។ ទោះជាយ៉ាងណាក៏ដោយការប្រជុំនៅក្នុងសប្តាហ៍ក្រោយដែលនឹងធ្វើនៅក្នុងក្រុងភ្នំពេញនេះ គឺត្រូវឲ្យមានការកាត់បន្ថយនូវអ្វីដែលនាំមកនូវទោសភ័យដល់ការងារកាត់ទោសទាំងឡាយណានាពេលអនាគតដែលអនុវត្តទៅហើយតែពុំបានសំរេច។ ស្ថិតនៅក្រោមការចាត់ចែងមួយរបស់សកលវិទ្យាល័យយ៉េល នឹងមានគណៈប្រតិភូចូលរួមចំនួនប្រមាណជា៥០នាក់ ក្នុងនោះមានភាគីកម្ពុជា និងប្រទេសជាច្រើនទៀតក្នុងពិភពលោក ដើម្បីឲ្យចូលរួមមើលការកាត់ក្តីមួយពីបទប្រល័យពូជសាសន៍និងបទឧក្រិដ្ឋកម្មនានាដែលបានប្រឆាំងនឹងមនុស្សលោក។ គណៈប្រតិភូទាំងនោះនឹងត្រូវធ្វើការសិក្សាអំពីច្បាប់ ធ្វើការវិភាគរកផលចំណេញ និងខាតពីក្នុងច្បាប់និមួយៗ គឺធ្វើយ៉ាងណាឲ្យអាចយកច្បាប់នោះមកប្រើប្រាស់បានសមស្របសំរាប់កាត់ទោសប៉ុលពត និងថ្នាក់ដឹកនាំរបស់ពួកវា។ នៅក្នុងប្រទេសកម្ពុជា បន្ទាប់ពីភាពជូរចត់អស់ម្ភៃឆ្នាំកន្លងមកនេះគេសង្កេតឃើញមានការខំប្រឹងប្រែងធ្វើការដើម្បីនាំខ្លួនពួកខ្មែរក្រហមឡើងទៅកាត់ទោសនៅតុលាការ។

www.budinst.gov.kh www.elibraryofcambodia

## ផ្នែកទី៥

## វិជ្ជាជីវៈសារព័ត៌មាន និង វិជ្ជាជីវៈនិយម

## Journalism and Professionalism

បើទោះបីជាការសរសេរបទពណ៌នាមួយ ត្រូវបានគេទទួលស្គាល់ថា វាមានលក្ខណៈប្រកបទៅដោយការប្រឌិតញាណ(*as more creative*)ច្រើនជាងអត្ថបទព័ត៌មានធម្មតានោះយ៉ាងណាក៏ដោយ អ្នកសរសេរបទពណ៌នាម្នាក់នោះគឺនៅតែមានឈ្មោះថាជាអ្នកយកព័ត៌មានដដែល(*reporter*)។ ភារកិច្ចនេះគឺពិសេសណាស់ ហើយជួនកាលគឺមានសភាពធ្ងន់ធ្ងរជាងព័ត៌មានធម្មតាថែមទៀតផង។ នេះគឺជាការទទួលខុសត្រូវរបស់អ្នកសរសេរបទពណ៌នានោះ។ ក្នុងនាមជាអ្នកយកព័ត៌មាន ភារៈកិច្ចទទួលខុសត្រូវជាចំបង ដែលត្រូវធ្វើគឺ ចំពោះអ្នកអានរបស់យើង។ ការងាររបស់យើងគឺត្រូវកត់ ឬចម្លងព្រឹត្តិការណ៍និមួយៗឲ្យបានត្រឹមត្រូវ និងស្មោះត្រង់ជាទីបំផុត។ យើងត្រូវគោរពឲ្យបានអំពីសិទ្ធិមនុស្ស (*សិទ្ធិរបស់អ្នកអានជាពិសេស*) - ត្រូវឲ្យមានការគោរពសិទ្ធិចំពោះព័ត៌មានណា ដែលនាំឲ្យមានការប៉ះពាល់ដល់អាយុជីវិតរបស់អ្នកអាន និងត្រូវផ្តល់សិទ្ធិស្វ័យសំរេចដើម្បីឲ្យអ្នកអានហ៊ានទទួលខុសត្រូវលើអាយុជីវិតរបស់ខ្លួនដោយខ្លួនឯងតាមរយៈព័ត៌មាននោះ។

ក្នុងនាមជាអ្នកយកព័ត៌មានម៉្យាងរូបគឺ យើងត្រូវធ្វើការឲ្យបានច្រើនជាងការបដិសេធចោលនូវអ្វីដែលមានការវិនិច្ឆ័យរួចទុកជាមុន(*prejudices*)។ យើងត្រូវចាំថា មនុស្សខ្លះចង់ប្រើប្រាស់យើងដើម្បីស្វែងរកផលប្រយោជន៍ផ្ទាល់ខ្លួន។ ដូច្នេះយើងត្រូវបញ្ចេញសកម្មភាពរបស់យើងដើម្បីរកការពិតនោះឲ្យឃើញ។ ជួនកាលការងារនេះគឺ ហាក់ដូចជាមានការពិបាកណាស់។ ប៉ុន្តែបើយើងនាំគ្នាពិចារណាលើកត្តាមួយចំនួននៅខាងក្រោមនេះ យើងនឹងអាចរកឃើញនូវវិធីសាស្ត្រល្អៗ ដើម្បីជួយសំរួលដល់ការងារនេះបានជាមិនខាន។

### ភាពត្រឹមត្រូវ-ច្បាស់លាស់ (*Accuracy*)

ការសរសេរអត្ថបទពណ៌នាភាគច្រើនគឺ តែងមានលក្ខណៈវែងជាង

www.budinst.gov.kh www.elibraryofcambodia

អត្ថបទពត៌មានធម្មតា។ ដើម្បីសរសេរបទពណ៌នាមួយឲ្យបានល្អគឺ មានការងារច្រើនណាស់ដែលត្រូវធ្វើ និងមិនខុសគ្នាប៉ុន្មានពីការងារសរសេរអត្ថបទពត៌មានធម្មតាដែរ។ ចូរចាំថាការងាររបស់អ្នកយកពត៌មាន គឺត្រូវស្ថិតនៅក្រោមបរិយាកាសដ៏សែនតឹងរ៉ឹង(*severe space*)និងការកំណត់ឲ្យនូវពេលវេលា(*time limitations*)។

ដោយសារមកពីការងារនេះមានលក្ខណៈយ៉ាងដូច្នេះហើយ ទើបបានជាបណ្តាលឲ្យមានការបន្ថិតបន្ថំមួយដើម្បីឆ្ពោះទៅរកការពិត និងដែលត្រូវគេយកមកសរសេរឲ្យខាងតែបានដោយពុំមានការត្រួតពិនិត្យជាមុន។ ក៏ប៉ុន្តែដើម្បីនឹងឲ្យខ្លួនក្លាយទៅជាអ្នកយកពត៌មានដ៏មានថ្វីដៃម្នាក់ បើគ្រាន់តែធ្វើតាមករណីដូចខាងលើនេះគឺនៅពុំទាន់គ្រប់គ្រាន់នៅឡើយទេ។ ការដែលចាំបាច់ជាងនេះទៀតនោះគឺ យើងត្រូវចេះធ្វើការបញ្ជាក់ឲ្យបានច្បាស់លាស់អំពីពេលវេលា-ថ្ងៃ-ខែ-ទីកន្លែង និងឈ្មោះ...ឬអ្វីៗដែលសំខាន់ និងដែលមានទំនាក់ទំនងទៅនឹងព្រឹត្តិការណ៍នោះថែមទៀត។ កត្តានេះសំខាន់ណាស់ ពីព្រោះសារពត៌មានមួយដែលមានអ្នកអានជឿទុកចិត្តច្រើនជាងគេ គឺដោយសារមកពីសារពត៌មាននោះបានប្រកាន់ខ្ជាប់នូវភាពត្រឹមត្រូវឥតខ្ចោះ។ ហើយបើសិនជាសារពត៌មាននោះមានសំបូរទៅដោយអំពើខុសឆ្គងវិញ បើទោះបីជាការខុសឆ្គងនោះវាមានលក្ខណៈតូចតាចប៉ុណ្ណាក៏ដោយ ក៏អ្នកអានរបស់យើងលែងទុកចិត្តមកលើយើង ដែលជាអ្នកសរសេរពត៌មាននោះទៀតហើយ។ ភាពត្រឹមត្រូវ គឺជាភាពប្រាកដនិយមមួយ ដែលយើងទទួលបានតាមវិធីផ្ទៀងផ្ទាត់គ្នា។ ក្នុងន័យដ៏សាមញ្ញមួយ ការផ្ទៀងផ្ទាត់គ្នា គឺជាការពិនិត្យមើលឲ្យច្បាស់អំពីការសរសេរឈ្មោះ និងតួនាទីរបស់ប្រភពជាផ្លូវការណាមួយ, អង្គការដែលបុគ្គលនោះធ្វើការជាមួយ, អាសយដ្ឋាន ។ល។ និង ។ល។ ឲ្យបានច្បាស់លាស់។

**អ្នកចម្រាញ់ពត៌មាន** (*News Filters*)

គ្រប់បុគ្គលទាំងអស់ ដែលបាននិយាយប្រាប់យើងអំពីរឿងអ្វីមួយ

www.budinst.gov.kh www.elibraryofcambodia

គេមានមុខងារជាអ្នកចម្រាញ់ព័ត៌មាន។ ពីព្រោះព័ត៌មានទាំងអស់ គឺសុទ្ធតែត្រូវបានចម្រាញ់ជាមុន។ ចំពោះសាច់រឿងដែលអាចយកជាការបានរបស់បុគ្គលទីមួយ-ខ្លួនយើងផ្ទាល់បានឃើញព្រឹត្តិការណ៍នោះ-ជាមធ្យោបាយតែមួយគត់ក្នុងការសរសេរព័ត៌មាន ពីព្រោះសាក្សីដែលបានឃើញផ្ទាល់គឺរូបយើងនេះឯង ឬក៏ខ្លួនយើងនេះឯងដែលប្រហែលជាមានការពាក់ព័ន្ធជាមួយនឹងព្រឹត្តិការណ៍នោះដោយផ្ទាល់ផងក៏មិនដឹង។ បើសិនជាយើងពឹងផ្អែកទៅលើសាក្សីណាម្នាក់ផ្សេងទៀតដើម្បីប្រាប់យើងអំពីអ្វីដែលមានកើតឡើងនោះ គឺយើងប្រហែលជាត្រូវបាត់បង់នូវជំនឿទៅលើរឿងនោះក្នុងចំនួនណាមួយជាមិនខាន ហើយបើសាក្សីនោះយករឿងនេះទៅប្រាប់ដល់បុគ្គលណាម្នាក់ទៀត បន្ទាប់មកបុគ្គលម្នាក់នោះយករឿងដដែលហ្នឹងមកប្រាប់យើង។ បើមានតាមរបៀបដូច្នេះ គឺបានសេចក្ដីថា ខ្លួនយើងកំពុងស្ថិតនៅកាន់តែឆ្ងាយទៅៗពីរឿងនោះ។ ដូច្នេះជំនឿរបស់យើងទៅលើរឿងនោះក៏កាន់តែឃ្លាតឆ្ងាយ និងកាន់តែពុំសូវច្បាស់ថែមទៀត។ ធម្មតាមនុស្សតែងមានការភ្លេចភ្លាំង និងចូនកាលចូលចិត្តនិយាយបំផ្លើស។ ចំពោះករណីនេះគឺ ក្នុងការងារចម្រាញ់ព័ត៌មានមួយ បើមានបទអន្តរាគមន៍ច្រើនពេករវាងអ្នកយកព័ត៌មាន និងព្រឹត្តិការណ៍ដែលកើតឡើង គឺវានឹងបណ្ដាលឲ្យរឿងនោះត្រូវបាត់បង់ភាពទៀងត្រង់ខ្លះជាមិនខាន។ ជាការពិតណាស់មានពេលខ្លះគឺយើងត្រូវពឹងទៅលើអ្នកចម្រាញ់ព័ត៌មាន សំរាប់ធ្វើជាប្រភពព័ត៌មានឲ្យយើង។ យើងអាចកាត់បន្ថយនូវគុណវិបត្តិក្នុង ការផ្ដល់ព័ត៌មានខុសនេះបានដោយត្រូវធ្វើតាមបច្ចេកទេសមួយចំនួននៅខាងក្រោម។

**យកការសន្មត់របស់បុគ្គលណាមួយទៅធ្វើជាព័ត៌មាន** *(Attribution)*

ការខិតទៅកាន់តែឆ្ងាយពីការតាមសង្កេតមើល ដោយផ្ទាល់របស់អ្នកយកព័ត៌មានម្នាក់ គឺតែងធ្វើឲ្យអ្នកយកព័ត៌មានរូបនោះមានការមន្ទិលសង្ស័យកាន់តែ ច្រើនឡើងទៅលើភាពត្រឹមត្រូវ ដែលមាននៅត្រង់ផ្នែកណាមួយនៃព័ត៌មាន។ ការធ្វើឲ្យបានត្រឹមត្រូវច្បាស់លាស់ និងឲ្យងាយយល់បានដោយ

www.budinst.gov.kh www.elibraryofcambodia

ផ្ទាល់ គឺវាមានការពិបាកគ្រប់គ្រាន់ណាស់ទៅហើយ។ ប៉ុន្តែបន្ទាប់មកទៀត បើពត៌មាននោះបានត្រូវគេចម្រាញ់ម្តង ឬពីរដងរួចទៅហើយ។ គឺមានតែអ្នកយកពត៌មានផ្តេសផ្តាសជាងគេប៉ុណ្ណោះ ដែលហ៊ានប្រថុយយកកេរ្តិ៍ឈ្មោះនៃវិជ្ជាជីវៈរបស់ខ្លួនទៅប្តូរយកអ្វីដែលខ្លួនយល់ថាជាការត្រឹមត្រូវនោះ។ ដើម្បីនឹងធានាឲ្យអ្នកអានអាចយល់អំពីការពន្យល់នៃដំណើររឿងទីពីរ និងទីបីថា បានយោងតាមការសង្កេតមើលដោយផ្ទាល់គឺ យើងនៅមានបច្ចេកទេសមួយទៀត ដែលគេហៅថា ការសន្មត់របស់បុគ្គលណាម្នាក់ ដែលជាអ្នកនិយាយរឿងនោះប្រាប់ដល់យើង។ វិធីសាស្ត្រនេះ គឺយើងត្រូវធ្វើឲ្យអ្នកអានឆាប់យល់ ឬឆាប់ចាប់បានថា យើងពុំបានធ្វើសេចក្តីរាយការណ៍អំពីអ្វីមួយដោយយោងតាមការពិតទាំងស្រុងទាំងអស់នោះទេ។ ប៉ុន្តែ គឺយើងបានធ្វើសេចក្តីរាយការណ៍តែអំពីអ្វីដែលបុគ្គលនោះបាននិយាយ និងដែលបុគ្គលនោះហ៊ានសន្មត់ថា អ្វីដែលគាត់បាននិយាយនោះ គឺជាការពិត។

ខាងក្រោមនេះ គឺយើងអាចចងភ្ជាប់វិជ្ជាជីវៈរបស់យើងទៅនឹងអំណាចរបស់ប្រភពនៃពត៌មាន-បើមានបុគ្គលម្នាក់មានទំនាក់ទំនងជិតស្និតទៅនឹងករណីមួយ ហើយវិជ្ជាជីវៈរបស់គាត់ក៏មានការទាក់ទងទៅនឹងករណីនោះដែរ។ ដូច្នេះដើម្បីអាចរក្សានូវសេចក្តីសុខបាន គឺយើងមិនត្រូវសន្និដ្ឋានថាអ្វីដែលគាត់និយាយប្រាប់យើងនោះ គឺជាការពិតឲ្យសោះ។ ម៉្យាងទៀតបើបុគ្គលនោះគ្មានរឿងពាក់ព័ន្ធផ្ទាល់ជាមួយនឹងករណីនោះទេ គឺបានសេចក្តីថាបុគ្គលនោះក៏គ្មានសិទ្ធិអំណាចអ្វីទាំងអស់ដែរ។ យើងច្បាស់ជាមានការមន្ទិលសង្ស័យជាមិនខាន អំពីអ្វីដែលគាត់បាននិយាយប្រាប់យើងនោះ។ ចំពោះករណីនេះគឺ យើងត្រូវពិនិត្យមើលឲ្យបានល្អិតល្អន់ជាមុនសិនទៅលើអ្វី ដែលបុគ្គលនោះបាននិយាយ។ ក៏ប៉ុន្តែក្នុងនាមជាអ្នកយកពត៌មាន គឺយើងនៅមានភារៈកិច្ចទទួលខុសត្រូវក្នុងការផ្សព្វផ្សាយអំពីរឿង ដែលយើងត្រូវសរសេរនោះផងដែរ។ បើសិនជាដូច្នេះមែន គឺយើងនឹងមានការងាយស្រួលក្នុងការស្វែងរកភាពដែលពោរពេញទៅដោយការនិយមចូលចិត្ត ឬការធានាអះអាង

www.budinst.gov.kh www.elibraryofcambodia

ណាមួយ ពីបុគ្គលណាម្នាក់ បើទោះបីជាបុគ្គលនោះមានសិទ្ធិអំណាច ឬគ្មានក៏ដោយ។

**សេចក្តីសង្ខេប:**

១- សេចក្តីថ្លែងការណ៍នោះ គឺត្រូវបានសន្មត់ឲ្យទៅចំពោះបុគ្គលដែលជាអ្នកប្រព្រឹត្ត ឬអ្នកដែលបានថ្លែង។

២- ពត៌មានអំពីព្រឹត្តិការណ៍អ្វីមួយ ដែលអ្នកសរសេរពត៌មានពុំបានធ្វើជាសាក្សី ព្រឹត្តិការណ៍នោះគឺ ត្រូវបានសន្មត់ថា វាចេញមកពីប្រភពពត៌មាន។

៣- លើកលែងតែពត៌មាននោះជាពត៌មានធម្មតា បើមិនដូច្នេះទេ អ្នកត្រូវខំប្រឹងសាកល្បងធ្វើយ៉ាងណា ដើម្បីធ្វើឲ្យការផ្តល់ពត៌មានដែលអ្នកមិនបានឃើញផ្ទាល់នឹងភ្នែកនោះឲ្យបានពិស្តារ។

៤- ការផ្តល់ពត៌មានតាមការសន្មត់ពាក្យសំដី គឺជួយធ្វើឲ្យអ្នកអានមានការពិចារណាអំពីពត៌មាននោះថា តើគួរជឿដែរឬទេ?

**ប្រភេទនៃការផ្តល់ពត៌មានតាមការសន្មត់** *(Types of Attribution)*

បន្ទាប់ពីយើងបានធ្វើការបង្ហាញខ្លួនប្រាប់គេថា យើងជាអ្នកយកសារពត៌មានរួចមក គេក៏សុខចិត្តយល់ព្រមនិយាយប្រាប់យើងវិញ អំពីអ្វីៗដែលគេបានដឹង។ ដូច្នេះគឺបានសេចក្តីថា យើងអាចធ្វើការផ្សព្វផ្សាយអំពីពត៌មាននោះបានហើយ។ យើងត្រូវបញ្ជាក់ប្រាប់ដល់អ្នកអានឲ្យយល់ផងដែរថា នេះគឺជាពត៌មានមួយដែលយើងបានសន្មត់យកតាមពាក្យសំដីរបស់បុគ្គលម្នាក់ដែលសុខចិត្តយល់ព្រមនិយាយប្រាប់យើងអំពីរឿងនោះ។ មានពេលខ្លះបុគ្គលនោះសុខចិត្តនិយាយប្រាប់យើងមែន ប៉ុន្តែដើម្បីការពារខ្លួន គាត់ច្បាស់ជាមិនអនុញ្ញាតិឲ្យយើងធ្វើការផ្សព្វផ្សាយពត៌មាននោះថាវាជាការសន្មត់របស់គាត់ឡើយ។ ទាំងអស់នេះហើយគឺសុទ្ធសឹងជាបញ្ហាដែលយើងត្រូវតែនាំគ្នាពិនិត្យមើល ឡើងវិញឲ្យបានច្បាស់លាស់នៅត្រង់ចំណុចដែលមានស្តីអំពីប្រភពនៃពត៌មាន។ ខាងក្រោមនេះមានការណែនាំមួយចំនួនដែលអាចជួយដោះស្រាយនូវរាល់បញ្ហាពិបាកដូចខាងលើនេះបាន។

www.budinst.gov.kh www.elibraryofcambodia

សេចក្តីណែនាំខាងក្រោមនេះ គឺបានបង្កើតឡើងដោយឯកឧត្តមរដ្ឋលេខាធិការទទួលបន្ទុកផ្នែកសារព័ត៌មានរបស់លោកហ្វ៊ែរដឺ អតីតប្រធានាធិបតីសហរដ្ឋអាមេរិក។

- នៅលើឯកសារ (*On the Record*)៖ គ្រប់សេចក្តីថ្លែងការណ៍ទាំងអស់ គឺយើងអាចដកស្រង់យកពាក្យសំដី ដែលគេបានថ្លែងចេញមកនោះមកប្រើនៅក្នុងអត្ថបទរបស់យើងក៏បាន ឬក៏យកទៅធ្វើជាព័ត៌មានដោយសន្មត់យកពាក្យសំដីរបស់បុគ្គល ដែលជាអ្នកធ្វើសេចក្តីថ្លែងការណ៍នោះមកប្រើក៏បាន។
- ដោយលាក់មុខ (*On the Background*)៖ គ្រប់សេចក្តីថ្លែងការណ៍ទាំងអស់ គឺយើងអាចដកស្រង់យកពាក្យសំដី ដែលគេបានថ្លែងចេញនោះមកប្រើនៅក្នុងអត្ថបទបាន។ ប៉ុន្តែយើងមិនអាចធ្វើវាឲ្យទៅជាព័ត៌មានតាមការសន្មត់យកឈ្មោះ ឬតួនាទីរបស់បុគ្គល ដែលជាអ្នកធ្វើសេចក្តីថ្លែងការណ៍នោះមកប្រើបានទេ។ ប្រភេទព័ត៌មានដោយសន្មត់ដូច្នេះ ចាំបាច់គឺយើងត្រូវសរសេរប្រាប់ដល់អ្នកអានឲ្យបានដឹងជាមុនសិន។ ដូចជាត្រូវសរសេរដូច្នេះថា *អ្នកនាំពាក្យរបស់រដ្ឋាភិបាលម្នាក់ ឬតាមសំដីរបស់មន្ត្រីជាន់ខ្ពស់នៃរដ្ឋការសហព្រឹជាជាតិជាដើម... បាននិយាយឲ្យដឹងថា...*។
- ដោយលាក់មុខខ្លាំងមែនទែន (*On the Deep Background*)៖ អ្វីទាំងអស់ដែលគេបាននិយាយចេញមកហើយ តែយើងមិនអាចយកវាមកប្រើនៅក្នុងអត្ថបទ ឬមិនអាចយកវាទៅប្រើជាប្រភេទព័ត៌មានដោយសន្មត់បាន។ ដូច្នេះអ្នកយកព័ត៌មានត្រូវតែសរសេរដោយខ្លួនឯង ហើយត្រូវធ្វើព័ត៌មាននោះដោយសន្មត់ថា ជារបស់ប្រភពគួរជាទីទុកចិត្តណាមួយ ឬប្រភពណាមួយដែលស្ថិតនៅជិតព្រឹត្តិការណ៍នោះជាងគេ។ ប៉ុន្តែអ្នកត្រូវប្រយ័ត្ន--ចំពោះប្រភព ដែលចូលចិត្តធ្វើការទទូចចង់ផ្តល់នូវព័ត៌មានជាប្រភេទសន្មត់ពាក្យសំដីនេះ។ ពីព្រោះគេចង់ប្រើប្រាស់អ្នក

www.budinst.gov.kh www.elibraryofcambodia

ដើម្បីឲ្យជួយធ្វើការផ្សព្វផ្សាយនូវព័ត៌មានមួយតែអ្នកពុំបានដឹងខ្លួន ឬចង់ធ្វើឲ្យព័ត៌មាននោះ លេចឮដល់សាធារណៈជន ដើម្បីខ្លួនបានចំណេញនូវផលប្រយោជន៍អ្វីមួយ។ ទោះជាយ៉ាងណាក៏ដោយករណីនេះ គឺស្ថិតនៅលើជំនឿរបស់អ្នក ដែលមានទៅលើប្រភពព័ត៌មាននោះ ដោយយកភាពទៀងត្រង់របស់គេមកធ្វើជាទីសំអាង។ បើមិនដូច្នេះទេ រូបអ្នកដែលជាអ្នកយកព័ត៌មាន និងអង្គភាពសារព័ត៌មានរបស់អ្នកច្បាស់ជាមិនអាចគេចផុតពីគ្រោះថ្នាក់មួយ ដែលនាំឲ្យមានការអាប់ឱន ដល់កេរ្តិ៍ឈ្មោះនោះបានឡើយ។

- ក្រៅផ្លូវការ (*Off the Record*)៖ ព័ត៌មានដែលទទួលបានក្រៅផ្លូវការ គឺជាព័ត៌មានមួយ ដែលគ្រាន់តែចង់ឲ្យអ្នកសារព័ត៌មានបានដឹងតែប៉ុណ្ណោះ។ ដូច្នេះអ្នកមិនអាចយកព័ត៌មាននេះទៅធ្វើការផ្សព្វផ្សាយ ឬធ្វើឲ្យលេចឮជាសាធារណៈបានទេ។ ដើម្បីការពារនូវឯករាជភាពព័ត៌មានប្រភេទនេះ គឺមិនត្រូវយកទៅនិយាយប្រាប់ដល់អ្នកទីបីដែរ។

**ចំណាំ៖** ចូរអ្នកធ្វើការបង្ហាញខ្លួនឲ្យបានច្បាស់លាស់ជាមុនសិនទៅមុនពេលអ្នកចាប់ផ្តើមសម្ភាសន៍យកព័ត៌មានណាមួយដែលអ្នកចង់សរសេរនោះ។ ពីព្រោះមានពេលខ្លះប្រភពព័ត៌មានរបស់យើងគាត់មានព័ត៌មានល្អៗច្រើនណាស់ប្រាប់ដល់យើង។ ប៉ុន្តែបន្ទាប់មកស្រាប់តែគាត់និយាយថានេះគឺជាព័ត៌មានក្រៅផ្លូវការទេ។ ចំពោះករណីដូចនេះ គឺដូចជាពុំយុត្តិធម៌សោះសំរាប់អ្នកយកព័ត៌មាន ដែលគ្នាកំពុងខិតខំបំពេញការងារសំរាប់សាធារណៈជនទូទៅ។

**ករណីមួយចំនួនដែលនាំឱ្យមានការផ្តាំខុស**

អ្នកយកព័ត៌មានដែលសំបូរទៅដោយបទពិសោធន៍ គេតែងតែចងចាំជានិច្ចថា ខ្លួនគេមិនអាចគេចផុតពីការខុសឆ្គងម្តងម្កាលបានឡើយ។ ជួនកាលគឺបណ្តាលមកពី៖

១_ ជាកំហុសរបស់ប្រភពព័ត៌មាន។

២_ ប្រភពនៃព័ត៌មាននោះជាអ្នកមានសិទ្ធិអំណាចមែន តែគាត់ពុំបានដឹង

www.budinst.gov.kh www.elibraryofcambodia

នូវរឿងពិត។

៣_ អាជ្ញាធរខ្លះប្រហែលជាមានបំណងចង់និយាយបង្វែងដាន, នាំអ្នកទៅរកផ្លូវខុស និងមានការភាន់ច្រឡំក្នុងការផ្តល់ព័ត៌មាន។

៤_ ទោះបីជាមានការផ្ទៀងផ្ទាត់ពិនិត្យពិច័យយ៉ាងណាក៏ដោយ ក៏ព័ត៌មាននោះនៅមានការខុសឆ្គងខ្លះជាមិនខាន។ ជួនកាលបើទោះបីជាព័ត៌មាននោះបានទទួលមកពីការស្រាវជ្រាវនៅតាមបណ្ណាល័យក៏ដោយ។ ប៉ុន្តែការខុសឆ្គងគឺ នៅតែមានដដែល ពីព្រោះមកពីឡាប់ដើមនោះប្រហែលជាមានកំហុសស្រាប់។ មានទិន្នន័យ និងឯកសារមួយចំនួនបានភាពច្របូកច្របល់ដោយសារមកពីមានគេមកមុនយើង។

**ព័ត៌មានដែលពុំមានភាពត្រួតពិនិត្យ** *(Non Verifiable Information)*

មានព័ត៌មានខ្លះ គឺយើងមិនអាចធ្វើការពិនិត្យមើលរកខុស ឬត្រូវបានឡើយ។ ឧទាហរណ៍ដូចជាព័ត៌មានដែលស្តីអំពីទស្សនៈយោបល់ណាមួយ ឬអំពីគំនិតដ៏ទូលំទូលាយណាមួយ។ល។ ដូច្នេះអ្នកយកព័ត៌មានគឺត្រូវតែសរសេរព័ត៌មាននោះដោយសន្មត់យកតាមសេចក្តីថ្លែងការណ៍របស់បុគ្គលដែលជាអ្នកនិយាយនូវរឿងនោះតែម្តង។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយនៅក្នុងពេលដែលកំពុងធ្វើសម្ភាសន៍អ្នកយកព័ត៌មានត្រូវឆ្លៀតឱកាសធ្វើការស្វែងយល់អំពីទស្សនៈ ឬមតិយោបល់ណាមួយនោះឲ្យបាន ដោយយោងតាមការប្រើប្រាស់សំណួរមួយចំនួនដូចជាៈ "*តើអ្នកមានអ្វីជាភស្តុតាង?*" ឬ "*តើមកពីហេតុអ្វីបានជាអ្នកហ៊ាននិយាយអញ្ចឹង?*"ជាដើម។ល។ សំណួរទាំងនេះ គឺធ្វើឲ្យបុគ្គលដែលអ្នកកំពុងសម្ភាសន៍ជាមួយចាប់ផ្តើមធ្វើយុត្តិកម្ម គឺធ្វើការបង្ហាញអំពីភាពសមហេតុសមផល ឬចាប់ផ្តើមពន្យល់ អំពីទស្សនៈយោបល់របស់គាត់ប្រាប់ដល់យើងជាមិនខាន។ បន្ទាប់ពីពេលដែលយើងបានបោះពុម្ពផ្សាយ និងបានពន្យល់នៅក្នុងព័ត៌មាននោះ ដោយសន្មត់ថាអ្វីទាំងអស់នេះគឺជាពាក្យសំដីរបស់បុគ្គលនោះ។ ធ្វើដូច្នេះគឺយើងបានផ្តល់នូវឱកាសឲ្យអ្នកអានអាចធ្វើការពិចារណាបានថា តើទស្សនៈយោបល់នោះ

www.budinst.gov.kh www.elibraryofcambodia

សមហេតុសមផលដែរ ឬអត់?

**តុល្យភាព និង យុត្តិធម៌** (*Balance and Fairness*)

មានពាក្យចាស់បូរាណមួយ ដែលគេតែងនាំគ្នានិយាយតៗគ្នារហូតមកដល់សព្វថ្ងៃថា"*ទាល់តែមានទាំងសងខាងទើបវាមានរឿង*"។ តុល្យភាពគឺជាវិធីសាស្ត្រនៃការពិពណ៌នាអំពីអ្វីមួយ ដែលនៅក្នុងនោះ អ្នកយកពត៌មានត្រូវរកមើលឲ្យគ្រប់ជ្រុងជ្រោយអំពីមតិយោបល់ណាដែលផ្ទុយគ្នា ឬដែលមានជាយថាទស្សន៍ទៅនឹងរឿងមួយនោះ។ ដូចគ្នាដែរអ្នកយកពត៌មាននៅមានភារៈកិច្ចទទួលខុសត្រូវមួយទៀតគឺធ្វើយ៉ាងណាឲ្យមានតុល្យភាពក្នុងការបង្ហាញអំពីទស្សនៈពីរផ្ទុយគ្នា និងត្រូវធ្វើយ៉ាងណាដើម្បីឲ្យអ្នកអានអាចធ្វើការវិនិច្ឆ័យរកខុសត្រូវបានផងថា តើទស្សនៈណាមួយ ដែលអាចយកបកធ្វើជាការបាន។

អ្វីៗដែលមានការទាក់ទងជាមួយនឹងតុល្យភាព គឺសុទ្ធតែជាទស្សនាទាននៃភាពយុត្តិធម៌។ ភាពយុត្តិធម៌ ដែលមានពិពណ៌នានៅក្នុងនេះ គឺបានដកស្រង់ចេញពី *The Washington Post's* Desk Book on Style ។ គេបាននិយាយថា "អ្នកយកពត៌មាន និងនិពន្ធនាយករបស់សារពត៌មានឌឺប៉ុស្ដិ៍ទាំងអស់គ្នា គប្បីប្ដេជ្ញាធ្វើឲ្យបានយុត្តិធម៌..."។ ភាពយុត្តិធម៌គឺអាចកើតឡើងតាមការអនុវត្តន៍ ដែលមានជាគំរូដូចមានលើកនៅខាងក្រោមនេះស្រាប់។

- ពុំមានយុត្តិធម៌សោះឡើយ បើសិនជារឿងនោះពុំមាននិយាយនូវការពិតគឺអំពីអ្វីដែលសំខាន់ៗ ឬដែលចាំបាច់។ ដូច្នេះយុត្តិធម៌ គឺត្រូវហានរួបទៅដោយភាពគ្មានខ្វះចន្លោះ។
- ពុំមានយុត្តិធម៌សោះឡើយ បើសិនជារឿងនោះមាននិយាយអំពីអ្វី ដែលគ្មានទំនាក់ទំនងទៅនឹងពត៌មាននោះសោះ។ ដូច្នេះយុត្តិធម៌គឺ ត្រូវហានរួបទៅដោយភាពទាក់ទងគ្នាទៅវិញទៅមកជាចាំបាច់។
- ពុំមានយុត្តិធម៌សោះឡើយ បើសិនជារឿងនោះវានាំអ្នកអានឲ្យឆ្ពោះទៅ

www.budinst.gov.kh www.elibraryofcambodia

រកផ្លូវខុស ឬធ្វើឲ្យមានការភាន់ច្រឡំ ទោះដោយចេតនាក្តី ឬអចេតនាក្តី។ ដូច្នេះយុត្តិធម៌ គឺត្រូវបានរួមទៅដោយភាពស្មោះត្រង់ - ភាពប្រាកដប្រជាជាមួយអ្នកអាន។

- ពុំមានយុត្តិធម៌សោះឡើយ បើសិនជាអ្នកយកពត៌មានធ្វើការលាក់លៀមនូវភាពលំអៀង ឬភាពរំជួលចិត្តរបស់ខ្លួននៅពីក្រោយពាក្យប្រៀបធៀបណាមួយក្នុងគោលបំណង ដើម្បីវាយតម្លៃអំពីអ្វីមួយដែលមានដូចជាពាក្យ "បដិសេធ, ថ្វីបើ..., ទទួលខ្លួន... និង ...យ៉ាងធំសម្បើម។ល។" (*'refused', 'despite', 'admit' and 'massive'*) ដូច្នេះយុត្តិធម៌គឺត្រូវមានរួមទៅដោយភាពត្រឹមត្រូវជាងការបង្អួត។

**កម្មវិស័យភាព ភាពដែលសំរេចតាមគោលបំណង** (*Objectivity*)

កម្មវិស័យភាពទើបនឹងបានក្លាយទៅជាប្រធានបទមួយ ដែលមានការពិបាកជាទីបំផុតសំរាប់អ្នកសារពត៌មានជាទូទៅ ពីព្រោះវាហាក់ដូចជាមានបញ្ហាបាយពិចណាស់ ដើម្បីអាចសំរេចបានតាមទិសដៅ ឬដើម្បីទាមទារឲ្យបានទៅដល់គោលដៅនោះ។ មនុស្សយើងម្នាក់ៗអាចស្គាល់ពិភពលោកបានតាមរបៈវប្បធម៌ ដែលយើងម្នាក់ៗទទួលបានតាមការសិក្សាអប់រំដែលយើងគ្រប់ៗគ្នាបានក្រេបជញ្ជក់ និងតាមបទពិសោធន៍នៅក្នុងភាគជីវិតដែលយើងធ្លាប់បានឆ្លងកាត់។ អ្វីៗទាំងអស់នេះហើយដែលធ្វើឲ្យទស្សនៈយោបល់របស់យើងមានអនុភាព។ បន្ទាប់ពីនោះបកចូរចាំថា អ្នកសារពត៌មានក៏ជាមនុស្សលោកដែរ។ យើងទាំងអស់គ្នា គឺតែងតែមានជំនឿដូចគ្នាថា អ្វីដែល "*ត្រូវ*" ឬ"*ខុស*" ឬ"*ល្អ*" ឬ"*អាក្រក់*"។ ប៉ុន្តែដើម្បីអាចសំរេចបានទៅតាមទិសដៅ គឺយើងត្រូវតែបញ្ឈប់ជាបណ្តោះអាសន្ននូវអ្វីដែលយើងធ្លាប់ជឿ ហើយចូរសាកល្បងធ្វើកុំឲ្យជំនឿទាំងនោះជះឥទ្ធិពលមកលើអត្ថបទរឿងរបស់យើងបានឲ្យសោះ។ យើងគួរព្យាយាមធ្វើយ៉ាងណាដើម្បីព្យួរនូវទស្សនៈយោបល់ដែលយើងធ្លាប់មានរួចហើយទុកនៅមួយកន្លែងសិន។ បើធ្វើដូច្នេះបាន គឺយ៉ាងហោចណាស់ ក៏យើងអាចសំរេចនូវ

www.budinst.gov.kh www.elibraryofcambodia

គោលបំណងរបស់យើងបានពាក់កណ្តាលដែរ។

ចូរចាំថា យើងមានវប្បធម៌ខុសគ្នា។ ដូច្នេះការគិតគូរពិចារណាក៏មានផ្សេងៗពីគ្នាដែរ។ សូម្បីតែនៅក្នុងរង្វង់វប្បធម៌តែមួយក៏ដោយក៏នៅតែមានទស្សនៈយោបល់ និងជំនឿមួយចំនួនមិនដូចគ្នាដែរ។ មានទស្សនៈមួយចំនួនត្រូវបានគេផ្លាស់ប្តូរដូចអ្វីដែលជារឿងពិតនៅក្នុងអតីតកាល (ដែលគេមានជំនឿថា ពិភពលោកមានរាងសំប៉ែតនេះជាឧទាហរណ៍ស្រាប់ ឥឡូវក៏បានក្លាយទៅជារឿងផ្តេសផ្តាស់ទៅវិញ)។ អ្វីដែលគេយល់ថាជារឿងផ្តេសផ្តាស់នោះ គឺដូចជាកាលពី១០០ឆ្នាំមុនគេបានរកឃើញថា (ជម្ងឺគឺបណ្តាលមកពីពពួកសត្វល្អិតម៉្យាង ដែលសព្វថ្ងៃនេះគេហៅថាមេរោគនោះ។) មកដល់សព្វថ្ងៃនេះ ទើបគេអាចរកឃើញនូវភស្តុតាងមកបញ្ជាក់ថា នេះជាការពិត។ អ្នកសារពត៌មានដែលមានថ្វីដៃ គឺគេមិនយកវិន័យចាស់ មិនយកអំណាច និងស្ថាប័នមកប្រើជាអភ័យឯកសិទ្ធិ ដើម្បីសួរនាំយករឿងស្មានៗមកនិយាយថា ជារឿងត្រឹមត្រូវបានទេ។ ការសួរនាំដើម្បីស៊ើបអង្កេតប្រហែលជាអាចជួយធ្វើឲ្យមានភាពត្រឹមត្រូវបាន។ ប៉ុន្តែបើការសួរនាំរបស់យើងនោះគ្មានរបៀប យើងក៏មិនអាចសំរេចនូវទិសដៅនោះបានឡើយ ពីព្រោះមកពីយើងបានសន្មត់រឿងនោះរួចទៅហើយថា វាជាការពិត។

www.budinst.gov.kh www.elibraryofcambodia

## អំពីការស្រាវជ្រាវ
## (Research)

**ប្រភពព័ត៌មាន** (*Sources*)

ពាក្យចាស់បូរាណមួយឃ្លាបានពោលថា វិជ្ជាជីវៈសារព័ត៌មានគឺជាការបង្ហាញនូវភស្តុតាងដើម្បីបញ្ជាក់អំពីការពិត។ នោះគឺបានសេចក្តីថា *អ្នកសារព័ត៌មានម្នាក់ ដែលអាចមានថ្វីដៃល្អ ក៏ដោយសារតែគាត់មានប្រភពព័ត៌មានដ៏ល្អៗដែរ !* ប្រភពនៃព័ត៌មានទាំងនោះគឺ មានតាំងពីអ្នករដ្ឋការ អ្នកនាំពាក្យ អ្នកដែលមានវត្តមាននៅក្នុងព្រឹត្តិការណ៍នានា ឯកសារ កំណត់ត្រា សារព័ត៌មាន ទស្សនាវដ្តី និងសៀវភៅ។ល។

**ចូរចងចាំថា** - មនុស្សគ្រប់រូបដែលអ្នកបានជួបនិយាយជាមួយពួកគេទាំងនោះ គឺសុទ្ធតែជាប្រភពព័ត៌មានមួយ ដែលយើងអាចយកជាការបាន។ គឺមានតាំងពីបុគ្គលដែលបានឲ្យតម្រុយជាសញ្ញានៃរឿងមួយ ឬបុគ្គលដែលមានឥទ្ធិពលអាចនិយាយអំពីរឿងសំខាន់ណាមួយជាដើម។ល។ នៅមានប្រភពផ្សេងៗទៀតដែលអាចជួយធ្វើជាជំនួយសំរាប់ផ្ទៀងផ្ទាត់ព័ត៌មាន ឬជួយផ្តល់ជាព័ត៌មានបន្ថែមទៅលើរឿងដែលសំខាន់ៗតាមជំនាញ។ ទោះបីជាបុគ្គលនោះមិនសំខាន់យ៉ាងណាក៏ដោយ - ឧទាហរណ៍ថា បុគ្គលនោះគ្រាន់តែជាលេខា ឬជាស្មៀនជាដើម ក៏គាត់នៅតែជាប្រភពព័ត៌មានដ៏សំខាន់មួយដែរ។ ការចងសម្ព័ន្ធមិត្តជាមួយនឹងលេខាម្នាក់ គឺនាងប្រហែលជានឹងអាចជួយនាំពាក្យរបស់អ្នកទៅប្រាប់ដល់ចៅហ្វាយនាយរបស់នាង ឬក៏នាងអាចប្រាប់ដល់អ្នក អំពីទីកន្លែងដែលអ្នកអាចចូលទៅជួបជាមួយចៅហ្វាយនាយរបស់នាងបានតាមការឲ្យដំណឹងមុនដោយប្រញាប់ប្រញាល់បំផុត។

ប្រភព ព័ត៌មានអាចចែកចេញជាប្រភេទផ្សេងៗពីគឺ៖

**ប្រភពព័ត៌មានជាមនុស្ស** (*Human Sources*)

មនុស្សម្នាក់ដែលសំបូរទៅដោយព័ត៌មានដែលអ្នកសារព័ត៌មានម្នាក់កំពុងចង់បានដើម្បីនឹងយកទៅសរសេរជារឿងមួយ ឬសារមួយ គឺអ្នកនោះហើយ

www.budinst.gov.kh www.elibraryofcambodia

ជាប្រភពព័ត៌មាន។ យើងត្រូវខិតខំធ្វើការកសាងប្រភពព័ត៌មានឲ្យបានច្រើនជាទីបំផុត។ ហើយប្រភពទាំងអស់នោះ គឺយើងត្រូវធ្វើយ៉ាងណាឲ្យគេមានជំនឿមកលើយើង (ពួកគេអាចជួយយើងបានច្រើនណាស់ បើសិនជាគេចូលចិត្តយើង)។ បើសិនពួកគេជាមនុស្សល្អ គឺពួកគេនេះហើយដែលជាប្រភពព័ត៌មានរបស់យើងតរៀងទៅ។ បើយើងចេះគួរសម រាក់ទាក់ ហើយចេះចែករំលែកព័ត៌មានឲ្យគ្នាទៅវិញទៅមកផង គឺបានសេចក្តីថា យើងមានការទទួលខុសត្រូវខ្ពស់លើប្រភពព័ត៌មានរបស់យើងហើយ។

**ការថែរក្សាប្រភពព័ត៌មាន** (*Keeping the Source*)

បើទោះបីជាការដែលត្រូវប្រស្រ័យគ្នានោះ ពុំមានការសរសេរជាលាយលក្ខណ៍អក្សរ ឬក៏ការចរចារនោះមានតាមវិធីណាក៏ដោយក៏ប្រភពព័ត៌មាន និងអ្នកសារព័ត៌មានត្រូវតែមានការប្រស្រ័យទាក់ទងគ្នាទៅវិញទៅមកជានិច្ច។ នេះគឺជាការជាចាំបាច់ណាស់ ការប្រស្រ័យទាក់ទងគ្នា គឺត្រូវតែធ្វើឡើងដោយមានការទុកចិត្តគ្នាទៅវិញទៅមក អ្នកសារព័ត៌មានត្រូវការប្រភពក៏ព្រោះតែចង់បានព័ត៌មាន។ ចំណែកឯប្រភពនៃព័ត៌មានវិញក៏ប្រហែលជាត្រូវការជំនួយពីអ្នកសារព័ត៌មាន ដើម្បីឲ្យជួយធ្វើការផ្សព្វផ្សាយនូវអ្វីមួយ ដែលគេយល់ថា ជាការត្រឹមត្រូវ និងពិតត្រង់ដើម្បីប្រាប់ដល់សាធារណៈជន។ ការចងស្ពានមានមេត្រីនេះ គឺពុំមែនជាការងាយស្រួលប៉ុន្មានទេ បើប្រភពព័ត៌មានរបស់យើងគេមិនពេញចិត្តដោយប្រការណាមួយនោះ។ ហើយតទៅអនាគត គេក៏ប្រហែលជានឹងអាចបំភ្លេចយើងចោលបានថែមទៀត។ ប្រភពព័ត៌មានដែលល្អៗ គឺជាប្រភពព័ត៌មានដែលមានការពាក់ព័ន្ធទៅនឹងរឿង ឬព្រឹត្តិការណ៍ណាមួយ។ ប៉ុន្តែបើប្រភពព័ត៌មាននោះត្រូវជាមិត្តភ័ក្តិរបស់អ្នកយកព័ត៌មានវិញ គឺវាប្រហែលជាធ្វើឲ្យមិត្តភាពរវាងអ្នកទាំងពីរមានជួបនូវវិបត្តិខ្លះៗជាមិនខាន។ តើអ្នកយកព័ត៌មានត្រូវការពារមុខមាត់ឲ្យមិត្តរបស់ខ្លួន ឬក៏ត្រូវផ្សព្វផ្សាយព័ត៌មាននោះឲ្យសាធារណៈជនបានដឹង ដោយត្រូវបំផ្លាញកិត្តិយសមិត្តរបស់ខ្លួនចោលឬ? មធ្យោបាយដែលប្រសើរជាងគេ

www.budinst.gov.kh www.elibraryofcambodia

សំរាប់ជាដំណោះស្រាយបញ្ហាដ៏សែនធំធេងដូចខាងលើនេះ គឺអ្នកត្រូវធ្វើតាមតួនាទីរបស់ខ្លួនដោយមិនប្រកាន់ម្ខាងៗ។ គ្រប់មធ្យោបាយទាំងអស់គឺត្រូវតែស្លូតបូត និងចងមិត្តឲ្យបានច្រើន។ ត្រូវចេះចែករំលែកនូវពត៌មានឲ្យគ្នាទៅវិញទៅមក។ ប៉ុន្តែអ្នកក៏ត្រូវតែនិយាយបញ្ជាក់ជាមុនឲ្យបានច្បាស់ផងដែរថា ដែលអ្នកហ៊ានធ្វើដូច្នេះ គឺក្នុងនាមខ្លួនជាអ្នកសារពត៌មានម្នាក់តែប៉ុណ្ណោះ។

*កាតព្វកិច្ចទី១* ដែលអ្នកត្រូវធ្វើនោះគឺ ឲ្យបានដល់អ្នកអាន និងបំពេញតាមចំណូលចិត្តរបស់អ្នកអាន។ បន្ទាប់មកគឺសំរាប់បុគ្គលដែលជាអ្នកផ្តល់នូវប្រាក់ខែដល់អ្នកតែប៉ុណ្ណោះ។ មានមនុស្សច្រើនណាស់ដែលគេនាំគ្នាគោរពតាមវិធីសាស្ត្រនេះ។ យើងហៅវាថា *បូរណភាព* (*integrity*) គឺការចេះគោរពគ្នាទៅវិញទៅមក។ បូរណភាពនេះមានគុណសម្បត្តិពិសេសណាស់នៅក្នុងវិជ្ជាជីវៈសារពត៌មាន។

**ការការពារប្រភពពត៌មាន** (*Protecting the Source*)

ការចូលរួមជិតដិតជាងគេទៅនឹងបូរណភាពនោះគឺ កិច្ចការពារប្រភពពត៌មានរបស់យើង។ អ្នកដែលជាប្រភពពត៌មានគឺ ជាសរសៃឈាមរបស់អ្នកយកពត៌មាន។ គ្មានប្រភព គឺគ្មានពត៌មាន គ្មានការផ្ទៀងផ្ទាត់។ បើគ្មានប្រភពទេអ្នកយកពត៌មាន នឹងពុំមានធ្វើអ្វីក្រៅពីការផ្សព្វផ្សាយនូវពាក្យសំដី ដែលមានថ្លែងជាផ្លូវការប៉ុណ្ណោះ។ ជួនកាលប្រភពពត៌មានខ្លះគេបានបង្ហើបអំពីពត៌មានមួយឲ្យយើងដឹងក៏ព្រោះតែមកពីគេចង់បង្ហាញអំពីភាពស្មោះត្រង់របស់គេដល់សាធារណៈជនដោយពុំមានខ្លាចបាត់បង់ការងារ ឬអាយុជីវិតរបស់គេឡើយ។ បើមានករណីដូច្នេះមែន អ្នកយកពត៌មានត្រូវតែមានសីលធម៌មួយដោយហ៊ានទទួលខុសត្រូវ និងហ៊ានការពារនូវអត្តសញ្ញាណរបស់ប្រភពពត៌មាននោះ។ ការការពារនោះទៀតសោត គឺពុំមែនគ្រាន់តែជាកិច្ចជួយសង្គ្រោះដល់ប្រភពពត៌មាននោះប៉ុណ្ណោះទេ។ តាមពិតគឺដោយសារមកពីប្រភពពត៌មាននោះនឹងលែងមានឱកាសបាន បំរើសាធារណៈជនតាម

www.budinst.gov.kh www.elibraryofcambodia

រយៈការផ្តល់ព័ត៌មានមកឲ្យយើងជាបន្តទៀត។

*ជាថ្មីម្តងទៀត ចូរប្រយ័ត្ន !* យើងបានដឹងរួចមកហើយថា បញ្ហាមិត្តភាពរវាងប្រភពព័ត៌មានមួយនឹងអ្នកសារព័ត៌មាន គឺជាបញ្ហាមួយស្មុគស្មាញជាទីបំផុត។ វាអាចបណ្តាលនឹងឲ្យមានទំនាស់រវាងអ្នកទាំងពីរដោយលែងស្មោះត្រង់នឹងគ្នាទៀតផង។ ចូរចងចាំផងដែរថា នៅក្នុងករណីដើម្បីចូលឲ្យបានជិតទៅនឹងព័ត៌មានមួយ គឺមានការពិបាកខ្លាំងណាស់។ ជួនកាលគឺដោយសារមកពីវាមានការហាមឃាត់ ដែលបង្ករឡើងដោយបុគ្គលមួយចំនួនតូច។ ដូច្នេះបើយើងធ្វើការផ្សព្វផ្សាយនូវព័ត៌មាននោះឲ្យគេបានដឹងគឺបានសេចក្តីថាយើងបានបង្ហាញអំពីប្រភពរបស់យើងឲ្យគេដឹងដែរ។

**ការប្រើប្រាស់ប្រភព** (*Using Sources*)

នៅខាងក្រោមនេះ គឺជាសេចក្តីណែនាំមួយចំនួនសំរាប់ជាជំនួយឲ្យស្គាល់អំពីប្រភពនៃព័ត៌មាន:

- ត្រូវធ្វើការអង្កេតដោយផ្ទាល់ទៅតាមកាលៈទេសៈ ដែលអាចធ្វើបាន។ ត្រូវចេះធ្វើខ្លួនឯងឲ្យដូចជាប្រភពព័ត៌មានមួយ។ ត្រូវសាកល្បងធ្វើយ៉ាងណាឲ្យខ្លួនយើង មានវត្តមាននៅលើគ្រប់ព្រឹត្តិការណ៍ទាំងអស់ ឬនៅតាមទីដែលទើបនឹងមានរឿងមហន្តរាយរួច។ សព្វថ្ងៃនេះមានរឿងមួយ ដែលពុំសូវល្អមើលសោះ ពីព្រោះមកពីមានអ្នកសារព័ត៌មានមួយចំនួនគេមានចំណូលចិត្តប្រើទូរស័ព្ទដើម្បីយកព័ត៌មាន។
- នៅពេលចាំបាច់ណាមួយ ដែលត្រូវពឹងផ្អែកទៅលើករណីទីពីរយើងត្រូវប្រើប្រាស់ប្រភពណាដែលគេមានការផ្សាយ, មានកំណត់ត្រា និងមានឯកសារដែលប្រកបទៅដោយគុណភាពខ្ពស់។ ករណីដែលមានស្តីអំពីលក្ខន្តិកៈ អំពីកិច្ចព្រមព្រៀង ឬអំពីច្បាប់និតិកម្មណាមួយ។ ចាំបាច់គឺ ត្រូវឲ្យមានលិខិតថតចម្លងមួយច្បាប់សំរាប់ទុកជាឯកសារ។ ត្រូវប្រើប្រាស់បុគ្គលណាជាប្រភព ដែលពោរពេញទៅដោយការយល់ដឹង និងមានឥទ្ធិពលខ្លាំងជាងគេ។

www.budinst.gov.kh www.elibraryofcambodia

- ត្រូវពិនិត្យរកមើលអំពីទស្សនៈយោបល់នានា ដែលពួកអ្នកសង្កេតការណ៍គេបានលើកឡើង។ ប៉ុន្តែចូរកុំភ្លេចថា អ្នកត្រូវតែយកផ្លូវកណ្តាលមកធ្វើជាមាត្រាដើម្បីនឹងប្រមូល នូវរាល់ករណីទាំងអស់ពីក្នុងព្រឹត្តិការណ៍មួយនោះ។ អ្នកត្រូវតែយកចិត្តទុកដាក់ទៅនឹងពាក្យសំដីរបស់អ្នកដែលកំពុងធ្វើសេចក្តីថ្លែងការណ៍ កំពុងឡើងសម្តែងនូវអ្វីមួយជាសាក្សី ឬជាមន្ត្រីរាជការនានាជាដើម។ល។
- ត្រូវរៀបចំទុកដាក់ថែរក្សានូវអ្វីៗ ដែលអ្នកត្រូវប្រើសំរាប់ទាក់ទងជាមួយប្រភពទាំងអស់នោះឲ្យបានរៀបរយ។ គឺមានដូចជាអាស័យដ្ឋាន និងលេខ ទូរស័ព្ទជាដើម។ល។
- ត្រូវរៀបចំឲ្យរួចជាស្រេច ឬត្រូវគិតគូរទុកជាមុនថា តើប្រភពណាមួយ ដែលអាចផ្តល់នូវទស្សនៈយោបល់ អំពីរឿងការងាររបស់មន្ត្រីរាជការ និងរដ្ឋអំណាចដែលមានដូចជាៈ នគរបាល, អ្នកពន្លត់អគ្គិភ័យ, រដ្ឋលេខាធិការសារពត៌មាន, អ្នកនាំពាក្យរបស់រដ្ឋាភិបាល, អាជ្ញាធរ និងបុគ្គលិកសិក្សាធិការ។ល។
- ដើម្បីឲ្យមានការងាយស្រួល នៅក្នុងការទទួលពត៌មានឲ្យបានឆាប់រហ័ស គឺអ្នកត្រូវមានទំនាក់ទំនងឲ្យបានជិតស្និទជាមួយនឹងបុគ្គលិកនៅក្នុងក្រសួង ឬមន្ទីរនានាដែលគេមានមុខងារជាអ្នកត្រួតពិនិត្យមើលឯកសារផ្លូវការរបស់ក្រសួង ឬមន្ទីរនោះ។
- ត្រូវទទួលស្គាល់ថា បុគ្គល និងអ្វីៗទាំងឡាយ ដែលជាប្រភពពត៌មានរបស់យើង គឺគេមានព្រំដែនរបស់គេដែរ ។

**ការប្រើប្រាស់សាវតាររបស់ពត៌មាន** (*Using Background Information*)

អ្នកប្រកបវិជ្ជាជីវៈជាអ្នកសារពត៌មានគឺ តែងមានការចង់ដឹងចង់ឮអំពីអ្វីៗទាំងអស់។ ហើយអ្នកដែលមានថ្វីដៃពូកែជាងគេ គឺច្រើនតែជាអ្នកដែលមានខួរក្បាលផ្ទុកទៅដោយពត៌មាន។ ដូច្នេះអ្នកប្រកបមុខរបរជាអ្នកសារពត៌មាន គឺដូចជាអតិថិជនមួយរូបដែលពោរពេញទៅដោយការស្រេកឃ្លាន

www.budinst.gov.kh www.elibraryofcambodia

នូវព័ត៌មានដោយមិនរើសប្រធានបទ។ អ្វីៗទាំងអស់នេះ គឺគេហៅថាសាវតា ព័ត៌មានរបស់អ្នកសារព័ត៌មាន។ សាវតានៃព័ត៌មាននេះ គឺត្រូវរំលឹកឡើងវិញ ឲ្យបានញឹកញាប់ និងត្រូវបំពេញបន្ថែមនៅត្រង់ណាដែលមានការខ្វះចន្លោះ។ ដើម្បីឲ្យបានក្លាយទៅជាអ្នកសារព័ត៌មានដ៏មានថ្វីដៃល្អម្នាក់។ គឺអ្នកត្រូវអាន និងនិយាយជាមួយគេឯងឲ្យបានច្រើនដើម្បីសិក្សា និងចងចាំនូវព័ត៌មាន ទាំងនោះ។ ពាក្យថាសាវតា (*background*) នេះគឺវាមាននិយមន័យបីយ៉ាង៖

១. អ្នកសារព័ត៌មានម្នាក់បានរក្សាទុកនូវព័ត៌មាន។ ព័ត៌មាននោះអាចជា ព័ត៌មានដែលយើងទទួលបានពីយូរណាស់មកហើយ ឬដែលទើប នឹងទទួលបានភ្លាមៗដើម្បីប្រើសំរាប់ដោះស្រាយកិច្ចការសំខាន់ៗ។ បើសិនជាពុំមានចំណេះដឹងអំពីសាវតានេះទេ, ការដែលចង់ប្រមូល រកការពិតមួយគឺ អាចក្លាយទៅជាមិនបានការ និងមិនច្បាស់លាស់។ ការប្រមូលព័ត៌មានយកមករក្សាទុកនេះគឺអាចជួយធ្វើឲ្យ(*a reference library*) ឯកសារយោងនៅក្នុងបណ្ណាល័យមួយអាចទទួលបាននៅ ភាពកាន់តែប្រសើរឡើង។ ទាំងអស់នេះ គឺអាចប្លុកសរុបតាំងពី សៀវភៅឯកសារយោងគ្រប់ប្រភេទ អត្ថបទនានាដែលបានកាត់ ចេញពីទំព័រកាសែត រួចយកមកបិទចងក្រងជាសំណុំឯកសារមួយ ក្បាល (សំណុំឯកសារនេះ ពិតជាអាចជួយផ្តល់នូវព័ត៌មានដ៏ត្រឹមត្រូវ ជាមិនខាន) សៀវភៅទូរស័ព្ទនានា និងបញ្ជីរាយឈ្មោះអង្គការនានា ដោយមានពិពណ៌នាអំពីរចនាសម្ព័ន្ធ និងមុខងាររបស់អង្គការទាំងអស់ នោះផង។ ការដែលមានបង្ការទុកជាមុន ដូច្នេះគឺអាចជួយពង្រឹង កិច្ចការនៅក្នុងបន្ទប់ព័ត៌មាន ដែលមានដូចជាការចាត់ចែងការងារឲ្យ អ្នកយកព័ត៌មានសំខាន់ៗដើម្បីដើរយកព័ត៌មាន។ ការធ្វើដូច្នេះគឺអាច ធ្វើឲ្យអ្នកយកព័ត៌មានម្នាក់ៗ មានឱកាសអាចបណ្តុះបណ្តាលជំនាញ របស់ខ្លួនឲ្យមានកំរិតកាន់តែខ្ពស់ឡើងថែមទៀត និងអាចប្រមូលបាន នូវសាវតានៃព័ត៌មានដែលមានប្រធានបទ ឬសកម្មភាពសំខាន់ៗបាន

www.budinst.gov.kh www.elibraryofcambodia

ច្រើនជាងធម្មតា។ ត្រូវដឹងជាមុនថា តើយើងត្រូវទៅរកមើលវានៅទីណា? នៅក្រសួង ស្ថាប័នរដ្ឋាភិបាល ឬអង្គការក្រៅរដ្ឋាភិបាល ជាដើម។ល។ អ្វីៗទាំងអស់នេះ គឺត្រូវតែមានកត់ត្រាទុក។

២_ អ្វីៗទាំងអស់ដែលមាននៅក្នុងរឿងមួយ គឺវាទាំងអស់នោះហើយ ដែលបានពន្យល់អំពីព្រឹត្តិការណ៍នោះ។ ចូរតាមដានរកមើលអំពីការរីកចំរើនរបស់វា ហើយដាក់បញ្ចូលបន្ថែមនូវអ្វីដែលជារឿងពិត និងដែលប្រភពទាំងអស់នោះគេពុំបានផ្តល់ឲ្យ។ បើពុំមានសាវតារអំពីពត៌មាននោះទេ ដូច្នេះបរិបទមួយនោះ ឬអត្ថបទរឿងមួយនោះនឹងអាចក្លាយទៅជាគ្មានខ្លឹមសារ។

៣_ អ្វីៗទាំងអស់ដែលប្រភពពត៌មានមួយ គេមិនចង់ឲ្យយើងប្រើឈ្មោះរបស់គេនៅក្នុងការសន្ទនាអំពីពត៌មានមួយនោះ គឺយើងត្រូវរក្សាវាទុកនៅមួយកន្លែងសិន។ ពីព្រោះយើងនៅមិនទាន់ដឹងថា តើយើងត្រូវប្រើវា ឬក៏អត់នោះទេ។ ករណីនេះ គឺស្ថិតនៅលើការចង់បានរបស់បុគ្គល ដែលជាអ្នកបានសន្ទនាអំពីពត៌មាននោះ។

**តាមដានអំពីអ្វីដែលគេបាននិយាយ** (*Making Sound Observations*)

អ្នកសារពត៌មានម្នាក់ដែលកំពុងទទួលធ្វើកិច្ចការមួយ គឺគេកំពុងតែប្រឈមមុខជាមួយនឹងហេតុការពិតដ៏ច្រើនលើសលុប។ អង្គប្រជុំមួយត្រូវបញ្ចប់ទៅ បន្ទាប់ពីបានចំណាយពេលអស់ជាច្រើនម៉ោង និងដែលមានលើកឡើងអំពីប្រធានបទដ៏សែនទូលំទូលាយ។ នៅក្នុងសេចក្តីថ្លែងការណ៍មួយមានវាគ្មិនម្នាក់អាចនិយាយបានរាប់ពាន់ពាក្យ។ ដូច្នេះបន្ទាប់មកទៀត តើយើងត្រូវធ្វើយ៉ាងណាដើម្បីនឹងស្រង់ (*extract*) យកចំណុចសំខាន់ៗ ដែលមានការទាក់ទងទៅនឹងហេតុការណ៍ពិតមួយនោះ។ យើងមានកត្តាសំខាន់ៗបីយ៉ាងសំរាប់ប្រើជាជំនួយនៅក្នុងការងារដូចខាងលើនេះ។

១_ ត្រូវតែស្គាល់សហគមនោះឲ្យច្បាស់លាស់។ បន្ទាប់មកទើបចាប់ផ្តើមប្រមូលអារម្មណ៍ធ្វើការស្វែងយល់ឲ្យបានដឹងថា តើអ្នកអានគេចង់

www.budinst.gov.kh www.elibraryofcambodia

បានអ្វី និងតើចង់ដឹងអំពីអ្វីខ្លះ។

២. ត្រូវតែរកឲ្យឃើញអំពីសាច់រឿង រួចចាប់ផ្តើមធ្វើការបង្ហាញអំពីសាច់រឿងនោះដោយប្រុងប្រយ័ត្ន ។ ដូច្នេះហេតុការពិត និងអ្វីៗទាំងអស់ដែលជាករណីសំរាប់ជួយជ្រោមជ្រែង និងដើម្បីជួយធ្វើការបរិយាយអំពីសាច់រឿងនោះ គឺយើងអាចប្រមូលវាបានដោយស្វ័យប្រវត្តិ។

៣. ត្រូវរកឲ្យឃើញអំពីវិធានកម្ម បន្ទាប់មកត្រូវបង្ហាញអំពីការឈប់ចាប់មួយទៅលើអ្វីដែលមានតែមួយគត់ មិនប្រក្រតី មិនធម្មតា និងមិនច្រំដែល។ ចូរពិនិត្យមើលអំពីការណែនាំទាំងអស់ឲ្យបានពិស្តារៈ

**ត្រូវស្គាល់អំពីសហគមនោះឱ្យបានច្បាស់** *(Know the Community)*

អ្វីដែលអាចធ្វើឲ្យមានការទាក់ទិនដល់អ្នកអានមួយចំនួន និងអាចធ្វើឲ្យអ្នកអានឆាប់មានការចាប់អារម្មណ៍ អ្វីទាំងអស់នោះក៏ប្រហែលជាមិនមានការទាក់ទិនជាមួយអ្នកអាន និងអាចធ្វើឲ្យអ្នកអានមួយចំនួនផ្សេងទៀតឆាប់ធុញទ្រាន់នោះក៏ទេដែរ។ កត្តាចាំបាច់ជាទីបំផុត គឺអ្នកសារពត៌មានត្រូវតែស្គាល់ឲ្យបានច្បាស់ អំពីបញ្ហាទំនាក់ទំនងរវាងអ្នកអានជាមួយនឹងការបោះពុម្ពផ្សាយរបស់ខ្លួន។ ត្រូវតែធ្វើការស្វែងយល់ឲ្យបានច្បាស់ថា តើពួកគេទាំងអស់នោះសុទ្ធតែជាអ្នកចេះដឹង ឬក៏សុទ្ធតែជាអ្នកមានទ្រព្យសម្បត្តិ? តើសារពត៌មានរូបនោះ មានធ្វើ ការផ្តោតអារម្មណ៍ទៅលើតែក្រុមតូចណាមួយ ក្រុមពិសេសណាមួយ ឬក៏សំរាប់សាធារណៈជនទូទៅ?

**ត្រូវរកឱ្យឃើញអំពីសាច់រឿង** *(Find the Theme)*

គ្រប់រឿងរ៉ាវទាំងអស់គឺ តែងមានចំណុចសំខាន់មួយ ដែលយើងតែងតែយកមកធ្វើជាសេចក្តីផ្តើម ឬឃ្លាដំបូងសំរាប់អត្ថបទពត៌មានមួយ។ យើងអាចនាំគ្នាហៅចំណុចសំខាន់នេះថា ជាផាកចុងក្រោយ *(the bottom line)* គឺគេបានសង្ខេបនូវអ្វីៗទាំងអស់ដែលមាននៅក្នុងសាច់រឿងនោះ។ បន្ទាប់មកទើបគេលើកយកវាទៅនិយាយឲ្យបានពិស្តារនៅក្នុងអង្គសេចក្តីនៃអត្ថបទពត៌មានដើម្បីជាកិច្ចជួយជ្រោមជ្រែង និងជូនកាលសំរាប់ជាចម្លើយទៅ

www.budinst.gov.kh www.elibraryofcambodia

នឹងសំនួរដែលមានលើកឡើងនៅក្នុងសេចក្ដីផ្ដើមនោះផង។ នៅក្នុងពេលដែលអ្នកសារពត៌មានបានរកឃើញអំពីចំណុចសំខាន់មួយនោះរួចហើយ។ បន្ទាប់មកគឺគាត់ត្រូវចាប់ផ្ដើមធ្វើការផ្សំផ្គុំនូវអ្វីទាំងអស់ ដែលជាការពិតដើម្បីសំរាប់ជាកិច្ចគាំទ្រដល់សាច់រឿង និងដើម្បីជួយបន្ថែមនូវពត៌មានផ្សេងៗទៀតដែលមានការទាក់ទងទៅនឹងសាច់រឿងនោះ។ និពន្ធនាយកសារពត៌មានអូស្ត្រាលីម្នាក់បាននិយាយថា "មុននឹងចេញទៅយកពត៌មានអ្នកយកពត៌មានត្រូវតែចេះសង្ខេបសាច់រឿងនោះមិនឲ្យមានលើសពី១០ពាក្យឡើយ។

**ត្រូវរកឲ្យឃើញអំពីចិនាដកម្ម** *(Look for Drama)*

មានមនុស្សច្រើនណាស់ ដែលនឹងអានអត្ថបទរឿងសំខាន់ៗរបស់យើង ពីព្រោះអត្ថបទនោះនឹងប្រាប់ដល់អ្នកអានទាំងអស់អំពីអ្វីដែលថ្មី ដែលជាប្រលោមលោកប្លែកពីគេឯង និងដែលស្មានមិនដល់។ ដើម្បីនឹងទទួលនូវលទ្ធផលដូច្នេះបាន អ្នកយកពត៌មានត្រូវតែចេះធ្វើការសិក្សាឡើងវិញដោយត្រូវធ្វើខ្លួនឲ្យដូចជាទារក ដែលទើបនឹងបើកភ្នែក និងបានឃើញនូវអ្វីៗទាំងអស់នៅក្នុងពិភពលោកនេះសុទ្ធតែជារបស់ថ្មីៗ និងដែលគួរជាទីចាប់ចិត្តឥតគណនា។ នៅក្នុងពេលជាមួយគ្នានោះដែរ គឺត្រូវធ្វើខ្លួនឲ្យដូចជា មនុស្សចាស់ម្នាក់ដែលអាចបែងចែករាពខុសគ្នារវាងចំណុចដែលសំខាន់ និងចំណុចដែលមិនសំខាន់ ឬគ្មានខ្លឹមសារ។ អ្នកយកពត៌មានដែលពោរពេញដោយបទពិសោធន៍ភាគច្រើនតែងមានការយល់ឃើញដូចគ្នានៅលើចំណុចសំខាន់មួយដែលគេនាំគ្នាហៅថា ជាចំណុចកណ្ដាលនៃធាតុពិត។ ប៉ុន្តែអ្វីដែលខុសគ្នានោះនឹងមានលើកជាពិស្ដារ និងដែលត្រូវ ធ្វើការបរិយាយនៅក្នុងអង្គសេចក្ដី ដែលអ្នកយកពត៌មានផ្សេងៗទៀតពុំបាន លើកយកមកនិយាយ។

**អ្នកយកពត៌មានដូចជាអ្នកជ្រៀតចូល** *(The Reporter as Intruder)*

លោក វ៉ល្ធើរ លើពម៉ិន *(Walter Lippman)* ជាអ្នកសារពត៌មាន និងជាបណ្ឌិតសភាជាតិអាមេរិកាំងម្នាក់បានចាត់ទុកអ្នកសារពត៌មានថា ជាសត្វរុយនៅលើជញ្ជាំង *(the fly on the wall)* គឺបានសេចក្ដីថា អ្នក

www.budinst.gov.kh www.elibraryofcambodia

សារពត៌មានត្រូវធ្វើខ្លួនឲ្យដូចជា អ្នកសង្កេតការណ៍ម្នាក់ តែមិនត្រូវរំភើបទៅនឹងព្រឹត្តិការណ៍ដែលខ្លួនកំពុងតែសង្កេត និងតាមដាននោះទេ។ ប៉ុន្តែការយកពត៌មាន គឺត្រូវតែមានការថតរូប និងការសួរសំនួរ។ ដូច្នេះតើយើងត្រូវធ្វើយ៉ាងណា ទើបបានដឹងថាអ្នកយកពត៌មានពុំបានទទួលនូវអនុភាពអ្វីសោះអំពីព្រឹត្តិការណ៍នោះ?មនុស្សគ្រប់រូបត្រូវតែបង្ហាញការស្មោះត្រង់ ត្រូវហ៊ាននិយាយសារភាពថា តើនៅក្នុងចិត្តរបស់ខ្លួនកំពុងមានអ្វីខ្លះ? ហើយបើមានអ្នកសារពត៌មានណាម្នាក់អាចឆ្លើយទៅនឹងសំនួរនេះរួច គឺបានសេចក្តីថាអ្នកសារពត៌មានរូបនោះច្បាស់ជានឹងទទួលបាននូវការយកចិត្តទុកដាក់ពីចំណោមអ្នកយកពត៌មានដូចគ្នាជាមិនខាន?

នៅមានករណីមួយទៀត ដែលផ្ទុយទៅនឹងសភាពការណ៍ខាងលើគឺនៅក្នុងពេលដែលអ្នកយកពត៌មានម្នាក់បានដឹងអំពីអ្វីៗទាំងអស់ដែលមាននៅជុំវិញខ្លួនរបស់គេ។ ដូចជាមានមនុស្សមួយចំនួនចង់ឡើងទៅឈរនៅលើវេទិកាមួយនោះណាស់។ គេធ្វើដូច្នេះ គឺដើម្បីចង់ឲ្យយើងដែលជាអ្នកយកពត៌មានមានការចាប់អារម្មណ៍ទៅលើរូបគេផ្ទាល់តែម្តង ឬក៏ដើម្បីបុព្វហេតុអ្វីមួយប៉ុណ្ណោះ។ករណីដូចបានលើកឡើងនៅខាងលើនេះ គឺហាក់ដូចជាបានបញ្ជាក់ឲ្យយើងឃើញថា វត្តមានរបស់អ្នកយកពត៌មានតែងទទួលបាននូវអនុភាពដ៏ធំធេងណាស់អំពីព្រឹត្តិការណ៍មួយ។ ដូច្នេះតើយើងជាអ្នកសារពត៌ពានត្រូវធ្វើយ៉ាងណា ដើម្បីអាចទប់ទល់ទៅនឹងស្ថានភាពបែបនេះបាន? នៅមានប្រការមួយទៀតដែលយើងត្រូវតែធ្វើឲ្យបាន គឺត្រូវសាកល្បងមើលយ៉ាងណាដើម្បីគេចឲ្យផុតពីការបូកសរុបរូបយើងជាមួយនឹងហ្វូងអ្នកការសែតដ៏ទៃទៀត និងត្រូវរហ័សរហួន។ ម្យ៉ាងទៀតត្រូវធ្វើយ៉ាងណាកុំឲ្យគេកានការចាប់អារម្មណ៍មកលើរូបយើងឲ្យសោះ។ ត្រូវប្រើសម្លៀកបំពាក់ធម្មតា - និងសាកល្បងនៅលាយឡំជាមួយនឹងហ្វូងមនុស្សដែលមាននៅជុំវិញខ្លួនយើង។

www.budinst.gov.kh www.elibraryofcambodia

## ផ្នែកទីបួន

### ការបរិហារកេរ្តិ៍ – តើវាជាអ្វី និងហេតុអ្វីបានជាវាសំខាន់?

មុននឹងឆ្លើយទៅនឹងសំនួរខាងលើនេះយើងមានចំណុចមួយចំនួន ដែលចង់ជំរាបជូន។ ទ្រឹស្តីទាំងអស់នៃការបរិហារកេរ្តិ៍ ដែលយើងបានលើកយកមកពិភាក្សាជាបន្តបន្ទាប់នេះគឺ យើងយោងតាមឯកសារខាងផ្នែកច្បាប់ដែលធ្លាប់មានជាប្រវត្តិសាស្ត្រនៅក្នុងប្រទេសនិយាយភាសាអង់គ្លេស - ជាពិសេសគឺមានចក្រភពអង់គ្លេស អូស្ត្រាលី និងណូវ៉ែលហ្សេឡង់។ ច្បាប់បរិហារកេរ្តិ៍នៅសហរដ្ឋអាមេរិកក៏មានលក្ខណៈប្រហាក់ប្រហែលគ្នា ទៅនឹងប្រទេសមួយចំនួនដូចខាងលើនេះដែរ។ ប៉ុន្តែវាហាក់ដូចជាមានលក្ខណៈស្មុគស្មាញជាងទៅតាមទិដ្ឋភាពនៃរដ្ឋធម្មនុញ្ញរបស់ប្រទេសនិមួយៗ និងការគ្រប់គ្រងនាពេលបច្ចុប្បន្ន ដែលតម្រូវឲ្យមានការប្តឹងផ្តល់គ្នាពីបទបរិហារកេរ្តិ៍នេះទៅតាមរឿងរ៉ាវដែលកើតមានឡើង។ មានពេលមួយនោះ កាលពីច្រើនរយឆ្នាំមុន អ្នកចុងចោទជាពិសេស គឺត្រូវការពារខ្លួនដោយយោងទៅតាមអ្វី ដែលធ្លាប់មានជាអាទិភាព-ត្រូវបានយកទៅធ្វើនិទស្សន៍ឲ្យមានជាគោលការណ៍មួយដោយយោងតាមបំណកប្រែនៃច្បាប់របស់តុលាការ។

ព្រះរាជាណាចក្រ កម្ពុជាយើង ទើបនឹងបង្កើតបានច្បាប់សារព័ត៌មានថ្មីមួយ។ បំណកប្រែ (*interpretation*) និងអ្វីៗទាំងអស់ដែលជាអាទិភាពគឺនៅមិនទាន់បានធ្វើ និទស្សន៍ឲ្យបានទូលំទូលាយនៅឡើយទេ។ ចម្លើយសំរាប់សំនួរដែលសួរថា តើអ្វីទៅជាបទបរិហារកេរ្តិ៍ និងអ្វីដែលសំរាប់ការការពារខ្លួននៅពេលមានបណ្តឹង គឺត្រូវបានគេចំណាយពេលធ្វើនិទស្សន៍ជាច្រើនឆ្នាំណាស់មកហើយ។ តើនៅមានអ្វីបន្តទៀត? ទោះជាយ៉ាងណាក៏ដោយ គឺយើងនៅមានការពិភាក្សាគ្នាស្តីពីទ្រឹស្តីមួយចំនួនដែលមានការទទួលស្គាល់ជាទូទៅពីប្រជាជាតិ ដែលនិយាយភាសាអង់គ្លេស។ ឥឡូវចូរយើងនាំគ្នាបែរទៅរកសំនួរដែលសួរថា តើអ្វីទៅជាបទបរិហារកេរ្តិ៍ នោះវិញ។ តាមមើលទៅយើងប្រហែលជាត្រូវលើកយកផ្នែកខាងក្រោមនៃសំនួរនេះ

www.budinst.gov.kh www.elibraryofcambodia

មកធ្វើការបកស្រាយជាមុនសិន។

នៅក្នុងពេលមួយ ដែលលោកកំពុងធ្វើទស្សនកិច្ចនៅក្នុងព្រះរាជាណាចក្រកម្ពុជាលោកម៉ៃខិល ឃើបប៊ី (*Michael Kirby*) អតីតតំណាងពិសេសរបស់លោកអគ្គលេខាធិការអង្គការសហប្រជាជាតិផ្នែកសិទ្ធិមនុស្សនៅកម្ពុជា លោកបានមានប្រសាសន៍ដូចមាននៅខាងក្រោមនេះ។ ប្រសាសន៍របស់លោកត្រូវបានអ្នកសារព័ត៌មានសឹងតែពេញមួយពិភពលោកយល់ស្របតាមលោកទាំងអស់ : *“ធ្វើជាអ្នកសារព័ត៌មានគឺ ពុំមែនដើម្បីលុយកាក់ ឬដើម្បីនិយាយរឿងអាស្រូវ និងបោះពុម្ពផ្សាយនូវរូបថតកំប្លែងតែមួយមុខប៉ុណ្ណោះទេ។ មានវិជ្ជាជីវៈជាអ្នកសារព័ត៌មានគឺ ថ្លៃថ្នូរណាស់នៅក្នុងការដែលយើងបានផ្តល់ព័ត៌មានឲ្យបានដល់មនុស្សគ្រប់ៗគ្នា។ ខ្ញុំសូមអំពាវនាវដល់អ្នកទាំងអស់គ្នាត្រូវយល់ច្បាស់អំពីសារសំខាន់នៃវិជ្ជាជីវៈនេះ និងអំពីសក្តានុពលនៃសេចក្តីថ្លៃថ្នូរនោះ គឺដើម្បីសំរាប់សិទ្ធិមនុស្ស។ បន្ទាប់ពីសិទ្ធិដើម្បីរស់រាន គឺនៅមានសិទ្ធិដ៏ចាំបាច់មួយទៀតដែលសំខាន់ជាងគេនោះ គឺសេរីភាពក្នុងការបញ្ចេញមតិយោបល់។”*

លោកឃើបប៊ីបាននិយាយដូចអ្នកដទៃទៀតដែលធ្លាប់និយាយដែរថា :

*“ជាមួយនឹងសេរីភាពថ្មីនេះ (ការបញ្ចេញមតិយោបល់) គឺបាននាំមកនូវការទទួលខុសត្រូវថ្មីមួយទៀត... ការទទួលខុសត្រូវនេះ និងសច្ចៈធម៌ គឺជាសេចក្តីត្រូវការតែមួយគត់សំរាប់បង្ហាញការពិត... អ្នកសារព័ត៌មានដ៏ពូកែម្នាក់ គឺមានសិទ្ធិពេញលេញនៅក្នុងការបង្ហាញអំពីមតិយោបល់ដោយយុត្តិធម៌ និងដ៏ត្រឹមត្រូវរបស់ខ្លួន-គឺជាសិទ្ធិក្នុងការពន្យល់ដែលប្រកបទៅដោយគតិយុត្តិធម៌-ប៉ុន្តែបើសិនជាអ្នកយកអ្វីដែលជាទស្សនៈយោបល់នោះមកលាយជាមួយនឹងអ្វីដែលជាការពិតវិញ គឺបានសេចក្តីថាអ្នកកំពុងតែធ្វើឲ្យអ្នកអានទទួលរងនូវការអាប៉ស់ដោយមកពីមានការច្រឡំថា មតិយោបល់របស់អ្នក គឺជាការពិត។”*

ករណីនេះគឺសំខាន់ណាស់នៅក្នុងបទបរិហារកេរ្តិ៍។ យើងនឹងធ្វើការអាន

www.budinst.gov.kh www.elibraryofcambodia

អំពីអ្វីដែលហៅថាជា មតិយោបល់ និងអ្វីដែលជាការពិតនេះបន្ថែមទៀត។ ប៉ុន្តែពេលនេះចូរយើងនាំគ្នាពិនិត្យមកលើអត្ថន័យមួយចំនួននៃពាក្យបរិហារកេរ្តិ៍នេះ។ ជាទូទៅបទបរិហារកេរ្តិ៍មានពីរប្រភេទៈ

១- **Slander**; ការបន្តុះបង្អាប់ ឬនិយាយបង្ខូចនរណាម្នាក់តាមការប្រើពាក្យសំដី និង

២- **Libel**; ការនិយាយបន្តុះបង្អាប់ ឬនិយាយបង្ខូចនរណាម្នាក់តាមរយៈចុះផ្សាយបោះពុម្ព។ តាមធម្មតាការប្រើចុះផ្សាយបោះពុម្ពដើម្បីបន្តុះបង្អាប់ ឬនិយាយបង្ខូចនរណាម្នាក់ គឺមានសភាពធ្ងន់ធ្ងរខ្លាំងជាងគេ ពីព្រោះវាមានទ្រង់ទ្រាយជាអមតៈ។ ហើយទន្ទឹមនឹងនោះនៅមានមនុស្សច្រើនណាស់ ដែលគេបានអានម្តងហើយម្តងទៀត។ បើមនុស្សម្នាក់ត្រូវបានគេនិយាយបន្តុះបង្អាប់ (តាមការប្រើពាក្យសំដី រូបថត និងរូបតុក្កតាកំប្លែង... ) គឺអ្នកនោះត្រូវៈ

- រងគ្រោះដោយត្រូវទទួលបាននូវការស្អប់ខ្ពើម ការមើលងាយ មើលថោក ការចំអក និងក្លាយខ្លួនទៅជាអ្នកដែលគេមិនចង់ឃើញមុខ។
- អ្នកដើមចោទ (អ្នកដែលបានប្តឹងថា ខ្លួនត្រូវបានគេនិយាយបង្ខូច) ត្រូវទទួលបាននូវការមើលស្រាលពីសមាជិកក្នុងសង្គម។ និង,
- ប្រជាប្រិយភាពក្នុងមុខជំនួញ ពាណិជ្ជកម្ម ឬវិជ្ជាជីវៈរបស់បុគ្គលម្នាក់នោះនឹងត្រូវរងរបួស។ (នៅក្នុងករណីទីពីរខាងលើនេះ គឺសំខាន់ណាស់។ យើងចាំបាច់ត្រូវតែសួរខ្លួនយើងថា តើសាធារណៈជនជាទូទៅគេយល់យ៉ាងណាដែរ បន្ទាប់ពីគេបានអាន ឬបានស្តាប់នូវពាក្យអស់ទាំងនោះ?)

ប៉ុន្តែបើមាននរណាម្នាក់ យកករណីបរិហារកេរ្តិ៍នេះទៅប្តឹងអ្នកសារពត៌មានណាម្នាក់នោះ សាមីខ្លួនដើមចោទចាំបាច់ត្រូវតែមានភស្តុតាងបង្ហាញដូចខាងក្រោមនេះ។

- តើអ្វីខ្លះដែលបានផ្សព្វផ្សាយរួចមកហើយនោះថា ជាការនិយាយបន្តុះ

www.budinst.gov.kh www.elibraryofcambodia

បង្អាប់មកលើរូបខ្លួន?

- តើអ្វីខ្លះដែលបាននិយាយសំដៅមកលើរូបខ្លួន? និង
- ករណីរបៀបនេះ តើធ្លាប់មានចំពោះអ្នកដទៃក្រៅពីរូបខ្លួនដែរឬទេ?

គ្រប់ប្រជាជាតិទាំងអស់នៅក្នុងលោកយើងនេះ អ្នកសារព័ត៌មានត្រូវបង្ហាញចំពោះតុលាការ គ្មានអ្វីក្រៅពីដើម្បីដោះស្រាយពាក្យបណ្ដឹងពីបទបរិហារកេរ្តិ៍នេះទេ។ មានអ្នកសារព័ត៌មានជាច្រើនរូបត្រូវបានបញ្ជូនទៅពន្ធនាគារ ឬអង្គភាពសារព័ត៌មាននោះត្រូវបង់ពិន័យជាប្រាក់ដើម្បីទុកជាការព្រមានដោយសារខ្លួនមានកំហុសមែន។ មានអ្នកនយោបាយជាច្រើននាក់ និងមនុស្សមួយចំនួនក្នុងលោកយើងនេះ ដែលមានភាសាអង់គ្លេសជាយាន ពួកគេបានក្លាយខ្លួនទៅជាអ្នកមានបន្ទាប់ពីត្រូវបានតុលាការកាត់សេចក្ដីឲ្យឈ្នះដោយសារមកពីបានរកឃើញថា អ្នកសារព័ត៌មានម្នាក់នោះពិតជាបាននិយាយបន្ទះបង្អាប់ ឬនិយាយបង្ខូចកិត្តិយសពួកគេមែន។

ជាថ្មីម្ដងទៀតនៅក្នុងព្រះរាជាណាចក្រកម្ពុជាយើង អ្វីៗដែលចុងចោទត្រូវដឹងនោះគឺ មានលើកនៅក្នុងច្បាប់សារព័ត៌មានទាំងអស់ និងប្រហែលជាត្រូវមានការវិវឌ្ឍន៍នៅក្នុងពេលដ៏ខ្លីណាមួយជាមិនខាន។ ប៉ុន្តែបើនិយាយអំពីច្បាប់ដែលធ្លាប់មានជាប្រពៃណីរបស់ប្រទេសដែលប្រើភាសាអង់គ្លេសវិញ គឺមានច្រើនណាស់សំរាប់អ្នកចុងចោទពីបទបរិហារកេរ្តិ៍នេះ។

**ប្រភេទនៃឯកសិទ្ធិ** (*Privilege*) មានពីរយ៉ាង ៖

- ឯកសិទ្ធិដាច់ខាត (*Absolute Privilege*) - គឺត្រូវបានគេយកទៅអនុវត្តន៍នៅលើការងារគ្រប់បែបយ៉ាងទាំងអស់សំរាប់សភា និងនៅក្នុងពេលដែលតុលាការកំពុងធ្វើសវនាការ។ ឯកសិទ្ធិដាច់ខាតនេះត្រូវបានតាក់តែងឡើងសំរាប់ជួយដល់មនុស្សគ្រប់រូប ដើម្បីឲ្យអាចនិយាយបានតាមចំណង់ ដោយមិនខ្លាចថា មានទរណាប្ដឹងឡើយ។
- ឯកសិទ្ធិមានលក្ខខណ្ឌ (*Qualified Privilege*) - គឺត្រូវបានគេយកទៅអនុវត្តន៍នៅក្នុងពេល ដែលសាមីខ្លួនត្រូវបានគេយកទៅ

www.budinst.gov.kh www.elibraryofcambodia

និយាយបន្តុះបង្អាប់ ហើយដែលខ្លួនបានដឹងពាក្យចោទ ដែលគ្មានភស្តុតាង នោះតាមរយៈអ្នកទីបី។ ឧទាហរណ៍--ខ្ញុំត្រូវធ្វើសំណូមពរដល់អតីតៈចៅហ្វាយរបស់ខ្ញុំដើម្បីឲ្យគាត់ជួយសរសេរឯកសារយោងមួយ ស្តីអំពីប្រវត្តិការងាររបស់ខ្ញុំ។ ខ្ញុំត្រូវតែមានវត្ថុនេះ ពីព្រោះខ្ញុំចង់រកការងារថ្មីទៀតធ្វើ។ អតីតៈចៅហ្វាយរបស់ខ្ញុំ គាត់ប្រហែលជាយល់ថា ខ្ញុំនេះជាមនុស្សខ្ជិលណាស់ ហើយគាត់ប្រហែលជាធ្វើចំណាររនៅលើឯកសារនោះ ដូចខាងលើនេះជាមិនខាន។ បើទោះបីជាខ្ញុំ មិនយល់ស្របតាមគំនិតរបស់គាត់នោះក៏ដោយ ខ្ញុំគឺមិនអាចប្តឹងអតីតៈចៅហ្វាយខ្ញុំដោយចោទគាត់ថា ជាអ្នកបន្តុះបង្អាប់ ឬជាអ្នកបរិហារកេរ្តិ៍ខ្ញុំនោះបានឡើយ ពីព្រោះចៅហ្វាយថ្មីខ្ញុំ គាត់ក៏ចង់បានយោបល់ ស្តីអំពីរូបខ្ញុំ ពីចៅហ្វាយចាស់នោះដែរ។

ជួនកាលមានអ្នកសារព័ត៌មានមួយចំនួននិយាយថា មានសាធារណៈជនច្រើនណាស់ ដែលមានចំណូលចិត្តចង់ដឹងអំពីរឿងបន្តុះបង្អាប់គ្នានេះ។ ជាពិសេស គឺការបន្តុះបង្អាប់ដែលមានទៅលើមនុស្សសំខាន់ៗ និងជួនកាលអំពីការងាររបស់ចុងចោទ។ ប៉ុន្តែនេះគឺជារឿងមួយដែលស្មុគស្មាញជាទីបំផុត ពីព្រោះតុលាការប្រហែលជាអាចមិនយល់ស្របតាមគំនិតរបស់លេខានិពន្ធ ឬអ្នកសារព័ត៌មានថាជារឿង ដែលសាធារណៈជនចូលចិត្តនោះឡើយ។ តុលាការប្រហែលជាយល់ដូចនេះថា ការសរសេររឿងបន្តុះបង្អាប់ដើម្បីបរិហារកេរ្តិ៍នេះ គឺដើម្បីគ្រាន់តែឲ្យកាសែតរបស់ខ្លួនលក់ដាច់ប៉ុណ្ណោះ។ បើសិនជាអ្នកដែលមានខ្លួនថាត្រូវបានគេបន្តុះបង្អាប់ដើម្បីបរិហារកេរ្តិ៍នោះ អាចធ្វើការបង្ហាញថា លេខានិពន្ធ ឬអ្នកយកព័ត៌មានបានចុះផ្សាយនូវរឿងនោះ គឺក្នុងបំណងណាមួយ-ឧទាហរណ៍គឺដើម្បីនិយាយសំដៅមកលើខ្លួន ឬដើម្បីធ្វើឲ្យខ្លួនទទួលនូវការអាម៉ាស់។ ធ្វើដូច្នេះ គឺគេហៅថា ការព្យាបាទ។ ដូច្នេះបុព្វសិទ្ធិប្រភេទនេះ នឹងលែងមានអនុភាពទៀតហើយ។

**សេចក្តីរាយការណ៍ដោយត្រឹមត្រូវ**

បើអ្នកសរសេរអត្ថបទរឿងមួយ ស្តីពីការងាររបស់សភា ឬរបស់

www.budinst.gov.kh www.elibraryofcambodia

តុលាការ។ អ្នកអាចដកស្រង់យកពាក្យសំដី ដែលមាននិយាយបន្តុះបង្អាប់ដើម្បី បរិហារកេរ្តិ៍ឈ្មោះមកប្រើបាន បើសិនជាក្នុងការសរសេរនោះមានបង្ហាញនូវភាពត្រឹមត្រូវ និងច្បាស់លាស់។

**អ្នកសារពត៌មានត្រូវតែចងចាំអំពីគន្លឹះមួយចំនួនខាងក្រោមនេះ**

- ត្រូវដកស្រង់ពាក្យសំដីដែលគេបាននិយាយ ដើម្បីបរិហារកេរ្តិ៍ឈ្មោះឲ្យបានត្រឹមត្រូវឥតខ្ចោះ និងត្រូវបញ្ជាក់ថា អ្នកណាជាអ្នកនិយាយនោះផង។
- ត្រូវសរសេរកុំឲ្យលំអៀង មិនត្រូវយកចិត្តទុកដាក់ទៅលើពាក្យសំដីរបស់ភាគីតែម្ខាងៗ។
- ពាក្យសំដីដើម្បីបរិហារកេរ្តិ៍ឈ្មោះ ដែលអ្នកបានដកស្រង់យកមកប្រើនោះត្រូវដាក់នៅក្នុងបរិបទមួយ និងមិនត្រូវសរសេរផ្សព្វផ្សាយឲ្យដូចជារឿងរបស់វាផ្ទាល់ទេ។ ឧទាហរណ៍ ៖ នៅចុងបញ្ចប់នៃថ្ងៃកាត់ក្តីនេះលោកសុភាចារ បុរសបានធ្វើការបូកសរុបពាក្យចោទ ដែលគ្មានភស្តុតាង និងពាក្យចោទប្រកាន់មួយចំនួនធំទៀត។ ប៉ុន្តែខាងចុងចោទនៅមានឱកាសដើម្បីឆ្លើយដោះស្រាយនៅថ្ងៃស្អែក។

បើយើងចង់សរសេរអត្ថបទមួយដែលមានភ្ជាប់គ្រប់ ករណីដូចមាននៅក្នុងការកាត់ក្តីនេះ ដោយពុំបានបញ្ជាក់ថា ខាងចុងចោទនៅមានឱកាសឆ្លើយដោះស្រាយនៅថ្ងៃស្អែកផងនោះ។ ដូច្នេះអត្ថបទរបស់អ្នកមិនអាចចាត់ទុកថា ត្រឹមត្រូវ និងមិនមានការលំអៀងនោះបានឡើយ។ ដើម្បីសរសេរអត្ថបទមួយឲ្យអាចទទួលបាននូវការជឿជាក់នៅក្នុងអត្ថបទនោះ គឺត្រូវប្រកាន់ឲ្យខ្ជាប់ខ្ជួននូវភាពមិនលំអៀង និងត្រឹមត្រូវ។ ហើយបើសិនជាមានការលំអៀង ឬមិនត្រឹមត្រូវវិញ ចុងចោទនឹងត្រូវចាញ់ក្តីនោះជាមិនខាន។ ដូច្នេះក្នុងនាមយើងជាអ្នកសារពត៌មានមួយរូប គឺយើងត្រូវ បំពេញការងាររបស់យើងឲ្យបានហ្មត់ចត់ជាទីបំផុត។ ត្រូវឲ្យច្បាស់លាស់ មិនត្រូវធ្វើការវាយតម្លៃថា ដូច្នេះ ឬ ដូច្នោះ -- មិនលំអៀង និងត្រូវមានសច្ចៈធម៌។

www.budinst.gov.kh www.elibraryofcambodia

**បកស្រាយអោយបានត្រឹមត្រូវ**

ក្នុងករណីនេះគឺ ត្រូវបានគេយកទៅអនុវត្តន៍នៅលើចុងចោទ ដែលភាគច្រើន គឺសុទ្ធតែជាអ្នកធ្វើអត្ថាធិប្បាយ។ ប៉ុន្តែពួកគេតែងមានការពឹងផ្អែកទៅលើបុគ្គលដែលសំបូរទៅដោយវិចារណ្ញាណច្បាស់លាស់ និងដែលហ៊ានទទួលស្គាល់ថា ពាក្យសំដីទាំងនោះ គឺគ្រាន់តែជាមតិយោបល់មួយប៉ុណ្ណោះ និងមិនមែនជាពាក្យសំដី ដែលចង់សំដែងចេញថា វាជាការពិតនោះទេ។

**ប៉ុន្តែដើម្បីនឹងអាចយកជាការបានវិញ ខាងចុងចោទត្រូវមានៈ**

- ពាក្យសំដីដែលជាមតិយោបល់ទាំងនោះគឺ ត្រូវឲ្យមានភាពច្បាស់លាស់ថា គឺមិនមែនជាការពិតនោះទេ។
- ការពិតជាមូលដ្ឋាននៅក្នុងការបកស្រាយនោះ ត្រូវបញ្ជាក់ឲ្យច្បាស់ និងត្រូវមានបង្ហាញនៅក្នុងឯកសារ។
- ត្រូវធ្វើការបង្ហាញថា អ្វីទាំងអស់នោះគឺ សុទ្ធតែជាការពិត (អ្នកយកពត៌មានត្រូវមានភស្តុតាង) ឬមានបុព្វសិទ្ធិផ្តាច់មុខ។
- ការបកស្រាយនោះត្រូវប្រកាន់ខ្ជាប់នូវភាពត្រឹមត្រូវ។
- ការបកស្រាយនោះត្រូវសំដែងការស្មោះត្រង់មួយថា ពិតជាមតិយោបល់ មែន។ និង,
- ការបកស្រាយនោះ គឺពិតជាការលើកឡើងនៃករណីមួយសំរាប់បំពេញ តាមបំណងរបស់សាធារណៈជនមែន។

*ដើម្បីឲ្យការងារខាងចុងចោទអាចបានប្រសិទ្ធិភាព ការបកស្រាយរបស់អ្នកសារពត៌មានទាំងអស់ត្រូវឈរលើការពិតជាមូលដ្ឋាន។ ហើយការពិត និងមតិយោបល់នោះទៀតសោត គឺត្រូវឲ្យមានការបញ្ជាក់ឲ្យបានច្បាស់លាស់។ យើងអាចនិយាយផ្សេងពីនេះបានដែរថា អ្វីទាំងអស់នោះ គឺជាការឈ្លោះជជែកគ្នាមួយមែន គឺវាមានចែងយ៉ាងច្បាស់លាស់ ឬមានគេលើកយកមកនិយាយមែន-ហើយអ្វីៗទាំងអស់ដែលបានលើកឡើងនោះគឺ*

www.budinst.gov.kh www.elibraryofcambodia

*សុទ្ធតែជារឿងពិត ឬជារឿងមួយដែលបានលើកឡើងដោយមានមកពីខ្លួនមានសិទ្ធិដាច់ខាត។ អ្នកមិនអាចនិយាយថាការបកស្រាយមួយនោះឲ្យដូចជាការពិតបានទេ។ ដូចជាថា លោក X គឺ ជាមនុស្សភ្លីភ្លើ។ អ្នកមិនអាចសរសេរបំភ្លៃលើការបកស្រាយមួយដោយគ្មានភស្តុតាងបានទេ។ ដូចជាថាបើតាមយោបល់ខ្ញុំ លោក X គឺជាមនុស្សភ្លីភ្លើមែន។ អ្នកអាចសរសេរ ឬនិយាយដូច្នេះបាន លុះត្រាតែ អ្នកមានការពិតមួយចំនួនបកនាំមុខក្នុងការបកស្រាយនោះ។*

សេចក្តីថ្លែងការណ៍ដែលមានសុភវិនិច្ឆ័យ និងដើម្បីបំពេញទៅតាមបំណងរបស់សាធារណៈជននោះ គឺមានពីរប្រភេទ ៖

១- គឺនៅត្រង់កន្លែងណាមួយ ក្នុងប្រធានបទនៃសេចក្តីថ្លែងការណ៍នោះមានបញ្ជាក់ថា គឺដើម្បីស្វាគមន៍បតិយោបល់ពីសាធារណៈជន។ ឧ. ដូចជាការសំដែងសិល្បៈ ឬការបោះពុម្ពផ្សាយនៃរឿងនិទានខ្លីៗដែរ។

២- សេចក្តីថ្លែងការណ៍នោះត្រូវមានស្តីអំពីអ្វីមួយ ដែលធ្វើឲ្យសាធារណៈជនមានការចាប់អារម្មណ៍។ អ្វីដែលជាទីចាប់អារម្មណ៍របស់សាធារណៈជន គឺមានដូចជា ទង្វើរបស់រដ្ឋាភិបាល សកម្មភាពរបស់អ្នកនយោបាយ និងមន្ត្រីរាជការ ឬអ្វីផ្សេងទៀត ដែលមានឥទ្ធិពលមកលើមនុស្សទូទៅ។ ដូច្នេះអ្វីទាំងអស់នោះ គឺប្រហែលសុទ្ធតែជារឿងត្រឹមត្រូវតាមច្បាប់ទើបបានជាមានគេចាប់អារម្មណ៍មកលើ ឬមានចម្ងល់អំពីអ្វីដែលកើតមានឡើងមកនោះ ឬអំពីអ្វីដែលនឹងកើតមានឡើងចំពោះរូបគេ និងចំពោះអ្នកផ្សេងទៀត។

**ជាទូទៅអ្នកសារព័ត៌មានអាចធ្វើការបោះពុម្ពផ្សាយនូវការបកស្រាយស្តីពី៖**

- ទង្វើជាទូទៅរបស់ស្ថាប័នរដ្ឋ
- ទង្វើជាជំនាញរបស់មន្ត្រីរាជការ
- ទប្រព្រឹត្តការងារសាធារណៈ

www.budinst.gov.kh www.elibraryofcambodia

- ទម្រង់ការងាររបស់តុលាការ
- ការងាររបស់បញ្ញវន្ត និងសិល្បៈករ
- ការសំដែងសិល្បៈ
- កីឡា
- ទំនាក់ទំនងសាធារណៈ

បើគ្រាន់តែស្តាប់ គឺហាក់ដូចជាស្រួលណាស់ - ឥឡូវថាវារញ្ជើងទៅចុះ! មានច្បាប់មួយចំនួន ដែលយើងនាំគ្នាហៅថា ការទទួលខុសត្រូវក្នុងការបង្ហាញភស្តុតាងកុហកជាមួយការកាត់ទោស។ ឧទាហរណ៍-- បើសិនជាខ្ញុំត្រូវបានគេចោទប្រកាន់ថា បានលួចរថយន្តមួយ។ ប៉ូលីសត្រូវបង្ហាញភស្តុតាងថា ខ្ញុំបានលួចរថយន្តនោះមែន។ ប៉ុន្តែនៅក្នុងច្បាប់បរិហារកេរ្តិ៍ គឺវាផ្សេងពីនេះ-អ្នកសារព័ត៌មានត្រូវបង្ហាញភស្តុតាងថា អ្វីដែលបានលើកឡើងនៅក្នុងបទអត្ថាធិប្បាយនោះ គឺសុទ្ធតែជារឿងពិតទាំងអស់។ (អ្វីដែលផ្ទុយ គឺវាជាការពិត នៅសហរដ្ឋអាមេរិក-ការវិនិច្ឆ័យទោសនៅតុលាការប្រហែលជាត្រូវបានគេលើកឡើងថា កូនក្តីរបស់ខ្លួនត្រូវទទួលរងនូវការខាតបង់ គឺដោយសារមកពីការនិយាយផ្តេសផ្តាស់ដោយគ្មានភស្តុតាង។)

*បើសិនជាអត្ថបទនោះត្រូវបានសរសេរដោយ យោងតាមការពិតហើយដែលមិនមានបង្ហាញភស្តុតាងបាននៅតុលាការ។ ដូច្នេះទោះបីជាការបកស្រាយនោះ មានលក្ខណៈត្រឹមត្រូវយ៉ាងណាក៏ដោយក៏វាមិនអាចការពារអ្នកបានដែរ។*

**ការនិយាយពិតត្រង់**

នៅតាមកន្លែងខ្លះ ការនិយាយពិតត្រង់ គឺជាឧបករណ៍សំរាប់ការពារខ្លួន។ រីឯកន្លែងខ្លះទៀត គឺត្រូវមានបង្ហាញថា អត្ថបទរបស់អ្នកដែលបានបោះពុម្ពផ្សាយនោះ គឺដើម្បីសំរាប់ជាប្រយោជន៍សាធារណៈ។ ការចងក្រងរបៀបនេះ គឺដើម្បីសំរាប់ការពារដល់បុគ្គលផងទាំងពួងឲ្យរួចផុតពីការ

www.budinst.gov.kh www.elibraryofcambodia

ដែលគេយករឿងរ៉ាវជន យកទៅធ្វើការផ្សព្វផ្សាយ នៅលើទំព័រកាសែត។ ការបង្ហាញភស្តុតាង អំពីការនិយាយពិតត្រង់ជួនកាល គឺវាមានការពិបាកខ្លាំងណាស់ បើសិនជាយើងគ្មានឯកសារសំរាប់ធ្វើភស្តុតាង ឬគ្មានមនុស្សណាម្នាក់ ដែលអាចឡើងទៅធ្វើជាសាក្សីនៅចំពោះមុខតុលាការ។

## ការពិត និង មតិយោបល់

## (Fact and Opinion)

តាមទំនៀមទម្លាប់របស់អ្នក មានវិជ្ជាជីវៈជាអ្នកសារពត៌មាននៅក្នុងលទ្ធិប្រជាធិបតេយ្យគឺ គេបាននាំគ្នាធ្វើការបកស្រាយយ៉ាងច្បាស់លាស់ អំពីអ្វីដែលជាការពិត និងអំពីអ្វីដែលជាមតិយោបល់។ ពួកគេទាំងប្រុសទាំងស្រីអាចធ្វើដូច្នេះបាន ក៏ដោយសារតាមបច្ចេកបាយរៀងៗខ្លួន។ នៅក្នុងលទ្ធិប្រជាធិបតេយ្យអ្នក ដែលមានវិជ្ជាជីវៈជាអ្នកសារពត៌មាន គឺពួកគេមានការប្តេជ្ញាមួយ គឺការឈរនៅលើសច្ចៈធម៌។ នៅក្នុងលទ្ធិប្រជាធិបតេយ្យអ្នកសារពត៌មានត្រូវហ៊ានទទួលខុសត្រូវចំពោះវាសនារបស់មនុស្សគ្រប់ៗគ្នា មិនមែនសំរាប់តែមនុស្សមួយក្រុមតូចនោះទេ។ ដើម្បីឲ្យការទទួលខុសត្រូវនោះបានគ្រប់ជ្រុងជ្រោយ ពួកគេត្រូវលើកតែ អំពីអ្វីដែលជារឿងពិតសំរាប់អ្នកអានអ្នកស្តាប់ ឬអ្នកទស្សនាឲ្យអាចទទួលយករឿងនោះទៅធ្វើការពិចារណាដោយខ្លួនឯង។ ធ្វើដូច្នេះគឺពុំមែនមានន័យថា អ្នកសារពត៌មានពុំអាចបញ្ចេញមតិយោបល់របស់ខ្លួនបាននោះក៏ទេដែរ។ បើសិនជាគេចង់សរសេរ អំពីមតិយោបល់មួយ ពួកគេត្រូវអនុវត្តន៍តាមវិធីសាស្រ្តមួយចំនួនដូចខាងក្រោមនេះ។

ជាដំបូង គឺត្រូវធ្វើការបញ្ជាក់ឲ្យច្បាស់លាស់អំពីជំពូករឿង ដែលត្រូវសរសេរនោះថា តើជាមតិយោបល់ ឬក៏ជាពត៌មាន? យើងត្រូវតែធ្វើដូច្នេះ គឺដើម្បីឲ្យអ្នកអានបានដឹងជាមុនថា អ្វីដែលគាត់កំពុងតែអាននោះ គឺជាការពិត ឬក៏គ្រាន់តែជាមតិយោបល់មួយរបស់អ្នកសរសេរ។ ប៉ុន្តែបើទោះបីជារឿង

www.budinst.gov.kh www.elibraryofcambodia

មួយនោះមានបង្ហាញថាជារឿង ដែលកើតចេញពីការបញ្ចេញមតិយោបល់នោះយ៉ាងណាក៏ដោយ ក៏យើងមិនត្រូវឲ្យមានការប្រមាថមើលងាយ ឬការបន្តុះបង្អាប់ដែរ។

ដើម្បីចៀសវាងការឡើងទៅបង្ហាញមុខនៅតុលាការ ដូចនៅប្រទេសអូស្ត្រាលី អាមេរិក និងបារាំងជាដើម។ អ្នកសារពត៌មានត្រូវអនុវត្តន៍តាមគោលការណ៍មួយចំនួនដូចខាងក្រោមនេះ។

១- ត្រូវប្រកាន់ខ្ជាប់នូវសច្ចធម៌ អ្នកសរសេរអត្ថបទទាំងប្រុសទាំងស្រីត្រូវមានជំនឿជាក់ទៅលើមតិយោបល់របស់ខ្លួន។ ហើយបើមានរឿងដែលកើតចេញមកពីមតិយោបល់នោះ ក្លាយទៅជារឿងឆាកកំប្លែង ឬក៏ជារឿង ដែលស្មេរបានសរសេរដោយមកពីមានការមិនចូលចិត្ត ឬដោយសារមកពី មានបតិប្រឆាំង។

ដូច្នេះបន្ទាប់មកអ្នកសរសេរ ឬអ្នកសារពត៌មាននោះអាចនឹងត្រូវឡើងតុលាការពីបទចោទប្រកាន់ថា បានសរសេរ ឬនិយាយបរិហារកេរ្តិ៍អ្នកដទៃ។ បើតុលាការធ្វើការវិនិច្ឆ័យទៅរកឃើញថា មតិយោបល់នោះខ្វះសច្ចៈធម៌ មិនត្រឹមត្រូវ ឬការសរសេរនោះ គឺដើម្បីអោយសារពត៌មានរបស់ខ្លួនលក់ដាច់ដាច់ ឬដោយមានបំណងចង់ប្រមូលអ្នកអាន អ្នកស្តាប់ ឬអ្នកទស្សនាឲ្យបានច្រើន។ ដូច្នេះស្មេរនោះនឹងត្រូវទទួលការពិន័យទោសពីបទបរិហារកេរ្តិ៍។

២- ការបញ្ចេញមតិយោបល់ត្រូវតែឈរទៅលើអ្វីដែលជារឿងពិត គឺរឿងពិតដែលមានស្រាប់នៅក្នុងរឿងនោះ ឬក៏មានសាធារណៈជនដឹងឮច្រើន។

៣- ការបញ្ចេញមតិយោបល់ត្រូវធ្វើឲ្យបានត្រឹមត្រូវ អ្វីដែលត្រឹមត្រូវនោះវាបានបង្ករ ឲ្យមានជាមតិយោបល់នេះឡើង។ ជាពិសេស គឺជាមតិយោបល់ដែលកើតចេញពីការពិត និងដែលមានមនុស្សគ្រប់គ្នាបានដឹងរួចមកហើយ។

www.budinst.gov.kh www.elibraryofcambodia

## ការអនុវត្តន៍តាមវិជ្ជាជីវៈដើម្បីចៀសវាងបទបរិហារកេរ្តិ៍

**ច្បាស់លាស់ - ត្រឹមត្រូវ!**

នេះគឺជាកត្តាមួយដែលសំខាន់ជាងអ្វីៗទាំងអស់។ ឧបមាថាយើងសរសេរ ឈ្មោះរបស់មនុស្សម្នាក់ខុស គឺយើងត្រូវបាត់បង់នូវអ្វីៗទាំងអស់ក្នុងនាមខ្លួនជាអ្នកចុងចោទ។ នេះជាឧទាហរណ៍មួយនៅ អូស្រ្តាលីមានប៉ូលីសម្នាក់ត្រូវបានគេចោទពីបទពុករលួយ។ ប៉ុន្តែមានប៉ូលីសម្នាក់ទៀតមានឈ្មោះដូចគ្នាបេះបិទ តែគាត់ធ្វើការនៅក្នុងស្នងការដ្ឋានមួយផ្សេងទៀត។ អ្នកយកព័ត៌មានបានសរសេរអត្ថបទមួយអំពីរឿងពុករលួយនេះ ប៉ុន្តែអំពីបុគ្គលដែលគាត់លើកយកមកសរសេរនោះគឺខុស។ គាត់បានលើកអំពីប៉ូលីសដែលគ្មានពុំដឹងខ្លួនសោះមកសរសេរថា ជាមនុស្សជាប់ចោទ។ បន្ទាប់មកក៏មានការប្តឹងផ្តល់គ្នា ហើយប៉ូលីសដែលជាជនរងគ្រោះក៏បានឈ្នះ។

**ត្រូវចាំប្រយ័ត្នស្វែងយល់អំពីការពិត**

អ្វីដែលជាការពិត គឺជាទស្សនៈមួយដែលគេពុំអាចចាប់ផ្តាក់បានពីព្រោះបុគ្គលដែលបានប្រាប់យើងអំពីរឿងអ្វីមួយ តើយើងអាចសន្និដ្ឋានថាវាជាការពិតមែនឬ? ឧទាហរណ៍--មានលិខិតប្រកាសព័ត៌មានមួយរបស់បេក្ខជនម្នាក់នៅទីស្នាក់ការបោះឆ្នោតបានប្រកាសថា ក្រសួងសិក្សាធិការជាតិមិនល្អទេពីព្រោះមានកូនសិស្សចំនួនជាងពាក់កណ្តាល បន្ទាប់ពីបានធ្វើការប្រឡងសាកល្បងវិញ្ញាសារការអានបក ពួកគេទទួលបានពិន្ទុក្រោមមធ្យមភាគ។ តើនេះជាការ ពិតមែនឬ?

អ្នកយកព័ត៌មានម្នាក់បានសរសេរអត្ថបទស្តីពីការប្រយុទ្ធគ្នាដ៏ធំមួយនៅលើសមរភូមិ។ តាមការធ្វើសម្ភាសន៍កូនទាហានមួយរូបបានលើកអំពីសេចក្តីក្លាហាននៃឯកភាពរបស់ខ្លួន។ តើយើងអាចសន្និដ្ឋានថាសំដីរបស់កូនទាហានរូបនេះជាការពិតមែនទេ?

តុលាការម្នាក់ត្រូវបានគេចោទថា គាត់បានទទួលលុយច្រើនណាស់

www.budinst.gov.kh www.elibraryofcambodia

ពីអ្នកនយោបាយម្នាក់ ដែលកំពុងតែមានបញ្ហានៅចំពោះមុខច្បាប់។ បុគ្គលដែលបាននិយាយរឿងនោះប្រាប់ដល់អ្នក គេបានឲ្យអ្នកដឹងដែរថា គេនឹងមិនធ្វើសាក្សីនៅក្នុងរឿងនេះទេ។ ដូច្នេះតើអ្នកត្រូវធ្វើយ៉ាងណាទើបដឹងថារឿងនោះពិតមែន ឬមិនពិត?

នៅក្នុងច្បាប់បរិហារកេរ្តិ៍ ចួនកាលគឺវាហាក់ដូចជាមានការស្មុគស្មាញជាងអ្វីទាំងអស់។ ពីព្រោះអ្នកសារពត៌មានត្រូវតែបង្ហាញភស្តុតាងជាក់ស្តែងនៅចំពោះមុខតុលាការ។ ដូច្នេះតើយើងត្រូវធ្វើយ៉ាងណាដើម្បីស្រាវជ្រាវរកឲ្យឃើញថា តើអ្វីទៅដែលជាការពិតនោះ? មានអ្នកសារពត៌មានច្រើនណាស់ដែលត្រូវធ្វើការសាកល្បងដើម្បីរកឲ្យឃើញថា អ្វីដែលគេបាននិយាយប្រាប់នោះ តើគួរឲ្យជឿ និងតើអាចយកជាការបានដែរឬទេ? ឬមួយក៏ត្រូវមានការស៊ើបអង្កេតថែមទៀត។ ការសាកល្បងនេះត្រូវមានការរួមផ្សំទៅនឹងសំនួរដោយសួរខ្លួនឯងថា បើអញយករឿងនេះទៅសរសេរផ្សព្វផ្សាយ តើបុគ្គលដែលជាអ្នកនិយាយនូវរឿងនេះគាត់បានចំណេញអ្វីខ្លះ? ចូរពិនិត្យមើលឲ្យបានច្បាស់នៅលើឧទាហរណ៍ទីមួយ - យើងប្រហែលជាបានរកឃើញថា បេក្ខជនឈរឈ្មោះបោះឆ្នោតរូបនោះ គឺគាត់ប្រាកដជាចង់បានអំណាចអ្វី ដែលគាត់បាននិយាយអំពីប្រព័ន្ធសិក្សាធិការជាតិថាមិនល្អនោះ គឺជាការឃោសនាមួយដែលអាចជួយគាត់ស្វែងរកអំណាចមួយបាន។ ការឲ្យយោបល់ដូច្នេះគឺ អាចបណ្តាលធ្វើឲ្យអាជ្ញាធរដែលមានស្រាប់មានការកើតទុក្ខព្រួយពុំសុខចិត្ត។ ដូច្នេះចាំបាច់ យើងត្រូវពិនិត្យឲ្យបានល្អិតល្អន់ជាមុនសិនអំពីរឿងអ្វីមួយ ដែលគេបាននិយាយប្រាប់ដល់យើងនោះ។

ក្នុងករណីដូច្នេះជាដំបូងគឺ យើងត្រូវសួរខ្លួនឯងថា តើមានកូនសិស្សចំនួនប៉ុន្មាននាក់ដែលបានមកប្រឡងសាកនោះ? តើនៅមានកត្តាអ្វីខ្លះទៀតដែលបណ្តាលធ្វើឲ្យមានចំនួនកូនសិស្សប្រឡងធ្លាក់ច្រើនយ៉ាងនេះ? តើពួកគេសុទ្ធតែជាកូនអ្នកក្រទាំងអស់មែនឬ? តើមាននរណាខ្លះដែលគេពុំបានយកចិត្តទុកដាក់ក្នុងរឿងនេះ? តើយើងអាចសុំជួបជាមួយគាត់ដើម្បី

www.budinst.gov.kh www.elibraryofcambodia

និយាយអំពីរឿងប្រឡូងនេះបានដែរឬទេ? ការនិយាយលើកខ្លួនរបស់ទាហានរូបនោះ គឺដើម្បីចង់ឲ្យគេហៅគាត់ថា ជាវិរបុរសមែនឬ? តើគាត់ទើបនឹងត្រឡប់មកពីសមរភូមិមែនឬ? ឬមួយក៏គាត់ជាមនុស្សកំសាក? ចំពោះរឿងចៅក្រមកាត់សេចក្តី អំពីរឿងអ្នកនយោបាយម្នាក់នោះ តើយ៉ាងណាដែរ? តើអ្នកដែលនិយាយប្រាប់យើងអំពីរឿងនោះគាត់មានភស្តុតាងដែលអាចបង្ហាញថា អ្នកនយោបាយនោះបានប្រគល់ប្រាក់ឲ្យទៅតុលាការដែរឬទេ?

**ការសាកល្បងរកការពិត**

អ្នកសារពត៌មានដែលមានថ្វីដៃពូកែ ជួនកាលគេហ៊ានធ្វើការវែកញែករឿងមួយថា ជារឿងអាក្រក់។ ពីព្រោះគេមិនជឿលើអ្វី ដែលគេបានប្រាប់នោះទេ។ ទោះបីជាយ៉ាងដូច្នេះក៏ដោយ អ្នកសារពត៌មានប្រភេទនេះគឺគ្មានចង់បានអ្វីក្រៅពីចង់ឲ្យគេហៅពួកខ្លួនថាជាអ្នកមានវិជ្ជាជីវៈពិតប្រាកដ ពីព្រោះភាពប្រាកដនិយមរបស់ពួកគេគឺអាចជួយស្វែងរកការពិតមួយឃើញ។

**ចូរខ្មស្សាហ៍សួរខ្លួនឯងនូវសំនួរមួយចំនួនដូចខាងក្រោមនេះ**

១- តើប្រភពពត៌មាននោះមាន សមត្ថភាពអាចបង្ហាញការពិតដែរឬទេ? អ្វីដែលអ្នកនោះបាននិយាយប្រាប់ តើគាត់ទទួលបាននៅក្នុងពេលដែលគាត់កំពុងស្ថិតក្នុងសកម្មភាពមួយ ដូចជាបន្ទាប់ពីបានពិសារស្រាបៀរអស់ពីរ-បីកំប៉ុង ឬមួយក៏រឿងនោះបានមកដល់គាត់ ដោយមកពីគាត់មានតួនាទីជា អ្នកទទួលខុសត្រូវនៅក្នុងរឿងនោះ។

២- តើប្រភពនោះមានបំណងចង់ចំណេញអ្វីមួយ បន្ទាប់ពីដំណើងនោះត្រូវបានផ្សព្វផ្សាយ។

៣- បើមានអត្ថបទឯកសារសរសេរដោយដៃ ឬបោះពុម្ពដែលយើងយកវាមកប្រើជាប្រភពពត៌មាន។ យើងត្រូវសួរទៅគេវិញថា តើឯកសារនោះជាឯកសារប្រភេទណា? ជាឯកសារផ្លូវការដែលគេបានកត់ទុក? (ឯកសារប្រភេទនេះល្អណាស់ ពីព្រោះវាមានលក្ខណៈអព្យាក្រឹត្យ

www.budinst.gov.kh www.elibraryofcambodia

ស្រាប់-អ្វីដែលមាននៅក្នុងនោះ គឺសុទ្ធតែជារឿងពិត និងដែលប្រកបទៅដោយរូបភាពជាភស្តុតាង។) តើឯកសារនោះគេបានរៀបចំឡើងដើម្បីឥទ្ធិពលអ្វីមួយសំរាប់ជាប្រយោជន៍ដល់ពួកគេ ឯកសារប្រភេទនេះគឺច្រើនតែជាលិខិតប្រកាសពត៌មាន និងដែលជារឿយៗ គឺយើងត្រូវធ្វើការស៊ើបអង្កេត និងស្រាវជ្រាវបន្ថែម។

៥- តើមានអ្នកណាផ្សេងទៀតដែលអាចជួយបំភ្លឺលើករណីនេះបាន? តើបុគ្គលនោះឯករាជដែរឬទេ? តើការពន្យល់បកស្រាយរបស់បុគ្គលទីពីរ ឬទីបីមានខ្លឹមសារដូចគ្នានឹងបុគ្គលទីមួយដែរឬទេ?

នៅក្នុងបទសម្ភាសន៍មួយ អ្នកនយោបាយប្រឆាំងម្នាក់បាននិយាយអំពីរឿងរបស់រដ្ឋមន្ត្រីម្នាក់។ ការនិយាយ គឺបានធ្វើឡើងដោយគ្មានភស្តុតាង"ជាក់ស្តែង"ឡើយ។ អ្នកបានដកស្រង់យកសំដីរបស់គាត់មកសរសេរ។ បើអ្នកធ្វើដូច្នេះតើវាយុត្តិធម៌ដែរឬទេ? អង្គប្រជុំរបស់អង្គការក្រៅរដ្ឋាភិបាលមួយបានរៀបចំឡើងដើម្បីពិភាក្សាគ្នា អំពីបញ្ហាអេដស៍។ ប៉ុន្តែនៅក្នុងពេលនោះមានសមាជិកអង្គប្រជុំពីរនាក់ បានជជែកគ្នាយ៉ាងខ្លាំងរហូតដល់ធ្វើឲ្យមានការរំខានដល់អង្គប្រជុំទាំងមូល។ បន្ទាប់មកអ្នកបានយករឿងនោះមកសរសេរតែអ្នកពុំបានយកចិត្តទុកដាក់អំពីបញ្ហាអេដស៍សោះ។ បើអញ្ចឹងតើមានយុត្តិធម៌ដែរឬទេ? បាតុកម្មមួយដែលធ្វើឡើងដោយកូនសិស្សបានក្លាយកាន់តែសាហាវឡើងៗ។ មានបនុស្សចំនួនដប់នាក់ត្រូវបានប៉ូលីសចាប់ខ្លួន។ អ្នកបានយករឿងបាតុកម្ម និងការចាប់ចងរបស់ប៉ូលីសនោះមកសរសេរ តែអ្នកពុំបានសរសេរអំពីអ្វី ដែលមាននៅពីក្រោយបាតុកម្មនោះទេ។ បើអញ្ចឹងតើយុត្តិធម៌ដែរឬទេ? ន័យពិតប្រាកដរបស់ពាក្យថាយុត្តិធម៌ គឺមានការពិបាកខ្លាំងណាស់ដើម្បីនឹងធ្វើឲ្យបានសំរេច។ ប៉ុន្តែចូរយើងនាំគ្នាមើលលើក្របសីលធម៌មួយចំនួន ដែលអាចជួយដល់យើងឲ្យយល់ និងស្គាល់អំពីអ្វីដែលហៅថាយុត្តិធម៌នោះ។

www.budinst.gov.kh www.elibraryofcambodia



វគ្គសិក្សាក្រមសីលធម៌អ្នកសារពត៌មាន

www.budinst.gov.kh www.elibraryofcambodia

## ក្រមសីលធម៌សំរាប់សារពត៌មានដកស្រង់ចេញពីប្រទេសមួយចំនួន

### គោលការណ៍សំរាប់ការផ្សព្វផ្សាយ (ច្បាប់សារពត៌មាន) ដែលបានរៀបចំឡើងដោយក្រុមប្រឹក្សាសារពត៌មានអាល្លឺម៉ង់

សេរីភាពសារពត៌មាន ត្រូវបានធានានៅក្នុងច្បាប់ជាមូលដ្ឋាននៃសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ គឺមានស្ដីអំពីឯករាជ្យភាពជាមួយ និងសេរីភាពនៃពត៌មាន, ការបញ្ចេញទស្សនៈយោបល់ និងការរិះគន់ទិតៀន។ ក្នុងការងាររបស់ខ្លួន ក្នុងនាមជាចាងហ្វាងការផ្សាយ, និពន្ធនាយក និងអ្នកកាសែតទាំងអស់ត្រូវចងចាំជានិច្ចនូវការទទួលខុសត្រូវចំពោះមុខសាធារណជនទូទៅ និងអំពីកិត្យានុភាពរបស់ខ្លួនជាអ្នកសារពត៌មាន។ ពួកគេទាំងអស់ត្រូវតែសំដែងចេញនូវតួនាទីរបស់ខ្លួនដោយខំប្រឹងឲ្យអស់ពីសមត្ថភាព និងជំនឿ ហើយនិងមិនត្រូវអនុញ្ញាតិឲ្យការងាររបស់ខ្លួនទទួលរងនូវឥទ្ធិពលពីបុគ្គលដែលគិតតែពីផលប្រយោជន៍ផ្ទាល់ខ្លួន ឬពីការបំផុសបំផុលណាមួយ។ គោលការណ៍សំរាប់ការផ្សព្វផ្សាយនេះ បានរៀបចំឡើងសំរាប់ការពារឲ្យបាននូវសីលធម៌ក្នុងការប្រកបវិជ្ជាជីវៈ គឺពុំមែនពាក់ព័ន្ធឡើងដើម្បីឲ្យខូចប្រយោជន៍ខាងផ្លូវច្បាប់នោះឡើយ។

១. ត្រូវគោរពឲ្យបាននូវធាតុពិត និងភាពត្រឹមត្រូវ ដែលមតិសាធារណៈបានលើកឡើង នេះគឺជ័យជំនះមួយរបស់អ្នកការសែត។

២. ដំណឹង និងពត៌មានដែលបានយល់ព្រមទទួលយកមកចុះជាអត្ថបទ ឬជា រូបភាពសំរាប់ផ្សព្វផ្សាយ គឺត្រូវតែឲ្យមានការត្រួតពិនិត្យឲ្យបានល្អិតល្អន់ទៅតាមកាលៈទេសៈ ដែលហុចឲ្យដើម្បីរកមើលឲ្យឃើញនូវភាពត្រឹមត្រូវ។

ន័យរបស់វា គឺមិនត្រូវធ្វើឲ្យខុសពីភាពដើម ឬសរសេរក្បាលលិខិត ឬដាក់ចំណងជើងតាមការកែបន្ថំ។ មាតិការឿងរបស់ឯកសារនិមួយៗ គឺត្រូវ តែសំដែងឲ្យឃើញនូវភាពស្មោះត្រង់នៅក្នុងការ ដែលយកទៅ

www.budinst.gov.kh www.elibraryofcambodia

ផលិតឡើងវិញ។ សេចក្តីរាយការណ៍ណាមួយ ដែលពុំមានការជំរាបឲ្យបានដឹងជាមុន, ពាក្យចចាមអារាម និងអ្វីដែលជាការស្មាន គឺត្រូវតែរកឲ្យឃើញនូវការពិត។ នៅទីណាមានរូបភាពជានិមិត្តរូបមួយដែលត្រូវយកមកបោះពុម្ពផ្សាយ ចាំបាច់គឺត្រូវមានការបញ្ជាក់នៅលើចំណងជើងឲ្យបានច្បាស់ថា នេះគឺមិនមែនជាឯកសារមួយនៃរូបភាពនោះទេ។

៣. ការបោះពុម្ពផ្សាយរបាយការណ៍ ឬការអះអាងណាមួយ ដែលគេបានរកឃើញនូវកំហុសជាបន្តបន្ទាប់ គឺត្រូវតែឆាប់ធ្វើការកែសំរួលជាបន្ទាន់ និងឲ្យបានសមរម្យតាមការយល់ឃើញរបស់ការបោះពុម្ពផ្សាយ។

៤. របៀបរបបដែលមិនទៀងត្រង់គឺ មិនត្រូវឲ្យមានជាដាច់ខាតនៅក្នុងការងារចាំទទួលដំណឹង, ពត៌មាន ឬរូបភាព។

៥. តាមគោលការណ៍ជាទូទៅ ការយល់ព្រមគ្នាអំពីរឿងសំងាត់ណាមួយដែលទទួលបានមកពីអង្គប្រជុំ ឬពីជុំវិញនៃបទសំភាសន៍ គឺត្រូវធ្វើការអង្កេតឡើងវិញ។

៦. គ្រប់អ្នកកាសែតទាំងអស់ត្រូវរក្សាឲ្យបាននូវរាល់ការសំងាត់ ត្រូវចេះប្រើសិទ្ធិរបស់ខ្លួនក្នុងការមិនផ្តល់ភស្តុតាង និងទប់ស្កាត់មិនឲ្យមានការបង្ហាញ អត្តសញ្ញាណរបស់អ្នកផ្តល់ពត៌មានដល់អ្នកផ្សេង ដោយគ្មានការយល់ព្រមពីសាម៉ីខ្លួនជាមុន។

៧. ភារកិច្ចទទួលខុសត្រូវរបស់អ្នកកាសែត ចំពោះមុខសាធារណៈជនគឺត្រូវហាមប្រាមចោល នូវការបោះពុម្ពផ្សាយនៃបទវិចារណកថាណាដែលបានទទួលឥទ្ធិពលពីឯកជន និងជាផលប្រយោជន៍ក្នុងការរកស៊ីរបស់ភាគីទីបី។ ចាងហ្វាងការផ្សាយ និងនិពន្ធនាយកត្រូវទប់ទល់ឲ្យបាននូវគ្រប់ការប៉ុនប៉ងដូចខាងលើនេះ និងត្រូវធានាឲ្យបានថាគ្រប់វិចារណកថា និងការផ្សព្វផ្សាយពាណិជ្ជកម្មទាំងអស់ គឺត្រូវ

www.budinst.gov.kh www.elibraryofcambodia

ចែកឲ្យដាច់ពីគ្នា។ ការផ្សាយពាណិជ្ជកម្មតាមរបេះការចេញជាសេចក្ដីប្រកាសជារូបថត និងជារូបគំនូរ គឺត្រូវមានបញ្ជាក់តាមភិនភាគដូចមានរៀបរាប់រួចមកស្រាប់។

៨. អ្នកកាសែតត្រូវតែគោរពដល់ជីវិតរបស់បុគ្គល និងអ្វីដែលមាននៅជុំវិញបុគ្គល។ បើទោះបីជាឥរិយាបថរបស់បុគ្គលនោះធ្វើឲ្យមានការប៉ះពាល់ដល់ ផលប្រយោជន៍សាធារណៈយ៉ាងណាក៏ដោយ អ្នកកាសែតត្រូវតែលើកយកករណីនោះមកពិភាក្សាគ្នាជាមុនសិន។ ករណីដូចនេះត្រូវតែឲ្យមានការប្រុងប្រយ័ត្នជានិច្ច ដើម្បីធានាឲ្យបានថាការបោះពុម្ពផ្សាយនោះមិនរំលោភ ទៅលើសិទ្ធិរបស់បុគ្គលផ្សេងទៀតដែលពុំមានការពាក់ព័ន្ធ។

៩. វាគឺជាការផ្ដួយស្រឡះទៅនឹងសុភាវធម៌របស់អ្នកសារពត៌មាន ដែលបានធ្វើការផ្សព្វផ្សាយនូវពាក្យចោទប្រកាន់ណាមួយ ដោយឥតមានមូលហេតុជាពិសេស គឺពាក្យចោទប្រកាន់ ដែលមានលក្ខណៈបង្ខូចកេរ្តិ៍ឈ្មោះ។

១០. ការបោះពុម្ពផ្សាយឯកសារ ឬរូបភាពរបស់នរណាម្នាក់ ឬមាតិការឿងដែលនាំឲ្យមានការរអាក់អន់ចិត្ត ឬអំពីការរំដើបរំជួលនៃសាសនារបស់ក្រុមមនុស្សណាមួយ ទាំងអស់នេះគឺវាផ្ទុយទៅនឹងការទទួលខុសត្រូវរបស់អ្នកកាសែត។

១១. អំពើហិង្សា និងអំពើឃោរឃៅ គឺមិនត្រូវឲ្យមានការបំផ្លើសជាដាច់ខាត។ នៅក្នុងសេចក្ដីរាយការណ៍ គឺត្រូវតែឲ្យមានការយកចិត្តទុកដាក់ទៅលើអ្វី ដែលជាសេចក្ដីត្រូវការសំរាប់ការពារដល់កុមារ។

១២. មិនត្រូវឲ្យមានការប្រកាន់រវាងមនុស្សដូចគ្នា, ភេទ, ពូជសាសន៍, ជនជាតិ, សាសនា, សង្គមនៃមនុស្សមួយក្រុម ឬសញ្ជាតិ។

១៣. ការធ្វើសេចក្ដីរាយការណ៍អំពីបទឧក្រិដ្ឋណាមួយ ដែលកំពុងស្ថិតនៅក្រោមការស៊ើបអង្កេត ឬដែលតុលាការនៅពុំទាន់បានធ្វើការវិនិច្ឆ័យ

www.budinst.gov.kh www.elibraryofcambodia

ករណីនេះ គឺត្រូវបានហាមដាច់ខាតមិនឲ្យមានការបញ្ចេញ មតិយោបល់អ្វីទាំងអស់។ នៅមុន និងក្នុងពេលដែលកំពុងមានករណីដូចខាងលើទោះជាយ៉ាងណាក៏ដោយ អ្នកកាសែតមិនត្រូវមានមតិយោបល់អ្វីនៅក្នុងសេចក្តីផ្តើម ឬអង្គសេចក្តីនៃសេចក្តីរាយការណ៍មួយ ដែលមានការបកស្រាយថា ជាការប្រកាន់បក្ខពួក ឬដែលនាំឲ្យខូចប្រយោជន៍ដល់ករណីដូចខាងលើ។ ចំពោះអ្នកដែលកំពុងទទួលរងនូវការចោទប្រកាន់ គឺមិនត្រូវឲ្យមានការលើកបង្ហាញថា ជាភាគីដែលបានប្រព្រឹត្តខុស នៅមុនពេលតុលាការកាត់ទោសបានឡើយ។ ទោះជានៅទីណាក៏ដោយ ចំពោះករណីកូនក្មេង ដែលបានប្រព្រឹត្តខុសច្បាប់បន្តិចបន្តួច គឺត្រូវបានហាមឃាត់ មិនឲ្យមានការបង្ហាញឈ្មោះ និងរូបថតជាអត្តសញ្ញាណនៅលើការបោះពុម្ពផ្សាយណាមួយដោយពុំមានការ ពិចារណាអំពីអនាគតនៃយុវភាពនោះបានឡើយ។ នៅក្នុងពេលដែល តុលាការកំពុងធ្វើការវិនិច្ឆ័យ គឺត្រូវបានហាមដាច់ខាតមិនឲ្យធ្វើសេចក្តី រាយការណ៍ដោយពុំមានយុត្តិកម្មនៅមុនពេលតុលាការចេញសេចក្តីសំរេចចិត្តជាផ្លូវការនោះឡើយ។

១៤. នៅក្នុងសេចក្តីរាយការណ៍អំពីករណីពេទ្យ ឬអ្នកជំងឺ គឺត្រូវឲ្យមានការប្រុងប្រយ័ត្នជាប់ជានិច្ច ដើម្បីជៀសវាងឲ្យបាននូវភាពរំជើបរំជួលដែលនាំឲ្យអ្នកអានមានការភ័យខ្លាចដោយគ្មានភស្តុតាង ឬបាត់បង់នូវក្តីអស់សង្ឃឹម។ ការរកឃើញនូវការចាប់ផ្តើមនៃការស្រាវជ្រាវណាមួយ គឺមិនត្រូវលើកយកមកបង្ហាញថាជារឿងដែលបានសំរេច ឬក៏ជិតបានសំរេចហើយឲ្យសោះ។

១៥. ការទទួលយក ឬការផ្តល់ឲ្យនូវអ្វីដែលជាបុព្វសិទ្ធិ និងដែលនាំឲ្យមានការទន្ទ្រានទៅលើការបោះពុម្ពផ្សាយ ឬការប្រុងប្រយ័ត្នក្នុងការសរសេរវិចារណកថា គឺមិនអាចស៊ីចង្វាក់គ្នាជាមួយនឹងគំនិតដែលគួរឲ្យគោរព, ឯករាជ, និងការទទួលខុសត្រូវរបស់អ្នកកាសែតបានទេ។

www.budinst.gov.kh www.elibraryofcambodia

នរណាម្នាក់ទទួលសំណូក ដើម្បីធ្វើឲ្យមានការផ្សព្វផ្សាយ ឬទប់ស្កាត់ដំណឹង គឺត្រូវទទួលទោសថាជាអ្នកមិនសុចរិតទៀងត្រង់ និងនៅខ្វះជំនាញក្នុងការងារ។

១៦. ដើម្បីជាប្រយោជន៍ដល់សេចក្តីរាយការណ៍ដ៏ត្រឹមត្រូវមួយ ការស្តីបន្ទោសជាសាធារណៈ ដែលបានធ្វើឡើងដោយក្រុមប្រឹក្សាសារពត៌មានអាល្លឺម៉ង់ ជាធម្មតាគឺត្រូវបានផ្សព្វផ្សាយនៅក្នុងសារពត៌មានណាដែលមានការពាក់ព័ន្ធ។

**ក្រមសីលធម៌របស់សមាគមអ្នកសារពត៌មានអូស្ត្រាលី**

**(The Australian Journalists Association Code of Ethics)**

អនុប្រយោគ ទី១ : (សមាជិករបស់ ស.អ.អ.) ...ត្រូវតែរាយការណ៍ និងធ្វើការបកប្រែដំណឹងដោយក្តីស្មោះត្រង់ជាទីបំផុតដើម្បីនឹងបង្ហាញឲ្យគេឃើញច្បាស់នូវរាល់ការពិតទាំងអស់ និងដោយពុំមានធ្វើការហាមនូវអ្វីផ្សេងទៀតដែលពាក់ព័ន្ធទៅនឹងរឿងពិតនោះ ឬដែលធ្វើឲ្យខុសពីភាពដើម ឬដែលមានការដៅបញ្ឆោតដោយខុសឆ្គង។

អនុប្រយោគ ទី២ : ពួកគេមិនត្រូវស្រង់យកនូវអ្វីដែលពុំចាំបាច់នោះមកសំដែងចេញដោយប្រកាន់ថា ជាភេទប្រុស ឬស្រី ជារឿងពូជសាសន៍មាន ទំនោរចិត្ត ទៅលើភេទ ជំនឿ សាសនា ឋានៈ រវាងប្តី និងប្រពន្ធ ឬអំពីសមត្ថភាពផ្នែកកម្លាំងបាយ ឬកម្លាំងប្រាជ្ញា។

អនុប្រយោគ ទី៣ : ពួកគេត្រូវតែខំបញ្ចេញឲ្យអស់លទ្ធភាពដើម្បីកែតម្រូវនូវរាល់ពត៌មានដែលបានបោះពុម្ពផ្សាយ ឬផ្សព្វផ្សាយតាមរលកធាតុអាកាស បន្ទាប់ពីបានរកឃើញថា វាមិនត្រឹមត្រូវ និងនាំមកនូវទុក្ខទោស។

**ចិជ្ជាជីវៈសារពត៌មាននៃសង្គមអាមេរិកាំង**

**(The American Society of Professional Journilsts)**

គ្រប់ពេលវេលាទាំងអស់អ្នកសារពត៌មាន ត្រូវបង្ហាញនូវការគោរពចំពោះអ្វីដែលជាសេចក្តីថ្លៃថ្នូរចំពោះសិទ្ធិជាឯកជន និងសុខមាលភាពរបស់

www.budinst.gov.kh www.elibraryofcambodia

បុគ្គល ដែលមានមុខវិជ្ជាជាអ្នកប្រមូល និងផ្សព្វផ្សាយដំណឹង... ប្រព័ន្ធពត៌មានពុំត្រូវធ្វើការផ្សព្វផ្សាយឲ្យគេដឹងអំពីរឿងចោទប្រកាន់ក្រៅផ្លូវការ "នាំឲ្យមានការប៉ះពាល់ដល់កេរ្តិ៍ឈ្មោះ ឬចរិតណាមួយដោយពុំអនុញ្ញាតិឲ្យខាងចុងចោទមានឱកាសឆ្លើយតប (ទៅនឹងការចោទប្រកាន់ទាំងនោះ)។

**សមាគមចាងហ្វាងវិទ្យុ-ទូរទស្សន៍ (សហរអ)**

**(The Radio Television News Director's Association, USA)**

ការផ្សព្វផ្សាយពត៌មានតាមរលកធាតុអាកាស ត្រូវរៀបចំឡើងដោយមិនគ្រាន់តែដើម្បីនឹងជំរាបជូនអំពីពេលវេលា និងពត៌មានត្រឹមត្រូវតែប៉ុណ្ណោះទេ។ ប៉ុន្តែករណីដែលចាំបាច់ដូចគ្នាដែរនោះគឺ ត្រូវធ្វើការបង្ហាញនូវភស្តុតាងដោយសំរាំងទៅ លើហេតុការណ៍មួយដ៏មានខ្លឹមសារ និងដែលជាទស្សនៈ។

ការយល់ឃើញដូច្នេះ នៅបស្ចឹមប្រទេសគឺ ពុំមែនមានតែមួយគត់នោះទេ។

**សមាគមអ្នកសារពត៌មានឥណ្ឌូណេស៊ី**

**(Indonesian Journalist's Association)**

វិធីសាស្ត្រដើម្បីរាយការណ៍ និងការបញ្ចេញទស្សនៈ អ្នកសារពត៌មានឥណ្ឌូនេស៊ីគ្រប់រូបត្រូវ :

១. មធ្យោបាយចុងក្រោយបំផុតគឺ សំដែងការស្មោះត្រង់នៅក្នុងការប្រមូលឧបករណ៍សំរាប់ដំណឹងមួយ ...

២. ពិនិត្យពត៌មាននោះឡើងវិញដើម្បីគោរពឲ្យបាននូវសច្ចៈធម៌ និងច្បាស់លាស់ ឬតាមហេតុការណ៍ពិតនៅមុនពេលធ្វើការបោះពុម្ពផ្សាយ។ ត្រូវពិចារណាឡើងវិញអំពីអ្វីដែលបានទទួលពីប្រភពពត៌មានទាំងអស់។

៣. ត្រូវធ្វើការគូសបង្ហាញឲ្យបានច្បាស់អំពី ទស្សនៈយោបល់ និងហេតុការណ៍ពិត ដែលបានលើកយកមកសរសេរជាដំណឹង។ ធ្វើដូច្នេះគឺ

www.budinst.gov.kh www.elibraryofcambodia

ទស្សនៈ យោបល់ និងហេតុការណ៍ពិតវាមិននៅច្របល់គ្នា។
៤. សរសេរចំណងជើងបង្ហាញអំពីមាតិការបទនៃដំណឹង។
៥. គ្រប់ពេលទាំងអស់ត្រូវរក្សាឲ្យបាននូវកម្មវិស័យភាព សេចក្ដីទុកចិត្ត និងមិនលំអៀងនៅក្នុងការសរសេរ ឈ្មោះរបស់ម្ចាស់អត្ថបទ ដោយបញ្ជាក់ថា ទស្សនៈរបស់គាត់ដែលបានលើកមកនេះ គឺយោងតាមសេរីភាពក្នុងការ ទទួលខុសត្រូវ និងមិនត្រូវសរសេរបន្ថែមដែលនាំឲ្យមានការជះឥទ្ធិពល មិនល្អទៅលើសេចក្ដីថ្លៃថ្នូររបស់ឯកជន ឬក្នុងន័យបំផ្លើសដោយខ្វះសីលធម៌ ឬប្រាសចាកពីភាពដើម។
៦. សេចក្ដីគោរព គឺជាផ្ទុយទោសកម្មនៃការបោះពុម្ពផ្សាយដំណឹង ឬអត្ថបទដែលពុំឃើញថា មានការចោទប្រកាន់ ពាក្យចចាមអារាម ពាក្យបំបះបំបោរ ដែលនាំឲ្យមានទុក្ខទោសដល់សន្តិសុខជាតិ ឬរដ្ឋ ឬពាក្យមួលបង្កាច់ធ្វើឲ្យខុសពីហេតុការណ៍ពិត។
៧. ប្រតិបត្តិតាមគោលការណ៍ ដែលបានសន្មត់ទុកជាមុនអំពីនិរទោស នៅពេល ដែលចង់សរសេរអត្ថបទស្ដីពីការកាត់ទោសក្នុងបទឧក្រិដ្ឋកម្មណាមួយ។
៨. ការបោះពុម្ពផ្សាយត្រូវប្រុងប្រយ័ត្នជាទីបំផុត អំពីការសរសេរនាមឲ្យពេញអត្តសញ្ញាណ និងរូបថតរបស់បុគ្គលជាប់ចោទ។

សិទ្ធិឆ្លើយតបៈ

១. ដកចេញ ឬកែតម្រូវនូវពាក្យដែលមិនត្រឹមត្រូវ ឬដែលខុសឆ្គង។
២. ត្រូវដឹងថាបុគ្គលដែលមានការរអាក់អន់ចិត្តនឹងអ្វី ដែលមិនត្រឹមត្រូវណាមួយ គេមានសិទ្ធិធ្វើសេចក្ដីកែតម្រូវដើម្បីជួយធ្វើឲ្យការបោះពុម្ពផ្សាយនោះមានរបៀបរបបត្រឹមត្រូវឡើងវិញ។

**សហព័ន្ធអ្នកសារពត៌មានជាតិ – ម៉ាឡេស៊ី**

**(National Union of Journalists - Malaysia)**

២. (អ្នកសារពត៌មានម៉ាឡេស៊ីគ្រប់រូបត្រូវ) អនុលោមតាមករណីកិច្ច។

www.budinst.gov.kh www.elibraryofcambodia

ប្រមូលពត៌មាន និងការបោះពុម្ពផ្សាយដំណឹង ហើយនិងសិទ្ធិក្នុងការបញ្ចេញមតិយោបល់ដ៏ត្រឹមត្រូវ និងទិះទៀន។

៣. អ្នកសារពត៌មានត្រូវសរសេរអត្ថបទ ដោយយោងតាមហេតុការណ៍ពិត គឺជាហេតុកាណ៍ដែលខ្លួនបានឮ បានឃើញផ្ទាល់។ ពួកគេមិនត្រូវផ្តល់ ពត៌មានបំភ្លើស ឬធ្វើការក្លែងបន្លំលើឯកសារណាមួយឡើយ . . .។

៥. ពត៌មានណាមួយដែលបានបោះពុម្ពផ្សាយចេញទៅ ហើយត្រូវបានរកឃើញថា មានលក្ខណៈមិនត្រឹមត្រូវ និងដែលនាំឲ្យមានទុក្ខទោស ពួកគេត្រូវផ្តល់ឱកាសឲ្យមានការកែតម្រូវ។

**ក្លឹបអ្នកសារពត៌មានជាតិ ហ្វីលីពីន**

**(NationalPress Club of the Philippines)**

ខ្ញុំត្រូវសរសេរអត្ថបទ និងធ្វើការបកប្រែដំណឹងមួយឲ្យបានហ្មត់ចត់ យកចិត្តទុកដាក់ មិនសរសេរបំផ្លើសការពិត ឬធ្វើឲ្យខុសពីភាពជាក់ស្តែង ដោយសារ បកពីការធ្វេសប្រហែស ការខុសឆ្គង និងការបញ្ជាក់មិនត្រឹមត្រូវ។

**ក្រមសីលធម៌សំរាប់សារពត៌មាន របស់អ្នកសារពត៌មានថៃ**

**(Journalist's Code of Ethics of the Thai Journalists)**

... អ្នកសារពត៌មានជនជាតិថៃទាំងអស់បានយល់ព្រមថា ៖

២. ត្រូវធ្វើការផ្តល់ដំណឹង រូបថត និងទស្សនៈផ្សេងៗឲ្យបានសមស្រប និងត្រូវ ចេះគួរសម ដោយពុំគិតពីផលប្រយោជន៍របស់បុគ្គល។

៣. មិនត្រូវផ្តល់នូវដំណឹងដែលប្រាសចាកពីហេតុការណ៍ពិត និងត្រូវធ្វើការកែតម្រូវជាបន្ទាន់ចំពោះការខុសឆ្គងណាមួយ ឬក្នុងការបោះពុម្ពផ្សាយណាមួយ ដែលមិនត្រឹមត្រូវ។

**បរិសិដ្ឋ ទីមួយ**

**ច្បាប់ស្តីពីរបបសារពត៌មាននៃព្រះរាជាណាចក្រកម្ពុជា**

**ជំពូកទីមួយ: សិទ្ធិ និង សេរីភាពខាងសារពត៌មាន**

www.budinst.gov.kh www.elibraryofcambodia

**មាត្រាមួយ:**

ច្បាប់នេះកំណត់របបសារពត៌មាន និងធានារ៉ាប់រងសេរីភាពសារពត៌មាន និងសេរីភាពខាងបោះពុម្ពផ្សាយឲ្យបានសមស្របតាមមាត្រា ៣១ និងមាត្រា៤១ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រាពីរ:**

សារពត៌មានមានសិទ្ធិរក្សាការសម្ងាត់ស្ដីពីប្រភពពត៌មានរបស់ខ្លួន ។

**មាត្រាបី:**

ដើម្បីរក្សាឯករាជ្យនៃសារពត៌មាន ការត្រួតពិនិត្យមុនពេលបោះ ពុម្ពផ្សាយត្រូវហាមឃាត់ ។

**មាត្រាបួន:**

ការបោះពុម្ពទូវពត៌មានផ្លូវការដូចជា សេចក្ដីថ្លែងការណ៍ ការប្រជុំ កំណត់ហេតុប្រជុំ ឬរបាយការណ៍ណាមួយ ។ល។ មិនអាចត្រូវផ្ដន្ទាទោសបានឡើយប្រសិនបើ ការផ្សាយនោះមានលក្ខណៈសមស្របតាមសភាពពិតពេញលេញ ឬមានសេចក្ដីសង្ខេបត្រឹមត្រូវតាមរឿងពិត។ ពត៌មានផ្លូវការដែលជាកម្មវត្ថុនៃមាត្រានេះ គឺសំដៅចំពោះ ៖

១- សេចក្ដីថ្លែងការណ៍ ការប្រជុំ កំណត់ហេតុប្រជុំ ឬរបាយការណ៍របស់រដ្ឋសភារាប់ទាំងគណៈកម្មាធិការ ឬគណៈកម្មការនានារបស់រដ្ឋសភាផងលើកលែងតែ ក្នុងករណីរដ្ឋសភា មានការប្រជុំសម្ងាត់ដូចមានចែងនៅក្នុងមាត្រា៨៨នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។

២- សេចក្ដីថ្លែងការណ៍ ការប្រជុំ កំណត់ហេតុប្រជុំ ឬរបាយការណ៍នៃផ្នែកនីតិប្រតិបត្តិរួបទាំងសេចក្ដីថ្លែងការណ៍របស់រដ្ឋមន្ត្រី និងមន្ត្រីនានា។

៣- គ្រប់ទិដ្ឋភាពនៃដំណើរការរបស់តុលាការ រាប់ទាំងនីតិវិធីទាំងឡាយផងលើកលែងតែក្នុងករណីដូចខាងក្រោមនេះ ៖

- តុលាការហាមមិនឲ្យបើកចំហដល់សាធារណជន
- បញ្ញត្តិដោយមាត្រា១៦ នៃច្បាប់នេះដែលទាក់ទងទៅនឹងអាជ្ញាធរកំបាំងរបស់

www.budinst.gov.kh www.elibraryofcambodia

បុគ្គលម្នាក់ៗនៅក្នុងដំណើរការជំនុំជំរះក្តី

- សំណុំរឿង ដែលនៅក្នុងការអង្កេតស៊ើបសួររបស់តុលាការនៅឡើយ។

**មាត្រាឧទ្ទាំៈ**

ក. គោលការណ៍ទូទៅៈ សារពត៌មានមានសិទ្ធិទទួលពត៌មាន ដែលស្ថិតក្នុងការគ្រប់គ្រងរបស់រាជរដ្ឋាភិបាល។ លើកលែងតែពត៌មានណាដែលបណ្តាលឲ្យ :

- អន្តរាយដល់សន្តិសុខជាតិ
- អន្តរាយដល់ទំនាក់ទំនងជាមួយប្រទេសដទៃ
- មានការបំពានលើសិទ្ធិរបស់បុគ្គលម្នាក់ៗ ដោយរាប់ទាំងសំណុំរឿងរបស់មន្ត្រី រាជការ សំណុំរឿងពេទ្យ សំណុំរឿង និងឯកសារផ្លូវការសម្ងាត់ដទៃទៀតជាដើម។
- មានការលាតត្រដាងឯកសារសម្ងាត់ផ្នែកពាណិជ្ជកម្ម ផ្នែកហិរញ្ញវត្ថុដែលបានមកពីបុគ្គល ឬអង្គភាពត្រឹមត្រូវតាមច្បាប់ណាមួយ និងការលាតត្រដាងនូវពត៌មានដែលពាក់ព័ន្ធទៅនឹងបទបញ្ញា ឬការត្រួតពិនិត្យរបស់ស្ថាប័ន ហិរញ្ញវត្ថុ។
- ប៉ះពាល់ដល់សិទ្ធិជនណាម្នាក់ ក្នុងការនាំឲ្យមានជំនុំជំរះក្តីដោយអយុត្តិធម៌។
- មានគ្រោះថ្នាក់ដល់មន្ត្រីដែលត្រូវអនុវត្តច្បាប់ ឬត្រូវបំពេញបេសកកម្ម។

ខ. ការស្នើសុំពត៌មានៈ ការស្នើសុំពត៌មានត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ ហើយត្រូវបញ្ជាក់ឲ្យច្បាស់លាស់ អំពីពត៌មានដែលស្នើសុំទៅស្ថាប័ននានា។ មន្ត្រីមានសមត្ថកិច្ចដែលគ្រប់គ្រងស្ថាប័ននោះ ត្រូវឆ្លើយតបទៅនឹងពាក្យសុំក្នុង រយៈពេលសាមសិបថ្ងៃ(៣០ថ្ងៃ)យ៉ាងយូរ។ ប្រសិនបើការស្នើសុំនោះ ត្រូវបានបដិសេធទាំងស្រុង ឬខ្លះៗនោះ។ ហេតុផលនៃការបដិសេធត្រូវបញ្ជាក់ឲ្យច្បាស់លាស់ជាលាយលក្ខណ៍អក្សរដែរ។

www.budinst.gov.kh www.elibraryofcambodia

**ជំពូកទីពីរ : ការទទួលខុសត្រូវនៃអ្នកសារព័ត៌មាន**

**មាត្រាទីមួយ:**

អ្នកសារព័ត៌មានមានសិទ្ធិបង្កើតសមាគមអ្នកសារព័ត៌មាន។ សមាគមអ្នកសារព័ត៌មាននោះត្រូវមានលក្ខណៈឯករាជ្យ។ សមាគមអ្នកសារព័ត៌មាននីមួយៗ ត្រូវអនុម័តលក្ខន្តិកៈរបស់ខ្លួនដែលមិនផ្ទុយនឹងច្បាប់ជាធរមាន ដោយមានការយល់ព្រមពីសមាជិកតាមការបោះឆ្នោត។ អ្នកដឹកនាំសមាគមអ្នកសារព័ត៌មានដែលជាសមាជិក ក្រុមអភិបាលត្រូវមានការបោះឆ្នោតជ្រើសរើសតាមលក្ខណៈប្រជាធិបតេយ្យ។

**មាត្រាទីពីរ:**

សមាគមអ្នកសារព័ត៌មាននីមួយៗ ត្រូវតាក់តែងក្រមសីលធម៌ដើម្បីអនុវត្តការងារក្នុងសមាគមរបស់ខ្លួនដែលអ្នកសារព័ត៌មាន មានកាតព្វកិច្ចគោរពគោលការណ៍ចាំបាច់ជាអាទិ៍ដូចតទៅ :

- គោរពសច្ចៈធម៌ និង គោរពសិទ្ធិ យល់ដឹងនូវសច្ចៈធម៌របស់សាធារណជន
- ត្រូវផ្សាយដំណឹងដោយសុចរិត ព្រមទាំងធ្វើអត្ថាធិប្បាយ ឬរិះគន់ឲ្យត្រឹមត្រូវ និងសមស្របតាមគតិយុត្តិធម៌ ។
- ត្រូវរាយការណ៍តាមហេតុការណ៍ ដែលខ្លួនដឹងពីប្រភពដើមតែប៉ុណ្ណោះ។ អ្នកសារព័ត៌មានមិនត្រូវបំបាត់ចោលនូវព័ត៌មានសំខាន់ៗ ឬកែបន្លំឯកសារ ផ្សេងៗឡើយ។
- ប្រើវិធីសុចរិតត្រឹមត្រូវដើម្បីស្វែងរកដំណឹង រូបថត និងឯកសារផ្សេងៗ។
- ត្រូវធ្វើការកែតម្រូវនូវព័ត៌មានណា ដែលចេញផ្សាយរួចហើយៗ មានលក្ខណៈមិនជាក់លាក់ និងនាំឲ្យមានការយល់ច្រឡំ។
- ត្រូវចៀសវាងការផ្សព្វផ្សាយព័ត៌មាន ដែលញុះញង់ឲ្យមានការប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿ សាសនា មតិ ឬ

www.budinst.gov.kh www.elibraryofcambodia

និន្នាការនយោបាយ ដើមកំណើតជាតិ ឋានៈ សង្គម ធនធាន ឬស្ថានភាពដទៃទៀត។

- ត្រូវគោរពសិទ្ធិ និងសេរីភាពរស់នៅក្នុងជីវភាពឯកជនរបស់បុគ្គល។
- ត្រូវគោរពឲ្យបានហ្មត់ចត់តាមក្បួនវេយ្យាករណ៍ខ្មែរ ក្នុងការសរសេរអត្ថបទ។
- ហាមបោះពុម្ពផ្សាយអត្ថបទ ឬរូបភាពអាសអាភាស និងរូបភាពនៃអំពើហិង្សា។
- ហាមរំលោភលើសិទ្ធិដើម្បីមានការជំនុំជំរះក្តីដោយយុត្តិធម៌របស់បុគ្គលម្នាក់ៗ ដូចមានចែងក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។

ត្រូវចាត់ទុកចំណុចដូចខាងក្រោមនេះជាការរំលោភដ៏ធ្ងន់ធ្ងរខាងផ្នែកវិជ្ជាជីវៈរបស់អ្នកសារពត៌មាន ៖

- ការលួចចម្លងគំនិត ឬស្នាដៃរបស់អ្នកដទៃយកដាក់ថាជារបស់ខ្លួន។
- ការបន្លំឲ្យគេយល់ខុស ដូចជាការសរសេរបញ្ចិតបញ្ចៀងដើម្បីឲ្យអ្នកអានមានការសង្ស័យដោយអយុត្តិធម៌លើបុគ្គលណាម្នាក់ ក្រុមណាមួយ ឬបក្សណាមួយ។
- ការប្តូលបង្កាច់ បរិហាកេរ្តិ៍ និងការជេរប្រមាថ។
- ការទទួលសំណូកក្នុងបែបណាមួយ ឬការជំរិតយកប្រាក់ ដើម្បីជាថ្នូរទៅ នឹងការបោះពុម្ពផ្សាយ ឬមិនបោះពុម្ពផ្សាយនូវពត៌មានណាមួយ។

**មាត្រាគ្រាំមិះ:**

មុនពេលចាប់ផ្តើមចែកចាយសារពត៌មាន និយោជក ឬនិពន្ធនាយកត្រូវធ្វើពាក្យមួយច្បាប់ជូនមកក្រសួងពត៌មាន ដើម្បីបញ្ជាក់អំពីអត្តសញ្ញាណរបស់ខ្លួន។ ក្រសួងនេះត្រូវចេញបង្កាន់ដៃឲ្យទៅសារពត៌មានវិញបន្ទាប់ពីបានទទួលសំណុំបែបបទទាំងមូល។ ក្នុងករណីដែលនាយកនៃការផ្សាយជាសមាជិករដ្ឋសភា ឬស្ថាប័នដែលមានបុព្វសិទ្ធិសារពត៌មាននោះចាំបាច់ត្រូវ

www.budinst.gov.kh www.elibraryofcambodia

ចាត់តាំងឲ្យមានសហនាយកការផ្សាយមួយរូបទៀត។ និយោជក ឬនិពន្ធនាយកដែលមិនគោរពបែបបទនេះជាមុន នឹងត្រូវផ្ដន្ទាទោស ដោយពិន័យជាប្រាក់ពីប្រាំសែនរៀល (៥០០,០០០រៀល) ទៅមួយលានប្រាំសែនរៀល (១,៥០០,០០០រៀល) ក្នុងករណីមិនរាងចាលត្រូវពិន័យជាប្រាក់ទ្វេឡើង។

**មាត្រាភ្រាំបួនៈ**

សំណុំបែបបទដែលនិយោជក ឬនិពន្ធនាយកត្រូវបំពេញមានជាអាទ៍ៈ

- អត្តសញ្ញាណប័ណ្ណនៃសារពត៌មាន
- ឈ្មោះ និងអាស័យដ្ឋានរបស់និយោជក ឬនិពន្ធនាយក
- ឈ្មោះ និងអាស័យដ្ឋានរបស់រោងពុម្ព
- លិខិតបញ្ជាក់អំពីទោសកំហុសណាមួយ បើមាន។

រាល់ការផ្លាស់ប្ដូរនៃពត៌មានណាមួយខាងលើនេះ និយោជក ឬនិពន្ធនាយកត្រូវ ជូនដំណឹងទៅក្រសួងពត៌មានឲ្យបានប្រាំថ្ងៃ (៥ថ្ងៃ) មុន។ លើកលែងតែករណីប្រធានសក្ដិ។

**មាត្រា៥ម៉**

ជនណាម្នាក់ដែលយល់ថាអត្ថបទ ឬឯកសារណាមួយ។ បើទោះបីជាអត្ថន័យរបស់អត្ថបទ ឬឯកសារនោះមានន័យអាចកំបាំង ឬរូបភាពណាមួយនៃការបោះពុម្ពផ្សាយជារូបគំនូរ ឬរូបថតប្រាសចាកពីការពិត និងដែលនាំឲ្យមានការប៉ះពាល់ដល់កិត្តិយស និងសេចក្ដីថ្លៃថ្នូររបស់ខ្លួន ជននោះមានសិទ្ធិទាមទារឲ្យសារពត៌មាននេះ ធ្វើការកែតម្រូវឡើងវិញ ឬមានសិទ្ធិឆ្លើយតបទៅកាន់ចាងហ្វាងការផ្សាយ និងធ្វើពាក្យបណ្ដឹងពីបទបរិហាកេរ្តិ៍ ...។ សេចក្ដីកែតម្រូវ ឬការឆ្លើយតបនោះ គឺត្រូវចុះផ្សាយក្នុងរយៈពេលប្រាំពីរថ្ងៃ(៧ថ្ងៃ)យ៉ាងយូរ បន្ទាប់ពីថ្ងៃដែលបានទទួលការទាមទារឲ្យធ្វើសេចក្ដីកែតម្រូវ ឬការឆ្លើយតបនោះ ឬនៅលើលេខបន្ទាប់។ ចំពោះករណីដែលពាក់ព័ន្ធដល់បុគ្គលសាធារណៈ គ្រប់ការពោលអះអាង ឬការទំលាក់កំហុស ដែលអ្នកសារពត៌មានយកមកចុះផ្សាយដោយផ្ទាល់

www.budinst.gov.kh www.elibraryofcambodia

ឬយកមកចុះផ្សាយបន្តខុសពីការពិត ក្នុងបំណងបំផ្លាញបុគ្គលសាធារណៈ នោះ គឺជាការមួលបង្កាច់ដែលច្បាប់ហាមឃាត់។

បើតុលាការរកឃើញថា ការផ្សាយណាមួយមានលក្ខណៈខុសពីការពិត តាមបណ្ដឹងរបស់ដើមបណ្ដឹងរដ្ឋប្បវេណី តុលាការអាចបង្គាប់ឲ្យសារព័ត៌មាននោះធ្វើការ :

- ចុះផ្សាយនូវសេចក្ដីកែតម្រូវ ឬ
- សងជំងឺចិត្ត ឬ
- ចុះផ្សាយនូវសេចក្ដីកែតម្រូវផង និងសងជំងឺចិត្តផង។

អត្ថបទកែតម្រូវ ដែលអ្នកសារព័ត៌មានចាំបាច់ត្រូវតែផ្សាយ គឺត្រូវចុះផ្សាយនៅលើទំព័រដូចគ្នា និងមានទំហំអក្សរប៉ុនគ្នាទៅនឹងអត្ថបទ ដែលបានចាត់ទុករួចមកហើយថា ជាអត្ថបទដែលបានធ្វើឲ្យមានការប៉ះពាល់កិត្តិយស និងសេចក្ដីថ្លៃថ្នូររបស់គេ ។

លើសពីនេះតុលាការអាចផ្ដន្ទាទោសដោយពិន័យជាប្រាក់ពីមួយលានរៀល (១,០០០,០០០រៀល) ទៅប្រាំលានរៀល (៥,០០០,០០០រៀល)។

ម្យ៉ាងទៀតក្នុងករណីដែលមានការវិនិច្ឆ័យអំពីអំពើណាមួយ ដែលមានចែងនៅក្នុងកថាខ័ណ្ឌខាងលើគឺ តុលាការអាចចេញបញ្ជាឲ្យធ្វើសេចក្ដីប្រកាសអំពីការសំរេចចិត្តមួយនៅតាមកន្លែង ដែលតុលាការនឹងកំណត់ឲ្យ។ ហើយតុលាការក៏អាចធ្វើការប្រកាសអំពីសាលក្រមនេះនៅក្នុងសារព័ត៌មានមួយឬច្រើនបានដោយទុកឲ្យជនជាប់ចោទចេញសោហ៊ុយទាំងអស់ក្នុងកម្រិតមិនឲ្យលើសពីមួយលានរៀល (១,០០០,០០០រៀល)។

**មាត្រា១២មួយ:**

សារព័ត៌មានមិនត្រូវបោះពុម្ពផ្សាយនូវអ្វី ដែលនាំឲ្យប៉ះពាល់ដល់សណ្ដាប់ធ្នាប់សាធារណៈតាមការញុះញង់ដោយផ្ទាល់ ដែលធ្វើឲ្យមនុស្សម្នាក់ឬច្រើននាក់ប្រព្រឹត្តអំពើហិង្សា។

ការប្រព្រឹត្តបទល្មើសដូចមានចែងនៅខាងលើនេះគឺ ត្រូវផ្ដនាទោសដោយ

www.budinst.gov.kh www.elibraryofcambodia

ពិន័យជាប្រាក់ពីមួយលានរៀល (១,០០០,០០០រៀល) ទៅប្រាំលានរៀល (៥០០០,០០០រៀល) ។

បុគ្គលរងគ្រោះដោយអំពើខាងលើ មានសិទ្ធិតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ទៅតុលាការ ។

គ្រប់ករណីទាំងអស់ តុលាការត្រូវពិនិត្យទៅលើទំនាក់ទំនងដោយផ្ទាល់រវាង អត្ថបទញុះញង់ និងអំពើនោះ។ អត្ថបទដែលមានចំណាស់លើសពីបីខែ (៣ខែ) មិនអាចយកមកប្រើក្នុងតុលាការសំរាប់ជាមូលដ្ឋានដើម្បីចោទប្រកាន់ បានឡើយ។

**មាត្រា១២ពីរ:**

សារព័ត៌មានមិនត្រូវបោះពុម្ពផ្សាយ ឬផ្សាយបន្តនូវព័ត៌មាន ដែលបណ្ដាល ឲ្យប៉ះពាល់សន្តិសុខជាតិ និងស្ថេរភាពនយោបាយ។

និយោជក និពន្ធនាយក ឬអ្នកនិពន្ធអត្ថបទនឹងត្រូវផ្ដន្ទាទោសដោយពិន័យ ជាប្រាក់ពីប្រាំលានរៀល(៥,០០០,០០០រៀល)ទៅដប់ប្រាំលានរៀល (១៥០០០,០០០រៀល)ដោយមិនទាន់គិតទាំងការ ដែលត្រូវផ្ដន្ទាទោស តាមច្បាប់ព្រហ្មទណ្ឌនៅឡើយ។

ក្រសួងព័ត៌មាន និងក្រសួងមហាផ្ទៃ មានសិទ្ធិរឹបអូសយកទ្រព្យសម្បត្តិរបស់ សារព័ត៌មានដែលមានទោសកម្ម។ ក្រសួងព័ត៌មាន មានសិទ្ធិឲ្យសារព័ត៌មាន នោះផ្អាកការផ្សាយក្នុងចំនួនសាមសិបថ្ងៃ (៣០ថ្ងៃ)យ៉ាងយូរ និងត្រូវបញ្ជូន សំណុំរឿងទៅតុលាការ ។

**មាត្រា១២បី :**

សារព័ត៌មានមិនត្រូវបោះពុម្ពផ្សាយ ឬផ្សាយបន្តនូវព័ត៌មានមិនពិតណា ដែលជាការជេរប្រមាថ ឬជាការមើលងាយដល់ស្ថាប័នជាតិ។ ការផ្សាយ បែបនេះអាច នឹងត្រូវផ្ដន្ទាទោសដោយពិន័យជាប្រាក់ពីពីរលានរៀល (២០០០,០០០រៀល) ទៅដប់លានរៀល (១០,០០០,០០០រៀល)។

**មាត្រា១២បួន :**

www.budinst.gov.kh www.elibraryofcambodia

សារពត៌មានមិនត្រូវបោះពុម្ពផ្សាយនូវអ្វី ដែលប៉ះពាល់ដល់ប្រពៃណីដ៏ល្អ របស់សង្គមជាតិ ដែលមានជាអាទ៍ ៖

- ពាក្យអសុរោះមិនគួគប្បីដូចជា អា ប៊ីង ជាដើម
- ពាក្យដែលពិពណ៌នាចំៗ អំពីសកម្មភាពរួមរក្ស
- រូបគំនូរ ឬរូបថតដែលបង្ហាញនូវកេរ្តិ៍អាទ ឬរូបអាក្រាត។ លើកលែងតែការផ្សព្វផ្សាយនោះសំរាប់ការអប់រំ។
- រូបភាពដែលប្រមាថមើលងាយប្រៀបធៀបមនុស្សទៅនឹងសត្វតិរិច្ឆាន។
- ការរំលោភលើមាត្រានេះអាចនឹងត្រូវផ្តន្ទាទោសដោយពិន័យជាប្រាក់ពីមួយលានរៀល (១,០០០,០០០រៀល) ទៅដល់ប្រាំលានរៀល (៥០០០០០០រៀល)។

**មាត្រា៨ប្រាំ :**

លុះត្រាតែមានការអនុញ្ញាតពីតុលាការជាមុនសិន សារពត៌មានពុំអាចផ្សាយនូវ ដំណឹង រូបថត ឬ គំនូរ ដែលអាចឲ្យអ្នកអានស្គាល់ឈ្មោះនិងអត្តសញ្ញាណរបស់ ៖

- ភាគីណាមួយក្នុងបណ្តឹងរដ្ឋប្បវេណី ដែលមានការទាក់ទងទៅនឹងរឿងបិតុភាព អាពាហ៍ពិពាហ៍ លែងលះប្តីប្រពន្ធ ឬ រឿងអាណាព្យាបាលលើកុមារ។
- យុវជនអាយុតិចជាងដប់ប្រាំបីឆ្នាំ (១៨ឆ្នាំ) ក្នុងបណ្តឹងរដ្ឋប្បវេណី ឬព្រហ្មទណ្ឌ ឬ
- ស្ត្រីរងគ្រោះដោយអំពើរំលោភលើរាងកាយ ឬ អំពើចាប់បង្ខំសេពសន្ថវៈ។ ក្នុងករណីដែលសាមីជន ឬ អ្នកអាណាព្យាបាលយល់ព្រមជាលាយល័ក្ខអក្សរ សារពត៌មានអាចផ្សព្វផ្សាយរឿងនេះបាន។ លុះត្រាតែការផ្សាយនោះមិននាំឲ្យប៉ះពាល់ដល់ការស៊ើបអង្កេតរបស់តុលាការ ។ បុគ្គលណាដែលបានត្រូវសារពត៌មានបំពានសិទ្ធិខាងលើនេះគឺ មានសិទ្ធិប្តឹងទៅតុលាការដើម្បីទាមទារជំងឺចិត្ត។ ការប្រព្រឹត្តល្មើសនឹងបទបញ្ញត្តិខាងលើ

www.budinst.gov.kh www.elibraryofcambodia

នេះនឹងត្រូវផ្តន្ទាទោស ដោយត្រូវពិន័យជាទឹកប្រាក់ ពីមួយលានរៀល (១000,000រៀល) ទៅប្រាំលានរៀល (៥,000,000រៀល)។

**មាត្រា៤ប់ប្រាំមួយ :**

ដំណឹងផ្សាយពាណិជ្ជកម្មអាចចាត់ទុកថាមានលក្ខណៈភូតកុហក បើការផ្សាយនោះមានន័យបំផ្លើសហួសហេតុអំពីគុណភាព ឬតម្លៃផលិតផល ឬសេវាណាមួយ ដែលនាំឲ្យអ្នកប្រើប្រាស់មានការភ័ន្តច្រឡំ។

ការផ្សាយពាណិជ្ជកម្មរបៀបនេះត្រូវតែហាមឃាត់។ ប៉ុន្តែសារពត៌មានដែលចុះផ្សាយនូវដំណឹងភូតកុហកនោះគឺ មិនមែនជាអ្នកទទួលខុសត្រូវចំពោះមុខច្បាប់ទេ។ លុះត្រាតែសារពត៌មាននោះ នៅតែបន្តការផ្សាយដំណឹងនេះទៀត បន្ទាប់ពីបានទទួលការហាមជាលាយល័ក្ខអក្សរពីតុលាការ ឬពីក្រសួងមានសមត្ថកិច្ចរួចហើយ។

ផ្ទុយទៅវិញម្ចាស់ឃោសនាពាណិជ្ជកម្ម គឺជាអ្នកទទួលខុសត្រូវចំពោះមុខច្បាប់ និងតុលាការ បើសិនជាមានការប្តឹងផ្តល់អំពីបុគ្គលម្នាក់ ឬសមាគមអ្នកប្រើប្រាស់ណាមួយ ដែលបានទទួលការខូចខាតប្រយោជន៍ដោយបណ្តាលមកពីការផ្សព្វផ្សាយពាណិជ្ជកម្មភូតកុហកនោះ។

ការផ្សាយពាណិជ្ជកម្មភូតកុហកអាចនឹងត្រូវផ្តន្ទាទោសដោយពិន័យជាទឹកប្រាក់ ពីមួយលានរៀល (១,000,000រៀល) ទៅប្រាំលានរៀល (៥000,000រៀល)។

## ជំពូកទីបី : ការគ្រប់គ្រងប្រភេទ

**មាត្រា៤ប់ប្រាំពីរ :**

នៅក្នុងព្រះរាជាណាចក្រកម្ពុជា បុគ្គលណាក៏ដោយជារូបវ័ន្តបុគ្គលក្តី ឬនីតិបុគ្គលក្តីមិនអាចធ្វើជាម្ចាស់ ឬអាចកាន់កាប់សារពត៌មានភាសាខ្មែរលើសពីពីរ (២)បានឡើយ។

**មាត្រា៤ប់ប្រាំបី :**

ចំនួនសរុបទាំងអស់នៃសារពត៌មានជាភាសាខ្មែរ ដែលជនបរទេសអាចកាន់

www.budinst.gov.kh www.elibraryofcambodia

កាប់បានគឺ មិនត្រូវឲ្យលើសពីម្ភៃភាគរយ (២០%) នៃចំនួនសារពត៌មានទាំងអស់ដែលមានផ្សាយនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

សារពត៌មានដែលបានអនុញ្ញាតឲ្យចេញផ្សាយរួចហើយត្រូវបានកាន់កាប់ដោយជនបរទេសគឺ មិនអាចត្រូវបំបិទចោលដោយមូលហេតុមកពីមានការថយចុះនូវចំនួនសរុបនៃសារពត៌មានជាភាសាខ្មែរនោះទេ។

**ជំពូកទី៩ : ការតម្កល់ទុក**

**មាត្រាដប់ប្រាំបួន :**

និពន្ធនាយក ឬនាយកការផ្សាយ ត្រូវតម្កល់ទុកសារពត៌មានរាល់លេខរបស់ខ្លួនចំនួនពីរច្បាប់ (២ច្បាប់) នៅបណ្ណាល័យជាតិ និង ប្រាំមួយច្បាប់ (៦ច្បាប់) នៅ ក្រសួងពត៌មាន។ ការតម្កល់នេះ គឺត្រូវធ្វើក្នុងរយះពេលដប់ប្រាំថ្ងៃ (១៥) បន្ទាប់ពីថ្ងៃបោះពុម្ពផ្សាយ បើរោងពុម្ពនោះនៅភ្នំពេញ និងសែសិបប្រាំថ្ងៃ (៤៥ថ្ងៃ) បើការ បោះពុម្ពនោះត្រូវធ្វើនៅកន្លែងដ៏ទៃទៀត។ ការប្រព្រឹត្តល្មើសនឹងបទបញ្ញត្តិខាងលើនេះនឹងត្រូវផ្តន្ទាទោសជាលក្ខណៈរដ្ឋបាលដោយពិន័យជាប្រាក់ពី(៣០,០០០រៀល) ទៅ (៣០០, ០០០រៀល)។

**ជំពូកទីប្រាំ : អវសានបញ្ញត្តិ**

**មាត្រាម្ភៃ :**

អំពើប្រព្រឹត្តិរបស់និយោជក និពន្ធនាយក ឬអ្នកនិពន្ធអត្ថបទដែលរំលោភច្បាប់ព្រហ្មទណ្ឌនឹងត្រូវទទួលទោសតាមច្បាប់ព្រហ្មទណ្ឌ។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយក៏គ្មានជនណាម្នាក់ត្រូវបានចាប់ចង ឬជាប់ពន្ធនាគារដោយសារការបញ្ចេញមតិឡើយ។

**មាត្រាម្ភៃមួយ :**

បទបញ្ញត្តិទាំងឡាយដែលមានពីមុនមកហើយ និងដែលមានការទាក់ទងទៅនឹងសារពត៌មានត្រូវចាត់ទុកជានិរាករណ៍។

ច្បាប់នេះត្រូវបានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជាអនុម័តនៅ

**ថ្ងៃទី១៨ ខែកក្កដា ឆ្នាំ១៩៩៥ សម័យប្រជុំលើកទី៤ នីតិកាល ទី១**

www.budinst.gov.kh www.elibraryofcambodia

www.budinst.gov.kh www.elibraryofcambodia